# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

### បឋមភាគ ១

ផ្ដើមប្រែរៀបរៀងតាមច្បាប់ដើមដោយ

លោកកល្យាណធម្មោ សុន្ទ៌រ-សារមឿន

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៥៧ គ. ស. ២០១៣

# អដ្ឋសាលិនី

## បឋមភាគ

## ១

ព. ស.

២៥៥៧

បោះពុម្ពលើកទី ៣
រក្សាសិទ្ធិ ( ហាមថតចម្លង)

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ ធម្មសង្គណី

### បឋមភាគ ១

**អមដោយៈ**

- ព្រះអភិធម្មបិដកខ្មែរ បឋមភាគ ៧៨
- អដ្ឋសាលិនី ធម្មសង្គណី ភាសាបាលីភាគ១
- អដ្ឋសាលិនី មូលដីកា-អនុដីកា ភាសាបាលីភាគ១
- អដ្ឋសាលិនី អត្ថយោជនា ភាសាបាលីភាគ១

ផ្តើមផ្តុំប្រៀបរៀងតាមច្បាប់ដើមដោយ

លោកកល្យាណធម្មោ សុន្ទរ៍-សាមឿន

# នមត្ថុ រតនត្តយស្ស

## ឧប្បត្តិកថា

បុព្វហេតុដែលនាំឱ្យខ្ញុំផ្ដើមប្រែរៀបរៀង គម្ពីរអដ្ឋកថាព្រះអភិធម្មនេះឡើង មិនមែនដោយហេតុដែលខ្ញុំជាអ្នកស្ទាត់ជំនាញ ឈ្លាសវៃនោះទេ, តែដោយហេតុ ៖-

-ចង់ចេះ, ព្រោះធម៌ព្រះអភិធម្មនេះ ជាធម៌ជ្រាលជ្រៅ ល្អិតសុខុម គម្ភីរភាពណាស់; បុគ្គលដែលរៀនធម៌នេះ បើមិនព្យាយាមយកចិត្តទុកដាក់ ពិចារណាពិច័យឱ្យបានច្រើនៗ មួយអន្លើដោយការបដិបត្តិទេ មិនអាចយល់បានច្បាស់លាស់ឡើយ ។

-ចង់ឱ្យគម្ពីរព្រះពុទ្ធសាសនា មានមូលដ្ឋានច្បាស់លាស់ពិតប្រាកដ អាចយកជាផ្លូវការបាន, ព្រោះកន្លងមក នៅក្នុងប្រទេសកម្ពុជាយើងនេះ ក្រៅពីព្រះត្រៃបិដក មិនទាន់ឃើញមានគម្ពីរណាមួយ ដែលជាគម្ពីរបន្ទាប់បន្សំពីព្រះត្រៃបិដក ត្រូវបានអ្នកប្រាជ្ញទាំងឡាយពីជំនាន់មុនប្រែ និងរៀបរៀងបានទាំងស្រុងនៅឡើយ ។ យើងសង្កេតឃើញដោយច្រើនៗតែកូនសៀវភៅបកិណ្ណកៈផ្សេងៗ ដែលអ្នកប្រាជ្ញបានដកស្រង់ពីព្រះត្រៃបិដកខ្លះ, ព្រះអដ្ឋកថាជាដើមខ្លះ មករៀបរៀងតាមដែលខ្លួនធ្លាប់បានរៀនមក ពីសំណាក់លោកគ្រូអាចារ្យផ្សេងៗ ហើយយកមកផ្សំជាមួយនឹងគំនិតរបស់ខ្លួន ។ សៀវភៅបែបនេះ គឺមានច្រើនណាស់ រហូតដល់ច្រើនពេកទៅ អ្នកសិក្សាបដិបត្តិទាំងឡាយមិនដឹងថា នឹងយកតាមសៀវភៅណាឱ្យបានពិតប្រាកដ បើភៅសៀវនេះថាអ៊ីចេះ សៀវភៅនោះថាអ៊ីចុះ ។ ល ។ ឯសៀវភៅនេះ មិនមែនជាសៀវភៅដែលខ្ញុំប្រែ

រៀបរៀងតាមគំនិតរបស់ខ្លួនផ្ទាល់ទេ, គឺប្រែរៀបរៀងទៅតាមច្បាប់ដើមទាំងស្រុង ។ ក្នុងការប្រែ និងរៀបរៀងទៀតសោត ខ្ញុំបានពឹងឱ្យភិក្ខុសាមណេរ និងឧបាសកខ្លះ ជួយសរសេរចម្លងតាមច្បាប់ដើម គឺច្បាប់ដែលគេប្រែរួចហើយ ឱ្យលោកជួយពិនិត្យឱ្យ បានត្រឹមត្រូវតាមច្បាប់ដើម ។ បន្ទាប់មក ខ្ញុំយកមកពិនិត្យ ផ្ទៀងផ្ទាត់តាមច្បាប់ដើម ផង, តាមអដ្ឋកថាបាលីផង, អដ្ឋសាលិនី អត្ថយោជនាបាលីផង និងមូលដីកា អនុដីកា បាលីផង ។ តែទុកជាយ៉ាងនេះក៏ដោយ ក៏មិនអាចជៀសផុតពីការខុសភ្លាំងភ្លាត់បាន ឡើយ, ហេតុដូច្នេះហើយ ខ្ញុំសូមពឹងលើអ្នកប្រាជ្ញ និងអ្នកសិក្សាទាំងឡាយ មេត្តាជួយ កែសម្រួល ដោយកុសលចេតនាផងចុះ ។

-អ្នកកាន់ព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា នឹងមានសេចក្តីប្រតិបត្តិ ត្រូវផ្លូវគ្នា ព្រោះមានគម្ពីរអដ្ឋកថានេះជាគ្រូ ប្រាប់ខុសត្រូវ ជាគោលចារិក សម្រាប់ អាងត្រូវគ្នាតែបែបមួយ ហើយនឹងបានកម្ចាត់បង់នូវអស្មិមានះ គឺប្រកាន់ខុសថា ត្រូវ នោះចេញ ។

-អដ្ឋកថាព្រះអភិធម្មបិដកនេះ ទុកជាប្រទីបជ្វាលា ឆ្លុះបំភ្លឺដល់អស់មហាជន ឱ្យឃើញសេចក្តីខុស នឹងត្រូវជាក់ មិនភាន់ច្រឡំ នាំឱ្យកើតមានប្រាជ្ញាស្មារតីល្អ ចេះ អៀនខ្មាស់ រង្កៀសរអា ស្អប់ខ្ពើមអំពើអាក្រក់ ឱ្យខ្មីឃ្មាតសង្វាត ខំប្រឹងប្រព្រឹត្តសុចរិត ស្លូតត្រង់ដែលជាពូជបង្កើតសេចក្តីសុខឱ្យមានបរិបូណ៌ឡើង ។ កាលបើមហាជន មាន សេចក្តីអៀនខ្មាស់ ជ្រេញចិត្តនឹងអំពើអាក្រក់ហើយ ព្រះពុទ្ធសាសនាក៏នឹងថ្កុំថ្កើងរុង

រឿង មានកេរ្តិ៍ឈ្មោះក្រអូបសាយទៅក្នុងលោកទាំងមូល ពីព្រោះធម៌សុចរិត មានក្លិនក្រអូបជាទីបំផុត ជាងក្លិននៃគ្រឿងក្រអូបទាំងអស់ ។

## អំពីរបៀបប្រែរៀបរៀង របស់អ្នកផ្តើមប្រែរៀបរៀង

របៀបមុខការគ្រប់យ៉ាង ដែលបានរៀបចំព្រះអដ្ឋកថានេះ ខ្ញុំជាអ្នកផ្តើមប្រែរៀបរៀង បានធ្វើដោយកម្លាំងព្យាយាមដ៏មាំមួន ព្រមទាំងបានពិនិត្យ ពិច័យ ដោយល្អិតល្អន់ ដូចមានសេចក្តីរាយដំណើរការតទៅនេះ ៖-

១-គម្ពីរ**អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគគឺ

**១. បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ **ធម្មសង្គណី**

**២. ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ **វិភង្គ**

**៣. តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ**បញ្ចបករណ៍** តាំងពី**ធាតុកថា** រហូតដល់ចប់គម្ពីរ **បដ្ឋាន** ទាំងអស់។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ហើយយើងមិនបានធ្វើទៅតាមលំដាប់លំដោយទេ ពោលគឺយើងធ្វើតែភាគ ឬលេខណាដែលស្រួលៗ មុន ។

២-ខ្ញុំបានយកគម្ពីរអដ្ឋកថាព្រះអភិធម្មបិដកច្បាប់ដើម (ច្បាប់ដែលគេប្រែរួច) ហើយចាត់ឱ្យលោកចម្លងស្រង់យកប្រែខ្លះ បាលីខ្លះ ទើបបានយកគម្ពីរអដ្ឋកថាព្រះអភិធម្មបិដកបាលីជាច្រើន មកធ្វើជាច្បាប់ផ្ទៀងផ្ទាត់បញ្ចារវាងប្រែ និងបាលី ។ បើផ្ទៀងផ្ទាត់បញ្ចាទៅហើយ ឃើញមានសព្ទប្រែត្រង់ណាដែលផ្សេងពីបាលីខ្លះ ខ្ញុំបានកែប្រែសព្ទដែលប្រែនោះ ឱ្យមកតាមលំនាំនៃសព្ទបាលី ជួនកាលដាក់សព្ទដែលមានលំនាំសេចក្តីប្រហែលគ្នា ក្នុងរង្វង់ក្រចក (---) ដើម្បីធ្វើសព្ទនោះ ឱ្យមានភាពទូលំទូលាយងាយយល់ ។

៣-ឯការផ្ទៀងផ្ទាត់បញ្ចានោះ ខ្ញុំបានយកគម្ពីរមូលដីកា, អនុដីកា និងយោជនា មកមើលជាដរាប ដើម្បីឱ្យឃើញសេចក្តីជាក់ប្រាកដ; ប៉ុន្តែ មិនបានដាក់សេចក្តីតាមន័យក្នុងដីកាទាំងពីរ និងយោជនានោះទាំងអស់ទេ, ផ្ទៀងតាមលំអានអដ្ឋកថាបាលីព្រះអភិធម្មបិដក គឺថាបាលីនោះ មានសេចក្តីប៉ុន្មាន ខ្ញុំប្រែឱ្យគត់តែត្រឹមប៉ុណ្ណោះឯង, តែបើប្រែប្រយោគណា មានសេចក្តីចង្អៀតពិបាកយល់នោះ ខ្ញុំបន្ថែមពាក្យ ឬសេចក្តីខ្លះតាមន័យក្នុងដីកាទាំងពីរ និងយោជនាដាក់ក្នុងវង់ក្រចក ( --- ) ។

ម្យ៉ាងទៀត ប្រយោគខ្លះ មានដំណើរបាលីលំបាកប្រែរៀងសេចក្តីសម្រួលមកជាសម្រាយនោះពេក លុះតែប្រែបញ្ចូលពាក្យថែមមកខ្លះ ទើបមិនងាប់សេចក្តី, កាលបើដូច្នោះ ខ្ញុំដាក់ក្នុងវង់ក្រចក (---) នេះដែរ ដូចជាពាក្យថា (នេះ) (នោះ) ជាដើម ដើម្បីឱ្យស្រួលតាមលំនាំសេចក្តីភាសាខ្មែរ, ប៉ុន្តែការដាក់វង់ក្រចកនេះ មិនបានគ្រប់

អន្លើទេ ។

៤-ពាក្យ ឬប្រយោគណា ដែលមានសេចក្ដីជ្រៅកំបាំងពេក បើមិនទាញយកមកអធិប្បាយពន្យល់ផងទេ មុខជានឹងមិនអាចយល់ចូលចិត្តសេចក្ដីបានឡើយ ។ ដូច្នេះ ខ្ញុំបានស្រង់យកសេចក្ដីអធិប្បាយ មកដាក់ជាលេខយោងឱ្យប្រាកដឡើង ដោយប្រើសញ្ញាផ្កាយ (*) សម្គាល់ឱ្យដឹងថា ពាក្យ ឬសេចក្ដីនោះបញ្ចូលថែមមក ដែលមានប្រាប់ឈ្មោះគម្ពីរក្នុងទីនោះៗ ស្រាប់ ។

៥-ដោយសារតែអត្ថសេចក្ដីនៃព្រះអភិធម្មមានគម្ភីរភាព, ក្នុងការរៀបរៀង ខ្ញុំបានប្រើអក្សរដែលមានទ្រង់ទ្រាយតូចធំព្រមទាំងនិមិត្តសញ្ញាផ្សេងៗ ទៀត ប្រយោជន៍ដើម្បីសាធុជនបានអានរៀនសូត្រឆាប់យល់ ។

* ប្រសិនបើនៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ។

នៅក្នុងសេចក្ដីនៃអដ្ឋកថានេះ គឺព្រះអរហន្តទាំងឡាយ ពន្យល់បកស្រាយទៅតាមព្រះពុទ្ធវចនៈ ដែលមាននៅក្នុងព្រះអភិធម្មបិដក, ព្រោះហេតុដូច្នោះ មុននឹងសាធុជនសិក្សាសៀវភៅនីមួយៗ សូមអានគម្ពីរព្រះអភិធម្មបិដក ទៅតាមលំដាប់ភាគ វគ្គ សេចក្ដីកណ្ឌនីមួយៗ សិន, កាលបើសាធុជនសិក្សាដូច្នេះ នឹងអាចយល់សេចក្ដីបានយ៉ាងឆាប់រហ័ស ។

**នត្ថិ បញ្ញា សមា អាភា** ពន្លឺស្មើដោយបញ្ញាមិនមានឡើយ! ។

**នត្ថិ សន្តិបរំ សុខំ** សុខដទៃក្រៅអំពីសេចក្តីស្ងប់មិនមានឡើយ!។

រាជធានីភ្នំពេញ

ពិនិត្យផ្ទៀងផ្ទាត់ចប់នៅថ្ងៃ ៧ ។ ៨/១០ ត្រូវនឹងថ្ងៃទី ០១ សីហា : ព. ស. ២៥៥៧ / គ. ស. ២០១៣

ខ្ញុំព្រះករុណាខ្ញុំបាទ **សុន្ទរ៍_សារមឿន**

អតីតសមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជំនាន់ទី ៣, ទូរសព្ទ: ០៩២ ៩០ ៨២ ៦៥, ០៩៧ ២៣ ៣០ ២១៥, ០២៣ ៦៣ ០១ ០២២, ០១៦ ៤៦ ៥២ ៣៤ ៕

## អ្នកដែលមានឧបការៈក្នុងការងារធម្មទាននេះ

១_លោកខន្តិធីរោ **វ៉ែន_ភិរម្យ** ជួយចម្លង និងផ្ទៀងតាមច្បាប់ដើម

២_លោកខន្តិជាតិកោ **ថៃ_ភិរក្ស** ជួយចម្លង និងផ្ទៀងតាមច្បាប់ដើម

៣_លោកធម្មរក្ខិតោ **គង់_ចន** ជួយផ្ទៀងតាមច្បាប់ដើម

៤_ឧបាសក **ចៅ_សារ៉ែអម** ជួយដំណើរការផ្សេងៗ

៥_ លោក **សួន ឱសថ** ជួយដំណើរការផ្សេងៗ

៦_លោកញាណបជ្ជទីបោ **គ្រឿង_ម៉ុនធឿន** ការីកុំព្យូទ័រ

៧-លោក **ហេង សុវណ្ណារ៉ា** និងក្រុមគ្រួសារ ឧបត្ថម្ភកុំព្យូទ័រ

៨- ឧបាសក **ស្រ៊ុន ចាន់ណា** និងក្រុមគ្រួសារ ឧបត្ថម្ភកុំព្យូទ័រ ។

## ឈ្មោះអ្នកចូលរួមជួយកែសម្រួល

១.លោក **សេង សុម្មុនី** អតីតៈនៃអគ្គាធិការរងក្រសួងធម្មការ

២.ព្រះមហាសីលប្បញ្ញោ **ស៊ាង ឈុនលី** (វត្តសំពៅមាស)

៣.ភិក្ខុធម្មបាល **រិត សោរឌី** (វត្តឧណ្ណាលោម)

៤.ភិក្ខុសុវណ្ណប្បជោត **គង់ ណារ៉ៃ** (ចៅអធិការវត្តសំពៅមាស)

៥.លោកធម្មយោគោ **មិន ណារ៉ាក់** ជួយពិនិត្យផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ

៦.ក្រុមទ្រទ្រង់ព្រះត្រៃបិដក (ប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ)

៧.ក្រុមពហុស្សុត **វត្តនិគ្រោធវ័ន** (គល់ទទឹង)

៨.លោក **រស់ សារ៉េន** (សាស្ត្រាចារ្យមហាវិទ្យាល័យព្រះសីហនុរាជ )

៩.លោក **ម៉ម ឈុំ** (ពុទ្ធសាសនបណ្ឌិត្យ)

១០.លោក **ជិត ជន** (សាស្ត្រាចារ្យមហាវិទ្យាល័យព្រះសីហនុរាជ)

១១.លោក **ជា ក្រស្នា** (សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត) ។

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង និងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗរូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

**ដោយអំណាចនៃមហាកុសលជាធម្មទាននេះ សូមឱ្យ ៖**

-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ

-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា

-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ

-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕

# និមិត្តសញ្ញាគ្រឿងសម្គាល់ផ្សេងៗ

(,) យ៉ាងនេះហៅថា "ចុល្លញ្ញាគ" សម្រាប់ដាក់សេចក្ដីមួយៗ ដែលត្រូវដកឱ្យដាច់ពីគ្នា ដើម្បីអានទៅមិនឱ្យច្រឡំ ។

(;) យ៉ាងនេះ ហៅថា "មហញ្ញាគ" សម្រាប់ដាក់សេចក្ដីដែលនិយាយអស់មួយឃ្លាមួយល្បះហើយ, ប៉ុន្តែមិនខណ្ឌ ព្រោះនៅមានតទៅទៀត ។

(:) យ៉ាងនេះ ហៅថា "ទ្វេភាគ" សម្រាប់ដាក់ក្នុងសេចក្ដីដែលត្រូវរាប់គោលខ-មាតិកា ឬដាក់ក្នុងបទដែលខែ ។

(.) យ៉ាងនេះ ហៅថា "ខណ្ឌដក" សម្រាប់ដាក់ក្នុងសេចក្ដីនៃរឿងមួយៗ ដែលនៅមិនទាន់ចប់រឿង អស់តែសេចក្ដី ទោះបីនៅសល់ក្រដាស់នៅខាងចុងច្រើនក្ដី ក៏ត្រូវតែខណ្ឌចោល ហើយដកសរសេរក្នុងបន្ទាត់មួយទៀតជាថ្មី ។

(.) យ៉ាងនេះ ហៅថា "ខណ្ឌ" សម្រាប់ដាក់ក្នុងប្រយោគមួយៗ ដែលត្រូវខណ្ឌ ។

(%)
។៚
} យ៉ាងនេះហៅថា "ខណ្ឌបរិយោសាន" សម្រាប់ដាក់ក្នុងទីបំផុតបង្អស់នៃសេចក្ដីមួយៗ ឬរឿងមួយៗ ដែលចប់ស្រេច ។

(?) យ៉ាងនេះ ហៅថា "បុច្ឆនសញ្ញា" សម្រាប់ដាក់ខាងចុងនៃពាក្យសួរ, ដណ្ដឹង, ឆ្ងល់
៚
ឬសង្ស័យអ្វីមួយ ។

( ) យ៉ាងនេះ ហៅថា "នខសញ្ញា" សម្រាប់ដាក់រាំងសេចក្ដីដែលត្រូវបញ្ចូល ឬរាំងសេចក្ដីដែលនិយាយពន្យល់ឱ្យស្ដាប់បាន ។

(") យ៉ាងនេះ ហៅថា "វិឡារសញ្ញាបើក" សម្រាប់បើក ឬខណ្ឌរាំងសេចក្ដីណាមួយ

ដែលជាសេចក្ដីសំខាន់គួរឱ្យចងចាំ ។

(") យ៉ាងនេះ ហៅថា "វិឡារសញ្ញាបិទ" សម្រាប់បិទសេចក្ដី, ពាក្យ និងឈ្មោះដែលសំខាន់នោះ កុំឱ្យច្រឡំសេចក្ដីដទៃ ។

(') យ៉ាងនេះ ហៅថា "អន្តរលេខបើក" សម្រាប់បើក ឬរាំងសេចក្ដីដែលអ្នកដទៃនិយាយ ហើយអ្នកម្នាក់ទៀតយកសេចក្ដីនុ៎ះ មកនិយាយដំណាល ។

(') យ៉ាងនេះ ហៅថា "អន្តរលេខបិទ" សម្រាប់បិទសេចក្ដីដែលអ្នកដទៃនិយាយ ហើយអ្នកម្នាក់ទៀតយកសេចក្ដីនុ៎ះ មកនិយាយដំណាល ក៏ដាក់សញ្ញានោះរាំង ដើម្បីកុំឱ្យច្រឡំសេចក្ដី ដែលត្រូវនិយាយតទៅទៀត ។

(,) យ៉ាងនេះ ហៅថា "ឧគ្គហៈ" ឬ "អវគ្គហៈ" សម្រាប់ដាក់ក្នុង ប្រយោគណាមួយដែលមានស្រះនៅជិតផ្ទាល់គ្នា ហើយត្រូវលុបស្រះមួយចេញ ។

(!) យ៉ាងនេះ ហៅថា "អច្ឆរិយសញ្ញា" សម្រាប់ដាក់ក្នុងសេចក្ដីរបស់អ្នកនិយាយដែលនិយាយកោតញញើត, ស្ញប់ស្ញែង ឬអស្ចារ្យនឹងអ្វីមួយ ហើយនិយាយបង្អូសខ្យល់សម្ដីនោះវែងជាងធម្មតា ឧ. " យើអើហ្ន! មិនដែលឃើញទេតើ" ។

(!) យ៉ាងនេះ ហៅថា "វិម្ហសញ្ញា" សម្រាប់ដាក់ខាងចុងពាក្យរបស់អ្នកនិយាយដែលមានសេចក្ដីសរសើរ ឬស្រឡាញ់ចូលចិត្តនឹងរបស់អ្វីមួយ ហើយនិយាយធ្វើខ្យល់សម្ដីបង្អូសយ៉ាងវែងៗ ឧ. "យើ ! ល្អអ្វីម្លេះ!" ។

(-) យ៉ាងនេះហៅថា "នយសញ្ញា" សម្រាប់គូសខាងចុងពាក្យ ដែលមានសេចក្ដីដូច

គ្នាខាងដើម ឬសម្រាប់គូសខាងក្រោមពាក្យដែលត្រូវទន្ទេញឱ្យចាំ ឬដែលជាសេចក្ដីសំខាន់ គួរពិនិត្យឱ្យពិតប្រាកដ ។

(+) យ៉ាងនេះ ហៅថា "កាកបាទ" សម្គាល់សេចក្ដីថា ទៅជា, និង, ហើយនិង ។

(>) យ៉ាងនេះ ហៅថា "គតសញ្ញា" សម្គាល់សេចក្ដីថា ទៅជា, កើតទៅជា ។

(<) យ៉ាងនេះ ហៅថា "អាគតសញ្ញា" សម្គាល់សេចក្ដីថា មកពី, កើតមកពី ។

(ៈ-) យ៉ាងនេះ ហៅថា "កុក្កុដនេត្រ" សម្រាប់ដាក់សេចក្ដីដែលត្រូវនិយាយតទៅ; ឧ. ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលថា ៈ- "ធ្វើល្អបានល្អ, ធ្វើអាក្រក់ បានអាក្រក់ " ជាដើម ។ សញ្ញានេះប្រែថា ភ្នែកមាន់ ។

(៙)យ៉ាងនេះ ហៅថា "កុក្កុដនេត្រ" ប្រែថា "ភ្នែកមាន់" សម្រាប់ដាក់ខាងដើមបន្ទាត់មុនសេចក្ដីធំនីមួយៗ ។

និមិត្តសញ្ញាទាំងអស់នេះ ខ្ញុំគ្រាន់តែស្រាវជ្រាវយកមក ដើម្បីជាប្រយោជន៍ដល់អ្នកដែលនិយមប្រើ កុំឱ្យមានការបាត់បង់ភ្លេចអស់ទៅតែប៉ុណ្ណោះ មិនបានយកមកប្រើក្នុងសៀវភៅនេះឱ្យបានគ្រប់អន្លើទេ ។ បើអស់លោកណា អាចដឹងនិមិត្តសញ្ញាផ្សេងៗ ទៀត យកមកដាក់បញ្ចូលបន្ថែមក្នុងទំព័រសៀវភៅនេះ ក៏ជាការល្អថែមមួយកម្រិតទៀតដែរ ។៚

# អដ្ឋសាលិនី

# អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ ១

**មាតិកាធម៌** **ទំព័រ**


**ឧប្បត្តិកថាជាដើម** ..... ..... ..... ...... ..... ..... ..... ..... .... អ

**អដ្ឋកថាធម្មសង្គណី** អារម្ភកថា .... ..... .... .... .... .... .... ..... .... .... .... ១

និទានកថា .... ..... ..... ..... ..... .... .... ..... ..... ..... ..... ..... ..... ..... .... ៥

សម្ដែងអំពីបករណ៍ ៧ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៨

ការមានមកនៃកថាវត្ថុ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៩


### ធម្មសង្គណី


សម្ដែងអំពីចិត្តវិភត្តិ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៦

សម្ដែងអំពីរូបវិភត្តិ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៧

សម្ដែងអំពីនិក្ខេបរាសិ .... ..... ..... ..... ..... ..... .... ..... ..... ..... ..... ១៧

សម្ដែងអំពីអត្ថុទ្ធារៈ ..... ..... ..... ..... ..... .... ..... ..... ..... ..... ..... ១៨
**វិភង្គប្បករណ៍ ..... ..... ..... ..... ..... ..... ..... ..... ..... ១៩**
**ធាតុកថាបករណ៍ ..... ..... ..... ..... ..... ..... ..... ..... .... ២១**
**បុគ្គលប្បញ្ញត្តិប្បករណ៍ ..... ..... ..... ..... ..... ..... ..... ..... ២៣**
**កថាវត្ថុប្បករណ៍ ..... ..... .... ..... ..... ..... ..... ..... .... ២៣**
**យមកប្បករណ៍ ..... ..... ..... ..... ..... ..... ..... ..... ..... ២៤**
**មហាបករណ៍ ..... ..... ..... ..... ..... ..... ..... ..... ...... ២៥**
សម្ដែងអំពីសមន្តប្បដ្ឋាន ២៤ ..... ..... ..... ..... ..... ..... ..... ..... ..... ៣០
សម្ដែងអំពីការប្រៀបធៀបនឹងសាគរ ..... ..... ..... ..... ..... ..... ..... ៣០
សម្ដែងអំពីព្រះឆព្វណ្ណរង្សី ..... ..... ..... ..... ..... ..... ..... ..... ..... ៣៧
បុព្វយោគរបស់ភិក្ខុ ៥០០ ..... ..... ..... ..... ..... ..... ..... ..... ..... ៤៥
បឋមពុទ្ធវចនៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៤៦
ពាក្យថា វិន័យមានអត្ថ ៣ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ៥១
ពាក្យថា ព្រះសូត្រមានអត្ថ ៦ យ៉ាង ..... ..... ..... ..... ..... ..... ..... .... ៥២
អភិធម្មមានអត្ថ ៥ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៥៤
សម្ដែងអំពីន័យដែលមិនផ្សេងគ្នានៃបិដក ..... ..... ..... ..... ..... ..... ... ៥៦
សម្ដែងអំពីន័យពាក្យថាបិដកដែលប្លែកផ្សេងគ្នា ..... ..... ..... ..... ..... ៥៨
សម្ដែងអំពីទេសនា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥៩

សម្ដែងអំពីសាសនៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥៩
សម្ដែងអំពីកថា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ....... ៦០
សម្ដែងអំពីសិក្ខាជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៦០
សម្ដែងអំពីគម្ពីរភាព ៤ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ៦១
សម្ដែងអំពីបរិយត្តិ ៣ ប្រភេទ ..... ..... ..... ..... ..... ..... ..... ..... .... ៦៤
សម្ដែងអំពីសម្បត្តិ ៣ ប្រភេទ ..... ..... ..... ..... ..... ..... ..... ..... ..... ៦៧
សម្ដែងអំពីវិបត្តិ ៣ ប្រភេទ ..... ..... ..... ..... ..... ..... ..... ..... ..... .. ៦៨
ពុទ្ធវចនៈមាន ៥ និកាយ ..... ..... ..... ..... ..... ..... ..... ..... ...... ...... ៧០
សម្ដែងអំពីទីឃនិកាយ ៣៤ សូត្រ ..... ..... ..... ..... ..... ..... ..... ..... ..៧០
សម្ដែងអំពីមជ្ឈិមនិកាយ ១៥២ សូត្រ ..... ..... ..... ..... ..... ..... ..... ... ៧១
សម្ដែងអំពីសំយុត្តនិកាយជាដើម .... ..... ..... ..... ..... ..... ..... ..... ... ៧២
ព្រះពុទ្ធវចនៈមានអង្គ ៩ ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៧៣
ព្រះពុទ្ធវចនៈ ៨៤.000 ព្រះធម្មក្ខន្ធ ..... ..... ..... ..... ..... ..... ..... .... ៧៥
ព្រះពុទ្ធវចនៈក្នុងវេលាធ្វើបឋមសង្គីតិ ..... ..... ..... ..... ..... ..... ..... .. ៧៦
សម្ដែងដោយចំពោះព្រះអភិធម្ម ..... ..... ..... ..... ..... ..... ..... ..... ... ៧៧
ភិក្ខុអ្នកទ្រទ្រង់អភិធម្មឈ្មោះថាធម្មកថិក ..... ..... ..... ..... ..... ..... ... ៨១
អ្នកជំទាស់ព្រះអភិធម្មឈ្មោះថាទម្លាយជិនចក្រ ..... ..... ..... ..... ..... ... ៨២

ព្រះអភិធម្មមាននិទានឬទេ ? ..... ..... ..... ..... ..... ..... ..... ...... ..... ៨៣
សម្ដែងអំពីព្រះអភិធម្មមាននិទាន ..... ..... ..... ..... ..... ..... ..... ..... .. ៨៤
ព្រះអភិធម្មមាននិទាន ២ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... .....៨៧

**អធិគមនិទាន**

សម្ដែងអំពីរឿងសុមេធតាបស ..... ..... ..... ..... ..... ..... ..... ..... ...... ៩០
សម្ដែងអំពីទីចង្ក្រមមានទោស ៥ យ៉ាង ..... ..... ..... ..... ..... ..... ..... ...៩៨
សម្ដែងអំពីទីចង្ក្រមដែលមិនមានទោស ..... ..... ..... ..... ..... ..... ..... ...៩៩
សេចក្ដីសុខរបស់សមណៈ ៨ យ៉ាង ..... ..... ..... ..... ..... ..... ..... ... ១០០
សម្ដែងអំពីវិស្សកម្មទេវបុត្រនិមិត្តអាស្រមបទជាដើម ..... ..... ..... .... ១០១
សម្ដែងអំពីសំពត់សាដកមានទោស ៩ យ៉ាង ..... ..... ..... ..... ..... ..... ១០៤
សំពត់សម្បកឈើមានអានិសង្ស ១២ យ៉ាង ..... ..... ..... ..... ..... ..... ១០៥
គល់ឈើមានគុណ ១០ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ១០៩
សម្ដែងអំពីការធ្វើផ្លូវ និងបានទទួលព្យាករណ៍ .... ..... ..... ..... ..... ... ១១១
សម្ដែងអំពីពុទ្ធការកធម៌ ១០ យ៉ាង .... ..... ..... ..... ..... ..... ..... .... ១២៣
**កោណ្ឌញ្ញកថាទី ២ ..... ..... ..... ..... ..... ..... ..... ....... ១៣៧**
**មង្គលកថាទី ៣ ..... ..... ..... ..... ..... ..... ..... .... .... ១៣៩**
**សុមនកថាទី ៤ ..... ..... ..... ..... ..... ..... ..... ..... ... ១៥១**

វេទតកថាទី ៥ ..... .... ..... ..... ..... ..... ..... ..... ..... ១៥២

សោភិតកថាទី ៦ ..... ..... ..... ..... ..... ...... ...... ..... ១៥៤

អនោមទស្សីកថាទី ៧ ..... .... ..... ..... ..... ..... .... .... ១៥៥

បទុមកថាទី ៨ .... .... ..... ..... ..... ..... ..... ..... ..... ១៥៦

នារទកថាទី ៩ ..... ..... ..... ..... ..... ..... ..... ..... .... ១៥៨

បទុមកថាទី ១០ ..... ..... ..... .... ..... ..... ..... ..... ... ១៥៩

សុមេធកថាទី ១១ ..... ..... ..... ..... ..... ..... ..... ..... ១៦០

សជាតកថាទី ១២ ..... ..... ..... ..... ..... ..... ..... ...... ១៦១

បិយទស្សីកថាទី ១៣ ..... ..... ..... ..... ..... ..... .... .... ១៦៣

អត្ថទស្សីកថាទី ១៤ ..... ..... ..... ..... ..... ..... ..... ..... ១៦៤

ធម្មទស្សីកថាទី ១៥ ..... ..... ..... ..... ..... ..... ..... ..... ១៦៥

សិទ្ធត្ថកថាទី ១៦ ..... ..... ..... ..... ..... ..... ..... ...... ១៦៧

តិស្សកថាទី ១៧ ..... ..... ..... ..... ..... ..... ..... ...... ១៦៨

បុស្សកថាទី ១៨ .. ..... ..... ..... ..... ..... ..... ..... ..... ១៦៩

វិបស្សីកថាទី ១៩ ..... ..... ..... ..... ..... ..... ..... ..... ១៧០

សិខីកថាទី ២០ ..... ..... ..... ..... ..... ..... ..... ...... ១៧១

វិស្សភូកថាទី ២១ ..... ..... ..... ..... ..... ..... ..... .... ១៧៣

កកុសន្ធកថាទី ២២ ..... ..... ..... ..... ..... ..... ..... ..... ១៧៤

**គោនាគមនកថាទី ២៣ ..... ..... ..... ..... ..... ..... ....... ១៧៥**

**កស្សបកថាទី ២៤ ..... ..... ..... ..... ..... ..... ..... ...... ១៧៦**

សម្តែងអំពីធម្មសមោធាន ៨ ប្រការ ..... ..... ..... ..... .... .... .... .... ១៧៨

សម្តែងអំពីទានជាបរមត្ថ .... .... ..... ..... ..... ..... ..... ..... ..... ..... ១៨១

សម្តែងអំពីសីលបារមីដែលជាបរមត្ថ .... .... .... ..... ..... ..... ..... ..... ១៨១

សម្តែងអំពីនេក្ខម្មបារមីជាបរមត្ថ ..... ..... ..... ..... ..... ..... ..... ..... ១៨២

សម្តែងអំពីបញ្ញាបារមីជាបរមត្ថ ..... ..... ..... ..... ..... ..... .... .... .... ១៨៣

សម្តែងអំពីទេសនានិទាន ...... ..... ..... ..... ..... ..... ..... ..... ..... ..... ១៩៥

ម្យ៉ាងទៀតព្រះអភិធម្មមាននិទាន ៣ ..... ..... ..... ..... ..... ..... ..... ១៩៧

## អដ្ឋកថាមាតិកានុបុព្វបទ

សម្តែងអំពីសប្បទេស និងនិប្បទេស .... .... ..... ..... ..... ..... ..... ..... ២០២

អធិប្បាយធម៌ជាកុសលត្តិកៈទី ១ ..... ..... ..... ..... ..... ..... ..... ២០៣

វិគ្រោះសព្ទថា កុសល និងធម៌ ..... ..... ..... ..... ..... ..... ..... ..... ..... ២០៦

សម្តែងអំពីសុខវេទនាតិកៈទី ២ ..... ..... ..... ..... ..... ..... ..... ..... ... ២១១

សម្តែងអំពីទុក្ខវេទនា ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ២១៤

សម្តែងអំពីលក្ខណៈរបស់សព្ទ ..... ..... ..... ..... ..... ..... ..... ..... ..... ២១៥

សម្តែងអំពីសម្បយុត្ត ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ២១៦

សម្ដែងអំពីវិបាកត្តិកៈទី ៣ ..... ..... ..... ..... ..... ..... ..... ..... .... ..... ២១៧

សម្ដែងអំពីឧបាទិន្នតិកៈទី ៤ ..... ..... ..... ..... ..... ..... ..... ..... ..... . ២១៨

សម្ដែងអំពីសង្កិលិដ្ឋតិកៈទី ៥ ..... ..... ..... ..... ..... ..... ..... ..... ..... ២១៨

សម្ដែងអំពីវិតក្កតិកៈទី ៦ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២១៩

សម្ដែងអំពីបីតិត្តិកៈទី ៧ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២០

សម្ដែងអំពីទស្សនត្តិកៈទី ៨ ..... ..... ..... ..... ..... ..... ..... ..... ..... ២២១

សម្ដែងអំពីទស្សនហេតុត្តិកៈទី ៩ ..... ..... ..... ..... ..... ..... ..... ..... ២២២

សម្ដែងអំពីអាចយគាមិត្តិកៈទី ១០ ..... ..... ..... ..... ..... ..... ..... ... ២២៣

សម្ដែងអំពីសេក្ខតិកៈទី ១១ ..... ..... ..... ..... ..... ..... ..... ..... ..... ២២៥

សម្ដែងអំពីបរិត្តតិកៈទី ១២ ..... ..... ..... ..... ..... ..... ..... ..... ..... .. ២២៥

សម្ដែងអំពីបរិត្តារម្មណត្តិកៈទី ១៣ ..... ..... ..... ..... ..... ..... ..... .... ២២៦

សម្ដែងអំពីហីនត្តិកៈទី ១៤ ..... ..... ..... ..... ..... ..... ..... ..... ..... .. ២២៦

សម្ដែងអំពីមិច្ឆត្តតិកៈទី ១៥ ..... ..... ..... ..... ..... ..... ..... ..... ..... ២២៧

សម្ដែងអំពីមគ្គារម្មណត្តិកៈទី ១៦ ..... ..... ..... ..... ..... ..... ..... ..... ២២៨

សម្ដែងអំពីឧប្បន្នតិកៈទី ១៧ ..... ..... ..... ..... ..... ..... ..... ..... ២២៩

សម្ដែងអំពីអតីតត្តិកៈទី ១៨ ..... ..... ..... ..... ..... ..... ..... ..... ..... ២៣០

សម្ដែងអំពីអនន្តរត្តិកៈទី ១៩ ..... ..... ..... ..... ..... ..... ..... ..... ..... ២៣០

សម្តែងអំពីអជ្ឈត្តិកៈទី ២០ ..... ..... ..... ..... ..... ..... ..... ..... ..... ២៣០
សម្តែងអំពីនិទស្សនត្តិកៈទី ២២ ..... ..... ..... ..... ..... ..... ..... ..... ២៣៣
សម្តែងអំពីចូឡន្តរទុកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៣៧
សម្តែងអំពីអាសវគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... .. ២៣៨
សម្តែងអំពីសំយោជនគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ២៤០
សម្តែងអំពីគន្ថគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤១
សម្តែងអំពីឱឃគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤១
សម្តែងអំពីយោគគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... .... ២៤២
សម្តែងអំពីនីវរណគោច្ឆកៈ .... ..... ..... ..... ..... ..... ..... ..... ..... .... ២៤២
សម្តែងអំពីបរាមាសគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ២៤២
សម្តែងអំពីមហន្តរទុកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៣
សម្តែងអំពីឧបាទានគោច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៥
សម្តែងអំពីកិលេសទុកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៥
សម្តែងអំពីបិដ្ឋិទុកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៦
សម្តែងអំពីសុត្តន្តិកទុកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៨
សម្តែងអំពីនាមរូបទុកៈ ...... ..... ..... ..... ..... ..... ..... ..... ..... ...... ២៥១

## អដ្ឋកថាកាមាវចរកុសល

អធិប្បាយបទភាជនិយនៃកាមាវចរកុសល ..... ..... ..... ..... ..... ..... ២៥៨
សម្តែងអំពីពាក្យបុច្ឆា ៥ យ៉ាង ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៩
សម្តែងអំពីសមយសព្ទ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៦៤
អធិប្បាយពាក្យថា កាមាវចរ ..... ..... ..... ..... ..... ..... ..... ..... ..... ២៧៨
អធិប្បាយពាក្យថា កុសល ..... ..... ..... ..... ..... ..... ..... ..... ..... ២៨១
អធិប្បាយពាក្យថា ចិត្ត ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៨៤
អធិប្បាយពាក្យថា ឧប្បន្នធម៌ ៤ ..... ..... ..... ..... ..... ..... ..... ..... ២៩២
សម្តែងអំពីឧប្បន្នសព្ទ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៩៣
អធិប្បាយពាក្យថា ចិត្តជាប្រធាន ..... ..... ..... ..... ..... ..... ..... ..... ២៩៧
អធិប្បាយពាក្យថា សោមនស្សសហគតៈ ... .... ..... ..... ..... ..... ..... ៣០២
សម្តែងអំពីសំសដ្ឋសព្ទ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣០៤
អធិប្បាយពាក្យថា ញាណសម្បយុត្ត ..... ..... ..... ..... ..... ..... ..... ... ៣០៦
អធិប្បាយពាក្យថា អារម្មណ៍ ..... ..... ..... ..... ..... ..... ..... ..... ..... ៣០៨
សម្តែងអំពីន័យអដ្ឋកថាមុត្តកៈ ..... ..... ..... ..... ..... ..... ..... ..... ... ៣១៥

## ឈ្មោះគម្ពីរផ្សេងៗ
## ដែលប្រើជាអក្សរកាត់ ក្នុងបឋមភាគ ១ នេះគឺ ៖-

| | |
|---|---|
| អដ្ឋ. យោ. | = អដ្ឋសាលិនី អត្ថយោជនា |
| អភិ. | = អភិធម្មបិដក |
| អំ. អដ្ឋក. | = អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. ឯកក. | = អង្គុត្តរនិកាយ ឯកកនិបាត |
| អំ. ចតុក្ក. | = អង្គុត្តរនិកាយ ចតុក្កនិបាត |
| អំ. ឆក្ក. | = អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. តិក. | = អង្គុត្តរនិកាយ តិកនិបាត |
| អំ. ទសក. | = អង្គុត្តរនិកាយ ទសកនិបាត |
| អំ. សត្តក. | = អង្គុត្តរនិកាយ សត្តកនិបាត |
| ឯកក. | = ឯកកនិបាត |
| ខុ. ឧ. | = ខុទ្ទកនិកាយ ឧទានវគ្គ |
| ខុ. ឥតិ | = ខុទ្ទកនិកាយ ឥតិវុត្តក |
| ខុ. អបទាន. | = ខុទ្ទកនិកាយ អបទានវគ្គ |
| ខុ. ចូឡ. | = ខុទ្ទកនិកាយ ចូឡនិទ្ទេស |
| ខុ. ចរិយា. | = ខុទ្ទកនិកាយ ចរិយាបិដក |

| | |
|---|---|
| ខុ. ជា. | = ខុទ្ទកនិកាយ ជាតក |
| ខុ. ធ. | = ខុទ្ទកនិកាយ ធម្មបទ |
| ខុ. វិ . | = ខុទ្ទកនិកាយ វិមានវត្ថុ |
| ខុ. សុ. | = ខុទ្ទកនិកាយ សុត្តនិបាត |
| ខុ. ថេរ. | = ខុទ្ទកនិកាយ ថេរគាថា |
| ខុ. ពុទ្ធ. | = ខុទ្ទកនិកាយ ពុទ្ធវង្ស |
| ខុ. បដិ. | = ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ទី. សី. | = ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ទី. មហា. | = ទីឃនិកាយ មហាវគ្គ |
| ទី. ម. | = ទីឃនិកាយ មហាវគ្គ |
| មូល. | = មូលដិកា |
| ម. មូ. | = មជ្ឈិមនិកាយ មូលបណ្ណាសក |
| ម. ម. | = មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក |
| ម. ឧ. | = មជ្ឈិមនិកាយ ឧបរិបណ្ណាសក |
| ម. មូ. | = មជ្ឈិមនិកាយ មូលបណ្ណាសក |
| វិនយ. | = វិនយបិដក |
| សំ. ខ. | = សំយុត្តនិកាយ ខន្ធវគ្គ ឬសំយុត្តនិកាយ ខន្ធវារវគ្គ |

| | |
|---|---|
| សំ. ម. | = សំយុត្តនិកាយ មហាវារវគ្គ |
| សី. | = សីហឡ |
| សំ. សឡា. | = សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. ស. | = សំយុត្តនិកាយ សគាថវគ្គ |
| សំ. និ. | = សំយុត្តនិកាយ និទានវគ្គ |
| សំ. ម. | = សំយុត្តនិកាយ មជ្ឈិមបណ្ណាសក ។ |

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ ធម្មសង្គណី

## បឋមភាគ ១

## ព. ស. ២៥៥៧

# អដ្ឋសាលិនី
# អដ្ឋកថាព្រះអភិធម្មបិដក
# ឈ្មោះ ធម្មសង្គណី

***នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕***

## អារម្ភកថា [១]

**ករុណា វិយ សត្តេសុ  បញ្ញាយស្ស មហេសិនោ**
**ញេយ្យធម្មេសុ សព្វេសុ  បវត្តិត្ថ យថារុចី ... ៕**

ព្រះសព្វញ្ញុតញ្ញាណនៃព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះអង្គស្វែងរកគុណដ៏ធំ ប្រព្រឹត្តទៅក្នុងញេយ្យធម៌ទាំងពួងតាមការពេញព្រះទ័យ, ដូចព្រះករុណាដែលទ្រង់ផ្សាយទៅក្នុងសត្វទាំងឡាយ; ព្រះសម្ពុទ្ធអង្គឯណា មានព្រះទ័យករុណានោះ ឱ្យឧស្សាហ៍ឡើងដោយល្អ ក្នុងសត្វលោកទាំងឡាយ កាលប្រថាប់គង់ចាំវស្សា ក្នុងតាវត្តិង្សទេវលោក, ក្នុងគ្រាដែលសម្តែងយមកប្បាដិហារ្យស្រេចហើយ; បានប្រថាប់គង់លើបណ្ឌុកម្ពលសិលាសនៈក្រោមដើមបរិច្ឆត្តកៈ [២] ទ្រង់ព្រះសិរីសោ

---

[១] ច្បាប់ខ្លះថា គន្ថារម្ភកថា ។ កថានេះជារបស់អ្នករចនាដើម មិនមែនជារបស់អ្នកប្រែរៀបរៀងទេ។

[២] ដើមរលួសផ្កុង, ដើមឈើទេវតា ។ អដ្ឋ. យោ. ដើមឈើនេះ តាំងនៅអំពីទីបំផុតនៃបរិស័ទ ដូចជាឆត្រ ។

ភាគ្យៈ ដូចព្រះអាទិត្យលើកំពូលភ្នំយុគន្ធរ; ព្រះអង្គដែលពួកទេវតាទាំងហ៊ីនចក្រវាឡ [៣] បានមកហែហមពទ្ធជុំវិញអង្គុយប្រជុំគ្នា; សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់បានធ្វើសន្តុសិតទេវបុត្រ ដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធានដល់ពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គ (ប្រព័ន្ធ) ព្រះអភិធម្ម ជាប់តគ្នាទៅ៣ហូត ១ វស្សានកាល ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។

ខ្ញុំសូមនមស្ការព្រះយុគលបាទនៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានសិរីសោភាគ្យៈព្រះអង្គនោះ សូមបូជាចំពោះព្រះសទ្ធម្ម និងធ្វើអញ្ជលីចំពោះព្រះសង្ឃ; ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ ចំពោះព្រះរតនត្រ័យដែលខ្ញុំធ្វើហើយនេះ សូមអន្តរាយទាំងឡាយ ចូរវិនាសបាត់ទៅ កុំបីមានសេសសល់ឡើយ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាទេវៈនៃទេវតា ជាអ្នកនាំពិសេស ជាអ្នកដែលភិក្ខុឈ្មោះថា **ពុទ្ធឃោសៈ** មានអាចារៈ និងសីលបរិសុទ្ធ, មានបញ្ញាឈ្លាសវៃ, ប្រាសចាកមន្ទិល, ទូលអារាធនាដោយគោរពចំពោះព្រះអង្គនោះ ក្នុងសម័យដែលទ្រង់សម្តែងព្រះអភិធម្មណា ដល់ទេវតាទាំងឡាយ, ហើយក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នក

---

[៣] ធម្មជាតិដែលមានការវិលទៅដូចជាកង់នៃរថ ឈ្មោះថា ចក្កវាឡ (អត្ថយោជនា) ។

ជាឧបដ្ឋាករបស់ព្រះមហេសី ជិតស្រះអនោត្តត្តៈ (ស្រះដែលមិនមានកម្តៅថ្ងៃចូលដល់) ដោយសេចក្តី (ណែនាំដោយសង្ខេប); ព្រះថេរៈបានស្តាប់ហើយ ក៏មកកាន់ផ្ទៃផែនដី, សម្តែងប្រាប់ដល់ភិក្ខុទាំងឡាយ; ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយទ្រទ្រង់ ចាំទុកហើយ ដោយប្រការដូច្នេះ ។

ក្នុងសម័យធ្វើសង្គាយនា ព្រះអានន្ទត្ថេរ អ្នកជាវេទេហមុនី [៤] បានចងក្រងម្តងទៀត, អដ្ឋកថានៃព្រះអភិធម្មនោះ វិចិត្រទៅដោយន័យផ្សេងៗ ដែលបុគ្គលពិចារណារឿយៗ ដោយបញ្ញាដ៏ជ្រាលជ្រៅទើបឈានចុះបាននោះ; ដែលព្រះថេរៈទាំងឡាយ អ្នកមានវសី (ស្ទាត់ជំនាញ) មានព្រះមហាកស្សបជាដើម ចងក្រងហើយក្នុងខាងដើម; ព្រះថេរៈអ្នកស្វែងរកគុណដ៏ធំទាំងឡាយ ចងក្រងតាមហើយជាខាងក្រោយទៀត; ម្យ៉ាងទៀត ព្រះអដ្ឋកថាអភិធម្មឯណា ដែលព្រះមហិន្ទត្ថេរនាំមកកាន់កោះដ៏ឧត្តមនេះ រៀបរៀងទុកដោយភាសាអ្នកកោះតម្ពបណ្ណិ [*]; ហើយលើកឡើងកាន់ភាសាដែលមិនមានទោស តាម

[៤] អដ្ឋ. យោ. អ្នកប្រាជ្ញដែលចេះដឹង (ស្គាល់) នូវហេតុដែលមានប្រយោជន៍ និងគ្មានប្រយោជន៍ ឈ្មោះថា វេទេហមុនី ។

[*] កោះដែលមនុស្សមានបាទដៃក្រហមរស់នៅ ។

ន័យនៃតន្តិភាសា *; មិនឱ្យលាយដោយលទ្ធិរបស់និកាយដទៃ ។ ការសម្តែងពាក្យវិនិច្ឆ័យរបស់ភិក្ខុអ្នកនៅក្នុងមហាវិហារ នឹងកាន់យកវត្ថុដែលគួរកាន់យក នឹងញុំាងបុគ្គលអ្នកមានបញ្ញា ឱ្យត្រេកអរហើយ នឹងប្រកាសអត្ថសូម្បីក្នុងអដ្ឋកថា ដែលមានមកទាំងឡាយ; ក៏ព្រោះហេតុដែលកម្មដ្ឋានទាំងឡាយ, ចរិយា, អភិញ្ញា និងវិបស្សនាទាំងអស់នេះ ខ្ញុំប្រកាសទុកក្នុងវិសុទ្ធិមគ្គហើយ; ព្រោះហេតុដូច្នោះ នឹងមិនកាន់យកកម្មដ្ឋានជាដើម តាមបែបទាំងអស់ទេ, នឹងធ្វើការពណ៌នាសេចក្តីតាមលំដាប់បទទាំងឡាយប៉ុណ្ណោះ; កាលបើខ្ញុំពោលហើយនូវព្រះអភិធម្មកថានេះ ដោយប្រការដូច្នេះ, សូមសាធុជនទាំងឡាយ កុំមានចិត្តរាយមាយ, ចូរតាំងចិត្តស្តាប់ចុះ, ព្រោះថា កថានេះ រកបានដោយលំបាកណាស់ ។ ៚

ចប់អារម្ភកថា

---

* ភាសាដែលមានរបៀបហៅថា តន្តិភាសា បានដល់ ភាសាបាលី (មគធភាសា) បញ្ជាក់ថា ភាសានេះ គឺជាភាសាយានដែលប្រើជាផ្លូវការក្នុងព្រះពុទ្ធសាសនា ។ (សេចក្តីពន្យល់យ៉ាងពិស្តារ អំពីដើមកំណើតនៃភាសានេះ នឹងមានសម្តែងនៅក្នុងសម្មោហវិនោទនីត្រង់និរុត្តិបដិសម្ភិទា) ។

# និទានកថា

បណ្ដាពាក្យទាំងឡាយនោះ ពាក្យថា **“អភិធម្ម”** សួរថា ឈ្មោះថា **អភិធម្ម** ព្រោះអត្ថ (សេចក្ដី) ថា ដូចម្ដេច ? (**កេនដ្ឋេន អភិធម្មោ**) ឆ្លើយថា ព្រោះអត្ថថា ជាធម៌ដ៏ក្រៃលែង និងជាធម៌ដ៏វិសេស (**ធម្មាតិរេកធម្មវិសេសដ្ឋេន អភិធម្មោ**), ពិតណាស់ **អភិ**សព្ទក្នុងពាក្យថា អភិធម្មនេះ សម្ដែងដល់សេចក្ដីថាសព្ទក្រៃលែង និងវិសេស; ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ពាឡ្ហា មេ អាវុសោ ទុក្ខា វេទនា អភិក្កមន្តិ, នោ បដិក្កមន្តិ; អភិក្កន្តវណ្ណេន** = ម្នាលអាវុសោ ទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំ រមែងចម្រើនក្រៃលែង, មិនថយចុះឡើយ”[៥]; និងដូចពាក្យជាដើមថា **មានសម្បុរល្អណាស់** ព្រោះហេតុដូច្នោះ ទើបពោលថា “ប្រៀបដូចជាឆត្រ និងទង់ជាច្រើន ត្រូវគេលើកឡើងហើយ, ឆត្រណា មានប្រមាណក្រៃលែង, មានសម្បុរ និងសណ្ឋានដ៏ពិសេសជាងឆត្រដទៃ, ឆត្រនោះ ឈ្មោះថា **“អតិឆត្រ** = ឆត្រដ៏ក្រៃលែង” ; ទង់ណាមានប្រមាណក្រៃលែង, សម្បូណ៌ដោយសេចក្ដី ពិសេសនៃពណ៌ដែលជ្រលក់ហើយផ្សេងៗនោះឯង, ទង់នោះហៅថា **“អតិធជោ** = ទង់ដ៏ក្រៃលែង” ; នឹងប្រៀបដូចកាលពួករាជកុមារ និងពួកទេវតារួមប្រជុំគ្នាហើយ, រាជកុមារណាក្រៃ

---

[៥] ម. ឧ., សំ. ខ. ។

លែងជាងដោយសម្បត្តិ, មានជាតិ, ភោគៈ, យស, ភាពជាធំជាដើម និងមានឆវីវណ្ណពិសេសជាង, ព្រះរាជកុមារនោះហៅថា “**អតិរាជកុមារ** = រាជកុមារដ៏ក្រៃលែង” , ទេវតាណា ក្រៃលែងជាងដោយអាយុ, វណ្ណៈ, ឥស្សរិយៈ, យស និងសម្បត្តិជាដើម និងមានឆវីវណ្ណពិសេសជាង ទេវតានោះ ហៅថា “**អតិទេវៈ** = ទេវតាអ្នកក្រៃលែង” ។ សូម្បីព្រហ្មដែលមានលក្ខណៈដូចនោះ គេក៏ហៅថា “**អតិព្រហ្ម** = ព្រហ្មអ្នកធំក្រៃលែង” , យ៉ាងណា; សូម្បីធម៌នេះ ក៏យ៉ាងនោះដែរ ហៅថា **អភិធម្ម** ព្រោះអត្ថថាជាធម៌ដ៏ក្រៃលែង និងពិសេស ។

ពិតណាស់ សំឡឹងដល់ព្រះសូត្រហើយ ព្រះពុទ្ធអង្គទ្រង់ចែកខន្ធ ៥ ទុក ដោយឯកទេស (ចំណែកខ្លះ) ប៉ុណ្ណោះ, មិនបានចែកដោយសព្វគ្រប់ (**និប្បទេស**) ទេ; តែសំឡឹងដល់ព្រះអភិធម្មហើយ ព្រះអង្គទ្រង់ចែកទុកដោយសព្វគ្រប់ ដោយអំណាចនៃសុត្តន្តភាជនិយន័យ, អភិធម្មភាជនិយន័យ និងបញ្ហាបុច្ឆកន័យ; ដល់អាយតនៈ ១២, ធាតុ ១៨, សច្ចៈ៤, ឥន្ទ្រិយ ២២ និងបច្ចយាការដែលសម្ដែងដល់អង្គ ១២, ក៏ត្រាស់ទុកដោយសព្វគ្រប់ដូចគ្នា; តាមពិត ន័យដែលជាសុត្តន្តភាជនិយក្នុងឥន្ទ្រិយវិភង្គ និងបញ្ហាបុច្ឆកន័យ ក្នុងបច្ចយាការប៉ុណ្ណោះមិនមាន; ពិតយ៉ាងនោះ សំឡឹងដល់ព្រះសូត្រហើយ សតិប្បដ្ឋាន ៤ ព្រះអង្គទ្រង់ចែកទុកដោយឯកទេសដូចគ្នា, មិនបានចែកទុក

ដោយសព្វគ្រប; តែសំឡឹងដល់ព្រះអភិធម្មហើយ ទ្រង់ចែកទុកដោយសព្វគ្រប់ ដោយអំណាចនៃន័យសូម្បីទាំងបី; សូម្បីសម្មប្បធាន ៤, ឥទ្ធិបាទ ៤, សម្ពោជ្ឈង្គ ៧, អរិយមគ្គមានអង្គ ៨, ឈាន ៤, អប្បមញ្ញា ៤, សិក្ខាបទ ៥, បដិសម្ភិទា ៤, ក៏ទ្រង់ចែកទុកដោយសព្វគ្រប់ ដោយអំណាចនៃន័យសូម្បីទាំងដែលដូចគ្នា; ក៏ក្នុងធម៌ទាំងឡាយនេះ ន័យដែលជាសុត្តន្តភាជនិយ ក្នុងសិក្ខាបទវិភង្គតែម្យ៉ាងមិនមាន; បើសំឡឹងដល់ព្រះសូត្រហើយ ញាណ ព្រះអង្គក៏ទ្រង់ចែកទុកដោយឯកទេសដូចគ្នា, មិនចែកដោយសព្វគ្រប់ឡើយ; កិលេសទាំងឡាយក៏ដូចគ្នា; តែសំឡឹងដល់ព្រះអភិធម្មហើយ ទ្រង់តាំងមាតិកាដោយន័យមានជាអាទិ៍ថា **"ញាណវត្ថុមានពួក ១"** ជាដើម [៦] ហើយចែកទុកដោយសព្វគ្រប់; កិលេសទាំងឡាយក៏ដូចគ្នា ទ្រង់ចែកទុកដោយន័យមិនមែនតិចទេ តាំងតែពីធម៌ពួកមួយៗ ជាដើម; តែថា សំឡឹងដល់ព្រះសូត្រការកំណត់ភូមិដទៃ ក៏ទ្រង់ចែកទុកដោយឯកទេសនោះឯង, មិនចែកទុកដោយសព្វគ្រប់ទេ; សំឡឹងដល់ព្រះអភិធម្មហើយ ទ្រង់កំណត់ភូមិដទៃទុកដោយអំណាចនៃន័យសូម្បីទាំងបី និងទ្រង់បញ្ញត្តិទុកដោយសព្វគ្រប់មែនពិត ។ ឈ្មោះថា **អភិធម្ម** ព្រោះអត្ថថា **ជាធម៌ដ៏ក្រៃលែង** និងវិសេស, ដោយប្រការដូច្នេះ ៕

---

[៦] អភិ. ។

## សម្តែងអំពីបករណ៍ ៧

**សម្តែងអំពីការកំណត់បករណ៍** ព្រះអភិធម្មនេះទ្រង់តាំងទុកដោយអំណាចនៃបករណ៍ ៧ គឺ

**១-ធម្មសង្គណីបករណ៍**

**២-វិភង្គប្បករណ៍**

**៣-ធាតុកថាបករណ៍**

**៤-បុគ្គលប្បញ្ញត្តិប្បករណ៍**

**៥-កថាវត្ថុប្បករណ៍**

**៦-យមកប្បករណ៍**

**៧-បដ្ឋានប្បករណ៍** ។

នេះជាកថា ដែលដូចគ្នារបស់អាចារ្យទាំងឡាយ ក្នុងអដ្ឋកថានេះ; ចំណែកអាចារ្យ **វិតណ្ឌវាទី** (អ្នកខ្វាស់) ពោលថា "ព្រោះហេតុអ្វីបានជាកាន់យកកថាវត្ថុផងដែរ, កថាវត្ថុនោះ **ព្រះមោគ្គលីបុត្តតិស្សត្ថេរ** តាំងទុកកាលព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ ២១៨ ឆ្នាំ មិនមែនឬ ? ព្រោះហេតុដូច្នោះ សូមឱ្យកាត់កថាវត្ថុនោះចេញ ព្រោះជាសាវកភាសិត" ។

**ច.** ឆ្លើយថា ខ្ញុំពោលថា បករណ៍ ៧ ឈ្មោះថា អភិធម្ម ។

**ស.** *សួរថា* លោកយកបករណ៍ណាមកជាបករណ៍ទី ៧?

**ច.** ឆ្លើយថា យកបករណ៍ ឈ្មោះថា **មហាធម្មហទយប្បករណ៍** រួមនឹងបករណ៍ ៦ ជាបករណ៍ទី ៧ ។

**ស.** ពោលថាក្នុងមហាធម្មហទយប្បករណ៍ មិនមានអ្វីដែលមិនធ្លាប់ពោលមកហើយ (គឺមិនមានអ្វីប្លែកទេ), ចំណែកបញ្ហាវារៈដែលសេសសល់ក៏មានតិចតួច, ព្រោះហេតុដូច្នោះ ទើបជា ៧ ព្រមទាំងកថាវត្ថុ; មិនមែនជា ៧ ទាំងកថាវត្ថុទេ, ជា ៧ ទាំងបករណ៍ដែលឈ្មោះថា **មហាធាតុកថា**; ក្នុងមហាធម្មហទយប្បករណ៍ មានបញ្ហាវារៈដែលសល់នៅតិចតួចប៉ុណ្ណោះ, ទាំងក្នុងមហាធាតុកថា ក៏មិនមានអ្វីថ្មីឡើយ, មានតន្តិ គឺបែបផែននៃពាក្យត្រឹមតែតិចតួចប៉ុណ្ណោះ ដែលនៅសល់, ទើបជា ៧ ដោយកថាវត្ថុនោះ ៕

## ការមានមកនៃកថាវត្ថុ

ពិតណាស់ ព្រះសម្មាសម្ពុទ្ធកាលទ្រង់សម្តែងនូវបករណ៍នៃអភិធម្មទាំង ៧ (សត្តប្បករណ៍) មកដោយលំដាប់ ល្មមដល់កថាវត្ថុ ក៏ទ្រង់តាំងមាតិកា (មេបទ) នៃបាលីមានប្រមាណ ១ ភាណវារៈ, ដែលនៅមិនពេញល្អក្នុងកថាមគ្គទាំងពួង ទ្រង់ធ្វើឱ្យល្មមសមគួរដល់ការប្រកបវាទៈ ដែលជាប្រធានទុក ៨ ខ (**អដ្ឋមុខាវាទយុត្តិ**) ដោយអំណាចនៃបញ្ចកៈទាំង ២ (គឺអនុលោមបញ្ចកៈ និងបច្ចនិកបញ្ចកៈ) ក្នុងបុគ្គលវាទ រហូតដល់បញ្ហា ៤ ខ

ជាដើមមុន ។

ក៏បែបផែននេះ ព្រះសាស្តាទ្រង់អាស្រ័យវាទៈទី ១ ទើបទ្រង់សម្តែងកំហុសទី ១, ទ្រង់អាស្រ័យវាទៈទី ២ ទើបទ្រង់សម្តែងកំហុសទី ២...។ ល ។ ទ្រង់អាស្រ័យវាទៈទី ៨ ទើបទ្រង់សម្តែងកំហុសទី ៨ គឺទ្រង់តាំងមាតិកាទុកយ៉ាងនេះថា ៖-

**សកវាទី:** លោកនៅតែឃើញ (ដឹង) បានដោយអត្ថដ៏ពិត (សច្ចិកត្ថ), និងអត្ថដ៏ឧត្តម (បរមត្ថ) ឬ ?

**បរវាទី :** អើ ! = **អាមន្តា** * ។

**ស. :** សភាវៈណា មានអត្ថដ៏ពិត, មានអត្ថដ៏ឧត្តម, លោកដឹងបុគ្គលនោះ បានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមនោះឬ ?

**ប. :** លោកកុំគប្បីពោលយ៉ាងនោះឡើយ ។

**ស. :** លោកចូរដឹងកំហុសចុះ...។

**ប. :** លោកមិនដឹងបុគ្គលបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ?

**ស. :** អើ !

**ប. :** សភាវៈណាមានអត្ថដ៏ពិត, មានអត្ថដ៏ឧត្តម, លោកមិនដឹង

---

* សព្ទនេះជានិបាត សម្រាប់ទទួលរង ប្រែបានច្រើនយ៉ាងដូចជា អើ, ករុណា, ត្រឹមត្រូវ, ត្រូវហើយ...។

បុគ្គលនោះដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ ?

**ស.** : លោកមិនត្រូវពោលយ៉ាងនោះទេ ។

**ច.** : លោកចូរដឹងកំហុស ។ល ។ បដិកម្ម ( ការធ្វើតប) ។

**ស.** : លោកដឹងបុគ្គលបានក្នុង ( សរីរៈ) ទាំងពួង... ។

**ច.** : លោកមិនដឹងបុគ្គលបានក្នុងទីទាំងពួង... ។

**ស.** : លោកដឹងបុគ្គលបានក្នុងកាលទាំងពួង... ។

**ច** : លោកមិនដឹងបុគ្គលបានក្នុងកាលទាំងពួង... ។

**ស.** : លោកដឹងបុគ្គលបានក្នុងសភាវធម៌ទាំងពួង ( មានខន្ធជាដើម)

**ច.** : លោកមិនដឹងបុគ្គលបានក្នុងសភាវធម៌ទាំងពួងឬ ?

**ស.** : អើ !

**ច.** : សភាវធម៌ណាមានអត្ថដ៏ពិត, មានអត្ថដ៏ឧត្តម, លោកមិនដឹងបុគ្គលនោះដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមនោះឬ ?

**ស.** : លោកមិនត្រូវពោលយ៉ាងនោះទេ ។

**ច.** : លោកចូរដឹងកំហុសចុះ ...[៧] ។

គប្បីជ្រាបការតាំងមាតិកាក្នុងព្រះបាលីទាំងពួង ដោយន័យនេះ; ក៏កាលទ្រង់តាំងមាតិកានេះ ទ្រង់ឃើញហេតុនេះឯង ទើបទ្រង់តាំងទុកថា ៖-

[៧] អភិ. ។

“កាលតថាគតបរិនិព្វានកន្លងទៅ ២១៨ ឆ្នាំ ព្រះថេរៈ ឈ្មោះថា **មោគ្គលីបុត្តតិស្សត្ថេរ** នឹងអង្គុយក្នុងកណ្ដាលភិក្ខុ ១.០០០ រូបប្រមូលព្រះសូត្រមក ១.០០០ គឺព្រះសូត្រ ៥០០ សូត្ររបស់សកវាទី, ព្រះសូត្រ ៥០០ សូត្ររបស់បរវាទី, ហើយនឹងចែកកថាវត្ថុប្បករណ៍ប្រមាណប៉ុននឹងទីឃនិកាយ”។ សូម្បីព្រះ**មោគ្គលីបុត្តតិស្សត្ថេរ** កាលនឹងសម្ដែងបករណ៍នេះ មិនបានសម្ដែងដោយញាណរបស់ខ្លួនទេ, តែសម្ដែងតាមមាតិកា ដែលតាំងទុកដោយន័យដែលព្រះសាស្ដាទ្រង់ប្រទាន; ព្រោះហេតុដូច្នោះ គម្ពីរនេះទាំងអស់ ទើបឈ្មោះថា **ពុទ្ធភាសិត** ដូចគ្នា, ព្រះថេរៈសម្ដែងតាមមាតិកាដែលតាំងទុកដោយន័យដែលព្រះសាស្ដាប្រទាន; សួរថា ដូចជាអ្វី ? ឆ្លើយថា ដូចជា**មធុបិណ្ឌិកសូត្រ**ជាដើម ។

ពិតណាស់ ដូចមធុបិណ្ឌិកសូត្រ ព្រះមានព្រះភាគទ្រង់តាំងមាតិកាទុកថា “ម្នាលភិក្ខុ ចំណែកនៃសញ្ញាជាគ្រឿងយឺតយូរ រមែងគ្របសង្កត់បុរស ព្រោះហេតុណា, បើថា ការដែលបុគ្គលភ្លើតភ្លើនត្រេកអរ, ប្រកាន់មាំ, មិនមានក្នុងហេតុនេះទេ, របស់នេះឯង ជាទីបំផុតនៃរាគានុស័យទាំងឡាយ” ជាដើម[៨], ហើយស្ដេចក្រោកចាកអាសនៈចូលទៅកាន់ព្រះវិហារ ។

ភិក្ខុទាំងឡាយ អ្នកទទួលព្រះធម្មទេសនាចូលទៅរក **ព្រះមហាកច្ចា**

---

[៨] ម. មូ. ។

**យនត្ថេរ** ហើយសួរសេចក្ដីនៃមាតិកា ដែលព្រះទសពលទ្រង់តាំងទុកហើយ, ព្រះថេរៈមិនវិសជ្ជនាត្រឹមតែពាក្យត្រូវសួរប៉ុណ្ណោះឡើយ ដើម្បីសម្ដែងការឱនលំទោនចំពោះព្រះទសពល ទើបនាំការប្រៀបធៀបដូចនឹងខ្លឹមឈើមកសម្ដែងថា "ម្នាលអ្នកមានអាយុទាំងឡាយ ប្រៀបដូចបុរសត្រូវការខ្លឹមឈើតែងស្វែងរកខ្លឹមឈើ" ជាដើម [៩] ហើយសរសើរព្រះសាស្ដាថា "ព្រះមានព្រះភាគដូចដើមឈើមានខ្លឹម, សាវ័កដូចមែកឈើ និងស្លឹកឈើ; ម្នាលអ្នកមានអាយុទាំងឡាយ ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងនូវវត្ថុដែលគួរដឹង, ទ្រង់ឃើញនូវវត្ថុដែលគួរឃើញ, ជាអ្នកមានចក្ខុ, មានព្រះញាណ, មានធម៌ដ៏ប្រសើរ, ជាអ្នកផ្សព្វផ្សាយ, ជាអ្នកប្រកាស, ជាអ្នកពន្យល់សេចក្ដី, ជាអ្នកប្រទានអមតធម៌, ជាម្ចាស់ធម៌, ជាតថាគត" ព្រះថេរៈទាំងឡាយអារាធនាញយៗ ហើយ ទើបចែកមាតិកា ជាសេចក្ដីតាមដែលព្រះមានព្រះភាគទ្រង់តាំងទុក ដោយបំណងយ៉ាងនេះថា "បើអ្នកទាំងឡាយប្រាថ្នា ក៏គប្បីចូលទៅគាល់ព្រះមានព្រះភាគដោយត្រង់ចុះ, ហើយទូលសួរសេចក្ដីនេះ, បើធៀបផ្ទឹមចូលគ្នានឹងសព្វញ្ញុតញ្ញាណបាន ក៏គប្បីកាន់យក បើធៀបផ្ទឹមគ្នាមិនបានទេ ក៏មិនគប្បីកាន់យក" ហើយពោលថា "ព្រះមានព្រះភាគទ្រង់ព្យាករដោយប្រការណា, អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្ដីនោះចុះ"

---

[៩] ម. មូ. ។

ទើបបញ្ជូនភិក្ខុទាំងឡាយនោះឱ្យទៅ ។

ពួកភិក្ខុទាំងនោះ ចូលទៅគាល់ព្រះសាស្តា ហើយទូលសួរសេចក្តីនោះ; ព្រះសាស្តាមិនត្រាស់ថា **“កច្ចាយនៈ ពោលមិនល្អទេ”** , តែទ្រង់បង្អោនព្រះសូរងហាក់នឹងលើកព្រះសុវណ្ណភិង្គារ (ឆ្នាំងទឹកមាស) ឡើង (ស្រង់ព្រះថេរៈ) កាលនឹងញុំាងអត្ថនោះឱ្យបរិបូណ៌ ដោយព្រះឱស្ឋដ៏មានសិរី ដូចផ្កាឈូក (**សតបត្តៈ ១០០ ស្រទាប់**) ដែលកំពុងរីកយ៉ាងល្អ, ទើបទ្រង់បន្លឺព្រះសូរសៀង ដូចជាសំឡេងនៃព្រហ្ម, ប្រទានសាធុការដល់ព្រះថេរៈថា **“សាធុ សាធុ”** ដូច្នេះ ហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈជាបណ្ឌិត, មហាកច្ចាយនៈមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសួរសេចក្តីនេះនឹងតថាគត, សូម្បីតថាគតក៏ព្យាករសេចក្តីនោះដូចមហាកច្ចាយនៈដែរ” [១០] ; ចាប់ដើមអំពីកាលដែលព្រះសាស្តាទ្រង់អនុមោទនាហើយយ៉ាងនេះ ព្រះសុត្តន្តៈទាំងអស់ ឈ្មោះថា ជាពុទ្ធភាសិត; សូម្បីព្រះសូត្រដែល**ព្រះអានន្ទត្ថេរ**ជាដើម ឱ្យពិស្តារហើយ ក៏មានន័យដូចគ្នានេះដែរ; ព្រះសម្មាសម្ពុទ្ធកាលទ្រង់សម្តែងគម្ពីរព្រះអភិធម្ម ៧ ល្មមដល់កថាវត្ថុ ទើបទ្រង់តាំងមាតិកាទុកដោយន័យដែលពោលហើយ; ម្យ៉ាងទៀតកាលទ្រង់ឈប់ បានទ្រង់ឃើញហេតុនោះថា ៖-

---

[១០] ម. មូ. ។

“កាលតថាគតបរិនិព្វានកន្លងទៅ ២១៨ ឆ្នាំ ភិក្ខុឈ្មោះថា **មោគ្គលី្លបុត្តតិស្សត្ថេរ** អង្គុយក្នុងកណ្ដាលភិក្ខុ ១.000 រូប ហើយនឹងប្រមូលព្រះសូត្រ ១.000 សូត្រ គឺក្នុងសកវាទិប្រាំរយសូត្រ, ក្នុងបរវាទិប្រាំរយសូត្រ, ចែកកថាវត្ថុប្បករណ៍ មានប្រមាណប៉ុនទីឃនិកាយ” ។ សូម្បីព្រះ**មោគ្គលី្លបុត្តតិស្សត្ថេរ** កាលនឹងសម្ដែងគម្ពីរនេះ ក៏មិនសម្ដែងដោយចំណេះរបស់ខ្លួនដែរ, តែសម្ដែងតាមមាតិកាដែលតាំងទុកដោយន័យ ដែលព្រះសាស្ដាទ្រង់ប្រទាន; ព្រោះហេតុដូច្នោះ គម្ពីរទាំងអស់ ទើបឈ្មោះថា ពុទ្ធភាសិតដោយពិត, ព្រោះព្រះថេរៈសម្ដែងតាមមាតិកាដែលតាំងទុក ដោយន័យដែលព្រះសាស្ដាទ្រង់ប្រទានហើយ; គម្ពីរទាំង ៧ រួមទាំងកថាវត្ថុ ទើបឈ្មោះថា **អភិធម្ម** ដោយប្រការដូច្នេះ ៕

## ធម្មសង្គណី

បណ្ដាបករណ៍ (គម្ពីរ) ទាំង ៧ នោះ **ក្នុងគម្ពីរសង្គណីវិភត្តិ** (ការចែក) ទុក ៤ គឺ

**១.ចិត្តវិភត្តិ** ការចែកចិត្ត

**២.រូបវិភត្តិ** ការចែករូប

**៣.និក្ខេបរាសិ** ការចែកកងធម៌ដែលតាំងទុក

**៤.អត្ថុទ្ធារៈ** ការលើកអត្ថឡើងសម្ដែង ។

## សម្ដែងអំពីចិត្តវិភត្តិ

បណ្ដាការចែកធម៌ទាំង ៤ ពួកនោះ ធម៌នេះគឺ

**១-កាមាវចរកុសលចិត្ត** ៨ ដួង

**២-អកុសលចិត្ត** ១២ ដួង

**៣-កុសលវិបាកចិត្ត** ១៦ ដួង

**៤-អកុសលវិបាកចិត្ត** ៧ ដួង

**៥-កិរិយាចិត្ត** ១១ ដួង

**៦-រូបាវចរកុសលចិត្ត** ៥ ដួង

**៧-រូបាវចរវិបាកចិត្ត** ៥ ដួង

**៨-រូបាវចរកិរិយាចិត្ត** ៥ ដួង

**៩-អរូបាវចរកុសលចិត្ត** ៤ ដួង

**១០-អរូបាវចរវិបាកចិត្ត** ៤ ដួង

**១១-អរូបាវចរកិរិយាចិត្ត** ៤ ដួង

**១២-លោកុត្តរកុសលចិត្ត** ៤ ដួង

**១៣-លោកុត្តរវិបាកចិត្ត** ៤ ដួង ។

រួមចិត្ត ៨៩ ដួង តាមដែលពោលមកនេះ ឈ្មោះថា **ចិត្តវិភត្តិ**; សូម្បីពាក្យថា **"ចិត្តុប្បាទកណ្ឌ"** ក៏ជាឈ្មោះរបស់ចិត្តវិភត្តិនេះដូចគ្នា; ចិត្ត

នោះ សម្តែងអំពីផ្លូវនៃពាក្យនិយាយ មានលើស ៦ *ភាណវារៈ*, តែបើឱ្យពិស្តារ ក៏មិនមានទីបំផុត និងមិនមានប្រមាណ ៕

## សម្តែងអំពីរូបវិភត្តិ

ក្នុងលំដាប់តអំពីចិត្តនោះ ឈ្មោះថា *រូបវិភត្តិ* ព្រះមានព្រះភាគទ្រង់តាំងមាតិកាទុកដោយន័យមានជាអាទិ៍ថា **"ធម៌ពួក ១ ធម៌ពួក ២"** ហើយទ្រង់ចែកសម្តែងដោយពិស្តារ; សូម្បីពាក្យថា **"*រូបកណ្ឌ* និក្ខេបកណ្ឌ"** ក៏ជាឈ្មោះរបស់រូបវិភត្តិនោះៗ ឯង; រូបកណ្ឌនោះ សម្តែងអំពីផ្លូវនៃពាក្យនិយាយ មានលើស ២ *ភាណវារៈ*, តែបើឱ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ៕

## សម្តែងអំពីនិក្ខេបរាសិ

ក្នុងលំដាប់តអំពីរូបកណ្ឌនោះ ឈ្មោះថា **រូបកណ្ឌនិក្ខេបរាសិ** ព្រះមានព្រះភាគ ទ្រង់លើកឡើងសម្តែងដោយមូលជាដើមយ៉ាងនេះ គឺ **ដោយមូល, ដោយខន្ធ, ដោយទ្វារ, ដោយភូមិ, ដោយអត្ថ, ដោយធម៌, ដោយនាម និងដោយភេទ ។**

**"មូលតោ ខន្ធតោ ចាបិ ទ្វារតោ ចាបិ ភូមិតោ**

**អត្ថតោ ធម្មតោ ចាបិ នាមតោ ចាបិ លិង្គតោ**
**និក្ខិបិត្វា ទេសិតត្តា និក្ខេបោតិ បវុច្ចតិ**

ដែលហៅថា ‘និក្ខេបៈ’ ដូច្នេះ ព្រោះការដែលព្រះអង្គលើកឡើងសម្ដែងដោយមូលខ្លះ, ខន្ធខ្លះ, ទ្វារខ្លះ, ភូមិខ្លះ, អត្ថខ្លះ, ធម៌ខ្លះ, នាមខ្លះ និងភេទខ្លះ”។

សូម្បីពាក្យថា ***“រូបកណ្ឌ និក្ខេបកណ្ឌ”*** ក៏ជាឈ្មោះរបស់និក្ខេបរាសិនោះឯង; រូបកណ្ឌ និក្ខេបកណ្ឌនោះ សម្ដែងអំពីផ្លូវនៃវាចា ក៏មានប្រមាណ ៣ ភាណវារៈ, កាលបើឱ្យពិស្ដារ ក៏មិនមានទីបំផុត មិនមានប្រមាណឡើយ ៕

## សម្ដែងអំពីអត្ថុទ្ធារៈ

ក៏ក្នុងលំដាប់តអំពីនិក្ខេបរាសិនោះ ឈ្មោះថា **អដ្ឋកថាកណ្ឌ** ជាពាក្យដែលលើកសេចក្ដីពុទ្ធវចនៈ គឺព្រះត្រៃបិដកឡើងសម្ដែងតាំងពីសរណទុកៈ, ភិក្ខុទាំងឡាយអ្នករៀនមហាបករណ៍ មិនកំណត់ចំនួនក្នុងមហាបករណ៍, តែរួមចំនួនមហាបករណ៍នោះទុក, សម្ដែងអំពីផ្លូវនៃពាក្យសម្ដីមានប្រមាណ ២ ភាណវារៈ, តែបើឱ្យពិស្ដារ ក៏មិនមានទីបំផុត, មិនមានប្រមាណទេ; ធម្មសង្គណីបករណ៍ទាំងអស់ រមែងមានដោយប្រការដូច្នេះ, ធម្មសង្គណីបករណ៍

នោះ សម្តែងអំពីផ្លូវនៃពាក្យសម្តី មានលើស ១៣ ភាណវារៈ, តែបើឱ្យពិស្តារ ក៏មិនមានទីបំផុត មិនមានប្រមាណ ។

**ធម្មសង្គណីបករណ៍ គឺ ចិត្តវិភត្តិ, រូបវិភត្តិ, និក្ខេបៈ និងអត្ថជោតនា (អធិប្បាយអត្ថ) នេះ មានអត្ថជ្រាលជ្រៅ និងល្អិត សូម្បីថានៈនេះ ព្រះអង្គក៏ទ្រង់សម្តែងហើយដោយប្រការដូច្នេះ ៕**

## វិភង្គប្បករណ៍

ក្នុងលំដាប់តអំពីធម្មសង្គណីបករណ៍នោះ ឈ្មោះថា **វិភង្គប្បករណ៍**; វិភង្គប្បករណ៍នោះ ព្រះមានព្រះភាគទ្រង់សម្តែងចែកធម៌ ១៨ យ៉ាងគឺ

**១-ខន្ធវិភង្គ** **២-អាយតនវិភង្គ**
**៣-ធាតុវិភង្គ** **៤-សច្ចវិភង្គ**
**៥-ឥន្ទ្រិយវិភង្គ** **៦-បច្ចយាការវិភង្គ**
**៧-សតិប្បដ្ឋានវិភង្គ** **៨-សម្មប្បធានវិភង្គ**
**៩-ឥទ្ធិបាទវិភង្គ** **១០-ពោជ្ឈង្គវិភង្គ**
**១១-មគ្គវិភង្គ** **១២-ឈានវិភង្គ**
**១៣-អប្បមញ្ញាវិភង្គ** **១៤-សិក្ខាបទវិភង្គ**
**១៥-បដិសម្ភិទាវិភង្គ** **១៦-ញាណវិភង្គ**
**១៧-ខុទ្ទកវត្ថុវិភង្គ** **១៨-ធម្មហទយវិភង្គ** ។

បណ្ដាវិភង្គទាំងនោះ ខន្ធវិភង្គចែកចេញជា ៣ យ៉ាងគឺដោយអំណាចសុត្តន្តភាជនិយ, អភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈ; ខន្ធវិភង្គនោះ សម្ដែងអំពីផ្លូវនៃពាក្យសម្ដី មានប្រមាណ ៥ ភាណវារៈ, តែបើឱ្យពិស្ដារ ក៏មិនមានទីបំផុត, មិនមានប្រមាណ; សូម្បីអាយតនវិភង្គជាដើម ខាងមុខពីនេះ លោកក៏ចែកដោយន័យ ៣ យ៉ាងនោះដូចគ្នា; បណ្ដាវិភង្គទាំងនោះ អាយនវិភង្គសម្ដែងអំពីផ្លូវនៃពាក្យសម្ដី មានលើស ១ ភាណវារៈ; ធាតុវិភង្គមានប្រមាណ ២ ភាណវារៈ; សច្ចវិភង្គមានប្រមាណ ២ ភាណវារៈដូចគ្នា; ក្នុងឥន្ទ្រិយវិភង្គ មិនមានសុត្តន្តភាជនិយ; ក៏ឥន្ទ្រិយវិភង្គនោះ សម្ដែងអំពីផ្លូវនៃពាក្យសម្ដី មានប្រមាណលើស ១ ភាណវារៈ*; សម្មប្បធាន..., ឥទ្ធិបាទ..., ពោជ្ឈង្គ... និងមគ្គវិភង្គ; តែនីមួយៗ មានលើស ១ ភាណវារៈ; ឈានវិភង្គមានប្រមាណ ២ ភាណវារៈ, អប្បមញ្ញាវិភង្គ មានប្រមាណលើស ១ ភាណវារៈ; ក្នុងសិក្ខាបទវិភង្គ មិនមានបទសុត្តន្តភាជនិយ ។ តែសិក្ខាបទវិភង្គនោះសម្ដែងអំពីផ្លូវនៃពាក្យសម្ដីមានប្រមាណលើសតែ ១ ភាណវារៈ; បដិសម្ភិទាវិភង្គ ក៏មានប្រមាណលើស ១ ភាណវារៈ ។ ញាណវិភង្គចែកចេញ ១០ យ៉ាង; តែញាណវិភង្គនោះ កាលសម្ដែងអំពីផ្លូវនៃពាក្យសម្ដី មានប្រមាណ

---

* បច្ចយាការវិភង្គ មានប្រមាណ ៦ ភាណវារៈ តែមិនមានបញ្ហាបុច្ឆកៈ សតិប្បដ្ឋានវិភង្គ មានប្រមាណលើស ១ ភាណវារៈ ។

៣ ភាណវារៈ; សូម្បីខុទ្ទកវត្ថុវិភង្គក៏ចែកទុក ១០ យ៉ាង; តែថាដោយផ្លូវនៃពាក្យសម្ដីមានប្រមាណ ៣ ភាណវារៈ ។ ធម្មហទយវិភង្គចែកទុក ៣ យ៉ាង សម្ដែងអំពីផ្លូវនៃពាក្យសម្ដីមានប្រមាណលើស ២ ភាណវារៈ, សូម្បីវិភង្គទាំងអស់ កាលឱ្យពិស្ដារ ក៏មិនមានទីបំផុត, មិនមានប្រមាណ, បករណ៍ ឈ្មោះថា វិភង្គប្បករណ៍នេះ កាលសម្ដែងអំពីផ្លូវនៃពាក្យសម្ដី មានប្រមាណ ៣៥ ភាណវារៈ, តែកាលឱ្យពិស្ដារ រមែងមិនមានទីបំផុត, មិនមានប្រមាណ ដោយប្រការដូច្នេះ ៕

## ធាតុកថាបករណ៍

ក្នុងលំដាប់តអំពីវិភង្គប្បករណ៍នោះ ឈ្មោះថា **ធាតុកថាបករណ៍** ទ្រង់ចែកចេញជា ១៤ យ៉ាងគឺ

**១-សង្គហោ, អសង្គហោ** ធមិសង្គ្រោះបាន, ធមិសង្គ្រោះមិនបាន

**២-សង្គហិតេន អសង្គហិតំ** ធមិដែលសង្គ្រោះមិនបាន ដោយធមិដែលសង្គ្រោះបាន ។

**៣-អសង្គហិតេន សង្គហិតំ** ធមិដែលសង្គ្រោះបាន ដោយធមិដែលសង្គ្រោះមិនបាន ។

**៤-សង្គហិតេន សង្គហិតំ** ធមិដែលសង្គ្រោះបាន ដោយធមិដែលសង្គ្រោះបាន ។

**៥-អសង្គហិតេន អសង្គហិតំ** ធម៌ដែលសង្គ្រោះមិនបាន ដោយធម៌ដែលសង្គ្រោះមិនបាន ។

**៦-សម្បយោគោ វិប្បយោគោ** ធម៌ដែលប្រកបគ្នា ធម៌ដែលមិនប្រកបគ្នា ។

**៧-សម្បយុត្តេន វិប្បយុត្តំ** ធម៌ដែលវិប្បយុត្តគ្នាបាន ដោយធម៌ដែលសម្បយុត្តគ្នា ។

**៨-វិប្បយុត្តេន សម្បយុត្តំ** ធម៌ដែលសម្បយុត្តគ្នាបាន ដោយធម៌ដែលវិប្បយុត្តគ្នា ។

**៩-សម្បយុត្តេន សម្បយុត្តំ** ធម៌ដែលសម្បយុត្តគ្នាបាន ដោយធម៌ដែលសម្បយុត្តគ្នា ។

**១០-វិប្បយុត្តេន វិប្បយុត្តំ** ធម៌ដែលវិប្បយុត្តគ្នាបាន ដោយធម៌ដែលវិប្បយុត្តគ្នា ។

**១១- សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ** ធម៌ដែលសម្បយុត្តគ្នាបាន ធម៌ដែលវិប្បយុត្តគ្នាបាន ដោយធម៌ដែលសង្គ្រោះគ្នា ។

**១២- សម្បយុត្តេន សង្គហិតំ អសង្គហិតំ** ធម៌ដែលសង្គ្រោះគ្នាបាន ធម៌ដែលសង្គ្រោះគ្នាមិនបាន ដោយធម៌ដែលសម្បយុត្តគ្នា ។

**១៣- អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ** ធម៌ដែលសម្បយុត្តគ្នាបាន ធម៌ដែលវិប្បយុត្តគ្នាបាន ដោយធម៌ដែលសង្គ្រោះគ្នាមិនបាន ។

**១៤. វិប្បយុត្តេន សង្គហិតំ អសង្គហិតំ** ធម៌ដែលសង្គ្រោះគ្នាបាន ធម៌ដែលសង្គ្រោះគ្នាមិនបាន ដោយធម៌ដែលវិប្បយុត្តគ្នា ។

ធាតុកថាបករណ៍នោះ សម្តែងអំពីផ្លូវនៃពាក្យសម្ដី មានប្រមាណលើស ៦ ភាណវារៈ, តែកាលឱ្យពិស្តារ រមែងមិនមានទីបំផុត, មិនមានប្រមាណ ៕

## បុគ្គលប្បញ្ញត្តិប្បករណ៍

ក្នុងលំដាប់តអំពីធាតុបករណ៍នោះ ឈ្មោះថា **បុគ្គលបញ្ញត្តិ**; បុគ្គលបញ្ញត្តិនោះ ចែកចេញទុក ៦ យ៉ាងគឺ

**១.ខន្ធប្បញ្ញត្តិ** **២.អាយតនប្បញ្ញត្តិ**

**៣.ធាតុប្បញ្ញត្តិ** **៤.សច្ចប្បញ្ញត្តិ**

**៥.ឥន្ទ្រិយប្បញ្ញត្តិ** **៦.បុគ្គលប្បញ្ញត្តិ ។**

បុគ្គលបញ្ញត្តិនេះ សម្តែងអំពីផ្លូវនៃពាក្យសម្ដី មានលើស ៥ ភាណវារៈ, តែកាលឱ្យពិស្តារ ក៏មិនមានទីបំផុត, មិនមានប្រមាណដូចគ្នា ៕

## កថាវត្ថុប្បករណ៍

ក្នុងលំដាប់តអំពីបុគ្គលបញ្ញត្តិប្បករណ៍ ឈ្មោះថា **កថាវត្ថុប្បករណ៍**; កថាវត្ថុប្បករណ៍នោះ ប្រមូលចែកទុក ១.០០០ សូត្រគឺ “ក្នុងសកវាទី

(លទ្ធិរបស់ខ្លួន) ៥០០ សូត្រ, ក្នុងបរវាទី (លទ្ធិអ្នកដទៃ) ៥០០ សូត្រ” ; កថាវត្ថុប្បករណ៍នោះ សម្តែងអំពីផ្លូវនៃពាក្យសម្តី មានប្រមាណប៉ុនទីឃនិកាយមួយ ដោយន័យដែលលើកឡើងកាន់សង្គីតិ មិនកាន់យកពាក្យដែលសរសេរទុកក្នុងកោដ្ឋាសៈ (គម្ពីរ) ក្នុងកាលឥឡូវនេះទេ, តែកាលឱ្យពិស្តាររមែងមិនមានទីបំផុត, មិនមានប្រមាណឡើយ ៕

## យមកប្បករណ៍

ក្នុងលំដាប់អំពីកថាវត្ថុប្បករណ៍នោះ ឈ្មោះថា **យមកប្បករណ៍** ទ្រង់ចែកទុក ១០ យ៉ាងគឺ

**១. មូលយមក ២. ខន្ធយមក**

**៣. អាយតនយមក ៤. ធាតុយមក**

**៥. សច្ចយមក ៦. សង្ខារយមក**

**៧. អនុសយយមក ៨. ចិត្តយមក**

**៩. ធម្មយមក ១០. ឥន្ទ្រិយយមក ។**

យមកប្បករណ៍នោះ សម្តែងអំពីផ្លូវនៃពាក្យសម្តីមានប្រមាណ ១២០ ភាណវារៈ, កាលបើសម្តែងដោយពិស្តារ រមែងមិនមានទីបំផុត មិនមានប្រមាណឡើយ ៕

## មហាបករណ៍

ក្នុងលំដាប់នៃយមកប្បករណ៏នោះ ឈ្មោះថា **មហាបករណ៍**; សូម្បីពាក្យថា “**បដ្ឋាន**” ក៏ជាឈ្មោះរបស់មហាបករណ៏នោះឯង; មហាបករណ៏នោះ ខាងដើមទ្រង់ចែកទុក ២៤ យ៉ាង ដោយអំណាចនៃបច្ច័យគឺ

១. **ហេតុប្បច្ច័យ** ហេតុជាបច្ច័យ

២. **អារម្មណប្បច្ច័យ** អារម្មណ៏ជាបច្ច័យ

៣. **អធិបតិប្បច្ច័យ** អធិបតីជាបច្ច័យ

៤. **អនន្តរប្បច្ច័យ** អនន្តរធម៌ជាបច្ច័យ

៥. **សមនន្តរប្បច្ច័យ** សមនន្តរធម៌ជាបច្ច័យ

៦. **សហជាតប្បច្ច័យ** សហជាតធម៌ជាបច្ច័យ

៧. **អញ្ញមញ្ញប្បច្ច័យ** អញ្ញមញ្ញធម៌ជាបច្ច័យ

៨. **និស្សយប្បច្ច័យ** និស្សយធម៌ជាបច្ច័យ

៩. **ឧបនិស្សយប្បច្ច័យ** ឧបនិស្សយធម៌ជាបច្ច័យ

១០. **បុរេជាតប្បច្ច័យ** បុរេជាតធម៌ជាបច្ច័យ

១១. **បច្ឆាជាតប្បច្ច័យ** បច្ឆាជាតធម៌ជាបច្ច័យ

១២. **អាសេវនប្បច្ច័យ** អាសេវនធម៌ជាបច្ច័យ

១៣. **កម្មប្បច្ច័យ** កម្មជាបច្ច័យ

១៤. **វិបាកប្បច្ច័យ** វិបាកជាបច្ច័យ

១៥. **អាហារប្បច្ច័យ** អាហារជាបច្ច័យ

១៦. **ឥន្ទ្រិយប្បច្ច័យ** ឥន្ទ្រិយជាបច្ច័យ

១៧. **ឈានប្បច្ច័យ** ឈានជាបច្ច័យ

១៨. **មគ្គប្បច្ច័យ** មគ្គជាបច្ច័យ

១៩. **សម្បយុត្តប្បច្ច័យ** សម្បយុត្តធម៌ជាបច្ច័យ

២០. **វិប្បយុត្តប្បច្ច័យ** វិប្បយុត្តធម៌ជាបច្ច័យ

២១. **អត្ថិប្បច្ច័យ** អត្ថិធម៌ជាបច្ច័យ

២២. **នត្ថិប្បច្ច័យ** នត្ថិធម៌ជាបច្ច័យ

២៣. **វិគតប្បច្ច័យ** វិគតធម៌ជាបច្ច័យ

២៤. **អវិគតប្បច្ច័យ** អវិគតធម៌ជាបច្ច័យ ។

ក៏ក្នុងឋានៈនេះគប្បីប្រមូលមកនូវបដ្ឋាន ៖-

ពិតណាស់ តិកៈ ២២ មានកុសលតិកៈជាដើម; ទុកៈ ១០០ ទាំងនេះ គឺ **ហេតូធម្មា ន ហេតូធម្មា..** ។ល។... **សរណាធម្មា, អសរណាធម្មា;** សូម្បីទុកៈដទៃ ទៀតឈ្មោះថា សុត្តន្តទុកៈ ៤២ គឺ **វិជ្ជា ភាគិនោ ធម្មា, អវិជ្ជា-ភាគិនោ ធម្មា... ខលខ ... ខយេ ញាណំ, អនុប្បាទេ ញាណំ ខ**

បណ្ណតិកៈ និងទុកៈទាំងនោះ ធមិនេះ គឺតិកៈ ២២ ទុកៈ ១០០ ឈ្មោះថា មាតិកានៃបករណ៍ទាំង ៧ ជាពុទ្ធវចនៈ ដែលព្រះជិនស្រីត្រាស់ភាសិតទុក, គឺជាធមិដែលព្រះសព្វញ្ញុតញ្ញាណសម្តែងហើយ ។

មានបញ្ហាចោទឡើងថា កាលបើដូច្នោះ ទុកៈ ៤២ ដទៃទៀតមកអំពីណា ? អ្នកណាតាំងទុក ? អ្នកណាជាអ្នកសម្តែង ? ។

**ឆ្លើយថា** មកអំពី **ព្រះធម្មសេនាបតីសារីបុត្រ**, ព្រះធម្មសេនាបតីនោះតាំងទុក គឺសម្តែងទុក ។

ក៏ព្រះថេរៈ កាលតាំងធមិទាំងឡាយនេះ មិនបានតាំងទុកដោយការលើកឡើងសម្តែងឯង, គឺដោយប្រើញាណ (បញ្ញា) របស់ខ្លួនទេ; តែព្រះថេរៈ បានប្រមូលបន្ថែមឡើងទីនីមួយៗ ដោយទសុត្តរសូត្រក្នុងសង្គីតិ មានឯកនិបាតជាដើម, តាំងទុកដើម្បីព្រះថេរៈអ្នកជំនាញអភិធម្ម អ្នកដែលស្ទាត់ព្រះសូត្រហើយ នឹងមិនលំបាកឡើយ ។ ក៏ទុកៈទាំងនេះ ចែកឱ្យដល់ទីបំផុតទុកនិក្ខេបកណ្ឌមួយ, ក្នុងទីដែលសល់លោកចែកអភិធម្មទុក រហូតដល់សរណទុកៈ; ពិតណាស់ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធមិ ឈ្មោះថា **តិកប្បដ្ឋាន** ព្រោះអាស្រ័យតិកៈ ២២ ក្នុងអនុលោមប្បដ្ឋាន; ទ្រង់សម្តែងធមិ ឈ្មោះថា **ទុកប្បដ្ឋាន** ព្រោះអាស្រ័យទុកៈ ១០០ ដែលសម្រេចរួចហើយ, ខាងមុខពីនេះ ក៏កាន់យកតិកៈ ២២ រួមទុកៈ ១០០ សម្តែងធមិឈ្មោះ **ទុកត្តិកប្បដ្ឋាន**; បន្ទាប់អំពីនោះ ក៏កាន់យកទុកៈ ១០០ រួមក្នុងតិកៈ ២២ សម្តែងធមិ ឈ្មោះ

ថា **តិកទុកបដ្ឋាន**; តពីនោះ ទ្រង់រួមតិកៈទាំងឡាយ ចូលក្នុងតិកៈទាំងឡាយនោះឯង សម្តែងធម៌ ឈ្មោះ **តិកត្តិកបដ្ឋាន**; និងទ្រង់រួមទុកៈទាំងឡាយ ចូលក្នុងទុកៈទាំងឡាយនោះៗ ឯង សម្តែងធម៌ ឈ្មោះថា **ទុកទុកបដ្ឋាន**; (ព្រះបាលីថា)៖-

**"តិកញ្ចបដ្ឋានវរំ, ទុកុត្តមំ, ទុកត្តិកញ្ចេវ, តិកទុកញ្ច,**

**តិកត្តិកញ្ចេវ,ទុកទុកញ្ច,ឆអនុលោមម្ហិ នយា សុគម្ភីរា ឲ**

**ន័យទាំង ៦ គឺតិកបដ្ឋានដ៏ប្រសើរ ១, ទុកបដ្ឋានដ៏ឧត្តម ១, ទុកត្តិកបដ្ឋាន ១, តិកទុកបដ្ឋាន ១, តិកត្តិកបដ្ឋាន ១, ទុកទុកបដ្ឋាន ១, ជាន័យដ៏ជ្រាលជ្រៅក្នុងអនុលោម"** [១១] ។

សូម្បីក្នុងបច្ចនីយបដ្ឋាន ក៏ឈ្មោះថា **សតិបដ្ឋាន** ព្រោះអាស្រ័យ-តិកៈ ២២, ឈ្មោះថា **ទុកបដ្ឋាន** ព្រោះអាស្រ័យទុកៈ ១០០, ឈ្មោះថា **ទុកត្តិកបដ្ឋាន** ព្រោះរួមតិកៈ ២២ ចូលក្នុងទុកៈ ១០០, ឈ្មោះថា **តិកទុ-កបដ្ឋាន** ព្រោះរួមទុកៈ ១០០ ចូលក្នុងតិកៈ ២២, ឈ្មោះថា **តិកត្តិកប-ដ្ឋាន** ព្រោះរួមតិកៈទាំងឡាយ ចូលក្នុងតិកៈទាំងឡាយនោះឯង, ឈ្មោះថា **ទុកទុកបដ្ឋាន** ព្រោះរួមទុកៈទាំងឡាយ ចូលក្នុងទុកៈទាំងឡាយ (នោះ) ដូច្នេះ ។

---

[១១] អភិ. ។

សូម្បីក្នុងបច្ចនីយប្បដ្ឋាន ក៏ទ្រង់សម្តែងបដ្ឋានដោយន័យទាំង ៦ ( នេះឯង) ព្រោះហេតុនោះ ព្រះសម្ពិតិកាចារ្យមហាថេរ ទើបពោលទុកថា ៖-

“ន័យទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ ១, ។ល។ ទុកទុកប្បដ្ឋាន ១, ជាន័យដ៏ជ្រាលជ្រៅក្នុងបច្ចនីយៈ”[១២] ។

ក្នុងលំដាប់បទតអំពីនោះ ក៏ទ្រង់សម្តែងក្នុងធម៌អនុលោមបច្ចនិយ, ដោយន័យទាំង ៦ នេះដូចគ្នា; ព្រោះហេតុនោះ លោកទើបពោលទុកថា ៖-

“ន័យទាំង ៦ គឺតិកប្បដ្ឋានដ៏ប្រសើរ១, ។ល។ ទុកទុកប្បដ្ឋាន ១, ជាន័យដ៏ជ្រាលជ្រៅក្នុង **អនុលោមបច្ចនិយ**”[១៣] ។

ក្នុងលំដាប់តអំពីនោះ ក៏ទ្រង់សម្តែងក្នុងធម៌អនុលោមបច្ចនីយៈ, ដោយន័យទាំង ៦ នេះដូចគ្នា; ព្រោះហេតុនោះ លោកទើបពោលថា ៖-

“ន័យទាំង ៦ គឺ តិកប្បដ្ឋានដ៏ប្រសើរ ១, ។ល។ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រាលជ្រៅ ក្នុងបច្ចនីយានុលោម”[១៤] ៕

[១២] អភិ. ។

[១៣] អភិ. ។

[១៤] អភិ. ។

## សម្ដែងអំពីសមន្តប្បដ្ឋាន ២៤

បដ្ឋានដែលប្រជុំសមន្តប្បដ្ឋាន ២៤ នេះគឺ បដ្ឋាន៦ក្នុងធមិអនុលោម, បដ្ឋាន ៦ ក្នុងធមិបដីលោម, បដ្ឋាន ៦ ក្នុងធមិអនុលោមបច្ចនីយប្បដ្ឋាន, បដ្ឋាន ៦ ក្នុងធមិបច្ចនីយានុលោម, ឈ្មោះថា **មហាបករណ៍** (គម្ពីរធំ) ៕

## សម្ដែងអំពីការប្រៀបធៀបនឹងសាគរ

ឥឡូវនេះ ដើម្បីការដឹងច្បាស់ដល់ព្រះអភិធម្មនេះ ជាធមិ ជ្រាលជ្រៅ គប្បីជ្រាបសាគរ (សមុទ្ទ) ៤ គឺ

**១-សំសារសាគរ** សមុទ្ទ គឺសង្សារ

**២-ជលសាគរ** សមុទ្ទ គឺទឹកមហាសមុទ្ទ

**៣-នយសាគរ** សមុទ្ទ គឺន័យ

**៤-ញាណសាគរ** សមុទ្ទ គឺព្រះញាណ ។

បណ្ដាសាគរទាំង ៤ នោះ ឈ្មោះថា **សំសារសាគរ** គឺសំសារវដ្ដ ដែលលោកពោលទុកយ៉ាងនេះថា ៖-

**“ខន្ធានញ្ច បដិបាដិ ធាតុអាយតនានញ្ច**

**អព្ពោច្ឆិន្នំ វត្តមានា សំសារោតិ បវុច្ចតិ។**

លំដាប់នៃខន្ធ, ធាតុ និងអាយតនៈ, ដែលកំពុងប្រព្រឹត្តទៅ មិន

ដាច់ខ្សែ លោកហៅថា សំសារៈ ” ។

នេះឈ្មោះថា **សំសារសាគរ** ។ សំសារសាគរនេះ ព្រោះហេតុដែលកតិកា (កំណត់) ខាងដើមការកើតឡើងនៃសត្វទាំងនេះ មិនប្រាកដ, គឺមិនមានកំណត់ថា “សត្វទាំងឡាយកើតឡើងមក ហើយក្នុងទីបំផុតត្រឹម ១00 ឆ្នាំប៉ុណ្ណោះ, ត្រឹម ១.000 ឆ្នាំប៉ុណ្ណោះ, ត្រឹម ១00.000 ឆ្នាំប៉ុណ្ណោះ, ត្រឹម ១00 កប្បប៉ុណ្ណោះ, ត្រឹម ១000 កប្បប៉ុណ្ណោះ, ត្រឹម ១00.000 កប្បប៉ុណ្ណោះ, ក្នុងកាលមុនពីនេះ មិនបានមានឡើយ” ; ឬថា “សត្វទាំងឡាយកើតឡើងហើយ ក្នុងកាលនៃព្រះរាជាព្រះនាមឯណោះ, ក្នុងកាលនៃព្រះពុទ្ធព្រះនាមឯណោះ; ក្នុងកាលមុនពីនោះ មិនមានឡើយ” ; តែថាមានដោយន័យនេះថា “ម្នាលភិក្ខុទាំងឡាយ កតិកាខាងដើមនៃអវិជ្ជា មិនប្រាកដក្នុងកាលមុនពីនេះ អវិជ្ជាមិនមាន, តែខាងក្រោយទើបមាន” [១៥] ។ កាលកំណត់កតិកាមានក្នុងខាងដើម និងទីបំផុតដែលបុគ្គលដឹងមិនបាននេះឈ្មោះថា **សំសារសាគរ** ។

មហាសាគរ គប្បីជ្រាបថា ឈ្មោះថា ជលសាគរ; មហាសមុទ្ទនោះជម្រៅ ៨៤000 យោជន៍; ឈ្មោះថា ការប្រមាណទឹកក្នុងមហាសមុទ្ទនោះថា មានប៉ុណ្ណេះ គឺមានទឹកមួយរយអាឡ្ហកៈ, មួយពាន់អាឡ្ហកៈ, ឬមួយ

---

[១៥] អំ. ទសក. ។

សែនអាឡ្ហកៈ មិនមានឡើយ; តាមសេចក្ដីពិត អន្លង់មហាសមុទ្ទនោះ រមែងប្រាកដថា នរណា១ មិនគប្បីរាប់បាន មិនគប្បីប្រមាណបាន រមែងដល់នូវការរាប់ថា ជាអន្លង់ទឹកធំដោយពិត; នេះឈ្មោះថា **ជលសាគរ**។

**នយសាគរ** តើដូចម្ដេច? **នយសាគរ** បានដល់ ព្រះពុទ្ធវចនៈ, គឺព្រះត្រៃបិដក; បីតិសោមនស្សដែលមិនមានទីបំផុត រមែងកើតឡើងដល់បុគ្គលទាំងឡាយ អ្នកដល់ព្រមដោយសទ្ធា, មានសេចក្ដីជ្រះថ្លាច្រើន, មានការដឹងច្បាស់ ដល់អ្នកពិចារណា**តន្តិ**ទាំងពីរ ។ ក៏តន្តិទាំងពីរតើដូចម្ដេច? **តន្តិ**ទាំងពីរ គឺព្រះវិន័យ និងព្រះអភិធម្ម; បីតិ និងសោមនស្សមិនមានទីបំផុត រមែងមានដល់ភិក្ខុវិន័យធរទាំងឡាយ អ្នកពិចារណាតន្តិនៃវិន័យថា “ឈ្មោះថា ការបញ្ញត្តិសិក្ខាបទ សមគួរដល់ទោស ‘ធម្មតាថា សិក្ខាបទនេះ រមែងមាន ព្រោះទោសនេះ, ព្រោះឈានកន្លងរបស់នេះ’ ; និងកើតដល់អ្នកពិចារណា**ឧត្តរិមនុស្សធម្មបេយ្យាល**, ដល់អ្នកពិចារណានីលបេយ្យាល, អ្នកពិចារណាសញ្ចរិត្តបេយ្យាលថា ការបញ្ញត្តិសិក្ខាបទ មិនមែនជាវិស័យរបស់ពួកជនដទៃ, ជាវិស័យរបស់ព្រះសម្ពុទ្ធប៉ុណ្ណោះ” ។

បីតិ និងសោមនស្ស មិនមានទីបំផុត ក៏តែងកើតដល់ភិក្ខុអ្នករៀនអភិធម្ម, អ្នកពិចារណាហើយនូវ**តន្តិ**នៃព្រះអភិធម្មថា “ព្រះសាស្ដារបស់យើងទាំងឡាយ កាលទ្រង់ចែកសេចក្ដីផ្សេងគ្នានៃខន្ធ, សូម្បីការផ្សេងនៃអាយតនៈ, សូម្បីការផ្សេងនៃធាតុ, ការផ្សេងនៃឥន្ទ្រិយ, ពលៈ, ពោជ្ឈង្គ,

កម្ម, វិបាក, ការកំណត់រូប និងអរូប; ធម៌ដ៏ល្អិតសុខុម ទ្រង់ធ្វើតែសេចក្ដីមួយៗ ក្នុងរូបធម៌ និងអរូបធម៌ឱ្យជាចំណែកៗ សម្ដែងទុក, ដូចការរាប់ផ្កាយទាំងឡាយលើផ្ទៃមេឃដូច្នោះ" ។ ក៏ក្នុងការកើតឡើងនៃបីតិសោមនស្សនោះ គប្បីជ្រាបសូម្បីរឿងដូចតទៅនេះ ៖-

ដូចបានស្ដាប់មក ព្រះថេរៈឈ្មោះ **មហានាគតិមិយតិស្សទត្តៈ** កាលទៅកាន់ត្រើយខាងនាយ ដោយគិតថា "យើងនឹងបានថ្វាយបង្គំមហាពោធិព្រឹក្ស" ទើបអង្គុយលើផ្ទៃខាងលើនៃនាវា ហើយក្រឡេកមើលមហាសមុទ្រទីនោះ; ក្នុងសម័យនោះ ត្រើយនាយ មិនប្រាកដដល់លោកឡើយ, ត្រើយអាយ ក៏មិនប្រាកដ; ដូចនឹងផ្ទាំងប្រាក់ដែលគេលាតចេញ, ក៏ដូចនឹងគ្រឿងលាតធ្វើជាផ្កាម្លិះដូច្នោះ ។ លោកគិតថា "កម្លាំងរលករបស់មហាសមុទ្រមានកម្លាំងឬទេ ? ឬថា **នយមុខ** (សេចក្ដីដែលព្រះមានព្រះភាគទ្រង់ណែនាំទុក) ក្នុងសមន្តប្បដ្ឋាន ២៤ ប្រភេទមានកម្លាំងជាង" ។ ពេលនោះ បីតិដ៏មានកម្លាំង ក៏កើតឡើងដល់អ្នកពិចារណាធម៌ដែលល្អិតសុខុមថា "ការកំណត់ក្នុងមហាសមុទ្ររមែងប្រាកដ, ព្រោះថា មហាសមុទ្រនេះ ខាងក្រោមកំណត់ដោយផែនដី, ខាងលើកំណត់ដោយអាកាស, ម្ខាងកំណត់ដោយភ្នំចក្រវាឡ, ម្ខាងកំណត់ដោយត្រើយ; តែការកំណត់នូវសមន្តប្បដ្ឋាន រមែងមិនប្រាកដ" លោកគ្របសង្កត់បីតិ ហើយចម្រើនវិបស្សនា ដែលអង្គុយហើយញុំាងកិលេសទាំងពួងឱ្យអស់ទៅ, តាំងស៊ប់ក្នុងព្រះអរហត្ត ដែលជា

ធម៌ដ៏លើស ហើយបន្លឺឧទានថា ៖-

“ព្រះយោគីរមែងឃើញធម៌ដែលជ្រាលជ្រៅ ដែលត្រាស់ដឹងបាន ដោយសែនលំបាក, មានហេតុជាដែនកើតឡើង, ដែលព្រះមហេសីទ្រង់ដឹងច្បាស់ដោយព្រះអង្គឯង, សម្ដែងទុកដោយលំដាប់ដោយសព្វគ្រប់, ក្នុងសមន្តប្បដ្ឋាននេះប៉ុណ្ណោះ, ដូចជារូបរាងតែមួយ” ។ នេះឈ្មោះថា **នយសាគរ** ។

**ញាណសាគរ** តើដូចម្ដេច ?

សព្វញ្ញុតញ្ញាណ ឈ្មោះថា **ញាណសាគរ** ។

ពិតណាស់ ញាណដទៃមិនអាចដើម្បីដឹងសាគរនោះថា “នេះឈ្មោះថា សំសារសាគរ, នេះឈ្មោះថាជលសាគរ, នេះឈ្មោះថានយសាគរ” , តែ សព្វញ្ញុតញ្ញាណប៉ុណ្ណោះ អាចដើម្បីដឹងបាន; ព្រោះហេតុដូច្នោះ សព្វញ្ញុតញ្ញាណ ទើបឈ្មោះថា **ញាណសាគរ**។

បណ្ដាសាគរទាំង ៤ នេះ នយសាគរ លោកប្រាថ្នាយកក្នុងទីនេះ; ពិតមែនហើយ ព្រះសព្វញ្ញុពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងចាក់ធ្លុះនូវនយសាគរនេះ ។

សូម្បីព្រះមានព្រះភាគអង្គនេះ ទ្រង់គង់នៅក្រោមដើមពោធិ៍ ទ្រង់ចាក់ធ្លុះរហូតនយសាគរនេះ, កាលទ្រង់ពិចារណាធម៌ដែលព្រះអង្គដឹងច្បាស់ហើយ ទ្រង់គង់ដោយបល្លង្កមួយរហូតមួយសប្ដាហ៍ថា “កាលតថាគតស្វះស្វែង

រកធម៌នេះឬអស់កាលកន្លងទៅ ៤ អសង្ខេយ្យ ក្រៃលែងដោយមួយសែនកប្ប, ខាងក្រោយ តថាគតគង់លើបល្ល័ង្កនេះ ទើបញុំាងកិលេស ១៥០០ ឱ្យអស់ ទៅហើយ, ដឹងច្បាស់បាន" ; លំដាប់នោះ ទើបស្ដេចក្រោកឡើងពីបល្ល័ង្ក **ទ្រង់ឈរសំឡឹងមើលបល្ល័ង្កអស់មួយសប្ដាហ៍** មានព្រះនេត្រមិនពព្រិច ដោយព្រះតម្រិះថា "សព្វញ្ញុតញ្ញាណតថាគតដឹងច្បាស់ហើយ លើបល្ល័ង្កនេះឬ? " ។

លំដាប់នោះ ពួកទេវតាទាំងឡាយមានបរិវិតក្កៈកើតឡើងថា "សូម្បីក្នុងថ្ងៃនេះ ព្រះសិទ្ធត្ថ គប្បីធ្វើនូវកិច្ចដែលគួរធ្វើជាពិតប្រាកដ, ទើបមិនលះការអាល័យនៅក្នុងបល្ល័ង្ក" ។ ព្រះសាស្ដាទ្រង់ជ្រាបបរិវិតក្កៈរបស់ទេវតាទាំងឡាយហើយ ដើម្បីញុំាងវិតក្កៈរបស់ទេវតាទាំងនោះឱ្យស្ងប់ ទើបហោះឡើងកាន់អាកាសវេហាស៍សម្ដែងយមកប្បាដិហារ្យ ។

ពិតណាស់ បាដិហារ្យដែលព្រះអង្គទ្រង់ធ្វើត្រង់មហាពោធិបល្ល័ង្កក្ដី, ត្រង់ទីប្រជុំនៃញាតិក្ដី, ត្រង់ទីប្រជុំបាដលីបុត្រក្ដី, ទាំងអស់បានហាក់ដូចជាយមកប្បាដិហារ្យ ដែលធ្វើក្រោមដើមគណ្ឌាម្ពព្រឹក្ស * នោះឯង; គ្រាទ្រង់ធ្វើបាដិហារ្យយ៉ាងនេះហើយ ទើបស្ដេចចុះពីអាកាស ស្ដេចយាងចង្ក្រមអស់មួយសប្ដាហ៍ ក្នុងចន្លោះនៃបល្ល័ង្ក និងស្ថានទីដែលព្រះអង្គទ្រង់ឈរ; ក្នុងថ្ងៃ

---

* ឈើឈ្មោះគណ្ឌាម្ព គឺជាស្វាយដែលបុរសឈ្មោះគណ្ឌៈដាំ (បទានុក្រមធម្មបទ) ។

ទាំង ២១ នេះ សូម្បីតែមួយថ្ងៃ ក៏រស្មីទាំងឡាយមិនបានចេញអំពីសរីរៈរបស់ព្រះសាស្តាទេ ។ **តែក្នុងសប្តាហ៍ទី ៤** *ទ្រង់គង់ក្នុងផ្ទះកែវ* **ត្រង់ទិសពាយព្យ**; ឈ្មោះថា *ផ្ទះកែវ* មិនមែនផ្ទះកែវដែលសម្រេចដោយរតនៈទេ, តែបណ្ឌិតគប្បីជ្រាបស្ថានទីដែលព្រះមានព្រះភាគទ្រង់ពិចារណាគម្ពីរទាំង ៧ ថាជា “*ផ្ទះកែវ*” ។

បណ្តាគម្ពីរទាំង ៧ នោះ សូម្បីទ្រង់ពិចារណាគម្ពីរធម្មសង្គណី រស្មីទាំងឡាយ ក៏មិនផ្សាយចេញពីព្រះសរីរៈ; កាលទ្រង់ពិចារណាវិភង្គប្បករណ៍, ធាតុកថា, បុគ្គលប្បញ្ញត្តិប្បករណ៍, កថាវត្ថុប្បករណ៍ និងយមកប្បករណ៍; រស្មីទាំងឡាយ ក៏មិនផ្សាយចេញពីព្រះសរីរៈដែរ, ប៉ុន្តែកាលណាឈានចុះកាន់មហាបករណ៍ផ្តើមពិចារណាថា **“ហេតុប្បច្ចយោ អារម្មណប្បច្ចយោ ។បេ។ អវិគតប្បច្ចយោ”** ។ កាលនោះ សព្វញ្ញុតញ្ញាណដោយភាពតែមួយរបស់ព្រះមានព្រះភាគទ្រង់ពិចារណានូវសមន្តប្បដ្ឋាន ២៤ ប្រការ, រមែងបានឱកាស (ចន្លោះ) ក្នុងមហាបករណ៍នោះឯង; ប្រៀបដូចត្រីធំ ឈ្មោះថា **តិមិរបិង្គលៈ** រមែងបានឱកាស ដោយឯកភាពគ្នា ក្នុងមហាសមុទ្រដ៏ជ្រៅ ៨៤.០០០ យោជន៍នោះឯង យ៉ាងណា, ព្រះសព្វញ្ញុតញ្ញាណ ក៏យ៉ាងនោះដែររមែងបានឱកាសក្នុងមហាបករណ៍ ដោយឯកភាពគ្នានោះឯង ៕

## សម្តែងអំពីព្រះឆព្វណ្ណរង្សី

កាលព្រះសាស្តា ទ្រង់ពិចារណាធម៌ល្អិតសុខុម តាមការសប្បាយដោយព្រះសព្វញ្ញុតញ្ញាណដែលមានឱកាស (ចន្លោះ) ដែលបានហើយយ៉ាងនេះ ព្រះឆព្វណ្ណរង្សី (រស្មី ៦ ពណ៌) គឺ

**១-នីលៈ** ខៀវដូចផ្កាអញ្ចន

**២-បីតៈ** លឿងដូចហរិតាល

**៣-លោហិតៈ** ក្រហមដូចផ្លៃស្រទន់

**៤-ឱទាតៈ** សដូចផ្ទាំងប្រាក់

**៥-មញ្ជេដ្ឋៈ** ពណ៌ហង្សបាទ ដូចផ្កាសិរមាន់

**៦-បភស្សរៈ** ពណ៌ផ្លេកដូចកែវផលិក ។

ក៏ផ្សាយចេញពីព្រះសរីរៈ; ផ្ទៃមេឃ ហាក់បីដូចជាពេញដោយផ្កាអញ្ចនផ្សាយហើយទូទៅ, ដូចដេរដាសដោយផ្កាកប្បាស ឬស្រទាប់ផ្កាឧប្បលខៀវ, ដូចទងត្នោតប្រដាប់ដោយកែវមណីដែលយោលទៅយោលមក, និងដូចផ្ទាំងវត្ថុពណ៌ខៀវចាស់ដែល (គេលាត) សន្ធឹងចេញ, ដោយអំណាចនៃរស្មីពណ៌ខៀវទាំងឡាយណា, **រស្មីពណ៌ខៀវទាំងឡាយនោះ** ចេញទៅហើយអំពី**ព្រះកេសា** (សក់), **ព្រះមស្សុ**[១៦] ទាំងឡាយ និងអំពីទីពណ៌ខៀវនៃព្រះ

[១៦] ពុកមាត់ ឬពុកចង្កា ។

នេត្រទាំងពីរ ។

ទិសាភាគទាំងឡាយ រមែងរុងរោចន៍ ដូចស្រោចស្រប់ (ជម្រះ) ដោយទឹកមាស ដូចត្រដាងផ្ទាំងមាសចេញទៅ, ដូចជ្រលក់ដោយចុណ្ណ (លំអិត) នៃរមៀត និងដូចពាសពេញដោយផ្កាកណិការ ដោយអំណាចនៃ **រស្មីពណ៌លឿង** ទាំងឡាយណា; **រស្មីពណ៌លឿង**ទាំងឡាយនោះ ផ្សាយចេញហើយអំពីព្រះឆវីវណ្ណ និងអំពីទីពណ៌លឿងនៃព្រះនេត្រទាំងពីរ ។

ទិសាភាគទាំងឡាយ រុងរោចន៍ហើយ ដូចជ្រលក់ដោយលំអិតថ្នាំពណ៌ក្រហម, ដូចស្រោចដោយទឹកល័ក្តដែលឆ្អិនល្អហើយ, ដូចគ្របដោយសំពត់កម្ពលក្រហម ដូចពាសដោយផ្កាជយព្រឹក្ស ផ្ការលួសបាយ និងផ្កាច្បារ ដោយអំណាចនៃ**រស្មីពណ៌ក្រហម**ទាំងឡាយណា; **រស្មីពណ៌ក្រហម**ទាំងឡាយនោះ ផ្សាយចេញអំពី**ព្រះមំសៈ**, **ព្រះលោហិត** និងទីពណ៌ក្រហមនៃព្រះនេត្រទាំងពីរ ។

ទិសាភាគទាំងឡាយ រុងរោចន៍ហើយ ពាសពេញខ្ចាត់ខ្ចាយដោយខីរធារា (ទទឹកដោះស្រស់) ដែលចាក់ចេញអំពីឆ្នាំងប្រាក់, ដូចពិតានផ្ទាំងប្រាក់ដែលគេចងលាតសន្ធឹងទុក, ដូចទងគ្នោតប្រាក់ដែលគេគ្រវីទៅមក, ដូចដេរដាសដោយផ្ការុន, ផ្កាកោមុទ, ផ្កាគន្ធិស, ផ្កាម្លិះលា និងផ្កាម្លិះរួតជាដើម ដោយអំណាចនៃរស្មីពណ៌សទាំងឡាយណា; **រស្មីពណ៌ស**ទាំងឡាយនោះ សព្វពេញខ្លួនផ្សាយចេញហើយអំពីព្រះអដ្ឋិទាំងឡាយ, អំពីព្រះទន្តទាំងឡាយ

និងអំពីទីពណ៌សនៃព្រះនេត្រទាំងពីរ ។

ចំណែករ**ស្មីពណ៌ហង្សបាទ** និង**ពណ៌ផ្លេក** ក៏ចេញអំពីចំណែកនៃព្រះសរីរៈនោះៗ; ព្រះរស្មីទាំង ៦ នោះ ចេញហើយចាប់នូវឃនមហាបឋវី (ពិភពផែនដី) ដោយប្រការដូច្នេះ; មហាបឋវីដ៏ក្រាស់ **២៤០.០០០** យោជន៍ ដូចដុំមាសដែលគេខាត់មន្ទិលចេញហើយ; រស្មីទាំងនោះ ចោះទម្លុះផែនដី ផ្សាយចុះទៅដល់ទឹកខាងក្រោម; ទឹកដែលទ្រផែនដីកម្រាស់ **៤៨០.០០០** យោជន៍ ដូចជាមាសដែលអណ្ដែតចេញអំពីបំពង់មាស; រស្មីទាំងនោះចាក់ទម្លុះទឹកហើយ ផ្សាយចុះទៅដល់ខ្យល់; ខ្យល់កម្រាស់ **៩៦០.០០០** យោជន៍ ដូចគំនរមាសដែលគេគរឡើងហើយ, រស្មីនោះចាក់ ធ្លុះខ្យល់ហើយអណ្ដែតទៅកាន់អជដាកាស (អាកាសទទេ) ខាងក្រោម ។

សម្ដែងអំពីចំណែកខាងលើវិញ ៖- រស្មីទាំងឡាយក៏ផុស (ផ្សាយ) ឡើងហើយទៅដល់ **ចាតុម្មហារាជិកា**, ចាក់ធ្លុះនូវ **ចាតុម្មហារាជិកា** ទៅដល់ជាន់តាវត្តិង្ស, បន្ទាប់អំពីនោះ ក៏ទៅ **យាមា**, **តុសិត**, **និម្មានរតី**, **បរនិម្មិតវសវត្តី**; បន្ទាប់អំពីនោះ ក៏ទៅ **ព្រហ្មលោក** ៩ ជាន់, បន្ទាប់អំពីនោះ ក៏ទៅដល់ **វេហប្ផលា**, បន្ទាប់អំពីនោះ ក៏ទៅដល់ **បញ្ចសុទ្ធាវាស**, ចាប់រូបព្រហ្មទាំង ៤, (ចាក់ធ្លុះ) រហូតដល់អរូបព្រហ្មទាំង ៤, ហើយអណ្ដែតទៅកាន់អជដាកាស (អាកាសទទេ) ។ សម្ដែងអំពីចំណែកខាង

ទទឹងទាំងឡាយ ៖- រស្មីទាំងឡាយផ្សាយទៅកាន់លោកធាតុទាំងឡាយដែលរកទីបំផុតមិនបាន; ក្នុងកន្លែងមានប្រមាណប៉ុណ្ណោះ មិនមានរស្មីព្រះចន្ទក្នុងព្រះចន្ទ; មិនមានរស្មីព្រះអាទិត្យក្នុងព្រះអាទិត្យ; មិនមានរស្មីដួងតារាក្នុងដួងតារាទាំងឡាយ, មិនមានរស្មីរបស់ទេវតាទាំងឡាយក្នុងទីទាំងពួង គឺទីឧទ្យាន, វិមាន, ដើមកល្បព្រឹក្សទាំងឡាយ, លើសរីរៈទាំងឡាយ, លើអាភរណៈទាំងឡាយ; សូម្បីមហាព្រហ្មអាចផ្សាយពន្លឺទៅលោកធាតុតិសហស្សី និងមហាសហស្សី ក៏ដូចអំពិលអំពែក ក្នុងពេលព្រះអាទិត្យរះឡើង, ព្រះចន្ទ្រ, ព្រះអាទិត្យ, ដួងតារា, ឧទ្យាន, វិមាន, ដើមឈើកប្បព្រឹក្សនៃទេវតា ក៏ប្រាកដត្រឹមតែជាការកំណត់ប៉ុណ្ណោះ ។

ពិតណាស់ ស្ថានទីមានប្រមាណប៉ុណ្ណោះ បានជាទីជាន់សង្កត់ (គ្របសង្កត់) ហើយដោយព្រះរស្មីនៃព្រះពុទ្ធទាំងឡាយនោះ; សូម្បីឫទ្ធិនេះ ក៏មិនមែនឫទ្ធិកើតអំពីការ**អធិដ្ឋាន**, មិនមែនឫទ្ធិកើត**អំពីភាវនានៃព្រះពុទ្ធទាំងឡាយឡើយ, តែកាលព្រះលោកនាថ ទ្រង់ពិចារណាធម៌ដ៏ល្អិតសុខុម ព្រះលោហិតក៏ថ្លា, វត្ថុរូបក៏ថ្លា, ព្រះឆវីវណ្ណក៏ផូរផង់**, វណ្ណធាតុមានចិត្តជាសមុដ្ឋានតាំងនៅមិនញាប់ញ័រក្នុងទីប្រមាណ ៨០ ហត្ថដោយជុំវិញ; ព្រះមានព្រះភាគទ្រង់ពិចារណាធម៌ដោយលក្ខណៈនេះអស់ ៧ ថ្ងៃ ។

មានពាក្យ**សួរថា** ធម៌ដែលព្រះមានព្រះភាគទ្រង់ពិចារណាអស់ ៧ យប់ ៧ ថ្ងៃ បានប្រមាណប៉ុន្មាន ?

ឆ្លើយថា រកប្រមាណមិនបានទេ ។

នេះឈ្មោះថា ទេសនាដោយព្រះហប្ញទ័យជាមុនសិន; កាលបើសេចក្តីជាយ៉ាងនោះ នរណាៗ ក៏មិនអាចពោលបានថា ក៏ព្រះសាស្តាកាលទ្រង់បន្លឺព្រះវាចាសម្តែងធម៌ដែលព្រះអង្គទ្រង់គិតដោយព្រះទ័យអស់ ៧ ថ្ងៃយ៉ាងនេះ ដោយកាលកន្លងទៅ ១០០ ឆ្នាំក្តី, ១.០០០ ឆ្នាំក្តី, ១០០.០០០ ឆ្នាំក្តី, ក៏មិនអាចដើម្បីឱ្យដល់ទីបំផុតបានដូច្នេះឡើយ ។

ពិតណាស់ ក្នុងកាលជាចំណែកដទៃ ព្រះតថាគតទ្រង់គង់កណ្តាលពួកទេវតាមួយហ្មឺនចក្រវាឡលើបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបរិជាតៈ (បរិច្ឆត្តកៈ) ក្នុងឋានសួគ៌ជាន់តាវត្តឹស, កាលទ្រង់សម្តែងធម៌ថា **“កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា”** ទ្រង់ធ្វើពុទ្ធមាតា ឱ្យជាកាយសក្ខី ក៏ទ្រង់សង្ខេបៗ នូវលំដាប់ធម៌អំពីចន្លោះធម៌ ហើយសម្តែងដោយចំណែក ១០០, ដោយចំណែក ១.០០០, ដោយចំណែក ១០០.០០០; ទេសនាដែលព្រះអង្គទ្រង់ឱ្យប្រព្រឹត្តទៅជាប់តគ្នា ៣ ខែ, ជាអនន្តរទេសនាប្រមាណមិនបាន, ប្រដូចគង្គាក្នុងអាកាសដែលហូរចុះមកយ៉ាងរហ័ស និងប្រដូចខ្សែទឹកដែលហូរចេញអំពីក្អមដែលផ្កាប់មាត់ដូច្នោះ ។

ពិតណាស់ សូម្បីក្នុងការអនុមោទនាភត្តនៃព្រះពុទ្ធទាំងឡាយ ទ្រង់អនុមោទនា ហើយពង្រីកចេញបន្តិច ក៏បានប្រមាណប៉ុននឹងទីឃនិកាយ និង

មជ្ឈិមនិកាយ ។ ម្យ៉ាងទៀត កាលទ្រង់សម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នាខាងក្រោយភត្ត ទេសនាក៏មានប្រមាណប៉ុននិកាយធំទាំងពីរ គឺសំយុត្តនិកាយ និងអង្គុត្តរនិកាយ ។ ព្រោះហេតុអ្វី ? ព្រោះភវង្គបរិវាស (ការនៅអាស្រ័យនៃភវង្គចិត្ត) របស់ព្រះពុទ្ធទាំងឡាយលឿន, រីមព្រះឱស្ឋរៀបស្និទ្ធល្អ, ព្រះជីវ្ហាទន់, ព្រះសូរសៀងពីរោះ, ព្រះវាចាពោលបានរហ័ស, ព្រោះហេតុដូច្នោះ សូម្បីព្រះធម៌ដែលព្រះអង្គទ្រង់សម្ដែងហើយត្រឹមតែមួយភ្លែតនោះ ទើបបានមានប្រមាណប៉ុណ្ណេះ, ធម៌ដែលព្រះអង្គទ្រង់សម្ដែងហើយ អស់ត្រៃមាស ទើបមិនមានទីបំផុត ប្រមាណមិនបានឡើយ ។

សេចក្ដីថា **ព្រះអានន្ទត្ថេរ** ជាពហុស្សូតទ្រទ្រង់ព្រះត្រៃបិដក, ឈរនៅហើយដោយជើងដែលឈរនោះឯង, រៀន, ប្រាប់, សម្ដែងគាថា ១៥.000, គាថាធម្មបទ ៦0.000 បទ, ដូចជនអ្នកបេះផ្កាទាំងមែក ធម៌មានប្រមាណប៉ុណ្ណោះ ឈ្មោះថា ជាឧទ្ទេសមគ្គ (ផ្លូវនៃឧទ្ទេស) មួយរបស់ព្រះថេរៈ; ព្រោះថា បុគ្គលដទៃកាលឱ្យឧទ្ទេសតាមលំដាប់បទដល់ព្រះថេរៈ មិនអាចដើម្បីឱ្យ គឺប្រាប់ឱ្យមិនទាន់, ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ គប្បីឱ្យសម្បូរ (ទាន់); ព្រះសាវ័កអ្នកមាន**សតិ**ច្រើន, មាន**គតិ**ច្រើន, មាន**ធិតិ** * ច្រើនយ៉ាងនេះ, សូម្បីរៀនទេសនាដែលព្រះសាស្ដាទ្រង់សម្ដែងហើយអស់ត្រៃមាស

* ធិតិ ប្រាជ្ញា ។

ដោយទំនងនេះ អស់ ១០០ ឆ្នាំ អស់ ១.០០០ ឆ្នាំ ក៏មិនអាចឱ្យបានដល់ទីបំផុតទេ ។

**សួរថា** ក៏ឧបាទិន្នកសរីរៈ (រាងកាយដែលមានចិត្តគ្រប់គ្រង) ជាប់ (ទាក់ទង) ដោយកវឡិង្ការាហារនៃព្រះតថាគត ព្រះអង្គទ្រង់សម្តែងធមិជាប់តគ្នាអស់ត្រៃមាសដូចនេះ តើប្រព្រឹត្តទៅបានដូចម្តេច?

ឆ្លើយថា ដោយការចិញ្ចឹមនោះឯង ។

ពិតណាស់ កាលនោះ ព្រះពុទ្ធទាំងឡាយទ្រង់ពិគ្រោះល្អហើយ, ទ្រង់កំណត់ល្អហើយ, ទ្រង់ពិចារណាល្អហើយ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងធមិ ទើបទ្រង់ប្រមើលមើលវេលាក្នុងមនុស្សលោក; ព្រះអង្គទ្រង់កំណត់វេលាភិក្ខាចារហើយ និម្មិតពុទ្ធនិមិត្តហើយ អធិដ្ឋានថា "ការកាន់ចីវរ, ការកាន់បាត្រ, ការបន្លឺសំឡេង, កិរិយាអាការនៃពុទ្ធនិមិត្តនេះ, ចូរមានយ៉ាងនេះ, ចូរសម្តែងធមិឈ្មោះមានប្រមាណប៉ុណ្ណេះ" , ហើយទ្រង់កាន់បាត្រ និងចីវរស្តេចទៅស្រះអនោតត្តៈ; ទេវតាថ្វាយឈើស្ទន់ឈ្មោះនាគលតា; ព្រះអង្គទ្រង់ទំពាឈើស្ទន់នាគលតានោះ ជម្រះសរីរៈក្នុងស្រះអនោតត្តៈ ហើយទ្រង់ឈរលើផ្ទៃមនោសិលា, ទ្រង់ស្លៀកស្បង់ពីរជាន់ដែលជ្រលក់ល្អហើយ, ទ្រង់ឃ្លុំចីវរ, ហើយកាន់បាត្រសិលាដែលមហារាជថ្វាយ, ស្តេចយាងទៅកាន់ឧត្តរកុរុទ្វីប; ទ្រង់នាំបិណ្ឌបាតមកអំពីទីនោះ ទ្រង់គង់ទៀបឆ្នេរស្រះអនោតត្តៈ ទ្រង់ឆាន់ហើយ ស្តេចយាងទៅព្រៃដើមចន្ទន៍

ដើម្បីសម្រាកពេលថ្ងៃ ។

ចំណែកព្រះធម្មសេនាបតីសារីបុត្តត្ថេរក៏ទៅក្នុងទីនោះដែរ នឹងធ្វើវត្តចំពោះព្រះសម្មាសម្ពុទ្ធហើយអង្គុយក្នុងទីដ៏សមគួរ; លំដាប់នោះ ព្រះសាស្តាទ្រង់ប្រទានន័យដល់ព្រះថេរៈហើយ ទើបត្រាស់ប្រាប់ថា “ម្នាលសារីបុត្រ ធម៌ដែលតថាគតសម្តែងហើយមានប្រមាណប៉ុណ្ណេះ” ; កាលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានន័យយ៉ាងនេះ កាលប្រទានន័យដល់ព្រះអគ្គសាវ័ក អ្នកសម្រេចបដិសម្ភិទាហើយ, ដូចបុគ្គលអ្នកឈរនៅទីបំផុតឆ្នេរហើយ លាតដៃបង្ហាញឱ្យឃើញមហាសមុទ្រដូច្នោះ; ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ រមែងប្រាកដច្បាស់ដល់ព្រះថេរៈដោយ ១០០ ន័យ, ១.០០០ ន័យ, ១០០.០០០ ន័យ ។

**សួរថា** ព្រះសាស្តាទ្រង់សម្រាកពេលថ្ងៃ ហើយស្តេចទៅសម្តែងធម៌វេលាណា?

**ឆ្លើយថា** ធម្មតាថា វេលាសម្រាប់សម្តែងធម៌ដល់អ្នកក្រុងសាវត្ថីដែលប្រជុំគ្នាហើយរមែងមាន, ក៏ស្តេចទៅក្នុងវេលានោះ ។

**សួរថា** អ្នកណាជ្រាប អ្នកណាមិនជ្រាបថា ព្រះសាស្តាទ្រង់យាងទៅសម្តែងធម៌ ឬថា ស្តេចយាងមកសម្តែងធម៌?

**ឆ្លើយថា** ទេវតាអ្នកមានសក្តិធំតែងជ្រាប, ទេវតាអ្នកមានសក្តិតូច

ទើបមិនជ្រាបទេ ។

**សួរថា** ព្រោះហេតុអ្វី ទេវតាអ្នកមានសក្តិតូចទើបមិនជ្រាប?

**ឆ្លើយថា** ព្រោះព្រះសម្មាសម្ពុទ្ធ ឬពុទ្ធនិមិត្ត មិនមានសេចក្តីផ្សេងជាមួយនឹងវត្ថុទាំងឡាយមានព្រះរស្មីជាដើម; សេចក្តីពិត សេចក្តីផ្សេងគ្នានៃព្រះពុទ្ធទាំងពីរព្រះអង្គនោះ ក្នុងព្រះរស្មី ឬព្រះសូរសៀង ឬក៏ព្រះតម្រាស់មិនបានមាន ។

ចំណែក **ព្រះសារីបុត្តត្ថេរ** ក៏នាំធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយៗ មកសម្តែងដល់ភិក្ខុ ៥០០ រូប ជាសទ្ធិវិហារិករបស់ខ្លួន; បណ្ឌិតគប្បីជ្រាបបុព្វយោគ (ការប្រកបកម្មក្នុងកាលមុន) របស់ភិក្ខុ ៥០០ រូបនេះ ៖-

## បុព្វយោគនៃភិក្ខុ ៥០០ រូប

បានឮថា ក្នុងកាលនៃព្រះទសពល ព្រះនាមថា **កស្សបៈ** ភិក្ខុពួកនោះកើតក្នុងកំណើតសត្វប្រចៀវ កាលប្រតោងញកភ្នំ ភិក្ខុ ២ រូបទ្រទ្រង់អភិធម្មស្វាធ្យាយព្រះអភិធម្មក៏ចាប់យកនិមិត្តក្នុងសំឡេង **សូម្បីមិនដឹងថា ជាធម៌ពួកខ្មៅ ជាធម៌ពួកស** ធ្វើកាលកិរិយាហើយទៅកើតក្នុងទេវលោក ដោយហេតុត្រឹមតែចាប់យកនិមិត្តក្នុងសំឡេងប៉ុណ្ណោះ ។ ទេវតាទាំងនោះនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ; ក្នុងកាលនោះ ពួកទេវតានោះមកកើតក្នុងមនុស្ស

លោក ជ្រះថ្លាក្នុងយមកប្បាដិហារ្យ ទើបបួសក្នុងសំណាក់នៃព្រះថេរៈ; ព្រះថេរៈនាំធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយៗ មកសម្តែងដល់ពួកភិក្ខុនោះ; ការបញ្ចប់ការសម្តែងព្រះអភិធម្មនៃព្រះសម្មាសម្ពុទ្ធ និងការរៀនគម្ពីរទាំង ៧ របស់ភិក្ខុទាំងឡាយនោះ បានមានព្រមៗគ្នានោះឯង ។

ផ្លូវនៃការប្រាប់ ព្រះអភិធម្មរបស់ព្រះសារីបុត្តត្ថេរ, ជាដើមហេតុសូម្បីវារៈសម្តែងអំពីការរាប់ចំនួនមហាបករណ៍ ក៏ព្រះថេរៈនោះឯងតាំងទុកហើយ ។ ពិតណាស់ ព្រះថេរៈមិនលប់លាង (រំលង) លំដាប់ធម៌ ដើម្បីកាន់យក ដើម្បីទ្រទ្រង់ចាំ ដើម្បីរៀនសូត្រ និងដើម្បីបង្រៀនបានស្រួលដោយវិធីនេះ ព្រោះហេតុដូច្នោះ ទើបចាត់តាំងទុកនូវវារៈពោលដោយការរាប់; ក៏គ្រាសេចក្តីជាយ៉ាងនេះ ព្រះថេរៈក៏ជាអ្នកទ្រទ្រង់ព្រះអភិធម្មមុនគេឬ? មិនមុនគេទេ, ព្រះសម្មាសម្ពុទ្ធអង្គនោះឯង ជាអ្នកទ្រទ្រង់ព្រះអភិធម្មមុនដំបូងគេបង្អស់, ព្រោះថា ព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្រោមមហាពោធិបល្លង្កទ្រង់ត្រាស់ដឹងហើយនូវព្រះអភិធម្មនោះ; ក៏គ្រានោះឯង ព្រះពុទ្ធទ្រង់គង់ដោយព្រះភ្នែនតែមួយអស់ ៧ ថ្ងៃ ទ្រង់បន្លឺឧទានថា ៈ-

**បឋមពុទ្ធវចនៈ**

**“យទា ហវេ បាតុភវន្តិ ធម្មា**

**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស;**

**អថស្ស កង្ខា វបយន្តិ សព្វា**

**យតោ បជានាតិ សហេតុធម្មំ ។**

ក្នុងកាលណា ធម៌ទាំងឡាយរមែងប្រាកដដល់ព្រះខីណាសវព្រាហ្មណ៍អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ អ្នកដុតបង់នូវកិលេស; ក្នុងកាលនោះ សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាសវព្រាហ្មណ៍នោះ ក៏សឹងតែរម្ងាប់អស់ទៅ ព្រោះថា ព្រះខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

**យទា ហវេ បាតុភវន្តិ ធម្មា**

**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស;**

**អថស្ស កង្ខា វបយន្តិ សព្វា**

**យតោ ខយំ បច្ចយានំ អវេទិ ។**

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រះខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ខីណាសវព្រាហ្មណ៍នោះ រមែងរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ព្រះខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យ ។

**យទា ហវេ បាតុភវន្តិ ធម្មា**

**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**

**វិធូបយំ តិដ្ឋតិ មារសេនំ**
**សុរិយោវ ឱភាសយមន្តលិក្ខំ** ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញ៉ាំងកិលេសឱ្យក្ដៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារ ហើយឋិតនៅ; ក្នុងកាលនោះ បីដូចជាព្រះអាទិត្យ ដែលរះឡើងធ្វើអាកាសឱ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់នូវងងឹត ឋិតនៅដូច្នោះឯង”[១៧] ។

នេះឈ្មោះថា **បឋមពុទ្ធវចនៈ**; តែអាចារ្យអ្នកពោលធម្មបទ បានពោលថា “ឈ្មោះថា បឋមពុទ្ធវចនៈនេះគឺ ៖-

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា** ៕

កាលតថាគតស្វែងរកជាងផ្ទះ (គឺតណ្ហា) មិនទាន់ជួបប្រទះ

---

[១៧] វិនយ., ខុ. ឱ. ។

តថាគត ក៏ត្រាច់ទៅមកៗ ក្នុងវដ្ដសំសារអស់ជាតិជាអនេក ការកើត ក៏ជាទុក្ខញយៗ នៃជាងផ្ទះគឺតណ្ហា ! ឥឡូវនេះ តថាគតឃើញជាងឯងហើយ, ជាងឯងនឹងសង់ផ្ទះ គឺអត្តភាពរបស់តថាគតតទៅទៀតមិនបានទេ ព្រោះឆ្អឹងជំនី គឺ (កិលេសដ៏សេស) ទាំងអស់របស់ជាងឯងតថាគតបានកាច់បំបាក់អស់រលីងគ្មានសល់ទេ (ទាំង) ដំបូលផ្ទះ គឺអវិជ្ជា តថាគតក៏រុះរើចោលចេញអស់រលីងហើយដែរ ។ ចិត្តរបស់តថាគតបានដល់នូវព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគតដល់នូវការអស់ទៅនៃតណ្ហាទាំងឡាយហើយ” [១៨] ។

ព្រះតម្រាស់ដែលព្រះមានព្រះភាគ ព្រះអង្គទ្រង់សេយ្យាសនៈក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសម័យជិតបរិនិព្វានត្រាស់ថា **“ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ, វយធម្មា សង្ខារា, អប្បមាទេន សម្បាទេថ** = ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ! ឥឡូវនេះ តថាគតនឹងផ្ដាំអ្នកទាំងឡាយថា សង្ខារទាំងឡាយមានកិរិយាសូន្យទៅជាធម្មតា, អ្នករាល់គ្នា ចូរញ៉ាំងប្រយោជន៍ឱ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទចុះ” [១៩] ឈ្មោះថា **បច្ឆិមពុទ្ធវចនៈ** ។

---

[១៨] ខុ. ធ. ។

[១៩] ទ. ម. ។

ព្រះសទ្ធម្មដែលប្រកាសអមតៈដែលព្រះអង្គត្រាស់ទុក ៤៥ វស្សា ក្នុងចន្លោះព្រះពុទ្ធវចនៈទាំងពីរ ដូចនាយមាលាការក្រងភួងផ្កា ៥, ដូចជាងកែវ ក្រងភួងផ្កា ឈ្មោះថា **មជ្ឈិមពុទ្ធវចនៈ** ។ សូម្បីពុទ្ធវចនៈទាំងអស់នោះកាលប្រមូលចូលគ្នាដោយបិដកមាន ៣ បិដក, ដោយនិកាយមាន ៥ និកាយ, ដោយអង្គមានអង្គ ៩, ដោយធម្មក្ខន្ធមាន ៨៤000 ធម្មក្ខន្ធ ។

តើដូចម្តេច ? ពិតណាស់ ពុទ្ធវចនៈទាំងអស់នេះ ដោយបិដកមាន ៣ ប្រភេទប៉ុណ្ណោះ គឺ**វិនយបិដក**, **សុត្តន្តបិដក** **និងអភិធម្មបិដក** ។ បណ្តាបិដកទាំង ៣ នោះ ពុទ្ធវចនៈនេះ គឺបាតិមោក្ខទាំងពីរ, វិភង្គទាំងពីរ, ខន្ធកៈ ២២, បរិវារៈ ១៦[២០] ឈ្មោះថា **វិនយបិដក** ។

ព្រះពុទ្ធវចនៈនេះ គឺ**ទីឃនិកាយ** ដែលរួបរួមព្រះសូត្រទុក ៣៤ សូត្រ មាន**ព្រហ្មជាលសូត្រ**ជាដើម, **មជ្ឈិមនិកាយ**ដែលរួបរួមព្រះសូត្រទុក ១៥២ សូត្រ មាន**មូលបរិយាយសូត្រ**ជាដើម, **សំយុត្តនិកាយ**ដែលរួបរួមព្រះសូត្រទុក ៧៧៦២ សូត្រ មាន**ឱឃតរណសូត្រ**ជាដើម, **អង្គុត្តរនិកាយ**ដែលរួបរួមព្រះសូត្រទុក **៩៥៥៧** សូត្រ មាន**ចិត្តបរិយាយសូត្រ**ជាដើម, **ខុទ្ទកនិកាយ**មាន ១៥ ប្រភេទ គឺ

១. ខុទ្ទកបាឋៈ, ២. ធម្មបទ, ៣. ឧទាន, ៤. ឥតិវុត្តកៈ, ៥. សុត្ត

---

[២០] ច្បាប់ខ្លះថា វិភង្គ ២ ខន្ធកៈ ២២ បរិវារៈ ១៦ ។

និបាត, ៦. វិមានវត្ថុ, ៧. បេតវត្ថុ, ៨. ថេរគាថា, ៩. ថេរីគាថា, ១០. ជាតក, ១១. និទ្ទេស, ១២. បដិសម្ភិទា, ១៣. អបទាន, ១៤. ពុទ្ធវំស និង ១៥. ចរិយាបិដក ឈ្មោះថា **សុត្តន្តបិដក** ។

បករណ៍ ៧ មានធម្មសង្គណីជាដើម ឈ្មោះថា **អភិធម្មបិដក**៕

## ពាក្យថាវិន័យ មានអត្ថ ៣ យ៉ាង

បណ្ដាបិដកទាំង ៣ នោះ **ព្រះវិនយបិដក** នេះ បណ្ឌិតអ្នកដឹងសេចក្ដីនៃព្រះវិន័យពោលថា **"វិន័យ"** ព្រោះមានន័យផ្សេងៗ, មានន័យវិសេស និងព្រោះទូន្មានកាយវាចា ។

សេចក្ដីថា ក្នុងព្រះវិនយបិដកនេះ ឈ្មោះថា មានន័យផ្សេងៗ គឺមានន័យដែលញែកទុក ដោយបាតិមោក្ខុទ្ទេស ៥ យ៉ាង, អាបត្តិ ៧ កងមានបារាជិកជាដើម, មាតិកា និងវិភង្គជាដើម; និងដែលឈ្មោះថា មានន័យវិសេស គឺន័យនៃអនុប្បញ្ញត្តិដែលមានការធ្វើឱ្យតឹង និងការធ្វើឱ្យធូរ ជាប្រយោជន៍, ម្យ៉ាងទៀតថា វិន័យនេះ ឈ្មោះថា ទូន្មានកាយវាចា ព្រោះការពារសេចក្ដីប្រព្រឹត្តិខុសផ្លូវកាយ និងវាចា; ព្រោះហេតុដូច្នោះ វិន័យនេះ បណ្ឌិតទើបពោលថា "ឈ្មោះថាវិន័យ" ព្រោះមានន័យផ្សេងៗ, ព្រោះមានន័យវិសេស និងព្រោះទូន្មានកាយ និងវាចា; ដោយហេតុនោះៗ ឯង

ដើម្បីភាពជាអ្នកឆ្លាត ក្នុងអត្ថនៃការពោលដល់ព្រះវិន័យនោះ លោកទើបប្រពន្ធ័គាថាទុកថា ៖-

**“វិវិធវិសេសនយត្តា វិនយនតោ ចេវ កាយវាចានំ**
**វិនយត្ថវិទូហិ អយំ វិនយោ ‘វិនយោ’តិ អក្ខាតោ ៹**

ព្រះវិនយ័នេះបណ្ឌិតអ្នកដឹងអត្ថនៃវិនយ័ទាំងឡាយ ពោលថា **“ព្រះវិន័យ”** ព្រោះមានន័យផ្សេងៗ, ព្រោះមានន័យវិសេស និងព្រោះទូន្មានកាយវាចា” ៕

## ពាក្យថា ព្រះសូត្រ មានអត្ថ ៦ យ៉ាង

ចំណែកព្រះសូត្រ បណ្ឌិតអ្នកដឹងអត្ថនៃព្រះសូត្រពោលថា **“ព្រះសូត្រ”** ព្រោះក្រសោបនូវប្រយោជន៏, ព្រោះជាតម្រាស់ដែលព្រះពុទ្ធត្រាស់ល្អហើយ, ព្រោះបញ្ចេញប្រយោជន៏, ព្រោះបង្ហូរប្រយោជន៏, ព្រោះជាទីការពារយ៉ាងល្អ និងព្រោះមានចំណែកប្រៀបដោយសរសៃអំបោះ និងបន្ទាត់ ។

ពិតណាស់ ព្រះសូត្រនោះ រមែងសម្ដែងប្រយោជន៏ទាំងឡាយ ដែលផ្សេងដោយប្រយោជន៏របស់ខ្លួន និងរបស់អ្នកដទៃជាដើម, ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ មានអត្ថដែលត្រាស់ទុកយ៉ាងល្អ ព្រោះត្រាស់ស្របតាមអធ្យាស្រ័យរបស់វេនេយ្យសត្វ; ក៏ព្រះសូត្រនេះ តែងហូរចេញនូវប្រយោជន៏ទាំងឡាយ ដូចសន្ទូងបញ្ចេញផ្លែ; និងតែងបង្ហូរចេញនូវប្រយោជន៏ទាំងឡាយ ដូច

មេគោបង្ហូរទឹកដោះចេញ; ឈ្មោះថា ការពារ គឺរក្សាប្រយោជន៍ទាំងឡាយទាំងពួងនោះយ៉ាងល្អ;ម្យ៉ាងទៀត ឈ្មោះថា មានចំណែកប្រៀបដោយសរសៃអំបោះ និងបន្ទាត់, ប្រៀបដូចសរសៃអំបោះ និងបន្ទាត់ជាប្រមាណរបស់ជាងចាំងទាំងឡាយយ៉ាងណា, សូម្បីព្រះសូត្រនេះ ក៏ជាប្រមាណរបស់វិញ្ញូជនទាំងឡាយ យ៉ាងនោះដែរ; មួយទៀត ផ្កាកម្រងទាំងឡាយ ដែលគេក្រងដោយចេសមិនរាត់រាយ មិនខ្ចាត់ខ្ចាយ យ៉ាងណា, សេចក្តីទាំងឡាយដែលទ្រង់រួបរួមទុកដោយព្រះសូត្រនេះ ក៏យ៉ាងនោះដែរ ។ ដោយហេតុនោះដើម្បីភាពជាអ្នកឆ្លាតក្នុងអត្ថនៃការពោលដល់ព្រះសូត្រនោះ លោកទើបពោលប្រពន្ធ័គាថាទុកថា ៖-

**“អត្ថានំ សូចនតោ សុវុត្តតោ សវនតោថ សូទនតោ**

**សុត្តាណា សុត្តសភាគតោ ច សុត្តំ ‘សុត្ត’ន្តិ អក្ខាតំ ។**

ព្រះសូត្រ លោកហៅថា ព្រះសូត្រ ព្រោះក្រសោបអត្ថ, ព្រោះត្រាស់ទុកល្អហើយ ព្រោះបញ្ចេញប្រយោជន៍ ព្រោះបង្ហូរប្រយោជន៍ ព្រោះការពារទុកល្អ និងព្រោះមានចំណែកប្រៀបដោយសរសៃអំបោះបន្ទាត់” ៕

## អភិធម្មមានអត្ថ ៥ យ៉ាង

ចំណែកព្រះអភិធម្ម បណ្ឌិតពោលថា **ព្រះអភិធម្ម** ព្រោះហេតុដែលក្នុងអភិធម្មបិដកនេះ ព្រះមានព្រះភាគត្រាស់ដឹងធម៌ដែលមានសេចក្ដីចម្រើន ១, ដែលគួរកំណត់ ១, ដែលគួរបូជា ១ ដែលកំណត់ទុក ១ និងជាទីក្រៃលែង ១ ។

ពិតណាស់ **អភិសព្ទនេះ** ប្រើក្នុងការសំគាល់ថា ចម្រើន, គួរកំណត់, គួរបូជា, ដែលកំណត់ទុក និងដែលក្រៃលែង ។ ពិតយ៉ាងនោះ **អភិសព្ទនេះ** ប្រើក្នុងពាក្យថា **ចម្រើន** ក្នុងប្រយោគមានជាអាទិ៍ថា "ម្នាលលោកដ៏មានអាយុ ទុក្ខវេទនាដ៏ធ្ងន់ តែងចម្រើន (កម្រើក) ដល់ខ្ញុំមិនបានថយចុះ"[២១] ។ ប្រើក្នុងន័យដែល**គួរកំណត់** ក្នុងប្រយោគមានជាអាទិ៍ថា "រាត្រីទាំងឡាយនោះណា លោកកំណត់ដឹងហើយ កំណត់ន័យទុកហើយ"[២២] ។ ប្រើក្នុងន័យដែល**គួរបូជា** ក្នុងប្រយោគជាដើមថា "ព្រះរាជាភិរាជដែលព្រះរាជាទ្រង់

[២១] ម. ឧ., សំ. ម. ។

[២២] ម. មូ. ។

[២៣] ម. ម, ខុ. សុ.។

[២៤] វិនយ. ។

[២៥] ខុ. វិ. ។

[២៦] អភិ. ។

បូជា ជាកំពូលមនុស្ស”[២៣] ។ ប្រើក្នុងន័យដែល**កំណត់ទុក** ក្នុងប្រយោគមានអាទិ៍ថា “**បដិពលោ វិនេតុំ អភិធម្មេ អភិវិនយេ** = ជាអ្នកអាចដើម្បីណែនាំក្នុងធម៌ដែលកំណត់ទុក ក្នុងវិន័យដែលកំណត់ទុក”[២៤] ។ អធិប្បាយថា ក្នុងធម៌ និងវិន័យដែលវៀរចាកការចម្រុះគ្នានឹងគ្នា ។ ប្រើក្នុងន័យថា ដ៏ក្រៃលែង (អធិកៈ) ក្នុងប្រយោគមានអាទិ៍ថា “មានសម្បុរល្អក្រៃលែង”[២៥] ។

ក៏ក្នុងអភិធម្មនេះ ព្រះមានព្រះភាគទ្រង់ត្រាស់នូវធម៌ទាំងឡាយដែលមានសេចក្ដីចម្រើនដោយន័យជាដើមថា “ភិក្ខុចម្រើនមគ្គដើម្បីចូលដល់រូបភពមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសមួយហើយ”[២៦] ក៏មាន ។ ត្រាស់ធម៌ទាំងឡាយដែលគួរកំណត់ ព្រោះភាពជាធម៌ដែលកំណត់ដោយអារម្មណ៍ទាំងឡាយ ដោយន័យជាដើមថា “ជារូបារម្មណ៍ សទ្ទារម្មណ៍” ក៏មាន ។ ត្រាស់ធម៌ទាំងឡាយដែលគួរបូជាដោយន័យជាដើមថា “**សេក្ខធម៌, អសេក្ខធម៌, លោកុត្តរធម៌**”[២៧] ក៏មាន ។ លោកអធិប្បាយថា ធម៌ដែលគួរបូជាត្រាស់ធម៌ទាំងឡាយដែលទ្រង់កំណត់ទុក ព្រោះជាធម៌ដែល

---

[២៧] អភិ. ។

កំណត់ដោយសភាវៈដោយន័យជាដើមថា “ផស្សៈមាន, វេទនាមាន”[២៨] ក៏មាន ។ នឹងត្រាស់ធម៌ទាំងឡាយដ៏ក្រៃលែងដោយន័យជាដើមថា “មហគ្គតធម៌, អប្បមាណធម៌, អនុត្តរធម៌”[២៩] ក៏មាន ។ ដោយហេតុនោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងអត្ថនៃការពោលដល់ព្រះអភិធម្មនោះ លោកទើបពោលប្រព័ន្ធគាថាទុកថា ៖-

**“យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា**
**វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។**

ព្រះអភិធម្ម បណ្ឌិតពោលថា ព្រះអភិធម្ម ព្រោះហេតុដែលព្រះអភិធម្មនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់ធម៌ដែលចម្រើន ១ ធម៌ដែលគួរកំណត់ ១ ធម៌ដែលគួរបូជា ១ ធម៌ដែលគួរកំណត់ (ញែក) ទុក ១ និងធម៌ដ៏ក្រៃលែង ១” ៕

## សម្ដែងអំពីន័យដែលមិនផ្សេងគ្នានៃបិដក

ក៏ក្នុងព្រះត្រៃបិដកទាំង ៣ នេះ បណ្ឌិតអ្នកដឹងអត្ថនៃបិដកសព្ទពោលថា ពាក្យថា បិដកដែលមិនប្លែកផ្សេងគ្នានោះថា ឈ្មោះថា បិដក

---

[២៨] អភិ. ។

[២៩] អភិ. ។

ព្រោះអត្ថថា **បរិយត្តិ** និង**ភាជនៈ** (វត្ថុជាទីតម្កល់), ឥឡូវនេះ គប្បីប្រមូលបិដកសព្ទនោះចូលគ្នាហើយ ជ្រាបបិដកទាំង ៣ មានវិន័យជាដើម ។

ពិតណាស់ សូម្បីបរិយត្តិ លោកក៏ហៅថា បិដក (តម្រា) ដូចក្នុងប្រយោគមានជាអាទិ៍ថា **"មា បិដកសម្បទានេន** = កុំជឿដោយអាងតម្រា"[៣០] ; សូម្បីភាជនៈយ៉ាងណាមួយ ក៏ហៅថា បិដក ដូចក្នុងប្រយោគមានជាអាទិ៍ថា **"អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកមាទាយ** = គ្រានោះបុរស (អ្នកធ្វើថ្នល់) កាន់យកនូវចប និងកញ្ជើ (បិដក) ហើយមក"[៣១] ។ ព្រោះហេតុដូច្នោះ បិដកត្ថវិទូ (បណ្ឌិតអ្នកដឹងអត្ថនៃបិដកសព្ទ) ទើបពោលថា ឈ្មោះថា បិដក ព្រោះអត្ថថា ជាបរិយត្តិ និងភាជនៈ (វត្ថុជាទីតម្កល់) ។

ឥឡូវនេះ **បណ្ឌិតគប្បីប្រមូលបិដកសព្ទចូលគ្នា ហើយគប្បីជ្រាបបិដកទាំងបី មានវិន័យជាដើម** គឺគប្បីធ្វើសមាស (វិន័យជាដើម) និងបិដកសព្ទ ដែលមានអត្ថ ២ យ៉ាង យ៉ាងនេះ ហើយគប្បីជ្រាបបិដកទាំងបីមានវិន័យជាដើមទាំងនេះថា ព្រះវិន័យនោះផង បិដកនោះផង ឈ្មោះថា វិនយបិដក ព្រោះជាព្រះបរិយត្តិ និងជាភាជនៈ (វត្ថុជាទីតម្កល់) នូវអត្ថនោះៗ; ព្រះសូត្រនោះផង បិដកនោះផង ឈ្មោះថា សុត្តន្តបិដក និងព្រះ

---

[៣០] អំ. តិក. ។

[៣១] ម. មូ. , អំ. តិក. ។

អភិធម្មនោះផង បិដកនោះផង ឈ្មោះថា អភិធម្មបិដក ដោយន័យដែលពោលហើយនោះឯងយ៉ាងនេះ មានប្រការដូច្នេះ ៕

## សម្តែងអំពីន័យពាក្យថាបិដកដែលប្លែកផ្សេងគ្នា

ក៏គ្រាជ្រាបយ៉ាងនេះហើយ ដើម្បីភាពជាអ្នកឆ្លាត ក្នុងសេចក្តីផ្សេងៗ ក្នុងបិដកទាំង ៣ នោះឯងទៀតថា ៖-

**ក្នុងបិដកទាំងឡាយនោះ បណ្ឌិតគប្បីសម្តែងប្រភេទនៃទេសនា សាសនៈ កថា សិក្ខា បហាន និងគម្ភីរភាព តាមសមគួរ គឺថាភិក្ខុពន្លះប្រភេទបរិយត្តិ សម្បត្តិ និងវិបត្តិណា ក្នុងបិដកណា ដោយប្រការណា គប្បីអធិប្បាយប្រភេទបរិយត្តិ សម្បត្តិ និងវិបត្តិនោះទាំងអស់ ដោយប្រការនោះចុះ ។**

ក្នុងខនោះមានពាក្យបរិយាយ និងអធិប្បាយដូចតទៅនេះ ៖-

សេចក្តីថា បិដកទាំង ៣ នោះលោកហៅតាមលំដាប់ថា **“អាណាទេសនា វោហារទេសនា បរមត្ថទេសនា យថាបរាធសាសនៈ យថានុលោមសាសនៈ យថាធម្មសាសនៈ សំវរាសំវរកថា ទិដ្ឋិវិនិវេឋនកថា និងនាមរូបច្ឆេទកថា”** ៕

## សម្តែងអំពីទេសនា

សេចក្តីថា បណ្តាបិដកទាំង ៣ នេះ ព្រះវិនយបិដក ហៅថា **អាណាទេសនា** ព្រោះព្រះមានព្រះភាគ ព្រះអង្គគួរដល់ការប្រើអំណាច (អាណា) ទ្រង់សម្តែងច្រើនទៅដោយអំណាច, ព្រះសុត្តន្តបិដកហៅថា **វោហារទេសនា** ព្រោះព្រះមានព្រះភាគទ្រង់ជាអ្នកឆ្លាតក្នុងវោហារ (បញ្ញត្តិសព្ទ) ទ្រង់សម្តែងច្រើនទៅដោយវោហារ, ព្រះអភិធម្មបិដក ហៅថា **បរមត្ថទេសនា** ព្រោះព្រះមានព្រះភាគ ជាអ្នកឆ្លាតក្នុងបរមត្ថធម៌ ទ្រង់សម្តែងច្រើនទៅដោយបរមត្ថធម៌ ៕

## សម្តែងអំពីសាសនៈ

មួយវិញទៀត បិដកទីមួយ ហៅឈ្មោះថា **យថាបរាធសាសនៈ** ព្រោះសត្វទាំងឡាយ អ្នកមានការខុសច្រើន, ព្រះមានព្រះភាគទ្រង់ពន្យល់ទូន្មានតាមដែលការខុសក្នុងព្រះវិនយបិដកនេះ; បិដកទីពីរ ហៅឈ្មោះថា **យថានុលោមសាសនៈ** ព្រោះពួកសត្វមានអធ្យាស្រ័យ អនុស័យ ចរិយា និងអធិមុត្តិមិនតែមួយ; ព្រះមានព្រះភាគទ្រង់ពន្យល់ទៅតាមលំដាប់ក្នុងសុត្តន្តបិដកនេះ; បិដកទីបីហៅឈ្មោះថា **យថាធម្មសាសនៈ** ព្រោះសត្វទាំងឡាយមានសេចក្តីសម្គាល់ក្នុងសភាវៈត្រឹមតែកងធម៌ថា **"យើង, របស់យើង"** ;

ព្រះមានព្រះភាគទ្រង់ពន្យល់តាមសមគួរដល់ធម៌ក្នុងព្រះអភិធម្មបិដកនេះ ៕

## សម្ដែងអំពីកថា

មួយវិញទៀត បិដកទីមួយ ហៅថា **សំវរាសំវរកថា** ព្រោះព្រះមានព្រះភាគត្រាស់ការសង្រួមតូចធំ ដែលជាបដិបក្សចំពោះការប្រព្រឹត្តិខុសទុកក្នុងព្រះវិនយបិដកនេះ, ពាក្យថា “**សំវរាសំវរ**” នេះ បានដល់សំវរៈតូច និងធំ ដូចកម្មាកម្ម (កម្មតូចនិងកម្មធំ) និងផលាផល (ផ្លែតូច និងផ្លែធំ); បិដកទីពីរហៅថា **ទិដ្ឋិវិនិវេឋនកថា** ព្រោះព្រះមានបុណ្យត្រាស់ដល់ការប្រឡាក់ទិដ្ឋិ ដែលជាបដិបក្សចំពោះទិដ្ឋិ ៦២ ទុកក្នុងព្រះសុត្តន្តបិដកនេះ, បិដកទីបីហៅថា **នាមរូបបរិច្ឆេទកថា** ព្រោះត្រាស់ដល់ការកំណត់នាម និងរូបដែលជាបដិបក្សចំពោះធម៌មានរាគៈជាដើម ទុកក្នុងព្រះអភិធម្មបិដកនេះ ៕

## សម្ដែងអំពីសិក្ខាជាដើម

ក៏សូម្បីក្នុងបិដកទាំងបីនេះ បណ្ឌិតគប្បីជ្រាបសិក្ខា ៣, បហានៈ ៣ និងគម្ភីរភាព ៤ យ៉ាង ។

ពិតយ៉ាងនោះ សម្ដែងអំពីន័យពិសេស ព្រះមានបុណ្យត្រាស់ **អធិ-**

**សីលសិក្ខា** ទុកក្នុងព្រះវិនយបិដក, ត្រាស់ **អធិចិត្តសិក្ខា** ទុកក្នុងព្រះសុត្តន្តបិដក និងត្រាស់ **អធិបញ្ញាសិក្ខា** ទុកក្នុងព្រះអភិធម្មបិដក ។ ក៏ព្រះភគវាត្រាស់បហានៈ (ការលះ) **វីតិក្កមកិលេស** ទុកក្នុងព្រះវិនយបិដក ព្រោះការដែលសីលជាបដិបក្សចំពោះការកន្លងរបស់កិលេស (វីតិក្កមកិលេស), ត្រាស់ **បរិយុដ្ឋានប្បហាន** ទុកក្នុងព្រះសុត្តន្តបិដក ព្រោះការដែលសមាធិជាបដិបក្សចំពោះកិលេសដែលរួបរឹត (បរិយុដ្ឋានក្កិលេស), ត្រាស់ **អនុសយក្កិលេសប្បហាន** ទុកក្នុងព្រះអភិធម្មបិដក ព្រោះការដែលបញ្ញាជាបដិបក្សចំពោះអនុសយក្កិលេស ។ ម្យ៉ាង ក្នុងបិដកទីមួយ ត្រាស់ការលះកិលេសទាំងឡាយដោយ **តទង្គប្បហាន** (លះមួយជួរខណៈ), ក្នុងបិដកពីរក្រៅនេះ ត្រាស់ការលះកិលេសដោយ **វិក្ខម្ភនប្បហាន** និង**សមុច្ឆេទប្បហាន**; ម្យ៉ាងទៀត ក្នុងបិដកទីមួយត្រាស់ការលះ កិលេស គឺទុច្ចរិត, ក្នុងបិដកពីរក្រៅនេះ ត្រាស់ការលះសេចក្តីសៅហ្មង គឺតណ្ហា និងទិដ្ឋិ ៕

## សម្តែងអំពីគម្ភីរភាព ៤ យ៉ាង

ក៏សូម្បីបិដកទាំងបីនេះ តែបិដកមួយៗគប្បីជ្រាបគម្ភីរភាព (សេចក្តីជ្រាលជ្រៅ) ៤ យ៉ាង គឺ ដោយធម៌, ដោយអត្ថ, ដោយទេសនា និងដោយបដិវេធ ។

បណ្ដាគម្ពីរភាពទាំង៤នោះ ព្រះបាលី (តន្តិ) ឈ្មោះថា **ធម៌**, សេចក្ដីនៃព្រះធម៌នោះ ឈ្មោះថា **អត្ថ**, ការសម្ដែងបាលីតាមដែលកំណត់ទុក យ៉ាងល្អដោយចិត្តនោះ ឈ្មោះថា **ទេសនា**, ការត្រាស់ដឹងតាមសភាវៈពិតនៃធម៌ និងអត្ថនៃបាលីនោះ ឈ្មោះថា **បដិវេធ**។ សេចក្ដីថា ធម៌ អត្ថ ទេសនា និងបដិវេធ ក្នុងបិដកទាំង ៤ នោះ ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះសត្វទាំងឡាយ អ្នកមានបញ្ញាតិចឈានចុះ (យល់) បានលំបាក, ជាទីពឹងដែលបុគ្គលអ្នកមានបញ្ញាតិចមិនគប្បីបាន, ប្រៀបដូចមហាសមុទ្រដែលសត្វតូចៗ ទាំងឡាយ មានទន្សាយជាដើម ឈានចុះឱ្យដល់បានដោយលំបាក ទាំងជាទីពឹងមិនបានដូច្នោះ, បណ្ឌិតក៏គប្បីជ្រាបគម្ពីរភាពទាំង ៤ យ៉ាង ក្នុងបិដក ទាំង ៣ នេះ តែបិដកនីមួយៗ ដោយប្រការដូច្នេះ ។

ន័យមួយទៀត ហេតុឈ្មោះថា **ធម៌**, ដូចដែលត្រាស់ទុកថា ៈ-

"ញាណក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា"[៣២]។ ផលរបស់ហេតុឈ្មោះថា **អត្ថ** ដូចដែលត្រាស់ទុកថា "ញាណក្នុងផលរបស់ហេតុ ឈ្មោះថា **អត្ថបដិសម្ភិទា**" ។ បញ្ញត្តិ លោកសំដៅដល់ការពោលធម៌សមគួរដល់ធម៌ ឈ្មោះថា **ទេសនា**, ឬការពោលធម៌ដោយអំណាចនៃអនុលោម បដិលោម សង្ខេប និងពិស្ដារជាដើម ឈ្មោះថា **ទេសនា** ។ ការត្រាស់ដឹង

---

[៣២] អភិ. ។

ឈ្មោះថា **បដិវេធ** ។ ក៏បដិវេធនោះ ទាំងលោកិយ និងលោកុត្តរ អធិប្បាយថា ការដឹងក្នុងធម៌ទាំងឡាយសមគួរដល់អត្ថ, ក្នុងអត្ថទាំងឡាយ សមគួរដល់ធម៌, ក្នុងបញ្ញត្តិទាំងឡាយសមគួរដល់បញ្ញត្តិ ដោយវិស័យ (អារម្មណ៍) ដោយអសម្មោហៈ (ការមិនវង្វេង) ថា ការដែលធម៌ទាំងឡាយនោះៗ ដែលព្រះភគវាត្រាស់ទុកក្នុងទីនោះៗ ជាធម៌មិនវិបរិត ប្រព្រឹត្តទៅជាមួយនឹងលក្ខណៈដែលគប្បីត្រាស់ដឹងបាន ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបគម្ភីរភាពទាំង ៤ យ៉ាង ក្នុងបិដកទាំង ៣ នេះ បិដកនីមួយៗ ព្រោះក្នុងបិដកទាំងនោះ ធម៌ ឬអត្ថណាៗ ឬក៏ទេសនាដែលបំភ្លឺសេចក្តីនោះៗ ដោយប្រការដែលគួរដឹងសេចក្តីនៅត្រង់ចំពោះញាណរបស់អ្នកស្តាប់ដោយប្រការនោះៗ, ឬក៏ថា ការត្រាស់ដឹង ពោលគឺការដឹងច្បាស់នូវធម៌ដែលមិនមានវិបរិតក្នុងបិដកទាំង ៣ នេះណា ឬការដែលធម៌ទាំងឡាយនោះៗ ដែលមានសភាវៈមិនវិបរិត ពោលគឺកំណត់បាន ដែលគប្បីចាក់ធ្លុះនូវធម៌ទាំងអស់នោះ, អ្នកមានបញ្ញាតិចមិនបានសាងកុសលសម្ភារទុក ត្រាស់ដឹងបានដោយលំបាក ទាំងជាទីពឹងក៏មិនបាន ប្រៀបដូចសាគរសត្វតូចៗ មានទន្សាយជាដើម ចុះដល់បានដោយលំបាក, ទាំងនឹងជាទីពឹងមិនបានដូច្នោះ ។

ក៏ពាក្យមានប្រមាណប៉ុណ្ណេះ ដែលខ្ញុំពោលដល់សេចក្តីនៃគាថានេះថា ៖-

**“ទេសនាសាសនកថា ភេទន្តេសុ យថារហំ**

**សិក្ខាប្បហានគម្ភីរ ភាវញ្ច បរិទីបយេ ។**

បណ្ឌិតគប្បីសម្ដែងប្រភេទនៃទេសនា សាសនៈ កថា សិក្ខា បហានៈ និងគម្ភីរភាពក្នុងបិដកទាំង ៣ នេះ តាមសមគួរ ដោយប្រការដូច្នេះ” ។

តែក្នុងគាថាដែលថា ៖-

**“បរិយត្តិភេទំ សម្បត្តឹ វិបត្តិញ្ចាបិ យំ យហឹ**

**បាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។**

ភិក្ខុសម្រេចប្រភេទបរិយត្តិ សម្បត្តិ និងវិបត្តិណា ក្នុងបិដកណា ដោយប្រការណា, ក៏គប្បីចម្រើនសេចក្ដីនោះទាំងអស់ ដោយប្រការនោះ” ។

បណ្ឌិតគប្បីឃើញសេចក្ដីប្លែកគ្នានៃ **បរិយត្តិ** ៣ ក្នុងព្រះត្រៃបិដកនោះ ដូចតទៅនេះ ៖-

## សម្ដែងអំពីបរិយត្តិ ៣ ប្រភេទ

ពិតណាស់ បរិយត្តិមាន ៣ ប្រភេទគឺ

**១. អលគទ្ទូបមបរិយត្តិ** បរិយត្តិប្រៀបដូចអសិរពិសកាច

**២. និស្សរណត្ថបរិយត្តិ** បរិយត្តិដើម្បីត្រូវការរលាស់ខ្លួនចេញ

៣. **គទ្ធគារិតបរិយត្តិ** បរិយត្តិប្រៀបដូចនាយឃ្លាំង ។

បណ្ដាបរិយត្តិទាំងនោះ បរិយត្តិដែលរៀនមិនល្អ គឺរៀនដើម្បីហេតុនៃការប្រណាំងប្រជែងជាដើម ឈ្មោះថា **អលគទ្ទូបមបរិយត្តិ** ដែលព្រះភគវាទ្រង់សំដៅយកត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុរសអ្នកត្រូវការដោយពស់ តែងស្វែងរកពស់, កាលត្រាច់ដើររកពស់, បុរសនោះឃើញពស់ដ៏ធំ, ក៏ត្រូវចាប់ពស់នោះត្រង់ពពារ ឬត្រង់កន្ទុយ; ពស់នោះគួរចឹកត្រង់ដៃ ឬដើមដៃ ឬក៏ត្រង់អវយវៈតូចធំណាមួយរបស់បុរសនោះ; បុរសនោះ គួរដល់សេចក្ដីស្លាប់ ឬទុក្ខស្មើរស្លាប់ ព្រោះការចាប់នោះជាហេតុ; សេចក្ដីនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះពស់ដែលបុរសចាប់ហើយមិនល្អយ៉ាងណា; ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងឡាយពួកខ្លះ ក្នុងធម្មវិន័យនេះ ក៏យ៉ាងនោះដែរ, រមែងរៀនធម៌ គឺ សុត្តៈ ។ល។ វេទល្លៈ; មោឃបុរសទាំងឡាយនោះ លុះរៀនធម៌នោះហើយ មិនពិចារណាសេចក្ដីនៃធម៌ទាំងឡាយនោះដោយបញ្ញា, កាលមោឃបុរសនោះមិនពិចារណាអត្ថដោយបញ្ញា ចំពោះធម៌ទាំងឡាយនោះ មិនទ្រាំចំពោះការសំឡឹង (វិចារវិច័យ), មោឃបុរសទាំងឡាយនោះ មានការប្រណាំងប្រជែងជាអានិសង្ស និងមានការញុំាងខ្លួនឱ្យផុតអំពីវាទៈនោះៗ ជាអានិសង្ស ទើបរៀនធម៌ ។ ម្យ៉ាងរៀនធម៌ដើម្បីប្រយោជន៍ដល់ធម៌ណា, រមែងមិនសោយផលនៃធម៌នោះទេ ។ ពួកធម៌នោះ ដែលពួកមោឃបុរសនោះរៀនហើយមិនល្អ តែងប្រព្រឹត្តទៅ

ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលដ៏យូរ; សេចក្ដីនោះ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលមោឃបុរសរៀនហើយ មិនល្អឡើយ”[៣៣] ។

ចំណែកបរិយត្តិណាដែលបុគ្គលរៀនល្អហើយ គឺសង្ឃឹមនូវការបរិបូរណ៍នៃគុណមានសីលគុណជាដើម ហើយទើបរៀន, មិនមែនរៀនព្រោះការប្រណាំងប្រជែងជាដើមទេ បរិយត្តិនេះឈ្មោះថា **និស្សរណត្ថបរិយត្តិ** (រៀនត្រូវការដើម្បីរលាស់ចេញ) ដែលព្រះភគវាទ្រង់សំដៅយក ទើបត្រាស់ទុកថា ៖-

“ធម៌ទាំងនេះ ដែលពួកកុលបុត្រនោះរៀនល្អហើយ តែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលដ៏យូរ; សេចក្ដីនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះពួកធម៌ គឺកុលបុត្ររៀនល្អហើយ”[៣៤] ។

ឯព្រះខីណាស្រព អ្នកមានខន្ធកំណត់ដឹងហើយ លះកិលេសហើយ មានមគ្គដែលចម្រើនហើយ មានធម៌កម្រើកដែលចាក់ធ្លុះហើយ ធ្វើនិរោធឱ្យជាក់ច្បាស់ហើយ តែងរៀនព្រះបរិយត្តិណា ដើម្បីរក្សាប្រពៃណី ដើម្បីរក្សាវង្សតែម្យ៉ាង, បរិយត្តិនោះ ឈ្មោះថា **ភណ្ឌាគារិកបរិយត្តិ** (បរិយត្តិ

---

[៣៣] ម. មូ. ។

[៣៤] ច្បាប់ខ្លះថា ពាក្យនេះនឹងមិនប្រាកដ ។

ប្រៀបដូចនាយឃ្លាំង)[៣៥] បណ្ឌិតគួរជ្រាបប្រភេទនៃព្រះបរិយត្តិ ៣ ក្នុងព្រះត្រៃបិដកនោះដូចដែលពោលមកហើយ[៣៦] ៕

## សម្តែងអំពីសម្បត្តិ ៣ ប្រភេទ

ក៏ភិក្ខុអ្នកបតិបត្តិល្អហើយ (**សុប្បដិបន្នោ**) ក្នុងព្រះវិន័យអាស្រ័យសីលសម្បទា រមែងសម្រេចវិជ្ជា ៣ ក៏ត្រាស់ប្រភេទនៃវិជ្ជា ៣ ទាំងនោះៗ ឯង លោកត្រាស់ទុកក្នុងព្រះវិន័យនេះ ។ ភិក្ខុអ្នកបដិបត្តិល្អហើយ ក្នុងព្រះសូត្រ អាស្រ័យសមាធិសម្បទា រមែងសម្រេចអភិញ្ញា ៦ ក៏ព្រោះត្រាស់ប្រភេទនៃសមាធិទាំងនោះៗ ឯង លោកត្រាស់ទុកក្នុងព្រះសូត្រនោះ ។ ភិក្ខុអ្នកប្រតិបត្តិល្អហើយក្នុងព្រះអភិធម្ម អាស្រ័យបញ្ញាសម្បទា រមែងសម្រេចបដិសម្ភិទា ៤ ក៏ព្រោះត្រាស់ប្រភេទនៃបដិសម្ភិទាទាំងនោះៗ ឯង លោកត្រាស់ទុកក្នុងព្រះអភិធម្មនោះ ។ ភិក្ខុអ្នកប្រតិបត្តិល្អហើយ ក្នុងព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្មទាំងនេះ រមែងសម្រេចសម្បត្តិដែលផ្សេងដោយវិជ្ជា ៣ អភិញ្ញា ៦ និងបដិសម្ភិទា ៤ នេះដោយលំដាប់ មានប្រការដូច្នេះ ៕

---

[៣៥] ច្បាប់ខ្លះថា ពាក្យនេះនឹងមិនប្រាកដ ។

[៣៦] ម. មូ. ។

# សម្តែងអំពីវិបត្តិ ៣ ប្រភេទ

ចំណែកភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះវិន័យ ជាអ្នកមានសេចក្តីសំគាល់ថា មិនមានទោសក្នុងផស្សៈដែលមានចិត្តគ្រប់គ្រងជាដើម ដែលព្រះភគវាទ្រង់ហាមហើយ ដោយការស្មើដោយសម្ផស្ស ដែលមានគ្រឿងក្រាល និងគ្រឿងស្លៀកដណ្តប់ មានសម្ផស្សជាសុខជាដើម ដែលទ្រង់អនុញ្ញាតហើយ; ដូចពាក្យដែលព្រះអរិដ្ឋៈពោលថា "ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ, ដោយប្រការដែលធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយ, ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយនេះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពទេ"[៣៧] តអំពីនោះ គេក៏ដល់នូវភាពជាអ្នកទ្រុស្តសីល ។

ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះសូត្រ មិនដឹងពាក្យអធិប្បាយ ដូចក្នុងប្រយោគមានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ចំពូកទាំងនេះ មានប្រាដកក្នុងលោក"[៣៨] ទើបកាន់យកខុស ។ ដែលព្រះភគវាទ្រង់សំដៅយកត្រាស់ទុកថា ៖-

"បុគ្គលមានខ្លួនដែលកាន់យកខុស ពោលបង្កាច់តថាគតផង, ជីកគាស់ (ទម្លាយ) នូវខ្លួនឯងផង នឹងជួបប្រសព្វវត្ថុដែលមិនមែនជាបុណ្យ ដ៏

[៣៧] វិនយ.; ម. មូ. ។

[៣៨] អំ. ចតុក្ក. ។

ច្រើនផង”[៣៩] ។ តអំពីនោះទៅ គេក៏ដល់នូវភាពជាអ្នកមិច្ឆាទិដ្ឋិ ។

ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះអភិធម្ម និងវិចារធម៌ខ្លាំងពេក ក៏គិតនូវវត្ថុដែលមិនគួរគិត (អចិន្តេយ្យ), តអំពីនោះ គេក៏ដល់នូវភាពជាអ្នកមានចិត្តរវើរវាយ; សមដូចព្រះតម្រាស់ដែលព្រះភគវាត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ អចិន្តេយ្យទាំង ៤ នេះ បុគ្គលមិនគួរគិត, កាលដែលគិត ក៏គួរជាអ្នកមានចំណែកនៃភាពជាអ្នកឆ្កួត នៃការចង្អៀតចង្អល់”[៤០] ។

ភិក្ខុអ្នកបដិបត្តិខុសក្នុងព្រះត្រៃបិដកនេះ រមែងដល់នូវវិបត្តិដែលផ្សេងដោយភាពជាអ្នកទ្រុស្តសីល ជាអ្នកមិច្ឆាទិដ្ឋិ និងជាអ្នកមានចិត្តរវើរវាយនេះ ដោយលំដាប់ មានប្រការដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណោះ សូម្បីគាថានេះ ក៏ខ្ញុំពោលហើយថា ៖-

**“បរិយត្តិភេទំ សម្បត្តឹ វិបត្តិញ្ចាបិ យំ យហឹ**
**បាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។**

ភិក្ខុរមែងសម្រេចប្រភេទនៃបរិយត្តិ សម្បត្តិ និងវិបត្តិណា ក្នុងបិដកណា ដោយប្រការណា ក៏គួរចម្រើនសេចក្ដីនោះទាំងអស់ ដោយប្រការនោះ” ។

---

[៣៩] វិនយ. , ម. មូ. ។

[៤០] អំ. ចតុក្ក. ។

បណ្ឌិតគ្រាជ្រាបបិដកទាំងឡាយដោយប្រការផ្សេងៗ ដោយអាការយ៉ាងនេះហើយ គួរជ្រាបពុទ្ធវចនៈ សូម្បីទាំងអស់ដែលប្រមូលមកហើយដោយអំណាចនៃបិដកទាំងនោះថាជាបិដក ៣ ដូច្នេះ ។

## ពុទ្ធវចនៈមាន ៥ និកាយ

ព្រះពុទ្ធវចនៈសម្ដែងអំពីនិកាយមាន ៥ និកាយគឺអ្វីខ្លះ? ឆ្លើយថា ព្រះពុទ្ធវចនៈនោះសូម្បីទាំងអស់មាន ៥ និកាយ គឺទីឃនិកាយ មជ្ឈិម-និកាយ សំយុត្តនិកាយ, អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ។

## សម្ដែងអំពីទីឃនិកាយ ៣៤ សូត្រ

បណ្ដានិកាយទាំង ៥ នោះ **ទីឃនិកាយ** តើដូចម្ដេច? ព្រះសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម រួបរួមជា ៣ វគ្គ ហៅថា **ទីឃនិកាយ;** ដូចគាថាដែលលោកប្រព័ន្ធទុកថា ៖-

**“ចតុត្តឹសេវ សុត្តន្តា តិវគ្គោ យស្ស សង្គហោ**
**ឯស ទីឃនិកាយោតិ បឋមោ អនុលោមិកោ ។**

ព្រះសូត្រ ៣៤ សូត្រប៉ុណ្ណោះ មាន ៣ វគ្គ លោករួបរួមទុកសម្រាប់និកាយណា និកាយនោះ ឈ្មោះថា ទីឃនិកាយ រាប់តាម

**លំដាប់ជានិកាយទី ១" ។**

**សួរថា** ព្រោះហេតុអ្វី និកាយទី ១ នេះ ទើបហៅថា ទីឃនិកាយ?

**ឆ្លើយថា** ព្រោះជាទីប្រជុំ និងជាទីអាស្រ័យនៃសូត្រទាំងឡាយ មានប្រមាណវែង ។

ពិតណាស់ ទីជាទីប្រជុំ ឬទីជាទីអាស្រ័យនៅក៏ហៅថា **និកាយ** ។ ក៏ក្នុងខនេះមានពាក្យសាធកៈ (តួយ៉ាង) ផ្លូវសាសនាផង, ផ្លូវលោកផង ដូចក្នុងប្រយោគមានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនពិចារណាឃើញសូម្បីនូវនិកាយមួយដែលវិចិត្រ ដូចសត្វតិរច្ឆាននេះ គឺនិកាយរបស់សត្វតូចៗដែលរួមគ្នាហើយ ១, និកាយរបស់សត្វដែលនៅក្នុងភក់ ១"[៤១] ។ ក៏គួរជ្រាបសេចក្តីនៃពាក្យសម្ពីក្នុងនិកាយ (៤ និកាយ) ដែលសេស ដោយប្រការដែលពោលមកហើយ ៕

## សម្តែងអំពីមជ្ឈិមនិកាយ ១៥២ សូត្រ

**មជ្ឈិមនិកាយ** តើដូចម្តេច? ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម លោករួបរួមទុក ១៥ វគ្គ ជាព្រះសូត្រប្រមាណ (ខ្នាត) កណ្តាល ឈ្មោះថា **មជ្ឈិមនិកាយ** ដូចគាថាដែលលោកប្រព័ន្ធទុកថា ៖-

---

[៤១] សំ. ខ. ។

**“ទិយឌ្ឍសតសុត្តន្តា ទ្វេ ច សុត្តានិ យត្ថ សោ**
**និកាយោ មជ្ឈិមោ បញ្ច ទសវគ្គបរិគ្គហោ ។**

ព្រះសូត្រ ១៥២ សូត្រ មានក្នុងនិកាយណា និកាយនោះ ឈ្មោះថា មជ្ឈិមនិកាយ លោករួបរួមទុក ១៥ វគ្គ” ៕

## សម្ដែងអំពីសំយុត្តនិកាយជាដើម

**សំយុត្តនិកាយ** តើដូចម្ដេច? ព្រះសូត្រ ៧.៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ដែលតាំងទុកដោយអំណាចនៃទេវតាសំយុត្តជាដើមហៅថា **សំយុត្តនិកាយ** ដូចគាថាដែលលោកប្រព័ន្ធទុកថា ៖-

**“សត្ត សុត្តសហស្សានិ សត្ត សុត្តសតានិ ច**
**ទ្វាសដ្ឋិ ចេវ សុត្តន្តា ឯសោ សំយុត្តសង្គហោ ។**

ព្រះសូត្រ ៧.៧៦២ សូត្រ មានក្នុងនិកាយណា, និកាយនោះ លោករួបរួមទុកជា **សំយុត្តនិកាយ**” ។

**អង្គុត្តរនិកាយ** តើដូចម្ដេច? ព្រះសូត្រ ៩.៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ដែលតាំងទុកដោយអំណាចនៃពាក្យពេចន៍លើសមួយកន្លែង ចំណែកមួយៗ ឡើងទៅម្ដងមួយៗ ដូចគាថាដែលប្រព័ន្ធទុកថា ៖-

**“នវ សុត្តសហស្សានិ បញ្ច សុត្តសតានិ ច**
**សត្តបញ្ញាស សុត្តានិ សំខ្យា អង្គុត្តរេ អយំ ។**

ព្រះសូត្រក្នុងអង្គុតរនិកាយចំនួន ៩.៥៥៧ សូត្រ មានក្នុងនិកាយណា, និកាយនោះ ឈ្មោះថា អង្គុត្តរនិកាយ” ។

**ខុទ្ទកនិកាយ** តើដូចម្តេច? គឺវិនយបិដក អភិធម្មបិដក និងបាឋៈ ១៥ ប្រភេទមានធម្មបទខុទ្ទកបាឋៈជាដើមទាំងអស់ ដែលសម្តែងទុកមុនហើយ វៀរព្រះពុទ្ធវចនៈដែលសេស គឺនិកាយ ៤ (មានទីឃនិកាយជាដើម) ឈ្មោះថា ខុទ្ទកនិកាយ ។ ដូចគាថាដែលលោកប្រព័ន្ធទុកថា ៖-

**ឋបេត្វា ចតុរោបេតេ និកាយេ ទីឃអាទិកេ**

**តទញ្ញំ ពុទ្ធវចនំ និកាយោ ខុទ្ទកោ មតោ ។**

លើកលែង ៤ និកាយ មានទីឃនិកាយជាដើមនេះ ព្រះពុទ្ធវចនៈដទៃអំពីនោះ មានហើយដល់និកាយណា, និកាយនោះ បណ្ឌិតហៅថា ខុទ្ទកនិកាយ។

និកាយ ៥ យ៉ាង មានដោយអំណាចនៃនិកាយយ៉ាងនេះ ៕

## ព្រះពុទ្ធវចនៈមានអង្គ ៩

ព្រះពុទ្ធវចនៈមានអង្គ ៩ តើអ្វីខ្លះ? សេចក្តីថា ក៏ព្រះពុទ្ធវចនៈទាំងអស់នេះមាន ៩ ប្រភេទ គឺ សុត្តៈ, គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទាន, ឥតិវុត្តកៈ, ជាតក, អព្ភូតធម្មៈ និងវេទល្លៈ ។

បណ្តាអង្គ ៩ នោះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារៈ ព្រះសូត្រក្នុងសុត្តនិបាត មានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និងតុវដ្ដកសូត្រជាដើម និងព្រះតម្រាស់របស់ព្រះតថាគត សូម្បីដទៃដែលមានឈ្មោះថា សុត្តន្តៈ (ទាំងនេះ) គប្បីជ្រាបថាជា **សុត្តៈ** ។ ក៏ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថាជា **គេយ្យៈ**; សម្តែងដោយពិស្តារ បានដល់សគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយជា **គេយ្យៈ** ។ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដទៃដែលមិនមានការប្រកបដោយអង្គ ៨ គប្បីជ្រាបថាជា **វេយ្យាករណ** ។ **ធម្មបទ ថេរគាថា ថេរីគាថា** និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថា សូត្រក្នុងសុត្តនិបាត គប្បីជ្រាបថាជា **គាថា** ។ ព្រះសូត្រ ៨២ សូត្រដែលបដិសំយុត្ត ដោយគាថាដែលសម្រេចដោយសោមនស្សញ្ញាណ គប្បីជ្រាបថាជា **ឧទាន** ។ ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា “**វុត្តញ្ហេតំ ភគវតា** = ដ្បិតព្រះភគវាទ្រង់ត្រាស់ព្រះតម្រាស់នេះ”[៤២] គប្បីជ្រាបថាជា **ឥតិវុត្តកៈ** ។ ជាតក ៥៥០ ជាតក មានអបណ្ណកជាតកជាដើម គប្បីជ្រាបថាជា **ជាតក** ។ ព្រះសូត្រដែលប្រកបដោយអច្ឆរិយៈ និងអព្ភូតធម្មទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា “ម្នាលភិក្ខុទាំងឡាយ អព្ភូតធម្មដ៏គួរអស្ចារ្យ ៤

---

[៤២] ខុ. ឥតិ. ។

ប្រការនេះ មានហើយក្នុងព្រះអានន្ទ”[៤៣] គប្បីជ្រាបថាជា **អព្ភុតធម្ម** ។ ព្រះសូត្រដែលមានអ្នកទូលសួរហើយបាននូវសេចក្ដីដឹង និងសេចក្ដីត្រេកអរទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កប្បញ្ហាសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថាជា **វេទល្លៈ** ។ កាលសម្ដែងអំពីអង្គ ព្រះពុទ្ធវចនៈមានអង្គ ៩ ដោយប្រការដូច្នេះ ៕

## ព្រះពុទ្ធវចនៈ ៨៤.០០០ ព្រះធម្មក្ខន្ធ

ព្រះពុទ្ធវចនៈ ៨៤.០០០ ព្រះធម្មក្ខន្ធ គឺអ្វីខ្លះ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នេះឯងមាន ៨៤.០០០ ប្រភេទ ដោយអំណាចនៃធម្មក្ខន្ធដែលព្រះអានន្ទរួបរួមទុកយ៉ាងនេះថា ៖-

**“ទ្វាសីតិ ពុទ្ធតោ គណ្ហិ[៤៤] ទ្វេ សហស្សានិ ភិក្ខុតោ**
**ចតុរាសីតិសហស្សានិ យេ មេ ធម្មា បវត្តិនោ ឱ**

**ធម៌ទាំងឡាយដែលតម្កល់នៅហើយ (ក្នុងខ្លួន) របស់ខ្ញុំដែលរៀនមកអំពីព្រះពុទ្ធជាម្ចាស់ ៨២.០០០ អំពីព្រះភិក្ខុ ២.០០០ រួមជា**

---

[៤៣] ទី. មហា. ១៦, អំ. ចតុក្ក. ។

[៤៤] ច្បាប់ខ្លះថា គណ្ហឹ. ។

៨៤.០០០ ព្រះធម្មក្ខន្ធ”[៤៥] ។

បណ្ដាព្រះពុទ្ធវចនៈទាំងនោះ ព្រះសូត្រមានអនុសន្ធិ ១ ហៅថា ធម្មក្ខន្ធ ១ ។ ព្រះសូត្រណាមានច្រើនអនុសន្ធិ, ក៏រាប់ចំនួនធម្មក្ខន្ធតាមអនុន្ធិក្នុងព្រះសូត្រនោះ ។ ក្នុងការប្រព័ន្ធជាគាថា ការសួរបញ្ហាជាធម្មក្ខន្ធ ១, ការវិស្សជ្ជនា ក៏ជាធម្មក្ខន្ធ ១ ។ ក្នុងព្រះអភិធម្ម ការចែកតិកៈ និងទុកៈមួយពួកៗ និងការចែកវារចិត្តមួយយ៉ាងៗ (១ ដួងៗ) ក៏ជាធម្មក្ខន្ធ ១ ។ ក្នុងព្រះវិន័យមានវត្ថុ, មាតិកា, បទភាជនីយ៍, អាបត្តិ, អនាបត្តិ, អន្តរាបត្តិ, ការកំណត់តិកៈ, ធម៌ដែលជាអតេកិច្ឆៈ, ដែលជាសតេកិច្ឆៈ; ក្នុងវត្ថុជាដើមនេះ មួយភាគៗ គប្បីជ្រាបថាជា ១ ធម្មក្ខន្ធៗ ។ សម្ដែងអំពីព្រះធម្មក្ខន្ធគប្បីជ្រាបថាជាព្រះធម្មក្ខន្ធ ៨៤.០០០ ដោយអាការយ៉ាងនេះ ៕

## ព្រះពុទ្ធវចនៈក្នុងវេលាធ្វើបឋមសង្គីតិ

ព្រះពុទ្ធវចនៈទាំងអស់នោះ ដោយប្រការតាមដែលពោលហើយនោះឯង គឺពួកសង្ឃអ្នកមានវសី **មានព្រះមហាកស្សប** ជាប្រធាន កាលសង្គាយនា ក្នុងការធ្វើបញ្ចសតិកសង្គីតិ បានសង្គាយនាកំណត់ប្រភេទច្បាស់លាស់ថា “នេះជាធម៌, នេះជាវិន័យ, នេះជាបឋមពុទ្ធវចនៈ, នេះជាមជ្ឈិមពុទ្ធវចនៈ,

---

[៤៥] ខុ. ថេរ. ។

នេះជាបច្ឆិមពុទ្ធវចនៈ, នេះជាវិនយបិដក, នេះជាសុត្តន្តបិដក, នេះជាអភិធម្មបិដក, នេះជាទីឃនិកាយ ។ល។ នេះជាខុទ្ទកនិកាយ, ទាំងនេះជានវង្គសត្ថុសាសនៈដែលមានសុត្តៈជាដើម, ទាំងនេះជាធម្មក្ខន្ធមាន ៨៤.០០០ ព្រះធម្មក្ខន្ធ" ។ ម្យ៉ាងទៀត ព្រះថេរៈទាំងនោះមិនបានកំណត់ត្រឹមតែប្រភេទដែលពោលនេះប៉ុណ្ណោះទេ, សូម្បីបានកំណត់ប្រភេទសង្គហៈដទៃៗ ដែលប្រាកដហើយ ក្នុងព្រះត្រៃបិដក មិនមែនតិច មានជាអាទិ៍ដូចឧទានសង្គហៈ (ពួកឧទាន) វគ្គសង្គហៈ បេយ្យាលសង្គហៈ និបាតសង្គហៈ ពួកនិបាត មានឯកនិបាត ទុកនិបាតជាដើម សំយុត្តសង្គហៈ និងបណ្ណាសសង្គហៈជាដើម សង្គាយនាហើយ យ៉ាងនេះអស់ ៧ ខែ ។

ក៏ក្នុងអវសាននៃសង្គាយនាព្រះពុទ្ធវចនៈនោះ មហាបឋវីនេះបានញាប់ញ័រ រញ្ជួយ កក្រើក មានប្រការមិនតែមួយ ចុះទៅដល់ទឹកទ្រផែនដីជាទីបំផុត ហាក់ដូចមានសេចក្ដីរីករាយកើតឡើងព្រម ហើយឱ្យសាធុការថា "ចូរមើលសាសនានៃព្រះទសពលនេះ ដែលព្រះមហាកស្សបត្ថេរធ្វើឱ្យអាចដើម្បីប្រព្រឹត្តទៅអស់កាលប្រមាណ ៥.០០០ ឆ្នាំ" ។ ថែមទាំងបានកើតមហស្ចារ្យទាំងឡាយដោយអនេកប្បការ ៕

## សម្ដែងដោយចំពោះព្រះអភិធម្ម

ក៏ក្នុងបិដកនេះ កាលព្រះថេរៈទាំងឡាយ សង្គាយនាព្រះពុទ្ធវចនៈ

ហើយយ៉ាងនេះ ព្រះអភិធម្មនេះ កាលសម្ដែងអំពីបិដកជា **អភិធម្មបិដក**, កាលសម្ដែងអំពីនិកាយជា **ខុទ្ទកនិកាយ**, កាលសម្ដែងអំពីអង្គជា **វេយ្យាករណ**, កាលសម្ដែងអំពីធម្មក្ខន្ធ ជា **ធម្មក្ខន្ធ** ច្រើនពាន់ធម្មក្ខន្ធ (៨២.000 ធម្មក្ខន្ធ) ។ បណ្ដាភិក្ខុទាំងឡាយអ្នកទ្រទ្រង់ព្រះអភិធម្មនោះ ក្នុងកាលមុន មានភិក្ខុមួយរូបអង្គុយនៅក្នុងទីប្រជុំបរិស័ទកាលនាំសូត្រអំពីព្រះអភិធម្មមក បានពោលធម្មកថាដូច្នេះថា "រូបក្ខន្ធជាអព្យាកតៈ, ខន្ធ ៤ ជាកុសលក៏មាន ជាអកុសល ជាអព្យាកតៈក៏មាន ។ អាយតនៈ ១០ ជាអព្យាកតៈ, អាយតនៈ ២ ជាកុសលក៏មាន, ជាអកុសលក៏មាន, ជាអព្យាកតៈក៏មាន, ធាតុ ១៦ ជាអព្យាកតៈ, ធាតុ ២ ជាកុសលក៏មាន, ជាអកុសលក៏មាន, ជាអព្យាកតៈ ក៏មាន ។ សមុទយសច្ចជាអកុសល, និរោធសច្ចជាអព្យាកតៈ, ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ ឥន្ទ្រិយ ១០ ជាអព្យាកតៈ, ទោមនស្សិន្ទ្រិយជាកុសល, អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ជាកុសល, ឥន្ទ្រិយ ៤ ជាកុសលក៏មាន, ជាអព្យាកតៈក៏មាន, ឥន្ទ្រិយ ៦ ជាកុសល ក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន" ។

ភិក្ខុមួយរូប ដែលអង្គុយនៅក្នុងទីនោះ បានសួរព្រះធម្មកថិកថា "ម្នាលលោកធម្មកថិក អ្នកនាំសូត្រមកវែង ដូចយកមកព័ទ្ធភ្នំសិនេរុ, សូត្រនេះ មានឈ្មោះថាអ្វី?" ។

**ធម្មកថិក** : ឈ្មោះថាអភិធម្មសូត្រ អ្នកមានអាយុ ។

**ភិក្ខុនោះ** : ព្រោះហេតុអ្វី បាននាំអភិធម្មសូត្រមក,ការនាំព្រះសូត្រដទៃដែលជាពុទ្ធភាសិតមកមិនសមគួរឬ ?

**ធ.** : ព្រះអភិធម្ម លោកពោលទុកហើយ

**ភិ.** : ព្រះអភិធម្មនេះ មិនមែនពុទ្ធភាសិតទេ ។

**ធ.** : ម្នាលអ្នកមានអាយុ តើអ្នកបានរៀនព្រះវិនយបិដកឬទេ?

**ភិ.** : ម្នាលលោក ខ្ញុំមិនបានរៀនទេ ។

**ធ.** : ប្រហែលជាអ្នកមិនទ្រទ្រង់ព្រះវិន័យទេដឹង កាលបើមិនដឹងទើបពោលយ៉ាងនេះ ។

**ភិ.** : ខ្ញុំរៀនតែព្រះវិន័យប៉ុណ្ណោះទេលោក ។

**ធ.** : សូម្បីព្រះវិន័យនោះ ក៏រៀនមិនល្អដែរ, គង់នឹងអង្គុយខាងក្រោយនៃបរិស័ទ ឬថា ព្រោះព្រះឧបជ្ឈាយ៍អ្នកឱ្យបុគ្គលដូចអ្នក បួសឧបសម្បទាប្រញាប់ពេកណាស់ ។ ព្រោះហេតុអ្វី? ព្រោះសូម្បីគ្រាន់តែព្រះវិន័យ

លោកក៏រៀនមិនល្អដែរ ។ ពិតណាស់ ព្រះភគវន្តមុនីត្រាស់តម្រាស់នេះ ក្នុងព្រះវិន័យនោះថា "ភិក្ខុអ្នកមិនចង់តិះដៀល ពោលតាមហេតុថា 'និមន្តលោករៀនព្រះសូត្រ រៀនគាថាទាំងឡាយ ឬរៀនអភិធម្មជាមុនសិន, ខាង

ក្រោយនឹងរៀនព្រះវិន័យ’[៤៦] ក៏មិនជាអាបត្តិ, សូម្បីតែពាក្យថា ភិក្ខុសូមឱកាសសួរបញ្ហាក្នុងព្រះសូត្រ តែត្រឡប់សួរអភិធម្ម ឬវិន័យ; សូមឱកាសសួរបញ្ហាក្នុងអភិធម្ម តែត្រឡប់សួរព្រះសូត្រ ឬវិន័យ; សូមឱកាសសួរបញ្ហាក្នុងវិន័យ, តែត្រឡប់សួរព្រះសូត្រ ឬអភិធម្ម”[៤៧] មានប្រមាណប៉ុណ្ណោះ លោកក៏មិនដឹងព្រះធម្មកថិកនោះ ទើបជាអ្នកគ្របសង្កត់បរវាទីបាន ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ក៏មហាគោសិង្គសូត្រ ជាសូត្រសំខាន់នេះ ព្រោះហេតុតែជាពុទ្ធភាសិត; ពិតណាស់ ក្នុងមហាគោសិង្គសូត្រនោះ **ព្រះធម្មសេនាបតីសារីបុត្តត្ថេរ** ទៅគាល់ព្រះភគវា ដើម្បីក្រាបទូលបញ្ហាដែលសួរ និងពាក្យឆ្លើយនូវគ្នានឹងគ្នា, កាលនឹងប្រាប់ពាក្យឆ្លើយរបស់ព្រះមហាមោគ្គល្លានត្ថេរ ទើបក្រាបទូលថា “ព្រះមហាមោគ្គល្លានត្ថេរពោលថា ‘សារីបុត្រ ភិក្ខុពីររូបក្នុងធម្មវិន័យនេះ ពោលអភិធម្មកថា, អ្នកទាំងពីររូបនោះ រមែងសួរបញ្ហាគ្នាហើយ, រមែងជួយដោះស្រាយគ្នា, មិនទាស់ទែងគ្នា, ឯធម្មីកថារបស់អ្នកទាំងពីរនោះ តែងប្រព្រឹត្តទៅបានល្អ ។ សារីបុត្រ ព្រៃគោសិង្គសាលវ័ន តែងរុងរឿង

---

[៤៦] វិនយ.។

[៤៧] ម. មូ. ។

ដោយភិក្ខុរូបនោះឯង”[៤៧] ។

ព្រះសាស្តាមិនត្រាស់ថា “ធម្មតាអ្នកទ្រទ្រង់អភិធម្ម ជាអ្នកនៅខាងក្រៅសាសនានៃតថាគត” , តែទ្រង់លើកសូរងឡើង ដូចព្រះសុវណ្ណាភិង្គារ (ចង្ក្រានមាស) កាលញ៉ាំងសេចក្តីឱ្យសម្បូណ៌ ដោយព្រះឱដ្ឋ (ឱស្ឋ) ដ៏មានសិរី ដូចព្រះចន្ទពេញបូណ៌មី ទើបទ្រង់បន្លឺព្រះសូរសៀងលាន់រន្ទឺដូចសំឡេងនៃព្រហ្ម ប្រទានសាធុការដល់ព្រះមហាមោគ្គល្លានត្ថេរថា “ល្អហើយៗ សារីបុត្រ” ហើយត្រាស់ថា “ម្នាលមោគ្គល្លាន ក៏កាលនឹងព្យាករដោយប្រពៃ ក៏គប្បីព្យាករតាមនោះចុះ, ម្នាលសារីបុត្រ ព្រោះថា មោគ្គល្លានជាធម្មកថិក”[៤៨] ៕

## ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មឈ្មោះថាធម្មកថិក

ពិតណាស់ បានឮថា ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មប៉ុណ្ណោះ ឈ្មោះថាជាព្រះធម្មកថិក, ក្រៅពីនេះ សូម្បីពោលធម៌ ក៏មិនមែនជាធម្មកថិកឡើយ ។ ព្រោះហេតុអ្វី? ព្រោះថា ភិក្ខុអ្នកមិនទ្រទ្រង់ព្រះអភិធម្មទាំងនោះ កាលពោលធម៌តែងពោលតាមលំដាប់កម្ម លំដាប់វិបាក កំណត់រូបារូប ធ្វើលំដាប់ធម៌ ឱ្យច្រឡូកច្រឡំ? ចំណែកភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម មិនឱ្យលំដាប់

---

[៤៧] ម. មូ. ។

[៤៨] ម. មូ. ។

ធមិច្រឡូកច្រឡំគ្នាទេ ។ ព្រោះហេតុដូច្នោះ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មនឹងពោលធមិ ឬមិនបានពោលក៏ដោយ, តែក្នុងកាលដែលគេសួរបញ្ហាហើយ ក៏នឹងពោលដោះស្រាយបញ្ហានោះបាន ព្រះសាស្តាទ្រង់សំដៅដល់ពាក្យនេះថា "ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មប៉ុណ្ណោះ ឈ្មោះថា ធម្មកថិក ដោយចំណែកមួយ" ទើបទ្រង់ប្រទានសាធុការហើយត្រាស់ថា "មោគ្គល្លានពោលល្អហើយ" ។

## អ្នកជំទាស់ព្រះអភិធម្មឈ្មោះថាឧម្លាយជិនចក្រ

បុគ្គលកាលជំទាស់ព្រះអភិធម្ម ឈ្មោះថា រមែងឱ្យការប្រហារ នៅក្នុងជិនចក្រ (ចក្រនៃព្រះជិនស្រី) នេះ, រមែងជំទាស់ព្រះសព្វញ្ញុតញ្ញាណ, រមែងមើលងាយ វេសារជ្ជញ្ញាណរបស់ព្រះសាស្តា, រមែងជំទាស់បរិស័ទអ្នកត្រូវការស្តាប់, រមែងចងគ្រឿងរារាំងអរិយមគ្គ នឹងប្រាកដក្នុងភេទករវត្ថុ ១៨ យ៉ាង យ៉ាងណាមួយ, ជាអ្នកគួរដល់ឧក្ខេបនីយកម្ម និយស្សកម្ម តជ្ជនីយកម្ម, ព្រោះធ្វើកម្មនោះៗ និងគួរបញ្ជូនលោកទៅថា "លោកចូរទៅ ចូរជាមនុស្សស៊ីដែលរស់នៅចុះ"៕

## ព្រះអភិធម្មមាននិទានឬទេ?

សូម្បីបុគ្គលគប្បីពោលយ៉ាងនេះថា "បើសិនព្រះអភិធម្មជាពុទ្ធភាសិតសោត, សូម្បីនិទានរបស់ព្រះអភិធម្មនុ៎ះ ក៏គួរចាត់ជាព្រះអភិធម្មផង" ; ដូចនិទានដែលលោកចាត់ទុកច្រើនពាន់ព្រះសូត្រ ដោយន័យមានជាអាទិ៍ថា "សម័យមួយព្រះមានព្រះភាគជាម្ចាស់ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ" ។ គប្បីជំទាស់អ្នកនោះថា "និទានរបស់ជាតក, សុត្តនិបាត និងធម្មបទជាដើមមានសភាពបែបនេះ ក៏មិនមាន, ធម៌ពួកនេះ ក៏មិនមែនជាពុទ្ធភាសិតទេ" , ហើយគប្បីប្រាប់សូម្បីឱ្យក្រៃលែងជាងនេះ ដោយអាការយ៉ាងនេះថា "ម្នាលបណ្ឌិត ធម្មតាគាថា ព្រះអភិធម្មនេះ ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ, មិនមែនជាវិស័យរបស់មនុស្សពួកដទៃ ។ ពិតមែន ការយាងចុះកាន់ព្រះគភ៌នៃព្រះពុទ្ធជាម្ចាស់ទាំងឡាយប្រាកដហើយ, អភិជាតិក៏ប្រាកដ, អភិសម្ពោធិក៏ប្រាកដ, ធម្មចក្កប្បវត្តនៈក៏ប្រាកដ, យមកប្បាដិហារ្យ ក៏ប្រាកដ, ការស្ដេចទៅកាន់ទីនៅរបស់ទេវតា ក៏ប្រាកដ, ការសម្ដែងធម៌ក្នុងទេវលោកក៏ប្រាកដ, ការស្ដេចចុះចាកទេវលោក ក៏ប្រាកដ ។

ដែលឈ្មោះថា ការលួចដំរីកែវ ឬសេះកែវរបស់ស្ដេចចក្រពត្តិហើយទឹមយានតូចទៅនោះ មិនមែនឋានៈ មិនមែនហេតុ, ឬឈ្មោះថា ការលួចចក្ករតនៈ ហើយព្យួរទុកត្រង់រទេះផ្ទុកចំបើងយកទៅ មិនមែនឋានៈ, មិន

មែនហេតុដែលប្រព្រឹត្តទៅបាន, ឬថា ឈ្មោះថា ការលួចកែវមណីដែលអាចផ្លុះបញ្ចាំងទីឆ្ងាយប្រមាណ ១ ប្រយោជន៍ដាក់ទុកក្នុងប្រអប់ ហើយប្រើប្រាស់ក៏មិនមែនឋានៈ, មិនមែនហេតុដែលប្រព្រឹត្តទៅបាន ។ ព្រោះហេតុអ្វី? ព្រោះជាភណ្ឌៈសមគួរដល់ស្តេចចក្រពត្តិ ខនេះយ៉ាងណា ។ ធម្មតាព្រះអភិធម្ម ក៏ដូច្នោះដែរ មិនមែនវិស័យរបស់ជនពួកដទៃ **ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ប៉ុណ្ណោះ**; ឯទេសនា ក៏ជាទេសនាទ្រង់សម្តែងទុកដោយអំណាចនៃព្រះសព្វញ្ញុពុទ្ធជាម្ចាស់ប៉ុណ្ណោះ ។ ពិតមែន ការយាងចុះកាន់ព្រះគភ៌របស់ព្រះពុទ្ធទាំងឡាយប្រាកដហើយ ។ ល ។ កាលស្តេចចុះចាកទេវលោកក៏ប្រាកដ; ម្នាលបណ្ឌិត ដែលឈ្មោះថា កិច្ចដោយនិទានរបស់ព្រះអភិធម្មរមែងមិនមាន” ដោយប្រការដូច្នេះ ។ ក៏កាលពោលយ៉ាងនេះហើយ បរវាទីក៏មិនអាចនឹងលើកឧទាហរណ៍ដែលប្រកបដោយសហធម៌ មកឆ្លើយតបបានទេ ៕

## សម្តែងអំពីព្រះអភិធម្មមាននិទាន

ចំណែកព្រះតិស្សគុត្តត្ថេរ [៤៩] អ្នកនៅក្នុងមណ្ឌលារាម បាននាំ **បទេសវិហារសូត្រ** នេះមកពោលថា “ព្រះមានព្រះភាគត្រាស់ទុកថា

[៤៩] ច្បាប់ខ្លះថា តិស្សភូតិត្ថេរ ។

ម្នាលភិក្ខុទាំងឡាយ តថាគតត្រាស់ដឹងគ្រាដំបូងនុ៎ះ នៅដោយធម៌ជាគ្រឿងនៅចំណែកណា, តថាគតក៏នៅដោយបទេសៈ គឺចំណែកនៃធម៌នោះដែរ" [៥០] គប្បីសម្តែងថា "ព្រះអភិធម្មនេះ មានមហាពោធិជានិទាន"។

ពិតមែន ឈ្មោះថា បទេសៈ (ក្នុងបទេសសូត្រ) មាន ១០ យ៉ាង គឺ

ខន្ធបទេស, **អាយតនបទេស**, ធាតុបទេស, សច្ចបទេស, ឥន្ទ្រិយបទេស, បច្ចយាការបទេស, សតិប្បដ្ឋានបទេស, ឈានបទេស, នាមបទេស និង ធម្មបទេស ។ បណ្តាបទេសទាំង ១០ នេះ គប្បីជ្រាបដូចតទៅ នេះ ៈ-

ព្រះសាស្តាទ្រង់សម្រេចបញ្ចក្ខន្ធដោយសព្វគ្រប់ (និប្បទេស) ក្រោមដើមមហាពោធិ៍, ហើយទ្រង់គង់ដោយវេទនាខន្ធនោះឯងអស់ត្រៃមាសនេះ; ទ្រង់សម្រេចអាយតនៈ ១២, ធាតុ ១៨, ដោយសព្វគ្រប់, ហើយទ្រង់គង់នៅដោយអំណាចនៃវេទនាក្នុងធម្មាយតនៈ និងដោយអំណាចនៃវេទនាក្នុងធម្មធាតុនោះឯង គង់ដោយអំណាចវេទនាក្នុងទុក្ខសច្ចនោះឯងអស់ត្រៃមាសនេះ; ទ្រង់ចាក់ធ្លុះឥន្ទ្រិយ ២២ ដោយសព្វគ្រប់, ហើយទ្រង់គង់ដោយអំណាចនៃឥន្ទ្រិយក្នុងពួក ៥ នៃវេទនាអស់ត្រៃមាសនេះ; ទ្រង់សម្រេចការត្រឡប់នៃបញ្ចយាការ ១២ បទ ដោយសព្វគ្រប់, ហើយប្រថាប់នៅដោយវេទនា មានផស្សៈជាបច្ច័យអស់ត្រៃមាសនេះ; ទ្រង់ដល់សតិប្បដ្ឋាន ៤ ដោយសព្វគ្រប់

[៥០] សំ. ម. ។

ហើយ ប្រថាប់នៅដោយអំណាចនៃវេទនាសតិប្បដ្ឋាន អស់ត្រៃមាសនេះ; ទ្រង់សម្រេចឈាន ៤ ដោយសព្វគ្រប់, ទ្រង់ប្រថាប់នៅដោយអំណាចនៃវេទនាក្នុងអង្គឈាននោះឯង អស់ត្រៃមាសនេះ; ទ្រង់សម្រេចនាមដោយសព្វគ្រប់, ហើយប្រថាប់នៅដោយអំណាចនៃវេទនាក្នុងនាមនុ៎ះឯងអស់ត្រៃមាសនេះ; ទ្រង់សម្រេចធម៌ទាំងឡាយដោយសព្វគ្រប់, ហើយគង់នៅដោយអំណាចនៃវេទនាតិកៈនោះឯងអស់ត្រៃមាសនេះ" ។ ព្រះថេរៈពោលនិទាននៃព្រះអភិធម្មដោយអំណាចនៃ**បទេសវិហារសូត្រ**ទុកយ៉ាងនេះ ។

ចំណែកព្រះសុធម្មទេវត្ថេរ [៥១] អ្នកនៅក្នុងគាមវាសី កាលបកប្រែធម៌ [៥២] ក្នុងលោហប្រាសាទជាន់ខាងក្រោម ពោលទុកថា "បរវាទីបុគ្គលនេះដូចផ្គងដើមដៃទាំងពីរកន្ទក់កន្ទេញនៅក្នុងព្រៃ និងដូចសាងក្ដីដែលមិនមានសាក្សី ទើបមិនជ្រាបសូម្បីព្រះអភិធម្មថា មាននិទាន" ហើយពោលយ៉ាងនេះទៀតថា "សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបរិច្ឆត្តកៈក្នុងឋានសួគ៌ជាន់តាវត្តិង្ស, ក្នុងសម័យនោះឯងព្រះភគវាទ្រង់ត្រាស់អភិធម្មកថា ដល់ពួកទេវតាជាន់តាវត្តិង្សថា "**កុសលា ធម្មា, អកុសលា ធម្មា, អព្យាកតា ធម្មា**" ជាដើម ។ ចំណែកក្នុង

---

[៥១] ច្បាប់ខ្លះថា សុមនទេវត្ថេរ ។

[៥២] មូលដិ. បានដល់ បាលី និងអដ្ឋកថា ។

ព្រះសូត្រដទៃៗ ក៏មាននិទានតែមួយគត់[៥៣] ៕

## ព្រះអភិធម្មមាននិទាន ២ យ៉ាង

ក្នុងព្រះអភិធម្ម មាននិទាន ២ យ៉ាង គឺ **អធិគមនិទាន** និង **ទេសនានិទាន** ។ បណ្តានិទានទាំង ២ នុ៎ះ **អធិគមនិទាន** គប្បីជ្រាបតាំងអំពីព្រះទសពល ព្រះនាមថា **ទីបង្ករ** រហូតដល់ព្រះមហាពោធិបល្លង្ក; **ទេសនានិទាន** គប្បីជ្រាបរហូតដល់ការប្រកាសព្រះធម្មចក្ក ។ ដើម្បីភាពជាអ្នកឆ្លាតក្នុងនិទានរបស់ព្រះអភិធម្ម ដែលសម្បូរណ៍ដោយនិទានទាំង ២ យ៉ាងនេះ បណ្ឌិតគប្បីជ្រាប**ការតាំងបញ្ហាកម្ម** ដូចតទៅនេះសិន ៖-

“សួរថា ព្រះអភិធម្មនេះ ឱ្យចម្រើនមកដោយអ្វី?, ឱ្យលូតលាស់ក្នុងទីណា?, សម្រេចហើយក្នុងទីណា?, សម្រេចហើយក្នុងកាលណា?, អ្នកណាសម្រេច?, វិចិត្រហើយក្នុងទីណា?, វិចិត្រហើយក្នុងកាលណា?, អ្នកណាវិចិត្រ?, សម្តែងក្នុងទីណា?, សម្តែងហើយដើម្បីប្រយោជន៍ដល់អ្នកណា?, សម្តែងហើយដើម្បីអ្វី?, អ្នកណាទទួលទុក?, អ្នកណាកំពុងសិក្សា?, អ្នកណាមានសិក្ខាសិក្សាហើយ?, អ្នកណាទ្រទ្រង់?, ជាពាក្យរបស់អ្នកណា?, អ្នក

---

[៥៣] មូល. និទាននៃទេសនាតែមួយប៉ុណ្ណោះ ព្រោះជានិទានដែលព្រះអង្គទ្រង់សម្តែងតាមសមគួរដល់អធ្យាស្រ័យ (របស់បុគ្គលម្នាក់ៗ) ។

ណានាំមក” ។

ក្នុងបញ្ហាកម្មនោះ **មានវិសជ្ជនាដូចនេះ ៖-**

ពាក្យសួរថា “ព្រះអភិធម្មនេះ **ឱ្យចម្រើនមកដោយអ្វី?**” មានពាក្យឆ្លើយថា ឱ្យចម្រើនមកដោយសទ្ធាបំណងទៅកាន់បញ្ញាការត្រាស់ដឹង ។ ត្រង់ពាក្យសួរថា **“ឱ្យលូតលាស់ក្នុងទីណា?”** មានពាក្យឆ្លើយថា ឱ្យលូតលាស់ក្នុងជាតក ៥៥០ ។ ត្រង់ពាក្យសួរថា **“សម្រេចហើយក្នុងទីណា?”** មានពាក្យឆ្លើយថា ក្រោមដើមពោធិ៍ ។ ត្រង់ពាក្យសួរថា **“សម្រេចក្នុងកាលណា?”** មានពាក្យឆ្លើយថា ក្នុងថ្ងៃពេញបូណ៌មីខែពិសាខ ។ ពាក្យសួរថា **“អ្នកណាសម្រេច?”** មានពាក្យឆ្លើយថា ព្រះសព្វញ្ញុពុទ្ធ ។ ពាក្យសួរថា **“វិចិត្រក្នុងទីណា?”** ឆ្លើយថា ក្រោមដើមពោធិ៍ ។ ពាក្យសួរថា **“វិចិត្រហើយក្នុងកាលណា?”** ឆ្លើយថា ក្នុងវេលាអស់ ៧ ថ្ងៃ ត្រង់ផ្ទះកែវ ។ សួរថា **“អ្នកណាវិចិត្រ?”** ឆ្លើយថា ព្រះសព្វញ្ញុពុទ្ធ ។ សួរថា **“សម្ដែងក្នុងទីណា?”** ឆ្លើយថា ក្នុងឋានទេវតាជាន់តាវត្តិង្ស ។ សួរថា **“សម្ដែងដើម្បីប្រយោជន៍ដល់អ្នកណា?”** ឆ្លើយថា ដល់ទេវតាទាំងឡាយ ។ សួរថា **“សម្ដែងដើម្បីអ្វី?”** ឆ្លើយថា ដើម្បីចេញអំពីឱឃៈ ៤ ។ សួរថា **“អ្នកណាទទួលទុក?”** ឆ្លើយថា ពួកទេវតា ។ សួរថា **“អ្នកណាកំពុងសិក្សា?”** ឆ្លើយថា ព្រះសេក្ខបុគ្គល និងកល្យាណបុថុជ្ជន ។

សួរថា **“អ្នកណាមានសិក្ខាសិក្សាហើយ?”** ឆ្លើយថា ព្រះអរហន្តខីណាស្រព ។ សួរថា **“អ្នកណាទ្រទ្រង់?”** ឆ្លើយថា ប្រព្រឹត្តទៅដល់ពួកជនណា ពួកជននោះ តែងទ្រទ្រង់ទុក ។ សួរថា **“ជាពាក្យនៃអ្នកណា?”** ឆ្លើយថា ជាព្រះតម្រាស់នៃព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។ សួរថា **“អ្នកណាជាអ្នកនាំមក?”** ឆ្លើយថា អាចារ្យជាអ្នកនាំមកតៗ គ្នា ។

ពិតមែន ព្រះអភិធម្មនេះ ដែលព្រះថេរៈទាំងឡាយមានជាអាទិ៍យ៉ាងនេះ គឺព្រះសារីបុត្តត្ថេរ, ព្រះភទ្ទជិ, ព្រះសោភិតៈ, ព្រះបិយជាលី, ព្រះបិយបាល, ព្រះបិយទស្សី, ព្រះកោសិយបុត្រ, ព្រះសិគ្គវ, ព្រះសន្ទេហៈ, ព្រះមោគ្គល្លីបុត្រ, ព្រះតិស្សទត្ត [៥៤] , ព្រះធម្មិយៈ, ព្រះទាសកៈ, ព្រះសោណកៈ និងព្រះរេវតៈជាអ្នកនាំមករហូតដល់កាលនៃតតិយសង្គីតិ; តអំពីនោះ សិស្សានុសិស្សរបស់ព្រះថេរៈទាំងនោះឯង នាំមកហើយតៗ គ្នា តាមអាចារ្យក្នុងជម្ពូទ្វីបយ៉ាងនេះ ដោយអាការយ៉ាងនេះសិន ។

ចំណែកព្រះអភិធម្ម ដែលព្រះមហានាគទាំងឡាយនេះ នាំមកកាន់កោះ (លង្កា) នេះ តាមដែលព្រះបុរាណាចារ្យប្រព័ន្ធជាគាថាទុកថា ៖-

**“តតោ មហិន្ទោ ឥដ្ដិយោ ឧត្តិយោ ចេវ សម្ពលោ**[៥៥]
**ភទ្ទនាមោ ច បណ្ឌិតោ ឯតេ នាគា មហាបញ្ញា**

[៥៤] ច្បាប់ខ្លះថា ព្រះសុទត្ត ។

[៥៥] ច្បាប់ខ្លះថា ឧត្តិយោ សម្ពលោ តថា ។

**ជម្ពុទីបា ឥធាគតា**។

ក្នុងកាលនោះ ព្រះថេរៈដ៏ប្រសើរ មានបញ្ញាច្រើនទាំងឡាយនេះ គឺព្រះមហិន្ទត្ថេរ ១, ព្រះឥដ្ឋិយត្ថេរ ១, ព្រះឧត្តិយត្ថេរ ១, ព្រះសម្ពលត្ថេរ ១ និងព្រះថេរៈ អ្នកជាបណ្ឌិតឈ្មោះថា ភទ្ទៈ ១ មកក្នុងកោះសីហឡៈនេះអំពីជម្ពូទ្វីប”[៥៦]។

តអំពីនោះ ព្រះអភិធម្មនោះ គឺអាចារ្យដទៃៗ ពោលគឺសិស្សានុសិស្សរបស់ព្រះថេរៈទាំងនោះឯង នាំមករហូតដល់បច្ចុប្បន្ននេះ ក៏ពោលដល់អធិគមនិទានណា នោះចាប់ផ្តើមពីព្រះទសពលព្រះនាមថា **ទីបង្ករ** រហូតដល់ព្រះមហាពោធិបល្លង្ក និងពោលដល់ទេសនានិទាន រហូតដល់ទ្រង់ប្រកាសធម្មចក្ររបស់ព្រះអភិធម្មនោះ គឺព្រះមហានាគទាំងឡាយនាំមកហើយយ៉ាងនេះ និងដើម្បីការជាក់ច្បាស់នៃអធិគមនិទាននោះ គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះ ៖-

## សម្តែងអំពីរឿងសុមេធតាបស

បានឮថា ក្នុងទីបំផុតនៃបួនអសង្ខេយ្យក្រៃលែងមួយសែនកប្ប ថយទៅពីភទ្ទកប្បនេះ មានព្រះនគរឈ្មោះថា **អមរវតី** ព្រាហ្មណ៍ឈ្មោះថា

[៥៦] វិនយ. ។

**សុមេធ** ជាអ្នកកើតល្អហើយទាំងពីរផ្នែក គឺជាអ្នកកាន់កំណើតបរិសុទ្ធល្អ ហើយអំពីមាតា និងបិតា, ជាអ្នកដែលគេមិនមើលងាយ, មិនរង្កៀសដោយការពោលដល់ជាតិត្រកូល រហូតដល់ទៅប្រាំពីរជួរត្រកូល, ជាអ្នកមានរូបស្អាតគួរពិចពិលរមិលមើល, នាំមកនូវសេចក្តីជ្រះថ្លា, ប្រកបដោយសម្បុរ និងទ្រង់ទ្រាយល្អអាស្រ័យនៅក្នុងព្រះនគរអមរវតីនុ៎ះ ។ សុមេធព្រាហ្មណ៍នោះ មិនបានធ្វើការងារដទៃ ក្រៅអំពីការរៀនសិល្បសាស្ត្ររបស់ព្រាហ្មណ៍ឡើយ ។ ក្នុងវេលាដែលគាត់នៅក្មេងនុ៎ះឯង មាតាបិតាក៏បានធ្វើមរណកាលទៅ ។ សម័យនោះ អាមាត្យឈ្មោះរាសិវឌ្ឍកៈ បាននាំបញ្ជីទ្រព្យមកបើកត្រង់បន្ទប់ដែលពេញទៅដោយមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ហើយប្រាប់ទ្រព្យ រហូតជួរប្រាំពីរត្រកូលថា “ម្នាលកុមារ ទ្រព្យជារបស់មាតាមានប្រមាណប៉ុណ្ណេះ, ទ្រព្យជារបស់បិតា តាយាយរបស់អ្នកមានប្រមាណប៉ុណ្ណេះជាដើម ហើយពោលថា អ្នកចូរប្រើប្រាស់ទ្រព្យនុ៎ះចុះ” ។

**សុមេធបណ្ឌិត** គិតថា “បិយជនទាំងឡាយរបស់យើងមានបិតា និងមាតាជាដើមប្រមូលទ្រព្យនេះទុកហើយនាំគ្នាទៅបរលោក មិនបានកាន់យកទ្រព្យសូម្បីមួយកហាបណៈទៅសោះ; ចំណែកយើងនឹងធ្វើហេតុដែលឱ្យកាន់យកទៅបាន ទើបសមគួរ” រួចក៏ក្រាបទូលដល់ព្រះរាជា ហើយឱ្យទូងស្គរប្រកាសក្នុងព្រះនគរ ឱ្យទានដល់មហាជន ហើយបួសជាតាបស ។ បណ្ឌិតគប្បីពោលគាថាសម្តែងដោយ **សុមេធតាបស** ទុកត្រង់នេះ ។

ពិតមែន រឿងសុមេធតាបសនេះលោកពោលទុកក្នុង **ពុទ្ធវង្ស**[៥៧] (ត្រង់ទីបង្គរកថាទីមួយ) ថា ៖-

“ក្នុងបួនអសង្ខេយ្យកម្រៃដោយសែនកប្ប មានព្រះនគរឈ្មោះថា អមរវតី ជានគរគួរីករាយ គួរមនោរម្យប្រកបដោយស្រូវ និងទឹកសម្បូរណ៍ មិនទំនេរ វៀរចាកសំឡេង ១០ ប្រការ គឺសំឡេងដំរី, សំឡេងសេះ, សំឡេងស្គរ, សំឡេងសង្ខ, សំឡេងរថ, សំឡេងពិណ, សំឡេងស្គរសម្ភោរ, សំឡេងរគាំងវង់ខែ*, សំឡេងស្គរតូច, សំឡេងហៅមកបរិភោគបាយទឹកថា ‘ពួកលោកចូរទំពារស៊ី, ចូរផឹកចុះ’, ក្រុងនោះដល់ព្រមដោយគុណលក្ខណៈទាំងពួង, គួរដល់សេចក្ដីប្រាថ្នាពេញចិត្តគ្រប់យ៉ាង, សម្បូរណ៍ដោយរតនៈ ៧ ប្រការខ្វាត់ខ្វែងទៅដោយវត្ថុផ្សេងៗ, ក្រុងដែលសម្រេចហើយដូចទេវនគរ ដែលជាទីនៅរបស់ពួកអ្នកមានបុណ្យទាំងឡាយ, យើងជាព្រាហ្មណ៍នាមថា សុមេធ ក្នុងនគរអមរវតី បន្សល់ទ្រព្យសម្បត្តិទុកច្រើនកោដិ មានសម្បត្តិច្រើនមហិមា, ជាអ្នកស្វាធ្យាយ, ជាអ្នកទ្រទ្រង់មន្ត, ជាអ្នកដល់ត្រើយនៃត្រៃវេទ, ជាអ្នកសម្រេចវិជ្ជាទាយលក្ខណៈ និងគម្ពីរឥតិហាសៈ ដែល

---

[៥៧] ខុ. ពុទ្ធ. (សិយា) ។

* ប្រហែលជាទ្រង់ទ្រាយដូចខែទេដឹង ? ។

សម្បូរណ៍ក្នុងគ្រានោះ យើងអង្គុយនៅក្នុងទីកំបាំងបានគិតយ៉ាងនេះថា ៖-

ក៏ឈ្មោះថា ការកើតក្នុងភពថ្មីជាទុក្ខ, ការបែកធ្លាយនៃសរីរៈក៏ជាទុក្ខ, ការស្លាប់ដោយសេចក្ដីវង្វេងក៏ជាទុក្ខ, ការត្រូវជរាញាំញីក៏ជាទុក្ខ ។ ក្នុងកាលនោះ យើងមានសេចក្ដីកើតជាធម្មតា, មានសេចក្ដីជរាជាធម្មតា, មានសេចក្ដីឈឺថ្កាត់ជាធម្មតានឹងស្វែងរកនូវព្រះនិព្វានដែលមិនចាស់, មិនស្លាប់, ដែលជាទីក្សេមក្សាន្តយ៉ាងណាហ្ន៎, យើងគប្បីជាអ្នកមិនមានសេចក្ដីអាល័យក្នុងជីវិត, មិនត្រូវការសូម្បីកាយស្អុយនេះដែលពេញទៅដោយសាកសពផ្សេងៗ ហើយទៅ ផ្លូវនោះដែលនរណាៗ មិនគប្បីអាចដើរទៅបាន ព្រោះមិនមានហេតុ, ឯផ្លូវនោះនឹងមានពិតប្រាកដ យើងនឹងស្វែងរកផ្លូវនោះ ដើម្បីការរួចផុតចាកភព ។

កាលសេចក្ដីចម្រើន (ភព) កំពុងមាន សេចក្ដីវិនាស (ចាកភព) ក៏គប្បីប្រាថ្នា, ប្រៀបដូចកាលមានសេចក្ដីទុក្ខ សូម្បីឈ្មោះថា សេចក្ដីសុខក៏រមែងមានដូច្នោះ ។

កាលភ្លើង ៣ កងនៅមាននិព្វាន (សេចក្ដីរលត់ភ្លើង) ក៏ត្រូវប្រាថ្នា, ប្រៀបដូចកាលមានសេចក្ដីក្ដៅ ឈ្មោះថា សេចក្ដីត្រជាក់ ក៏រមែងមានដូច្នោះ ។

សេចក្ដីកើតមាន ក៏ត្រូវប្រាថ្នាសេចក្ដីមិនកើត ប្រៀបដូចកាលមានសេចក្ដីអាក្រក់ សូម្បីសេចក្ដីល្អ ក៏រមែងមានដូច្នោះ ។

កាលស្រះទឹកអម្រឹត ដែលជាស្ថានទីជម្រះកិលេសមាន ប៉ុន្តែបុគ្គលមិនស្វែងរកស្រះនោះ នុ៎ះមិនមែនជាទោសរបស់ស្រះអម្រឹតនោះទេ ប្រៀបដូចបុរសធ្លាក់ចុះក្នុងរណ្ដៅលាមក ឃើញស្រះមានទឹកពេញមិនទៅរកស្រះ នឹងទៅជាទោសស្រះនោះមិនបានដូច្នោះដែរ ។

បុគ្គលដែលត្រូវកិលេសគ្របសង្កត់ហើយ កាលបើផ្លូវដែលផុតភ័យមាន តែមិនស្វែងរកផ្លូវ នុ៎ះមិនមែនសេចក្ដីខុសរបស់ផ្លូវនោះទេ ប្រៀបដូចបុរសត្រូវសត្រូវលោមព័ទ្ធហើយ កាលផ្លូវសម្រាប់នឹងគេចទៅមាន តែមិនគេចទៅ នឹងជាទោសរបស់ផ្លូវនោះមិនបានឡើយ ។

បុគ្គលមានទុក្ខត្រូវព្យាធិ គឺកិលេសបៀតបៀនរួបរឹត ហើយមិនស្វែងរកអាចារ្យ នោះមិនមែនជាកំហុសរបស់អាចារ្យ ប្រៀបដូចបុរសអ្នកឈឺចាប់ កាលពេទ្យមាន តែមិនឱ្យពេទ្យព្យាបាលនូវជម្ងឺនោះ នឹងជាទោសនៃពេទ្យនោះមិនបានទេ ។

យើងលះបង់កាយនេះ ដែលពោរពេញដោយសាកសពផ្សេងៗទៅ ដូចបន្ទោបង់ឧច្ចារៈទុកក្នុងបង្គន់ ប្រៀបដូចបុរស និងស្ត្រីបន្ទោបង់មូត្រលាមកទុកក្នុងទីបន្ទោបង់ ហើយទៅ, មិនអាល័យ, មិនត្រូវការដូច្នោះ ។

យើងគប្បីជាអ្នកមិនអាល័យ មិនត្រូវការ គប្បីលះបង់កាយដែលស្អុយដែលសន្សំនូវសាកសពផ្សេងៗនេះទៅចុះ ប្រៀបដូចបុរសស្រាយកញ្ចប់ សាកសពចងទុកត្រង់កដែលគួររង្កៀសហើយទៅ ក៏នឹងគប្បីមានសេចក្ដីសុខ មានសិរី មានអំណាច តាមតែទំនើងចិត្តខ្លួនឯងដូច្នោះ ។

យើងនឹងលះបង់កាយនេះដែលមានរន្ធ ៩ មាន (របស់) បដិកូលហូរចេញជានិច្ចហើយទៅ ដូចម្ចាស់ទូកលះបង់ទូកចាស់គ្រាំគ្រាទូកដែលទ្រុឌទ្រោម ធ្លុះធ្លាយ ដែលលិចហើយទៅ មិនអាល័យ មិនត្រូវការដូច្នោះ ។

យើងនឹងលះបង់កាយនេះ ដែលប្រាកដដូចមហាចោរហើយទៅ ព្រោះខ្លាចតែការទម្លាយត្រកូល ប្រៀបដូចបុរសដើរមកជាមួយពួកចោរ ហើយលះបង់ពួកចោរទៅ ព្រោះឃើញភ័យ គឺការទម្លាយវត្ថុដូច្នោះដែរ ។

គ្រាយើងគិតយ៉ាងនេះហើយ ទើបឱ្យទ្រព្យច្រើនរយកោដិដល់ជនទាំងឡាយ, ទាំងដែលមានទីពឹង និងមិនមានទីពឹង ហើយចូលទៅកាន់ហេមវ័ន ។ ក្នុងទីមិនឆ្ងាយពីហិមវ័នមានភ្នំឈ្មោះថា ធម្មិកបពិត

* យើងសាងអាស្រមទុកល្អហើយ បណ្ណសាលាក៏ប្រក់បាំងទុកល្អហើយ យើងសាងកន្លែងចង្ក្រមប្រាសចាកទោស ៥ ប្រការ ប្រកបដោយគុណ ៨ ប្រការ ដែលជាទីនាំមកនូវកម្លាំងនៃអភិញ្ញា; យើងលះសំពត់សាដក ដែលប្រកបដោយទោស ១២ ប្រការក្នុងកន្លែងនោះ ហើយស្លៀកដណ្ដប់សំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការ, អាត្មាអញលះបណ្ណសាលាដែលច្រឡូកច្រឡំដោយទោស ៨ ប្រការ ចូលទៅជិតអាស្រ័យគល់ឈើដែលប្រកបដោយគុណ ១០ ប្រការ; អាត្មាអញលះបង់ស្រូវដែលគេសាបព្រោះទុក កាន់យកផ្លែឈើដែលជ្រុះតាមតែនឹងបាន ដែលប្រកបដោយគុណជាអនេកប្បការ; អាត្មាអញបានតាំងសេចក្ដីព្យាយាមក្នុងការអង្គុយ ការឈរ និងការចង្ក្រម ខាងក្នុងសប្ដាហ៍ ក៏សម្រេចទៅដល់កម្លាំងនៃអភិញ្ញា"។

បណ្ដាគាថាទាំងនោះ ព្រះបាលីថា **"អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា** = អាត្មាអញសាងអាស្រមទុកល្អហើយ បណ្ណសាលា អាត្មាអញក៏ប្រក់បិទបាំងទុកល្អហើយ" នេះ សេចក្ដីថា សុមេធបណ្ឌិត អ្នកចេញទៅដោយគិតថា "អាត្មាអញនឹងបួស" លោកពោលទុកដូចអាស្រម បណ្ណសាលា និងទីចង្ក្រមនុ៎ះ លោកសាងដោយដៃរបស់ខ្លួនឯង ។ តែក្នុងព្រះបាលីនោះ គប្បីជ្រាបសេចក្ដីដូច្នេះថា ៖-

---

* អដ្ឋ. យោ. ពាក្យថា "ធម្មិកបពិត = ភ្នំប្រកបដោយធម៌" ព្រោះជាកន្លែងធ្វើធម៌របស់ព្រះពោធិសត្វ ដោយច្រើន ។

ក៏ព្រះបរមពោធិសត្វ ឈានចុះកាន់ហិមវ័នហើយគិតថា "ថ្ងៃនេះអាត្មាអញ នឹងចូលទៅកាន់ភ្នំឈ្មោះថា ធម្មិកៈ" ។ ស្ដេចសក្កៈ អ្នកជាស្ដេចនៃទេវតា ទ្រង់ទតព្រះនេត្រឃើញសុមេធបណ្ឌិត អ្នកចេញទៅដោយគិតថា "អាត្មាអញនឹងបួស" ទើបត្រាស់ហៅវិស្សកម្មទេវបុត្រមក ត្រាស់បញ្ជាថា "សុមេធបណ្ឌិតនេះចេញទៅហើយ ដោយគិតថា 'អាត្មាអញនឹងបួស' , ម្នាលបាៗ ចូរទៅសាងទីសម្រាប់នៅដល់ព្រះបរមពោធិសត្វចុះ"។ វិស្សកម្មទេវបុត្រនោះ ទទួលពាក្យរបស់ស្ដេចសក្កៈហើយ ក៏ទៅនិមិត្តអាស្រមដែលគួររីករាយ បណ្ណសាលាដែលបិទបាំងល្អហើយ និងទីចង្ក្រមដែលជាទីពេញចិត្ត ។ ចំណែកព្រះមានព្រះភាគជាម្ចាស់ ទ្រង់សំដៅយកអាស្រមនុ៎ះ ដែលសម្រេចដោយបុញ្ញានុភាពរបស់ខ្លួនក្នុងកាលនោះ ទើបត្រាស់ថា ៖-

"ម្នាលសារីបុត្រ អាស្រមតថាគតកសាងទុកល្អហើយ, បណ្ណសាលាតថាគតក៏សាងទុកល្អហើយជិតភ្នំធម្មិក(បពិត)នោះ តថាគតកសាងទីចង្ក្រមដែលវៀរចាកទោស ៥ យ៉ាង ទុកត្រង់អាស្រម* បទនោះ"។

បណ្ដាពាក្យទាំងនុ៎ះ ពាក្យថា "**សុកតោ មយ្ហំ** = តថាគតសាងទុកល្អហើយ" និងពាក្យថា "**បណ្ណសាលា សុមាបិតា**" សេចក្ដីថា សូម្បីសាលា

---

* អដ្ឋ. យោ. ពាក្យថា អាស្រមព្រោះជាកន្លែងគ្មានរវល់ គ្មានកង្វល់ ដោយការងារផ្សេងៗ មានកសិកម្មជាដើម។

ដែលប្រក់ដោយស្លឹកឈើ ក៏បានឈ្មោះថា ជាសាលាដែលតថាគតកសាងល្អហើយ ៕

## សំដែងអំពីទីចង្ក្រមមានទោស ៥ យ៉ាង

ពាក្យថា “**បញ្ចទោសវិវជ្ជិតំ** (វៀរចាកទោស ៥ យ៉ាង)” សេចក្តីថា ក៏ឈ្មោះថា ទោសនៃទីចង្ក្រមទាំង ៥ យ៉ាងនេះ គឺ

**១-ថទ្ធវិសមតា** ជាកន្លែងរឹង និងរដិបរដុប

**២-អន្តោរុក្ខតា** មានដើមឈើនៅខាងក្នុង

**៣-គហនច្ឆន្នតា** ជាទីប្រក់បិទដោយព្រៃក្រាស់

**៤-អតិសម្ពាធនតា** ជាទីចង្អៀតពេក

**៥-អតិសាលតា** ជាទីទូលាយពេក ។

ពិតមែន ទីចង្ក្រមដែលមានភូមិភាគរឹងរដិបរដុប ជើងទាំងពីររបស់អ្នកចង្ក្រមរមែងឈឺថ្កាត់ ជើងរមែងហើម ចិត្តរមែងមិនបានឯកគ្គតា កម្មដ្ឋានរមែងវិបត្តិ ។ តែផ្ទៃដែលទន់ស្មើគ្នា យោគីអាស្រ័យទីនៅស្រួលហើយ ក៏ធ្វើកម្មដ្ឋានឱ្យសម្បូរណ៍បាន ។ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបទីចង្ក្រម ព្រោះជាភូមិភាគរឹង និងរដិបរដុបថាជាទោសទី ១ ។ កាលបើដើមឈើមាននៅខាងក្នុង ឬមាននៅត្រង់កណ្តាល ឬក៏ក្នុងទីបំផុតនៃទីចង្ក្រម អ្នកចង្ក្រម

អាស្រ័យសេចក្ដីប្រមាទហើយ រមែងប៉ះទង្គិចជាមួយថ្ងាស់ ឬក្បាល, ព្រោះហេតុដូច្នោះ សេចក្ដីដែលទីចង្ក្រមមានដើមឈើនៅខាងក្នុង គប្បីជ្រាបថាជាទោសទី ២ ។ កាលចង្ក្រមក្នុងទីចង្ក្រមដែលដុះដោយព្រៃក្រាស់ មានស្មៅនិងវល្លិ៍ជាដើម រមែងជាន់សត្វមានពស់ជាដើម ក្នុងវេលាងងឹតឱ្យស្លាប់ ឬត្រូវសត្វមានពស់ជាដើមនោះចិក រមែងដល់នូវសេចក្ដីទុក្ខ, ព្រោះហេតុដូច្នោះ សេចក្ដីដែលទីចង្ក្រម គ្របដណ្ដប់ដោយព្រៃក្រាស់ គប្បីជ្រាបថាជាទោសទី ៣ ។ កាលដើរចង្ក្រមក្នុងទីចង្ក្រមចង្អៀតពេកដោយទទឹង ១ ហត្ថ ឬកន្លះហត្ថ ក្រចកក្ដី ម្រាមជើងក្ដី រមែងបែក ព្រោះភ្លាត់ហួសទៅក្នុងទីកំណត់, ព្រោះហេតុដូច្នោះ សេចក្ដីដែលទីចង្ក្រមចង្អៀតពេក គប្បីជ្រាបថាជាទោសទី ៤ ។ កាលចង្ក្រម ក្នុងទីចង្ក្រមទូលាយពេក ចិត្តរមែងរវើរវាយ, រមែងមិនបានឯកគ្គតា, ព្រោះហេតុដូច្នោះ សេចក្ដីដែលទីចង្ក្រមទូលាយពេក, គប្បីជ្រាបថាជាទោសទី ៥ ៕

## សម្ដែងអំពីទីចង្ក្រមដែលមិនមានទោស

ទីចង្ក្រមខ្នាតតូច (**អនុចង្កមំ**) ដោយចំណែកទទឹង១ហត្ថ១ចង្អាមក្នុងខាងទាំងពីរ (អមសងខាង) ប្រមាណ ១ ហត្ថ (ត្រង់កណ្ដាល ១ ហត្ថ ១ ចង្អាម ខាង១ ១ ហត្ថរួម ត្រូវជា ៣ ហត្ថ ១ ចង្អាម) ផ្នែកបណ្ដោយប្រមាណ ៦០ ហត្ថ មានដីទន់ដែលឆាយខ្សាច់ទុករាបគួរសម, ព្រោះហេតុដូច្នោះ ទី

ដូចនោះ បានហាក់ដូចទីចង្ក្រមរបស់ព្រះមហាមហិន្ទត្ថេរ អ្នកញុំាងសេចក្ដីជ្រះថ្លាឱ្យកើតដល់អ្នកកោះ (លង្កា) ក្នុងចេតិយគិរី ដោយហេតុនោះ សុមេធបណ្ឌិតទើបពោលថា “យើងសាងទីចង្ក្រមដោយវៀរចាកទោស ៥ យ៉ាង ក្នុងអាស្រមបទនោះ” ៕

## សេចក្ដីសុខរបស់សមណៈ ៨ យ៉ាង

ពាក្យថា **“អដ្ឋគុណសមុបាគតំ** = ប្រកបដោយគុណ ៨ ប្រការ” បានដល់ ប្រកបដោយសេចក្ដីសុខរបស់សមណៈ ៨ យ៉ាង ។ ធម្មតាថា សេចក្ដីសុខរបស់សមណៈមាន ៨ យ៉ាងគឺ

១-មិនហួងហែងវត្ថុទាំងឡាយមានទ្រព្យ និងស្រូវជាដើម ។

២-ភាពជាអ្នកស្វែងរកអាហារបិណ្ឌបាតប្រាសចាកទោស ។

៣-ភាពជាអ្នកឆាន់បិណ្ឌបាតដែលស្ងប់ ។

៤-កាលរាជត្រកូល គាបសង្កត់អ្នកស្រុកកាន់យកទ្រព្យ ដែលមានសារៈ ឬទាសៈប្រុសស្រី និងកហាបណៈជាដើម ភាពជាអ្នកមិនត្រូវសេចក្ដីសៅហ្មងព្រោះការបៀតបៀនអ្នកស្រុក ។

៥-មិនមានឆន្ទរាគៈក្នុងគ្រឿងប្រើប្រាស់ទាំងឡាយ ។

៦-ប្រាសចាកភ័យក្នុងកាលដែលត្រូវចោរប្លន់ ។

៧-មិនសេពគប់ស្និទ្ធស្នាលដោយព្រះរាជា និងមហាអាមាត្យរបស់

ព្រះរាជា ។

៨- មិនប៉ះទង្គិច (ទើសទាក់) ក្នុងទិសទាំង ៤ ។

ពាក្យនេះ មានអធិប្បាយថា ជនជាអ្នកនៅក្នុងអាស្រមនោះអាច ដើម្បីប្រសព្វសេចក្ដីសុខរបស់សមណៈ ៨ យ៉ាងនេះ យ៉ាងណា, តថាគត សាងអាស្រមនោះប្រកបដោយគុណ ៨ ប្រការ ។

ពាក្យថា **"អភិញ្ញាពលមាហរិំ** = នាំមកនូវកម្លាំងនៃអភិញ្ញា" សេចក្ដីថា ក្នុងកាលខាងក្រោយ តថាគតនៅក្នុងអាស្រមបទនោះ នឹងធ្វើ កសិណបរិកម្ម ចម្រើនវិបស្សនាដោយសេចក្ដីមិនទៀង ជាទុក្ខ ដើម្បីត្រូវការ ឱ្យអភិញ្ញាទាំងឡាយ និងសមាបត្តិទាំងឡាយកើតឡើងហើយ នាំវិបស្សនា ពលៈដែលមានកម្លាំងមក, អធិប្បាយថា តថាគតនៅក្នុងទីនោះ អាចដើម្បី នាំកម្លាំងនោះមកបាន យ៉ាងណា, តថាគតសាងអាស្រម ដ៏សមគួរដល់ វិបស្សនាពលៈនោះ ដើម្បីត្រូវការអភិញ្ញានោះ យ៉ាងនោះឯង ៕

## សម្ដែងអំពីវិសុកម្មទេវបុត្រនិម្មិតអាស្រមបទជាដើម

ក្នុងបទនៃគាថាដែលថា **"សាដកំ បជហឹ តត្ថ នវទោសមុបាគតំ** = អាត្មាអញលះសាដកដែលប្រកបដោយទោស ៩ យ៉ាង ក្នុងទីនោះ" នៃគាថាដែលថា ៖-

**"សាដកំ បជហឹ តត្ថ នវទោសមុបាគតំ**

**វាកចីរំ និវាសេសឹ ទ្វានសតុណមុបាគតំ”** ។

គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះ ៖-

បានឮថា កាលវិស្សុកម្មទេវបុត្រនិម្មិតវត្ថុទាំងពួង ដែលជាគ្រឿងប្រើប្រាស់របស់ពួកបព្វជិតយ៉ាងនេះ គឺនិម្មិតអាស្រមដែលប្រដាប់ដោយកុដិលេណ (ទីពួនសម្ងំ) និងទីចង្ក្រមជាដើម ដែលដេរដាស់ដោយដើមឈើមានផ្កា និងផ្លែជាទីរម្មណីយ៍ (មនោរម្យ) មានស្រះទឹកថ្លាស្អាត ប្រាសចាកពាលម្រឹគ និងសំឡេងសកុណជាតិ (សត្វស្លាប) ដែលគួរខ្លាច សមគួរដល់សេចក្ដីស្ងប់ស្ងាត់ រៀបចំផែនក្ដារសម្រាប់រឹប ក្នុងទីបំផុតទាំងពីររបស់ទីចង្ក្រម ដែលប្រដាប់ហើយ និម្មិតផ្ទាំងសិលាមានផ្ទៃស្មើគ្នា មានពណ៌ដូចសណ្ដែកបាយទុកក្នុងទីកណ្ដាលនៃទីចង្ក្រម ដើម្បីប្រយោជន៍ដល់ការអង្គុយ និម្មិតបរិក្ខារតាបស មានជដាមណ្ឌល (រមូរសក់កណ្ដាញ់), វាកចីវរ (សំពត់សម្បកឈើ), តិទណ្ឌ (ឈើមានជើងបី), កុណ្ឌី (ភាជនៈសម្រាប់ដាក់ទឹក) ជាដើមទុកខាងក្នុងបណ្ណសាលា និម្មិតក្អម ទឹកសម្រាប់ឆាន់ ស័ង្ខដងទឹកឆាន់ និងផ្ដិលដួសទឹកឆាន់ ទុកក្នុងមណ្ឌប (រោងបារាំ) និម្មិតអំបែងរងើកភ្លើង (ខ្ទះចង្ក្រាន) និងអុសជាដើមទុកក្នុងរោងភ្លើង ហើយចារឹកអក្សរទុកលើជញ្ជាំងបណ្ណសាលាថា “អ្នកណា១ ត្រូវការបួស ចូរកាន់យកបរិក្ខារទាំងនេះបួសចុះ” ហើយទៅកាន់ទេវលោកតាមដើមវិញ ។

**សុមេធបណ្ឌិត** កាលជ្រើសរើសរកកន្លែកជាទីសប្បាយ ដែលគួរសម ដល់ទីនៅរបស់ខ្លួន តាមច្រកភ្នំជិតជើងព្រៃហិមពាន្ត ឃើញអាស្រមបទ ដែលវិស្សុកម្មទេវបុត្រនិម្មិតដែលស្តេចសក្កទេវរាជប្រទានឱ្យ ជាទីគួររីករាយ ជិតស្ទឹង ហើយទៅក្នុងទីបំផុតនៃកន្លែងចង្ក្រម មិនឃើញស្នាមជើង ទើបគិតថា "បព្វជិតអ្នកនៅជាប្រចាំ ទៅភិក្ខាចារក្នុងស្រុកជិត១ នឹងជាអ្នកមានរាងកាយលំបាក ត្រឡប់ចូលទៅកាន់បណ្ណសាលាហើយអង្គុយ" រង់ចាំបន្តិច ហើយបើកទ្វារបណ្ណសាលាដោយគិតថា "បព្វជិតនេះ ទៅយូរណាស់ អាត្មាអញនឹងដឹង" ទើបទៅខាងក្នុង ក្រឡេកមើលខាងនេះ ខាងនោះ អានអក្សរទាំងឡាយលើជញ្ជាំងធំ ហើយគិតថា "បរិក្ខារទាំងនេះសមគួរដល់អត្តាអញ អញនឹងកាន់យកបរិក្ខារទាំងនេះហើយបួស"

ទើបលះគូសំពត់សាដកដែលខ្លួនស្លៀក និងដណ្តប់ចេញ ។ ដោយហេតុនោះ ព្រះភគវាទើបត្រាស់ថា **"សាដកំ បជហឹ តត្ថ** = តថាគតលះសំពត់សាដកដែលប្រកបដោយទោស ៩ យ៉ាង ក្នុងទីនោះ" ជាដើម អធិប្បាយថា ម្នាលសារីបុត្រ តថាគតចូលទៅដោយអាការយ៉ាងនេះ ហើយលះសាដកដែលប្រកបដោយទោស ៩ យ៉ាង ក្នុងបណ្ណសាលានោះ; លោកសម្តែងទុកថា សុមេធបណ្ឌិតនោះ កាលលះសាដក បានឃើញទោស ៩ យ៉ាង ទើបលះ ៕

## សម្តែងអំពីសំពត់សាដកមានទោស ៩ យ៉ាង

ពិតណាស់ ទោស ៩ យ៉ាង រមែងប្រាកដដល់បព្វជិតអ្នកបួសជាតាបស គឺៈ-

១-សំពត់នោះមានតម្លៃច្រើន ។

២-សំពត់ដែលមានអ្នកដទៃហួងហែង * ។

៣-សំពត់ដែលប្រើហើយប្រឡាក់ងាយ ព្រោះប្រឡាក់ហើយ ត្រូវលាង ត្រូវជ្រលក់ ។

៤-សំពត់ចាស់ហើយដោយការប្រើ ព្រោះថា កាលរហែកដាច់ហើយ ត្រូវដេរត្រូវប៉ះ ។

៥-សំពត់ថ្មីបានមកដោយក្រ ព្រោះត្រូវស្វែងរក ។

៦-សំពត់ដែលមិនសមគួរដល់ការបួសជាឥសី ។

៧-សំពត់ដែលមានទូទៅដល់សត្រូវទាំងឡាយ ព្រោះត្រូវការហួងហែងរក្សា ។

៨-សំពត់ជាគ្រឿងប្រដាប់របស់អ្នកប្រើប្រាស់ ។

៩-សំពត់ដែលមានអ្នកត្រូវការច្រើន ជារបស់ប្រើប្រចាំខ្លួនសម្រាប់ដើរទៅ ។

---

* ច្បាប់ខ្លះថា ការកើតឡើងនៃសំពត់នោះ ព្រោះជាប់ជំពាក់ដោយសារអ្នកដទៃ ។

## សំពត់សម្បកឈើមានអានិសង្ស ១២ យ៉ាង

ពាក្យថា **“ទារកចីរំ និវាសេសិំ** = ស្លៀកដណ្ដប់សំពត់សម្បកឈើ” សេចក្ដីថា ម្នាលសារីបុត្រ ក្នុងកាលនោះតថាគតឃើញទោស ៩ យ៉ាងនេះ ទើបលះសាដកហើយស្លៀកសំពត់សម្បកឈើ គឺកាន់យកសំពត់សម្បកឈើ ដែលបុគ្គលហែកស្មៅដំណេកទន្សាយជាចំរៀក១ ហើយត្បាញ ដើម្បីធ្វើជាសំពត់ស្លៀកដណ្ដប់ ។ ពាក្យថា **“ទ្វាទសគុណមុបាគតំ** = ប្រកបដោយគុណ ១២ ប្រការ” សេចក្ដីថា ប្រកបដោយអានិសង្ស ១២ ប្រការ ។ ពិតណាស់ សំពត់សម្បកឈើមានអានិសង្ស ១២ យ៉ាងគឺ ៖-

ជាសំពត់តម្លៃថោកល្អ ជារបស់គួរ នេះជាអានិសង្សទី ១, អាចដើម្បីធ្វើបានដោយដៃរបស់ខ្លួន នេះជាអានិសង្សទី ២, ប្រឡាក់តិច១ ដោយការប្រើប្រាស់ (ប្រឡាក់មើលមិនសូវដឹង) សូម្បីលាង ក៏មិនយូរ នេះជាអាសង្សទី ៣, សូម្បីចាស់ព្រោះការប្រើប្រាស់ ក៏មិនត្រូវដេរ នេះជាអាសង្សទី ៤, កាលស្វែងរកទៀត ក៏ធ្វើបានងាយ នេះជាអានិសង្សទី ៥, សមគួរដល់ការបួសជាតាបស នេះជាអានិសង្សទី ៦, សត្រូវទាំងឡាយមិនប្រើ នេះជាអានិសង្សទី ៧, មិនមែនជាគ្រឿងប្រដាប់របស់ជនអ្នកប្រើ នេះជាអានិសង្សទី ៨, ជារបស់ស្រាលក្នុងពេលស្លៀក នេះជាអានិសង្សទី ៩, ជារបស់អ្នកមានសេចក្ដីប្រាថ្នាតិចក្នុងចីវរប្បច្ច័យ នេះជាអានិសង្សទី ១០, ភាពជាអ្នក

មិនមានទោសរបស់អ្នកទ្រទ្រង់ធម៌ ព្រោះកើតអំពីសម្បកឈើ នេះជាអានិសង្សខទី ១១, សូម្បីកាលសំពត់សម្បកឈើវិនាសទៅ ក៏មិនអាល័យ នេះជាអានិសង្សខទី ១២ ។

បទគាថាដែលថា **"អដ្ឋទោសសមាកិណ្ណំ បជហឹ បណ្ណសាលកំ"** នៃគាថានេះថា ៖-

**"អដ្ឋទោសសមាកិណ្ណំ បជហឹ បណ្ណសាលកំ**
**ឧបាគមឹ រុក្ខមូលំ គុណេហិ ទសហុបាគតំ"** ។

**សួរថា : សុមេធបណ្ឌិត** លះសំពត់នោះបានដូចម្ដេច?

**ឆ្លើយថា :** ន័យថា សុមេធបណ្ឌិតនោះ កាលដោះសំពត់សាដកទាំងពីរនោះ កាន់យកសំពត់សម្បកឈើដែលជ្រលក់ហើយ ដូចជាផ្កាននោង ដែលពាក់នៅលើស្មា រួចក៏ដណ្ដប់សំពត់សំបកឈើមានពណ៌ដូចមាសមួយផ្ទាំងទៀតសង្កត់ពីលើសំពត់ស្លៀកនោះ ធ្វើស្បែកខ្លាមានក្រចក មានសណ្ឋានដូចផ្កាបុន្នាគ (បុសនាគ) ឱ្យជាសំពត់ នៅលើស្មាម្ខាង ហើយពាក់មណ្ឌលជដា ស៊កច្បោះរឹង និងផ្នួងសក់ ដើម្បីត្រូវការធ្វើឱ្យមិនញាប់ញ័រ ហើយតម្កល់ផ្តិលទឹកមានពណ៌ដូចកែវប្រពាឡទុកក្នុងសង្រែក ដូចបណ្ដាញកែវមុក្តា ហើយកាន់យកដងរែកដែលកោងក្នុងទី ៣ កន្លែង បំពាក់ផ្ដិលទឹក ទុកត្រង់ចុងដងរែកម្ខាង បំពាក់លើទំពក់ និងឈើជើង ៣ ជាដើម ទុកត្រង់ចុងដងរែកម្ខាង ហើយរែកគ្រឿងបរិក្ខារដាក់ឡើងលើស្មា កាន់ឈើច្រត់ដោយដៃស្ដាំចេញ

អំពីបណ្ណសាលា ចង្រ្កមទៅមកក្នុងទីចង្រ្កមធំវែង ប្រមាណ ៦០ ហត្ថ និង ពិចារណាមើលភេទរបស់ខ្លួន ហើយកើតសេចក្ដីឧស្សាហ៍ឡើងថា “មនោរថរបស់យើង ដល់ទីបំផុតហើយ បព្វជ្ជារបស់យើង ស្អាតល្អហ្ន៎ ! ក៏ឈ្មោះថាបព្វជ្ជានេះ វីរបុរសទាំងឡាយមានព្រះពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធសរសើរហើយ, រីករាយហើយ, គ្រឿងចងរបស់គ្រហស្ថ អាត្មាអញលះបានហើយ, អាត្មាអញកាលចេញបួសហើយ បាននូវបព្វជ្ជាដ៏ខ្ពង់ខ្ពស់, អាត្មាអញនឹងធ្វើសមណធម៌, អាត្មាអញនឹងបានសេចក្ដីសុខក្នុងមគ្គ និងផល” លើកសង្រ្កែកបរិក្ខារដាក់ចុះហើយ អង្គុយចុះលើផែនសិលា មានពណ៌ដូចសណ្ដែកខៀវត្រង់កណ្ដាលទីចង្រ្កម ដូចរូបដិមាមាស ញុំាងចំណែកនៃថ្ងៃឱ្យកន្លងទៅហើយចូលទៅកាន់បណ្ណសាលាក្នុងវេលាល្ងាច ដេកលើគ្រឿងលាតធ្វើដោយគ្រឿងឈើត្រង់ចំហៀងគ្រែឫស្សី មួយខាងឱ្យសរីរៈទទួលអាកាស ហើយភ្ញាក់ក្នុងវេលាជិតភ្លឺ រំពឹងដល់ការមករបស់ខ្លួនថា “អាត្មាអញនេះ ឃើញទោសក្នុងឃរាវាស ទើបលះយសដ៏ប្រសើរ មានភោគៈរាប់មិនបាន ចូលទៅកាន់ព្រៃ ជាអ្នកស្វែករកនេក្ខម្មៈ បួសហើយ; ចាប់តាំងអំពីនេះទៅ អញមិនគួរប្រមាទទេ ព្រោះថា សត្វល្អិត គឺមិច្ឆាវិតក្កៈ រមែងទំពាស៊ីអ្នកលះសេចក្ដីស្ងប់ស្ងាត់ (បរិវេក) ហើយត្រាច់ទៅ ឥឡូវនេះ យើងគួរព្ធូន (ចម្រើន) ដោយសេចក្ដីស្ងប់ស្ងាត់ ព្រោះថា យើងឃើញបលិពោធ (សេចក្ដីកង្វល់)

របស់ឃរាវាសហើយ ទើបចេញមក ក៏បណ្ណសាលានេះ ជាទីញុំាងចិត្តឱ្យរីករាយ, មានផ្ទៃដែលតាក់តែងហើយ មានពណ៌ដូចញ្ញៅទុំ ទាំងជញ្ជាំងក៏សស្អាតដូចផែនប្រាក់, ដំបូលបណ្ណសាលា មានពណ៌ដូចជើងព្រាប, រនាបគ្រែតូចក៏មានពណ៌ដូចគ្រឿងលាតដ៏វិចិត្រ; យើងដល់ឋានៈដែលជាទីនៅមានកន្លែងអាស្រ័យដ៏ស្រណុកស្រួល, ការដល់ព្រមដោយផ្ទះរបស់យើង ក៏រមែងមិនប្រាកដ ដូចភាពជាភូមិប្រទេស ដែលប្រសើរជាងបណ្ណសាលានេះ” ហើយត្រួតមើលនូវទោសទាំងឡាយ ទើបបានឃើញ**ទោសក្នុងបណ្ណសាលា ៨ យ៉ាងគឺ**

ត្រូវស្វែងរកទព្វសម្ភារៈ (គ្រឿងធ្វើផ្ទះ) ទាំងឡាយដោយគ្រឿងប្រកបច្រើនមករួមគ្នា ហើយនឹងធ្វើនេះជាទោសទី ១, ត្រូវមើលទព្វសម្ភារៈមានស្មៅ ស្លឹកឈើ និងដីឥដ្ឋដែលធ្លាក់ទៅជានិច្ច ដើម្បីឱ្យទព្វសម្ភារៈទាំងនោះតាំងនៅបានយូរ នេះជាទោសទី ២, ធម្មតាថា សេនាសនៈ រមែងដល់ភាពជារបស់ទ្រុឌទ្រោម កាលត្រូវក្រោកឡើងជួសជុលក្នុងកាលដែលមិនគួរភាពជាឯកគ្គតានៃចិត្ត ក៏រមែងមិនមាន, ព្រោះហេតុដូច្នោះ ភាពដែលត្រូវក្រោកឡើងជួសជុលនេះជាទោសទី ៣, ភាពដែលកាយនឿយ ព្រោះត្រូវធ្វើការងារ ដោយប៉ះពាល់ជាមួយសេចក្តីត្រជាក់ និងក្តៅ នេះជាទោសទី ៤, បុគ្គលអ្នកចូលទៅកាន់ផ្ទះហើយ អាចដើម្បីធ្វើសេចក្តីអាក្រក់យ៉ាងណាមួយក៏បាន ព្រោះហេតុដូច្នោះ ការដែលផ្ទះជាគ្រឿងបិទបាំងនេះជាទោសទី ៥, សេចក្តីប្រកាន់ខ្ជាប់ថា “ផ្ទះរបស់យើង” នេះជាទោសទី ៦, ក៏ឈ្មោះថា

ភាពជាអ្នកមានផ្ទះនៅនោះ ក៏រមែងដូចជាមានអ្នកនៅជាសំឡាញ់ ព្រោះហេតុដូច្នោះ ខនេះនឹងជាទោសទី ៧, ភាពដែលត្រូវជារបស់សាធារណៈច្រើន ព្រោះជារបស់ទូទៅដល់ខ្យុចប៊ុតឈាម ជីងជក់ និងតុកកែជាដើម នេះជាទោសទី ៨ ។

ព្រះមហាពោធិសត្វឃើញទោសទាំង ៨ យ៉ាងនេះ ដោយប្រការដូច្នេះ ទើបលះបណ្ណសាលា ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ៖-

**“តថាគតលះបណ្ណសាលា ដែលពោពេញទៅដោយទោស ៨ យ៉ាង ចូលកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង” ។**

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា “អាត្មាអញ គ្រាដែលបដិសេធគ្រឿងប្រក់ (បណ្ណសាលា) ហើយចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង”៕

## គល់ឈើមានគុណ ១០ យ៉ាង

ក្បែរគល់ដើមឈើនោះ មានគុណ ១០ យ៉ាងនេះ គឺភាពជារបស់មិនត្រូវចាប់ផ្តើម (មិនត្រូវសាងដូចផ្ទះ) នេះជាគុណខទី ១, ត្រង់គល់ដើមឈើនោះ គ្រាន់តែជាកាជ្រុលទៅនៅប៉ុណ្ណោះ មិនត្រូវបដិបត្តិមើល នេះជាគុណខទី ២, មែនពិត គល់ឈើនោះ បបោសចេញក៏ដោយ មិនបបោសចេញ ក៏

ដោយ ក៏រាប់ថា ជាទីស្រណុកសុខស្រួលសម្រាប់ប្រើប្រាស់នោះឯង ។ សេចក្ដីថា របស់ដែលមិនត្រូវក្រោកឡើង (ប្រក់) នេះជាគុណខទី ៣, គល់ឈើនោះរមែងមិនបិទបាំងសេចក្ដីតិះដៀល ព្រោះថា កាលបុគ្គលធ្វើសេចក្ដីអាក្រក់ក្បែរគល់ឈើនោះ រមែងខ្មាស់ ព្រោះហេតុដូច្នោះ ការដែលមិនបិទបាំងសេចក្ដីតិះដៀលនេះជាគុណខទី ៤, រមែងមិនឱ្យកាយស្វិតស្រពោន ដូចនៅកណ្ដាលវាល ព្រោះហេតុដូច្នោះ ការដែលកាយមិនស្វិតស្រពោន នេះជាគុណខទី ៥, សេចក្ដីមិនជាហេតុនៃការហួងហែង នេះជាគុណខទី ៦, ការហាមសេចក្ដីអាល័យក្នុងផ្ទះ នេះជាគុណខទី ៧, មិនមានការឱ្យចេញទៅ ដោយពាក្យថា "យើងនឹងមើលរក្សាផ្ទះនេះឯង, លោកចូរចេញទៅ" ព្រោះ (គល់ឈើ) ហាក់ដូចផ្ទះទូទៅជាចំណែកច្រើន នេះជាគុណខទី ៨, ភាពបានបីតិរបស់អ្នកនៅ នេះជាគុណខទី ៩, ភាពជាអ្នកមិនអាឡោះអាល័យ ក្នុងទីដែលខ្លួនទៅហើយៗ ព្រោះសេចក្ដីដែលទីសេនាសនៈ គឺគល់ដើមឈើជារបស់រកបានងាយ នេះជាគុណខទី ១០ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា "តថាគតលុះឃើញគុណទាំង ១០ នេះហើយ ទើបចូលទៅកាន់គល់ឈើ" ។

ព្រះមហាពោធិសត្វ កំណត់ហេតុទាំងឡាយនេះ មានប្រមាណប៉ុណ្ណោះហើយ ក្នុងថ្ងៃព្រឹកឡើង ទើបចូលទៅកាន់ស្រុកដើម្បីភិក្ខា ។ គ្រានោះ ពួកមនុស្សក្នុងស្រុកដែលព្រះមហាពោធិសត្វទៅដល់នោះ បានថ្វាយ

ភិក្ខាដោយឧស្សាហ៍ដ៏ធំ ។ ព្រះមហាពោធិសត្វ ធ្វើភត្តកិច្ចស្រេចហើយ ត្រឡប់មកកាន់អាស្រមអង្គុយគិតថា "យើងមិនបានបួសដោយសេចក្ដីគិតថា 'យើងនឹងមិនបានអាហារទេ' , ក៏ឈ្មោះថា អាហារដែលល្អនោះរមែងញុំាងសេចក្ដីស្រវឹងក្នុងការប្រកាន់ខ្លួន និងសេចក្ដីស្រវឹងក្នុងភាពជាបុរសឱ្យចម្រើន, ក៏ការអស់ទុក្ខដែលមានអាហារជាមូល មិនមានឡើយ, បើដូច្នោះមានតែយើងគប្បីលះអាហារដែលកើតអំពីធញ្ញជាតិ ដែលគេព្រោះនិងដាំ ដោយដាច់ខាត ហើយកាន់យកផ្លែឈើតាមតែនឹងរកបាន ដែលដល់ព្រមដោយគុណមិនមែនតិច ព្រោះហេតុដូច្នោះ អាត្មាអញនឹងលះអាហារដែលកើតអំពីធញ្ញជាតិ ដែលគេព្រោះ និងដាំហើយ បរិភោគផ្លែឈើតាមដែលរកបាន" ។ ចាប់ដើមអំពីកាលនោះ ព្រះមហាពោធិសត្វក៏ធ្វើយ៉ាងនោះហើយនាំមកត១ គ្នា ព្យាយាមនៅខាងក្នុង ៧ ថ្ងៃ ក៏ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឱ្យកើតឡើង ។

## សម្ដែងអំពីការធ្វើផ្លូវ និងបានទទួលព្យាករណ៍

ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖-

"តថាគតលះធញ្ញជាតិដែលព្រោះហើយ ស្ងួងហើយដោយមិនសល់ កាន់យកផ្លែឈើ ដែលធ្លាក់តាមតែរកបាន ដែលដល់ព្រមដោយគុណជាច្រើនអនេក ។ តថាគតតាំងសេចក្ដីព្យាយាមក្នុងការអង្គុយ,

ការឈរ, ការចង្ក្រមក្នុងទីនោះ ក្នុងខាងក្នុងសប្តាហ៍ តថាគតក៏បានសម្រេចកម្លាំងនៃអភិញ្ញា ។ កាលតថាគតដល់ការសម្រេចជាអ្នកជំនាញហើយក្នុងព្រះសាសនាយ៉ាងនេះ ព្រះជិនស្រីព្រះនាមទីបង្ករ ព្រះអង្គជានាយកនៃលោក ក៏ទ្រង់ឧប្បត្តិឡើង តថាគតជ្រុលជ្រប់ត្រេកអរក្នុងឈាន ទើបមិនបានឃើញនិមិត្ត ៤ គឺកាលព្រះអង្គទ្រង់ឧប្បត្តិ, ទ្រង់ប្រសូត, ត្រាស់ដឹង និងសម្តែងធម៌ ។

ពួកមនុស្សអ្នកមានចិត្តត្រេកអរ និមន្តព្រះតថាគតឱ្យស្តេចយាងទៅក្នុងខេត្តដែនប្រទេសជាយដែន ហើយនាំគ្នាជម្រះផ្លូវ ជាទីមករបស់ព្រះតថាគត ។ សម័យនោះ តថាគតគ្រងសំពត់វាកចីវរ (សំពត់សម្បកឈើ) ចេញអំពីអាស្រមរបស់ខ្លួន ហោះទៅឰដ៏អាកាស ។ ក្នុងកាលនោះ តថាគតឃើញជនមានសោមនស្ស ត្រេកអររីករាយចិត្ត ទើបចុះពីអាកាស សួរពួកមនុស្សក្នុងខណៈនោះថា មហាជនអ្នកមានសោមនស្ស មានការត្រេកអរ រីករាយហើយជម្រះ ធ្វើផ្លូវដើម្បីអ្នកណា? ពួកមហាជនទាំងនោះ ត្រូវតថាគតសួរហើយ ទើបប្រាប់ដល់តថាគតថា ព្រះជិនពុទ្ធ ទ្រង់ព្រះនាមថា ទីបង្ករ មិនមានអ្នកណាក្រៃលែងជាង, ជាលោកនាយក, ទ្រង់ឧប្បត្តិឡើងក្នុងលោក មហាជនបោសច្រាសផ្លូវធ្វើថ្នល់តភ្ជាប់គ្នាទៅ ដើម្បីព្រះអង្គនោះ ព្រោះស្តាប់ព្រះនាមថា “ពុទ្ធោ” បីតិក៏កើតឡើងដល់តថាគត ក្នុងខណៈនោះ,

កាលតថាគតពោលថា "ពុទ្ធោ ពុទ្ធោ" ទើបប្រកាសនូវសោមនស្ស ។ យើងមានសេចក្តីត្រេកអរហើយ ក៏មានចិត្តស្លុត ឈរគិតក្នុងទីនោះថា "អញនឹងដាំពូជទាំងឡាយទុកក្នុងទីនេះ, ខណោ មា វោ ឧបច្ចគ្គា ខណៈ (វេលា) កុំបានកន្លងនូវអញទៅឡើយ" ។ បើថា ពួកអ្នកបោសច្រាសផ្លូវ ដើម្បីព្រះពុទ្ធជាម្ចាស់សោត, សូមពួកអ្នកឱ្យឱកាស (ផ្លូវ) មួយភាគដល់អាត្មាចុះ សូម្បីអាត្មាអញក៏បោសច្រាសផ្លូវធ្វើថ្នល់ដែរ ។ ពួកគេក៏បានឱ្យឱកាសមួយភាគដល់តថាគត ដើម្បីជម្រះធ្វើថ្នល់ ក្នុងគ្រានោះ តថាគតកាលគិតថា "ពុទ្ធោ ពុទ្ធោ" ហើយទើបជម្រះផ្លូវក្នុងកាលនោះ ។ កាលផ្លូវថ្នល់របស់តថាគត មិនទាន់សម្រេច ព្រះជិនមហាមុនីទីបង្ករ ព្រមទាំងព្រះខីណាស្រពប្រមាណបួនសែន អ្នកមានអភិញ្ញា ៦, អ្នកមាំទាំ (តាទិបុគ្គល) ប្រាសចាកមន្ទិល, ក៏ស្តេចដំណើរមកកាន់ផ្លូវ ។ ការក្រោកឡើងទទួល ក៏កំពុងប្រព្រឹត្តទៅ ស្គរតន្ត្រីទាំងឡាយជាច្រើន ក៏គឹកកងឡើង, ពួកមនុស្ស និងទេព្តាទាំងឡាយ ម្នាក់ៗ ក៏នាំគ្នាត្រេកអររីករាយ បានញុំាងសាធុការឱ្យប្រព្រឹត្តទៅហើយ ។ ពួកទេព្តាមើលឃើញពួកមនុស្ស សូម្បីពួកមនុស្សក៏មើលឃើញពួកទេព្តា ពួកទេព្តា និងមនុស្សទាំងពីរ ម្នាក់ៗ ក៏លើកដៃប្រណម្យដើរតាមព្រះតថាគត ។ ពួកទេព្តាក៏ប្រគុំតន្ត្រីទិព្វ ពួកមនុស្សក៏ប្រគុំតន្ត្រីរបស់មនុស្ស, ពួកទេព្តា និងមនុស្សសូម្បីទាំងពីរ ម្នាក់ៗ ក៏ប្រគុំតន្ត្រីតាមព្រះតថា

គត ។ ពួកទេព្តាទៅតាមផ្លូវអាកាសរោយរាយផ្កាមន្ទារវៈ (ឈ្មោះឈើសូគីមួយប្រភេទ)* ផ្កាបទុម ផ្កាបារិឆត្តកៈដ៏ជាទិព្វ ទៅកាន់ទិសតូចទិសធំ និងបានរោយលំអិតចន្ទន៍ និងគ្រឿងក្រអូបដ៏ប្រសើរ ដែលជាទិព្វចុះកាន់ទិសតូចទិសធំទាំងអស់ ។ ពួកមនុស្សដែលដើរតាមផ្ទៃដីម្នាក់ៗបាចផ្កាចម្បា ផ្កាសលឡៈ ផ្កានីបៈ ផ្កាបុសនាគ និងផ្កាការកេត សព្វគ្រប់ទិសានុទិស ។ ចំណែកតថាគត រំសាយសក់ចេញ ដោះសំពត់សម្បកឈើ និងស្បែកខ្លាក្រាលលើភក់ ហើយដេកផ្កាប់ចុះ (ដោយតាំងចិត្តថា) សូមព្រះពុទ្ធជាម្ចាស់ ព្រមទាំងពួកសាវ័ក ស្តេចយាង និងនិមន្តជាន់ខ្ញុំព្រះអង្គចុះ, ទ្រង់កុំបានជាន់ភក់ឡើយ, ការដែលព្រះអង្គទ្រង់ដំណើរទៅដូច្នោះ នឹងជាប្រយោជន៍ដល់ខ្ញុំព្រះអង្គ ។ កាលខ្ញុំព្រះអង្គ ដេកលើផ្ទៃដីហើយ បានមានការគិតយ៉ាងនេះថា អញកាលប្រាថ្នាហើយ ថ្ងៃនេះនឹងសម្លាប់កិលេសទាំងឡាយបាន ។ ការដែលអញធ្វើឱ្យជាក់ច្បាស់នូវធម៌ដោយភេទ ដែលបុគ្គលដទៃមិនដឹងក្នុងពេលនេះ នឹងមានប្រយោជន៍អ្វី? អញសម្រេចសព្វញ្ញុតញ្ញាណ ហើយនឹងជាព្រះពុទ្ធក្នុងលោកព្រមទាំងទេវលោក ។ ការដែលអញជាបុរស សម្តែងការអាចឆ្លងទៅតែម្នាក់ឯងនឹងមានប្រយោជអ្វី? អញសម្រេចនូវសព្វញ្ញុត

---

* ខ្មែរហៅដើមឈើតូចមួយប្រភេទ ពួកយីហ៊ុប ស្លឹក និងផ្កាធំជាងយីហ៊ុប ផ្កាខ្ជិនក្រអូបឈ្ងុយ ។

ញ្ញាណហើយ នឹងញ៉ាំងមនុស្សលោក ព្រមទាំងទេវលោក ឱ្យឆ្លងទៅព្រមគ្នា ។ ការដែលអញជាបុរសមានបុញ្ញាធិការបានកសាងហើយ ដល់ការអាចឆ្លងម្នាក់ឯងនេះ នឹងមានប្រយោជន៍អ្វី? អញសម្រេចនូវសព្វញ្ញុតញ្ញាណហើយ នឹងញ៉ាំងពួកជនដ៏ច្រើនឱ្យឆ្លងតាមអញ ។ កាត់ក្រសែសំសារ កម្ចាត់ភពទាំងបី ឡើងកាន់ធម្មនាវា ហើយនឹងញ៉ាំងមនុស្សលោក ព្រមទាំងទេវលោកឱ្យឆ្លងទៅព្រមគ្នា ។ ព្រះពុទ្ធទីបង្ករព្រះអង្គដឹងច្បាស់នូវលោក ព្រះអង្គសមគួរទទួលគ្រឿងសក្ការៈ ដែលគេនាំមកបូជា ទ្រង់គង់ឈរលើសីសៈអាត្មាអញ បានត្រាស់ពាក្យនេះថា ៖-

"ពួកអ្នកចូរមើលតាបសនេះ អ្នកជាជដិលមានតបៈដ៏ខ្ពស់ ក្នុងកប្បដែលរាប់មិនបាន ពីកប្បនេះទៅ នឹងជាព្រះពុទ្ធក្នុងលោក អ្នកជាតថាគត ស្តេចចេញអំពីក្រុងកបិលពស្តុ ដែលគួរីករាយ និងទ្រង់តាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា។ នឹងទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ទ្រង់ទទួលបាយមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ទ្រង់សោយបាយបាយាសត្រង់ឆ្នេរស្ទឹង ឈ្មោះថានេរញ្ជរា ទើបស្តេចទៅកាន់គល់ពោធិព្រឹក្ស ដោយផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។

តអំពីនោះ ក៏ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹង

ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានយសធំ ក្រោមដើមអស្សត្ថព្រឹក្ស ។ ព្រះមាតាជាជនី (អ្នកបង្កើត) នៃតាបសនេះ នឹងមាននាមថា មាយា, ព្រះបិតាមាននាមថា សុទ្ធោទនៈ, តាបសនេះនឹងជាគោតមគោត្រ (ពូជពង្សនៃព្រះគោតម) គឺព្រះពុទ្ធជាម្ចាស់, ព្រះកោលិតៈ និងព្រះឧបតិស្សៈ អ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ តាំងមាំហើយ នឹងជាគូអគ្គសាវ័ក, ភិក្ខុអ្នកឧបដ្ឋាកឈ្មោះថា អានន្ទ នឹងបម្រើព្រះជិនស្រីនោះ ។ នាងខេមា និងនាងឧប្បលវណ្ណា អ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់តាំងមាំហើយ នឹងជាគូអគ្គសាវិកា, ដើមឈើដែលជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស" ។

ពួកមនុស្ស និងទេវតាបានស្តាប់ព្រះតម្រាស់នៃព្រះមហេសី ព្រះអង្គឥតមានអ្នកណាមួយស្មើថា "តាបសនេះនឹងជាពុទ្ធវីជង្កុរ (គឺជាពន្លកពូជនៃព្រះពុទ្ធ)" ក៏នាំគ្នាត្រេកអររីករាយចិត្ត, សំឡេងកើតអំពីការរីករាយប្រាមោទ្យដ៏ក្រៃលែង ក៏បន្លឺលាន់ឮ ។ ពួកមនុស្ស និងពួកទេវតាទាំងមួយហ្មឺនលោកធាតុ ក៏ទះដៃរីករាយ ប្រណម្យដៃនមស្ការ តាំងសេចក្តីប្រាថ្នាថា "កាលបើពួកយើង នឹងភ្លាត់ចាកសាសនានៃលោកនាថនោះ ក្នុងអនាគតកាល ពួកយើងក៏នឹងជួបជាមួយតាបសនេះ ប្រៀបដូចមនុស្សទាំងឡាយ អ្នកឆ្លងស្ទឹងធំ ភ្លាត់កំពង់ដែលតាំង

នៅចំពោះមុខ ក៏ចាប់យកកំពង់ក្រោម ឆ្លងមហាននទីបាន យ៉ាងណា ។ ពួកយើងទាំងអស់ ក៏យ៉ាងនោះដែរ បើផុតពីព្រះជិនស្រីព្រះអង្គនេះ ក្នុងអនាគត ក៏ជួបប្រទះតាបសនេះ ។ ព្រះពុទ្ធទីបង្ករជាលោកវិទូ ព្រះអង្គគួរទទួលគ្រឿងសក្ការៈ ដែលមនុស្ស និងទេវតា នាំមកបូជាហើយ ទ្រង់ប្រកាសកម្មរបស់យើង, ក៏ទ្រង់លើកព្រះបាទខាងស្តាំឡើង ស្តេចយាងដំណើរទៅ" ។ ពួកជិនបុត្រណានៅក្នុងទីនោះទាំងអស់គ្នា ម្នាក់ៗ ក៏ធ្វើប្រទក្សិណតថាគត ពួកមនុស្ស នាគ គន្ធព្វ ម្នាក់ៗ ក៏អភិវាទ ហើយចៀសចេញទៅ ។ កាលព្រះលោកនាថព្រមទាំងភិក្ខុសង្ឃនិមន្តផុតទៅដាច់កន្ទុយភ្នែក (ផុតទស្សនវិស័យ) តថាគត។ មានចិត្តត្រេកអររីករាយ ហើយក្រោកចាកអាសនៈក្នុងកាលនោះ ។ តថាគតមានសេចក្តីសុខដោយសេចក្តីសុខ, មានការរីករាយដោយការរីករាយ, បរិបូរណ៍ហើយដោយបីតិ អង្គុយផ្គត់ន្ទូវភ្នែនក្នុងកាលនោះ ។ លុះតថាគតអង្គុយផ្គត់ន្ទូវភ្នែន (បល្លង្ក) ក្នុងកាលនោះ ហើយបានមានការគិតយ៉ាងនេះថា ៖-

អញជាអ្នកជំនាញក្នុងឈាន ដល់អភិញ្ញាបារមីហើយ ។ ឥសីទាំងឡាយក្នុងហ្មឺនលោកធាតុ មិនស្មើអញ, អញគ្មានអ្នកណាស្មើក្នុងឥទ្ធិធម៌បានសេចក្តីសុខដូច្នេះ ។ កាលអញអង្គុយផ្គត់ភ្នែន ពួកទេវតាក្នុងហ្មឺនលោកធាតុ មួយអង្គ។ ក៏ឧទានវាចាបន្លឺសំឡេង លាន់ឮទៅថា

“លោកនឹងជាព្រះពុទ្ធយ៉ាងពិតប្រាកដ” , និមិត្តទាំងឡាយណា នៃព្រះពោធិសត្វទាំងឡាយក្នុងកាលមុន មកប្រាកដដល់តថាគតអ្នកអង្គុយផ្គត់ភ្នែនដ៏ប្រសើរ, និមិត្តទាំងឡាយនោះប្រាកដក្នុងថ្ងៃនេះ ។ ភាពត្រជាក់ប្រាសទៅ និងភាពក្ដៅតែងស្ងប់រម្ងាប់ ទៅក្នុងកាលមុនឯណា, និមិត្តទាំងនោះ តែងប្រាកដហើយដល់តថាគតក្នុងថ្ងៃនេះថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ មួយហ្មឺនលោកធាតុ គ្មានសំឡេងច្របូកច្របល់ជ្រួលជ្រើម ប្រាកដដល់តថាគតក្នុងកាលមុន និមិត្តទាំងនោះ ប្រាកដដល់តថាគតក្នុងថ្ងៃនេះថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ មហាវាយោមិនបក់ ស្ទឹងទាំងឡាយមិនហូរទៅ ក្នុងកាលមុនឯណា និមិត្តទាំងនោះប្រាកដដល់តថាគតក្នុងថ្ងៃនេះថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ផ្កាឈើទាំងឡាយដែលកើតលើគោក ដែលកើតក្នុងទឹកទាំងអស់ ក៏រីកក្នុងកាលមុន, ផ្កាឈើក៏រីកហើយក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ វល្លិ ឬដើមឈើមានផ្លែក្នុងកាលនោះ វល្លិ ឬដើមឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ រតនៈទាំងឡាយដែលឋិតនៅឰដ៏អាកាសក្ដី លើផែនដីក្ដី រុងរឿងក្នុងគ្រានោះ សូម្បីរតនៈទាំងឡាយនោះ ក៏រុងរឿងក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ តន្ត្រីទាំងឡាយ

ដ៏ច្រើនរបស់មនុស្ស និងជាទិព្វដែលឮក្នុងកាលមុន សូម្បីតន្ត្រីទាំងនោះ ក៏ឮក្នុងថ្ងៃនេះជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ផ្កាដ៏វិចិត្រធ្លាក់ពីអាកាសក្នុងកាលមុន, សូម្បីផ្កាទាំងនោះក៏ធ្លាក់ក្នុងថ្ងៃនេះជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ មហាសមុទ្រកញ្រ្ជោលហ្មឺនលោកធាតុកក្រើកញ័រក្នុងកាលនោះ សូម្បីនិមិត្តទាំងពីរនោះ ក៏ឮក្នុងថ្ងៃនេះថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ភ្លើងក្នុងនរកទាំងហ្មឺនលោកធាតុ ក៏រលត់ក្នុងខណៈនោះ ភ្លើងក្នុងនរកទាំងហ្មឺនលោកធាតុក៏រលត់ហើយក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ព្រះអាទិត្យប្រាសចាកមន្ទិល ដួងតារាទាំងពួងប្រាកដ ក្នុងកាលមុន សូម្បីនិមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះថា “អ្នកនឹងជាព្រះពុទ្ធ ដ៏ទៀង” ។ ទឹកផុសឡើងពីផែនដី ដោយភ្លៀងមិនបានធ្លាក់ក្នុងកាលមុននោះ សូម្បីទឹកនោះ ក៏ផុសឡើងពីផែនដីក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ ពួកផ្កាយនក្ខត្តឫក្សទាំងឡាយ ប្រកបដោយដួងចន្ទជាវិសាខបុណ្ណមី រុងរោចន៍ក្នុងមណ្ឌលនៃពពក ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ ពួកសត្វដែលអាស្រ័យរន្ធ និងអាស្រ័យតាមញកភ្នំ ចេញអំពីទីនៅរបស់ខ្លួន សត្វទាំងនោះ ក៏ចេញអំពីទីនៅរបស់ខ្លួនក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ សត្វ

ទាំងឡាយមិនមានការច្រណែនគ្នា មានសេចក្តីត្រេកអរក្នុងកាលនោះ ក៏ត្រេកអរសូម្បីក្នុងកាលនេះជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ រោគទាំងឡាយស្ងប់រម្ងាប់ សេចក្តីស្រេកឃ្លានវិនាសបាត់ទៅ ក្នុងកាលនោះ សូម្បីវត្ថុទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ រាគៈស្រាលស្តើង ទោសៈ និងមោហៈតែងវិនាសបាត់ទៅ ក្នុងកាលនោះ សូម្បីកិលេសទាំងឡាយទាំងអស់នោះ ប្រាសទៅហើយ ក្នុងថ្ងៃនេះជានិមិត្តថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង”។ ភ័យមិនមានក្នុងគ្រានោះ សូម្បីក្នុងថ្ងៃនេះ ភ័យនោះក៏មិនប្រាកដ ព្រោះនិមិត្តនោះៗ ទើបពួកខ្ញុំជ្រាបថា “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ធូលីមិនហុយឡើងខាងលើក្នុងពេលនោះ សូម្បីធូលីនេះ ក៏មិនប្រាកដក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ ទើបពួកខ្ញុំជ្រាបថា “អ្នកនឹងជាព្រះពុទ្ធ ដ៏ទៀង”។ ក្លិនមិនគួរប្រាថ្នាជៀសចេញទៅ ក្លិនទិព្វតែងផ្សាយទៅក្នុងកាលនោះ ក្លិនក្រអូបដ៏ជាទិព្វនោះ ផ្សាយទៅក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ពួកទេវតាទាំងអស់ វៀរអរូបព្រហ្មចេញ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ “អ្នកនឹងជាព្រះពុទ្ធដ៏ទៀង” ។ ឈ្មោះថា នរកទាំងឡាយទាំងអស់ប្រាកដក្នុងគ្រានោះ សូម្បីនរកទាំងឡាយទាំងអស់នោះ ក៏ប្រាកដ

ក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ "អ្នកនឹងជាព្រះពុទ្ធដ៏ទៀង" ។ ជញ្ជាំងផ្ទះ សន្ទះទ្វារ និងថ្ម តែងមិនជាគ្រឿងរាំងខ្សែភ្នែក ក្នុងគ្រានោះ ទព្វសម្ភារៈទាំងឡាយនោះ ដូចអាកាសសូម្បីក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ "អ្នកនឹងជាព្រះពុទ្ធដ៏ទៀង"។ ចុតិ និងឧបបត្តិ មិនប្រាកដក្នុងថ្ងៃនេះ ព្រោះនិមិត្តនោះ "អ្នកនឹងជាព្រះពុទ្ធដ៏ទៀង" និមិត្តទាំងឡាយនេះ តែងប្រាកដដល់សត្វទាំងឡាយ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង សូមអ្នកផ្គងសេចក្តីព្យាយាមឱ្យមាំ កុំដកថយ ចូរឈានទៅខាងមុខ សូម្បីយើងក៏ដឹងច្បាស់នូវនិមិត្តនោះថា "អ្នកនឹងជាព្រះពុទ្ធដ៏ទៀង" ។

យើង (សុមេធបណ្ឌិត) ស្តាប់ព្រះតម្រាស់នៃព្រះពុទ្ធ និងពួកទេវតាហ្មឺនលោកធាតុទាំងពីរហើយ មានសេចក្តីសោមនស្សត្រេកអររីករាយសប្បាយចិត្ត បានមានការគិតក្នុងកាលនោះយ៉ាងនេះថា ព្រះពុទ្ធទាំងឡាយ មានព្រះតម្រាស់គ្មានពីរឡើយ, ព្រះជិនស្រីទាំងឡាយមានព្រះវាចាមិនជាមោឃៈឡើយ, សំដីដែលមិនពិត មិនមានដល់ព្រះពុទ្ធទាំងឡាយឡើយ, អញនឹងជាព្រះពុទ្ធមែន ។ ដុំដីដែលបុគ្គលគ្រវែងទៅឰដ៏អាកាស តែងធ្លាក់ចុះទៅកាន់ផែនដីមែនពិត យ៉ាងណា, ព្រះតម្រាស់របស់ព្រះពុទ្ធ ព្រះអង្គប្រសើរបំផុត ជាព្រះតម្រាស់ទៀងប្រាកដ ក៏យ៉ាងនោះដែរ ។ សេចក្តីស្លាប់ ជារបស់ពិតដល់សព្វសត្វ

ទាំងឡាយ យ៉ាងណា, ព្រះតម្រាស់របស់ព្រះពុទ្ធគ្រប់អង្គប្រសើរបំផុត ក៏ជាព្រះតម្រាស់ទៀងប្រាកដ យ៉ាងនោះដែរ ។ កាលរាត្រីអស់ទៅហើយ ព្រះអាទិត្យរះឡើងពិតប្រាកដ យ៉ាងណា, ព្រះតម្រាស់របស់ព្រះពុទ្ធប្រសើរបំផុត ក៏ជាព្រះតម្រាស់ទៀងប្រាកដ យ៉ាងនោះដែរ ។ កាលសត្វសីហៈចេញចាកទីដេកហើយ ទៀងតែបន្លឺសំឡេង យ៉ាងណា, ព្រះតម្រាស់របស់ព្រះពុទ្ធព្រះអង្គប្រសើរបំផុត ក៏ជាព្រះតម្រាស់ទៀងប្រាកដ យ៉ាងនោះដែរ ។ សត្វទាំងឡាយលីរបស់ធ្ងន់ ទៅដល់ទីប្រាថ្នាហើយ តែងដាក់ចុះមែនពិត យ៉ាងណា, ព្រះតម្រាស់របស់ព្រះពុទ្ធ ព្រះអង្គប្រសើរបំផុត ក៏ជាព្រះតម្រាស់ ទៀងប្រាកដ យ៉ាងនោះដែរ ។

## សម្តែងអំពីពុទ្ធការកធម៌ ១០ យ៉ាង

ណ្ហើយចុះ អាត្មាអញនឹងពិចារណា (ជ្រើសរើស) ធម៌ទាំងឡាយដែលអភិសេកឱ្យទៅជាព្រះពុទ្ធ ផ្លូវនោះ និងផ្លូវនេះ ទាំងខាងលើ ទាំងខាងក្រោម គ្រប់ទិសទាំង ១០ រហូតដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងត្រិះរិះ ក៏បានរកឃើញ **ទានបារមី** ដែលជាពុទ្ធការកធម៌ទី ១ ជាគន្លងធំ ដែលព្រះមហេសីទាំងឡាយក្នុងកាលមុន ទ្រង់សន្សំហើយ ។ ទើបទូន្មានខ្លួនឯងថា អ្នកចូរបំពេញទានបារមី ដែលជាពុទ្ធការកធម៌ខទី ១ នេះ សមាទានធ្វើទុកឱ្យមាំមួន បើអ្នកប្រាថ្នាសម្រេចពោធិញ្ញាណ, ប្រៀបដូចក្អមដែលបុគ្គលណាមួយផ្កាប់មាត់ចុះ ទឹកហូរចេញអំពីក្អមមិនបានសល់ មិនបានរក្សាទឹកទុកក្នុងក្អមនោះយ៉ាងណា; អ្នកបើឃើញពួកស្មូមទាំងឡាយស្មូមហើយ ទោះថោកទាប កណ្តាល និងខ្ពង់ខ្ពស់ ចូរឱ្យទានមិនមានសេសសល់ ឱ្យដូចក្អមដែលគេផ្កាប់ចុះយ៉ាងនោះដែរ ។

ពិតណាស់ ពុទ្ធការកធម៌មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងពិចារណាពុទ្ធធម៌ដែលបន្ទុំពោធិញ្ញាណដទៃៗទៀត កាលតថាគតត្រិះរិះហើយក្នុងគ្រានោះ ក៏បានឃើញ **សីលបារមី** ជាពុទ្ធការកធម៌ខទី

២ ដែលព្រះមហេសីទាំងឡាយ ក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនថា អ្នកបំពេញសីលបារមី ដែលជាពុទ្ធការកធម៌ ខទី ២ នេះ, សមាទានធ្វើឱ្យមាំមួន បើអ្នកចង់សម្រេចពោធិញ្ញាណ ។

សត្វចាមរី មានរោមកន្ទុយជាប់ជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់រោមកន្ទុយចោលឡើយ យ៉ាងណាមិញ, អ្នកចូរបំពេញសីលទាំងឡាយក្នុងភូមិ ៤,[៥៨] ចូររក្សាសីលសព្វកាល ឱ្យដូចសត្វចាមរី[៥៩] រក្សារោមកន្ទុយយ៉ាងនោះចុះ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណារកធម៌ទាំងឡាយដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច កាលនោះ តថាគតកំពុងត្រិះរិះរក ក៏បានឃើញ **នេក្ខម្មបារមី** ដែលជាពុទ្ធការកធម៌ខទី ៣ ដែលព្រះមហេសីទាំងឡាយ ក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនថា អ្នកចូរបំពេញនេក្ខម្ម

---

[៥៨] មូល. និងអដ្ឋ. យ. ពាក្យថា ភូមិ ៤ បានដល់ សំវរភូមិទាំងឡាយ មានបាតិមោក្ខសំវរភូមិជាដើម ។

[៥៩] អដ្ឋ. យ. ធម្មតាសត្វចាមរីពេលណារោមកន្ទុយរបស់វាជាប់នៅត្រង់កន្លែងណា វាស៊ូងាប់ មិនព្រមឱ្យរោមកន្ទុយរបស់វាដាច់ឡើយ ។

បារមីដែលជាពុទ្ធការកធម៌ខទី ៣ នេះ សមាទានធ្វើឱ្យមាំមួន បើអ្នកចង់សម្រេចពោធិញ្ញាណ ។ បុរសដែលជាប់ក្នុងគុកអស់កាលដ៏យូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរឱ្យកើតឡើង ក្នុងគុកនោះទេ រមែងស្វែងរកការរួចទៅប៉ុណ្ណោះ យ៉ាងណា, ចូរអ្នកមើលភពទាំងអស់ដូចជាគុកចុះ, អ្នកចូរបែរមុខទៅរកនេក្ខម្ម ដើម្បីរួចចាកភពយ៉ាងនោះដែរ ។

ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណារកពុទ្ធធម៌ដទៃៗ ទៀត ដែលជាធម៌ញុំាងពោធិញ្ញាណ ឱ្យសម្រេច ។ កាលនោះ តថាគតកំពុងត្រិះរិះក៏បានឃើញ **បញ្ញាបារមីទី ៤** ដែលព្រះមហេសីទាំងឡាយក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ។ ទើបទូន្មានខ្លួនថា អ្នកចូរបំពេញបញ្ញាបាមីទីបួននេះ សមាទានធ្វើឱ្យមាំមួន បើអ្នកចង់សម្រេចពោធិញ្ញាណ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនវៀលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ យ៉ាងណា, អ្នកកាលសាកសួរជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមីហើយ នឹងបានសម្រេច

ពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណារកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។ កាលនោះតថាគតកំពុងត្រិះរិះរកក៏បានឃើញ **វីរិយបារមីទី ៥** ដែលព្រះមហេសីទាំងឡាយក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនឯងថា អ្នកចូរសមាទានធ្វើវីរិយបារមីទី ៥ នេះឱ្យមាំមួន បើអ្នកចង់សម្រេចពោធិញ្ញាណ, ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈ ជាស្តេចម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គងឡើងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា, អ្នកចូរផ្គងឡើងនូវព្យាយាម ឱ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ; លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណ ឱ្យសម្រេច ។ កាលនោះ តថាគតកំពុងត្រិះរិះ ក៏បានឃើញ **ខន្តិបារមីទី ៦**

ដែលព្រះមហេសីទាំងឡាយក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ។ ទើបទូន្មានខ្លួនឯងថា អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះឱ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់ពោធិញ្ញាណ មិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទាំងស្អាតក្តី ទាំងមិនស្អាតក្តី ដែលធ្លាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា, អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួង យ៉ាងនោះដែរ; លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងត្រិះរិះរក ក៏បានឃើញ **សច្ចបារមីទី** ៧ ដែលព្រះមហេសីទាំងឡាយក្នុងកាលមុន បដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនថា ចូរអ្នកសមាទានធ្វើនូវសច្ចបារមីទី ៧ នេះឱ្យមាំមួន កុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹកជាជញ្ជីងរបស់លោក ព្រមទាំងទេវ

លោក រមែងមិនឃ្លាតចាកវីចិក្នុងវស្សារដូវ ឬហេមន្តរដូវឡើយ យ៉ាងណា, អ្នកកុំឃ្លាតចាកវីចិក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ; លុះដល់សច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណាធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងត្រិះរិះរក ក៏បានឃើញ **អធិដ្ឋានបារមីទី ៨** ដែលព្រះមហេសីទាំងឡាយ ក្នុងកាលមុន បដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនថា អ្នកចូរសមាទានធ្វើនូវអធិដ្ឋានបារមីទី ៨ នេះឱ្យមាំមួន, អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មសុទ្ធឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា, អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណារកធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច។

កាលនោះ តថាគតកំពុងត្រិះរិះរក ក៏បានឃើញ **មេត្តាបារមីទី ៩** ដែលព្រះមហេសីទាំងឡាយ ក្នុងកាលមុន បដិបត្តិហើយ ធ្លាប់សេពហើយ ។ ទើបទូន្មានខ្លួនថា អ្នកចូរសមាទានធ្វើនូវមេត្តាបារមីទី ៩ នេះឱ្យមាំមួន ចូរកុំឱ្យមានបុគ្គលដទៃ ស្មើដោយមេត្តា បើអ្នកចង់លុះពោធិញ្ញាណ ។ ធម្មតាទឹក រមែងផ្សព្វផ្សាយនូវភាព ត្រជាក់ស្មើចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា, អ្នកចូរចម្រើនមេត្តាឱ្យស្មើចំពោះមិត្ត និងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងពិចារណារកធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឱ្យសម្រេច។ កាលនោះ តថាគតកំពុងត្រិះរិះរក ក៏បានឃើញ **ឧបេក្ខាបារមីទី ១០** ដែលព្រះមហេសីទាំងឡាយក្នុងកាលមុនបដិបត្តិហើយ ធ្លាប់សេពហើយ។ ទើបទូន្មានខ្លួនថា អ្នកចូរសមាទានធ្វើឧបេក្ខាបារមីទី ១០ នេះឱ្យមាំមួន នឹងសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដីតែងព្រងើយកន្តើយចំពោះវត្ថុស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាក

សេចក្ដីក្រោធ និងសេចក្ដីត្រេកអរចំពោះវត្ថុទាំងពីរនោះយ៉ាងណា, អ្នកចូរធ្វើខ្លួនឱ្យដូចជញ្ជីងចំពោះសុខ និងទុក្ខ សព្វកាលយ៉ាងនោះដែរ; អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខាន ។ ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណ ឱ្យសម្រេចធម៌ទាំងឡាយនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណេះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមីធម៌ទាំង ១០ នេះ មិនមានទេ, អ្នកចូរតាំងនៅក្នុងបាមីធម៌ទាំង ១០ នោះឱ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីទាំងនេះ ដោយសភាវៈ រសលក្ខណៈ (លក្ខណៈនៃសភាវៈដែលមានកិច្ចនាទី) ផែនដីទាំងមួយហ្មឺនលោកធាតុ ក៏ញាប់ញ័រដោយតេជៈនៃធម៌ ។ ផែនដីកម្រើកបន្លឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាប ឬចក្រយន្តប្រេង ត្រូវគេគាបហើយ (រមែងវិលញ័រ) យ៉ាងណា, ផែនដី ក៏កម្រើកយ៉ាងនោះដែរ ។

មហាសមុទ្រទាំងឡាយ ក៏បោះពពុះ (កញ្ច្រោល) បន្តគ្នា ទាំងកំពូលភ្នំ រមែងបង្អោនចុះក្នុងមហាសមុទ្រនោះ លុះបង្អោនចុះហើយ សំឡេងឮ ហឹ ហឹ ក៏ឮ ខ្ទ័រទៅហើយលើភ្នំសិនេរុរាជ ។ បរិស័ទទាំងឡាយនៅក្នុងទីអង្គាសព្រះពុទ្ធ ញាប់ញ័រ ហើយបាត់សតិ ដួលចុះជិតផែនដី ក្នុង

ទីនោះ ។ ក្អមច្រើនពាន់ឆ្នាំង ច្រើនរយ ប៉ះទង្គិចគ្នានឹងគ្នា បែកខ្ទេចខ្ទីទៅក្នុងទីនោះ ។ មហាជនទាំងឡាយបែកគ្នា ក៏តក់ស្លុត ភ័យខ្លាចស្លន់ស្លោផ្អើលមកជុំគ្នា ចូលគាល់ព្រះពុទ្ធទីបង្ករ ទូលសួរថា បពិត្រព្រះភគវា ព្រះអង្គមានចក្ខុ សេចក្តីល្អ ឬសេចក្តីអាក្រក់ នឹងមានដល់សត្វលោក យ៉ាងណា, លោកទាំងអស់ត្រូវឧបទ្រពហើយ សូមព្រះអង្គទ្រង់បន្ទោបង់ នូវឧបទ្រពនោះផងចុះ ។ គ្រានោះ ព្រះមហាមុនីទីបង្ករ ញ៉ាំងមហាជនទាំងនោះឱ្យជ្រាបថា អ្នកទាំងឡាយ ចូររសាយចិត្តចុះ កុំខ្លាចឡើយ ក្នុងការកម្រើកនៃផែនដីនេះ ។ តថាគតបានព្យាករតាបសណា ក្នុងថ្ងៃនេះថាតាបសនោះនឹងជាព្រះពុទ្ធក្នុងលោក តាបសនេះ ពិចារណាធម៌ ដែលព្រះជិនស្រី ធ្លាប់សេពហើយ ក្នុងកាលមុន ។ កាលតាបសនោះ ពិចារណាធម៌ដែលជាពុទ្ធភូមិ ដោយមិនសេសសល់ ដោយហេតុនោះ ផែនដីមួយហ្មឺនលោកធាតុ ក្នុងមនុស្ស និងទេវតានេះ ទើបកម្រើក ។ ព្រោះស្តាប់ព្រះតម្រាស់ព្រះពុទ្ធ ចិត្តរបស់ពួកមហាជននោះស្ងប់ហើយ ក្នុងខណៈនោះ មនុស្ស និងទេវតាទាំងអស់ ចូលទៅរកតថាគត ហើយថ្វាយបង្គំម្តងទៀត ។ យើងសមាទាននូវពុទ្ធគុណ ធ្វើចិត្តឱ្យមាំ ហើយនមស្ការព្រះពុទ្ធទីបង្ករ ទើបក្រោកចាកអាសនៈក្នុងខណៈនោះ ។ កាលតថាគតក្រោក

ចាកអាសនៈ ទេវតា និងពួកមនុស្សទាំងពីរពួក ម្នាក់ៗ ក៏រោយផ្កាទាំងរបស់ទិព្វ ទាំងរបស់មនុស្ស ដោយផ្កាទាំងឡាយ ។ ពួកទេវតា និងមនុស្សទាំងពីរឱ្យតថាគតទទួលនូវសេចក្តីសួស្តីថា សេចក្តីប្រាថ្នាដែលលោកប្រាថ្នាជារឿងធំ, លោកនឹងបានពោធិញ្ញាណនោះតាមប្រាថ្នា ។ សព្វីតិយោ វិវជ្ជន្តុ, សព្វរោគោ វិនស្សតុ, មា តេ ភវត្វន្តរាយោ សូមឱ្យចង្រៃទាំងឡាយទាំងពួងប្រាសចេញទៅ សូមសោករោគទាំងពួងជៀសវាងទៅ អន្តរាយកុំបីមានដល់លោកឡើយ សូមលោកត្រាស់ដឹងនូវពោធិញ្ញាណដ៏ឧត្តមដោយឆាប់ចុះ ។ ដើមឈើផ្កា រីកក្នុងសម័យ (រដូវ) ដែលដល់ព្រមហើយ យ៉ាងណា, បពិត្រមហាវីរៈ សូមលោកបើកបង្ហាញនូវពុទ្ធញ្ញាណនោះឯងចុះ យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយអង្គឯណាមួយ ទ្រង់បំពេញបារមី ១០ យ៉ាងណា, បពិត្រមហាវីរៈ សូមលោកបំពេញបារមី ១០ ក៏យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយអង្គឯណាមួយ ត្រាស់ដឹងក្រោមពោធិមណ្ឌល យ៉ាងណា, បពិត្រមហាវីរៈ លោកចូរត្រាស់ដឹងនូវពោធិញ្ញាណនៃព្រះជិនស្រី ក៏យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយអង្គឯណាមួយ ទ្រង់ប្រកាសធម្មចក្រ យ៉ាងណា, បពិត្រមហាវីរៈ សូមលោក

ប្រកាសធម្មចក្រ ក៏យ៉ាងនោះដែរ, ព្រះចន្ទក្នុងថ្ងៃបុណ្ណមីដ៏បរិសុទ្ធ តែងរុងរឿង យ៉ាងណា, សូមលោកមានចិត្តពេញហើយញ៉ាំងហ្មឺនលោកធាតុឱ្យរុងរឿង ក៏យ៉ាងនោះចុះ ។ ព្រះអាទិត្យផុតចាករាហូហើយមានពន្លឺភ្លឺក្រៃលែង យ៉ាងណា, សូមលោករួចផុតចាកលោក ភ្លឺស្វាងដោយសិរីសួស្តី ក៏យ៉ាងនោះចុះ ។ ស្ទឹងទាំងឡាយឯណាមួយតែងហូរទៅកាន់មហាសមុទ្រ យ៉ាងណា, សូមមនុស្សលោក ព្រមទាំងទេវលោក ហូរទៅកាន់សំណាក់របស់លោក ក៏យ៉ាងនោះដែរ ។

គ្រានោះ តថាគតដែលទេវតា និងមនុស្សទាំងឡាយ សរសើរហើយ សមាទានធម៌ ១០។ កាលបំពេញធម៌ទាំងឡាយនោះឱ្យបរិបូរណ៍ទើបចូលទៅកាន់ព្រៃធំ (ព្រៃហេមពាន្ត) ក្នុងកាលនោះឯង ។๛

**ចប់សុមេធកថា**

មនុស្សក្នុងនគររម្មៈ អង្គាសព្រះលោកនាយក ព្រមទាំងព្រះសង្ឃក្នុងកាលនោះហើយ នាំគ្នាចូលទៅគាល់ព្រះសាស្តាព្រះនាមថា ទីបង្ករព្រះអង្គនោះជាសរណៈ ។ ព្រះតថាគតព្រះនាមទីបង្ករ ញ៉ាំងមនុស្សទាំង

ឡាយខ្លះ ឱ្យតាំងនៅក្នុងសរណគមន៍ ញ៉ាំងមនុស្សទាំងឡាយខ្លះ ឱ្យតាំងនៅក្នុងសីល ៥ ពួកខ្លះ ឱ្យតាំងនៅក្នុងសីល ១០ ដ៏ប្រសើរ ។ ព្រះអង្គប្រទានសាមញ្ញផល ៤ ដែលជាផលដ៏ឧត្តមដល់អ្នកណាមួយ ក្នុងធម៌ដែលគ្មានធម៌ដទៃស្មើ គឺឱ្យបដិសម្ភិទា ៤ ដល់អ្នកនោះ ។ ព្រះនរាសភៈ ទ្រង់ប្រទានសមាបត្តិដ៏ប្រសើរ ៨ ដល់អ្នកណាមួយ, ប្រទានវិជ្ជា ៣ និងអភិញ្ញា ៦ ដល់អ្នកណាមួយ ព្រះមហាមុនីព្រះនាមទីបង្ករ ត្រាស់ឱវាទប្រជុំជនដោយសេចក្តីព្យាយាមនោះ ញ៉ាំងសាសនៈរបស់ព្រះអង្គ ដែលជាទីពឹងនៃសត្វលោក ឱ្យពិស្តារហើយ ដោយព្យាយាមនោះ ។ ព្រះពុទ្ធទីបង្ករ ទ្រង់មានលក្ខណៈមានព្រះហនុ (ចង្កា) ធំ និងព្រះបំពង់សុរង់ (ក) ល្អសមលក្ខណៈ ញ៉ាំងជនទាំងឡាយជាច្រើនឱ្យផុតទុគ្គតិ ។ ព្រះមហាមុនីទ្រង់ឃើញនូវជនអ្នកគួរដល់ការត្រាស់ដឹងក្នុងផ្លូវ សូម្បីស្ថិតនៅសែនយោជន៍ក៏ទ្រង់យាងទៅញ៉ាំងជននោះឱ្យត្រាស់ដឹងក្នុងខណៈ (នោះ)។

ព្រះសាសនារបស់ព្រះទីបង្ករនោះ ក្នុងការត្រាស់ដឹងលើកដំបូងរបស់ពួកសត្វ បានមានប្រមាណដល់រយកោដិ, លើកទី ២ មានប្រមាណ ៩០ កោដិ ។

ក្នុងលើកទី ៣ ព្រះពុទ្ធត្រាស់សម្តែងក្នុងពិភពទេវតាជាន់តាវត្តិង្ស បានមានការត្រាស់ដឹងរបស់ទេវតា ដល់ ៩ ហ៊ឺនកោដិ ។

ក្នុងសាសនានៃព្រះទីបង្ករនោះ បានមានការប្រជុំធំ ៣ ដង លើកទី ១ មានសាវ័កប្រជុំប្រមាណ ១ សែនកោដិ, លើកទី ២ កាលព្រះជិនស្រីទ្រង់ចូលនិរោធសមាបត្តិ មាននារទកូដៈ មានព្រះខីណាស្រព អ្នកប្រាសចាកមន្ទិលមកប្រជុំ ១០០ កោដិ លើកទី ៣ កាលព្រះមហាវីរៈទ្រង់គង់លើភ្នំសុទស្សនៈ បានប្រជុំធ្វើបវរណាកម្ម ដោយភិក្ខុសង្ឃប្រមាណ ៩ ហ៊ឺនកោដិ ។

ក្នុងសម័យនោះ តថាគតបួសជាជដិល មានតបៈដ៏ខ្លាំងក្លា សម្រេចអភិញ្ញា ៥ ត្រាច់ទៅឰដ៏អាកាស ។ ធម្មាភិសម័យបានមានហើយ ដល់សត្វចំនួន ២ សែនកោដិនាក់, ចំណែកត្រាស់ដឹងម្តង ១.០០០ ឬ ២.០០០ មានប្រមាណច្រើនណាស់ ។ សាសនារបស់ព្រះភគវាទីបង្ករ ក្នុងកាលនោះ បរិសុទ្ធ ប្រាសចាកមន្ទិលច្រើន ចម្រើនរុងរឿង ជាប្រយោជន៍ដល់ជនច្រើនណាស់ ។ ព្រះខីណាស្រពប្រមាណ ៤ សែនរូប សម្រេចអភិញ្ញា ៦ មានឫទ្ធិច្រើន ចោមរោមព្រះពុទ្ធទីបង្ករ ព្រះអង្គទ្រង់ជ្រាបច្បាស់នូវ

លោកសព្វ១ កាល ។

សម័យនោះ អ្នកទាំងឡាយណាមួយ ដែលនៅជាសេក្ខបុគ្គល នៅមិនដល់ទីបំផុតនៃព្រហ្មចរិយធម៌ លះបង់ភារៈនៃមនុស្ស (ស្លាប់) ហើយទៅ ។ អ្នកទាំងនោះ ត្រូវគេតិះដៀល, ពាក្យធនះ គឺព្រះធម្មវិន័យនៃព្រះអង្គនោះ ដែលព្រះខីណាស្រពប្រាសចាកមន្ទិល ជាព្រះអរហន្តអ្នកនឹងធឹងលោកប្រកាសល្អហើយ រមែងស្អាតល្អក្នុងលោក ព្រមទាំងទេវលោក ។

នគរដែលព្រះអង្គទ្រង់ឧប្បត្តិឈ្មោះថា រម្មវតី ក្សត្រព្រះនាមថា សុទេព ជាព្រះបិតា ព្រះនាងសុមេធាទេវី ជាព្រះមាតានៃព្រះសាស្តា ព្រះនាមទីបង្ករ ។ ព្រះសុមង្គល និងព្រះតិស្ស ជាគូអគ្គសាវ័ក, ឧបដ្ឋាករបស់ព្រះទីបង្ករ ឈ្មោះសាគត, ព្រះថេរីព្រះនាមនន្ទា និងនាមសុនន្ទា បានជាអគ្គសាវិកា, ដើមពោធិ៍នៃព្រះមានព្រះភាគអង្គនោះ ហៅថា បិប្ផលិ (ដើមលាប) ។

ព្រះមហាមុនីទីបង្ករ មានព្រះវរកាយកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឈ្មោះសាលរាជ ដែលរីកស្គុះស្គាយ ។ រស្មីនៃព្រះអង្គ ផ្សាយទៅដោយជុំវិញ ១២ យោជន៍ មានព្រះជន្មាយុមួយសែនឆ្នាំ ព្រះអង្គធរ

មាននៅ ញ៉ាំងពួកជនជាច្រើនឱ្យឆ្លងផុតសង្សារ ព្រះអង្គញ៉ាំងព្រះសទ្ធម្ម ឱ្យរុងរឿងហើយ ឱ្យមហាជនឆ្លងផុតសាគរហើយអស់ព្រះជន្មាយុ ព្រះអង្គព្រមទាំងសាវ័ក បានប្រកាសធម៌វិន័យ ឱ្យរុងរោចន៍ ហើយក៏ស្ដេចរលត់ខន្ធបរិនិព្វាន ដូចគំនរភ្លើងដែលភ្លឺចិញ្ចែងចិញ្ចាច ហើយក៏រលត់ទៅ ។ ឫទ្ធិ យស និងចក្ករតនៈនោះ ជិតព្រះយុគលបាទទាំងអស់ ក៏អន្តរធានទៅព្រមគ្នា ព្រោះសង្ខារទាំងឡាយ ជារបស់សាបសូន្យ មានសេចក្ដីប្រែប្រួលទៅជាធម្មតាដ៏ទៀងទាត់ ៕

ចប់ទីបង្ករកថាទី ១

# កោណ្ឌញ្ញកថាទី ២

ក៏ក្នុងកាលចំណែកខាងក្រោយមក ព្រះមានព្រះភាគទីបង្ករទ្រង់បរិនិព្វានកន្លងទៅមួយអសង្ខេយ្យ ព្រះសាស្ដាព្រះនាម **កោណ្ឌញ្ញ** ក៏ស្ដេចឧប្បត្តិឡើង។ សូម្បីសាសនារបស់ព្រះមានព្រះភាគអង្គនោះ ក៏មានសាវកសន្និបាត( ប្រជុំសាវ័ក) ៣ ដង ការប្រជុំលើកទី ១ មានសាវ័កប្រជុំប្រមាណ ១ សែនកោដិ លើកទី ២ មានសាវ័កប្រជុំប្រមាណ ១ ពាន់កោដិ លើកទី ៣ មានសាវ័កប្រជុំប្រមាណ ៩០

កោដិ ។

គ្រានោះ ព្រះពោធិសត្វ ជាស្តេចចក្រពត្តិ មាននាមថា **វិជិតាវី** បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មានប្រមាណបាន ១ សែនកោដិ ព្រះសាស្តាបានព្យាករពោធិសត្វថា "អ្នកនឹងជាព្រះពុទ្ធ" ហើយសម្តែងធម៌ ។ ព្រះពោធិសត្វនោះ ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ប្រគល់រាជសម្បត្តិចេញសាងផ្នួស (បួស) ទ្រង់សិក្សាព្រះត្រៃបិដក ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឱ្យកើតឡើង មានឈានមិនសាបសូន្យ ហើយកើតក្នុងព្រហ្មលោក ។

ក៏នគររបស់ព្រះពុទ្ធព្រះនាម **កោណ្ឌញ្ញ** ឈ្មោះ **រម្មវតី** ក្សត្រព្រះនាម សុនន្ទ ជាព្រះរាជបិតា ព្រះនាងទេវីព្រះនាម **សុជាតា** ជាព្រះមាតា **ព្រះភទ្ទត្ថេរ** និង **ព្រះសុភទ្ទត្ថេរ** ជាអគ្គសាវ័ក, **ព្រះអនុរុទ្ធត្ថេរ** ជាឧបដ្ឋាក, **ព្រះតិស្សាថេរី** និង **ព្រះឧបតិស្សាថេរី** ជាអគ្គសាវិកា, ដើមពោធិ៍ឈ្មោះ **សាលកល្យាណី**, **ព្រះសរីរៈរបស់ព្រះមហាមុនីនោះ កម្ពស់ ៨៨ ហត្ថ**, ព្រះអង្គមានព្រះជន្ម ១ សែនឆ្នាំ ៕

**ចប់កោណ្ឌញ្ញកថាទី ២**

## មង្គលកថាទី ៣

សម័យដទៃទៀត កាលព្រះកោណ្ឌញ្ញបរិនិព្វានកន្លងទៅហើយ ប្រមាណមួយអសង្ខេយ្យ ក្នុងកប្បមួយនោះឯង មានព្រះពុទ្ធស្តេចឧប្បត្តិឡើង ៤ ព្រះអង្គ គឺ **ព្រះពុទ្ធមង្គល, ព្រះពុទ្ធសុមនៈ, ព្រះពុទ្ធរេវតៈ** និង**ព្រះពុទ្ធសោភិតៈ** ។ ក៏ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាម **មង្គល** មានមហាសន្និបាត ៣ លើក, មហាសន្និបាតលើកទី ១ មានភិក្ខុមកប្រជុំប្រមាណ មួយសែនកោដិ ។ លើកទី ២ ប្រមាណ ១ ពាន់កោដិ លើកទី ៣ ប្រមាណ ៩០ កោដិ ។

បានឮថា អានន្ទកុមារ ជាព្រះភាតា (អនុជ) ផ្សេងមាតានឹងព្រះមានព្រះភាគអង្គនោះ ព្រមទាំងបរិស័ទ ៩០ កោដិ បានយាងទៅកាន់សំណាក់ព្រះសាស្តាដើម្បីស្តាប់ព្រះធម៌ ។ ព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថាដល់អានន្ទកុមារនោះ អានន្ទកុមារព្រមទាំងបរិស័ទសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ព្រះសាស្តាទ្រង់ប្រមើលមើលបុព្វចរិយារបស់កុលបុត្រទាំងនោះ ទ្រង់ឃើញឧបនិស្ស័យនៃការបានបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទើបទ្រង់លាព្រះហស្តខាងស្តាំត្រាស់ថា "អ្នកទាំងឡាយចូរមកជាភិក្ខុចុះ" ។ ខណៈនោះឯងកុលបុត្រទាំងអស់ ទ្រង់បាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិ ដូចព្រះថេរៈមាន

វស្សា ៦០ ដល់ព្រមដោយកិរិយាមារយាទចោមរោមថ្វាយបង្គំព្រះសាស្តា ។ សាសនារបស់ព្រះភគវាអង្គនេះ ក៏មានសាវ័កសន្និបាត ៣ លើកដែរ ។

ក៏រស្មីសរីរៈរបស់ព្រះពុទ្ធទាំងឡាយអង្គដទៃៗ មានប្រមាណ ៦០ ហត្ថ ដោយជុំវិញជាប្រមាណ, ប៉ុន្តែថា រស្មីសរីរៈរបស់ព្រះមានបុណ្យព្រះនាម **មង្គល** នោះ មិនដូចព្រះពុទ្ធអង្គដទៃទេ គឺមានរស្មីផ្សាយចេញដល់ ១ សែនលោកធាតុ តាំងនៅអស់កាលជានិច្ច ដើមឈើ ដី ភ្នំ មហាសមុទ្រជាដើម ដោយហោចទៅ រហូតដល់វត្ថុទាំងឡាយមានឆ្នាំងបាយជាដើម ដូចស្រោបដោយផ្ទាំងមាសដូច្នោះ។ ក៏ព្រះជន្មាយុរបស់ព្រះអង្គមានប្រមាណ ៩ ហ្មឺនឆ្នាំ ។ អស់កាលមានប្រមាណ ប៉ុណ្ណោះ ព្រះចន្ទ និងព្រះអាទិត្យជាដើម មិនអាចដើម្បីនឹងបញ្ចេញរស្មីរបស់ខ្លួន បាន ការកំណត់ពេលយប់ និងពេលថ្ងៃមិនប្រាកដ ។ ក្នុងពេលថ្ងៃ សព្វសត្វទាំង ឡាយត្រាច់ទៅដោយពន្លឺនៃព្រះពុទ្ធតែម្យ៉ាងអស់កាលជានិច្ច ដូចជាកាលត្រាច់ ទៅដោយពន្លឺនៃព្រះអាទិត្យ ។ សត្វលោកកំណត់ពេលយប់ និងពេលថ្ងៃបាន ដោយផ្កាកុសុម (ផ្កាឈើ) រីកថាជាពេលល្ងាច កំណត់សំឡេងបក្សីស្រែកយំថា ជាពេលព្រឹក ។

**សួរថា:** ក៏អានុភាពនេះរបស់ព្រះពុទ្ធទាំងឡាយអង្គដទៃៗ មិនមានទេឬ?

**ឆ្លើយថា:** មិនមែនមិនមានទេ; ពិតណាស់ សូម្បីព្រះពុទ្ធទាំងនោះ កាលប្រាថ្នាហើយ ក៏គប្បីផ្សាយរស្មីទៅកាន់ហ្មឺនលោកធាតុ ឬច្រើនជាងនោះក៏បាន, ប៉ុន្តែ ព្រះរស្មីសរីរៈរបស់ព្រះភគវន្តមុនី ព្រះនាម **មង្គល** ផ្សាយទៅកាន់ហ្មឺនលោកធាតុតាំងនៅជានិច្ចកាល ដោយអំណាចនៃការតាំងសេចក្តីប្រាថ្នាទុកក្នុងបុព្វជាតិដូចព្រះរស្មីមួយព្យាមរបស់ព្រះពុទ្ធទាំងឡាយអង្គដទៃដែរ ។

បានឮថា ព្រះពុទ្ធមង្គលអង្គនោះ ក្នុងខណៈដែលបំពេញបារមីជាពោធិសត្វ ស្ថិតនៅក្នុងអត្តភាពប្រាកដដូចព្រះវេស្សន្តរ ព្រមទាំងបុត្រ និងភរិយានៅលើភ្នំ ប្រាកដដូចភ្នំវង្កដ; គ្រានោះ មានយក្សមួយរូប ឈ្មោះថា **ខរទឋិក** ដឹងថាព្រះមហាបុរសមានព្រះទ័យក្នុងការចែកទាន ទើបក្លែងភេទជាព្រាហ្មណ៍ ចូលទៅហើយសុំទារកទាំងពីរព្រះអង្គនឹងព្រះមហាសត្វៗ ទ្រង់ត្រេកអរីករាយដោយព្រះតម្រិះថា "ឱហ្ន៎ យើងនឹងឱ្យកូនតូចដល់ព្រាហ្មណ៍" ហើយព្រះរាជទានទារកទាំងពីរដែលអាចញ៉ាំងផែនដីឱ្យកម្រើក រហូតដល់ទឹកទ្រផែនដី ។ យក្សឈរផ្អែកផែនក្តារដែលផ្អែកទុកត្រង់ទីបំផុតនៃទីចង្ក្រម កាលព្រះមហាសត្វក្រឡេកមើលនោះឯង ខាំស៊ីទារកទាំងពីរព្រះអង្គ ដូចខាំស៊ីបាច់ឫសឈើ ។ មហាបុរសឃើញយក្សហើយ គ្រាន់តែហាមាត់ប៉ុណ្ណោះ ធារ (ទ) លោហិត ក៏ហូរចេញដូចអណ្តាត

ភ្លើង មហាបុរសសូម្បីឃើញមាត់នៃយក្សនោះយ៉ាងនេះ ក៏មិនបានតូចព្រះទ័យសូម្បីត្រឹមចុងនៃសរសៃសក់ឡើយ; ទ្រង់ព្រះតម្រិះថា "**សុទិន្នំ វត មេ ទានំ** = ទានរបស់អញ បានឱ្យល្អហើយ" ; បន្ទាប់មក ព្រះអង្គបានញ៉ាំងបីតិសោមនស្សដ៏ធំ ឱ្យកើត ។

**មហាបុរស**នោះ បានតាំងការប្រាថ្នាថា "ដោយផលវិបាក ជាគ្រឿងហូរចេញនៃបុណ្យរបស់យើងនេះ ក្នុងអនាគតសូមរស្មីទាំងឡាយចេញអំពីសរីរៈដោយទំនងនេះ" ។ អាស្រ័យហេតុនោះហើយ ពេលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ទើបមានរស្មីទាំងឡាយចេញអំពីព្រះសរីរៈ ផ្សាយទៅកាន់ទីមានប្រមាណប៉ុណ្ណោះ ។

បុព្វចរិយាមួយទៀតរបស់ព្រះពុទ្ធមង្គលនោះ ៖-

បានឮថាព្រះមង្គលពុទ្ធអង្គនោះ ក្នុងពេលដែលព្រះអង្គនៅជាពោធិសត្វ បានឃើញចេតិយរបស់ព្រះពុទ្ធមួយអង្គ ទើបគិតថា "អញគួរលះបង់ជីវិតបូជាព្រះពុទ្ធអង្គនេះ" ទើបរុំសរីរៈទាំងអស់ដូចរុំប្រទីបគប់ភ្លើង ហើយយកទឹកដោះថ្លាដាក់លើថាសមាស កម្ពស់ប្រមាណ ១ ហត្ថ មានតម្លៃ ១ សែនកហាបណៈ

ដរាបដល់ពេញហើយអុជ ប្រទីបរុំទុកក្នុងថាសនោះឱ្យភ្លឺ ហើយទូលថាសមាស នោះដោយសីសៈ ញ៉ាំងសរីរៈទាំងអស់ឱ្យភ្លឺរុងរឿង ហើយធ្វើប្រទក្សិណព្រះចេតិយអស់រាត្រីទាំងអស់ ។ កាលព្រះពោធិសត្វព្យាយាមយ៉ាងនេះ ដរាបដល់អរុណរះឡើង សូម្បីត្រឹមតែរន្ធរោមមួយសរសៃក៏មិនឆេះ ហាក់ដូចជាកាលចូលទៅកាន់គុម្ពផ្កាបទុមដូច្នោះដែរ; សេចក្ដីថា ធម្មតាធម៌នោះ រមែងរក្សានូវអ្នកដែលរក្សាខ្លួន ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖-

**“ធម្មោ ហវេ រក្ខតិ ធម្មចារឹ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ**
**ន ទុគ្គតឹ គច្ឆតិ ធម្មចារី**[៦០] ។

ព្រះធម៌តែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ព្រះធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិទេ” ។

---

[៦០] ខុ. ថេរ., ខុ. ជា. ។

ដោយវិបាកជាគ្រឿងហូរចេញនៃកម្មនេះ រស្មីសិរីរៈរបស់ព្រះមានជោគ អង្គនោះ ទើបផ្សាយទៅកាន់ហ្មឺនលោកធាតុហើយតាំងនៅ ។

ក្នុងគ្រានោះ ព្រះបរមពោធិសត្វរបស់យើងទាំងឡាយ ជាព្រាហ្មណ៍ ឈ្មោះ **សុរុចិ** គិតថា "អញនឹងនិមន្តព្រះសាស្តា" ទើបចូលទៅគាល់ បានស្តាប់ ព្រះធម្មកថាដ៏ពិរោះ ហើយទូលនិមន្តថា "បពិតព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទទួលភិក្ខាររបស់ខ្ញុំព្រះអង្គនៅថ្ងៃស្អែកនេះ" ។ ព្រះមានជោគទ្រង់ត្រាស់សួរថា "ម្នាលព្រាហ្មណ៍ តើអ្នកត្រូវការភិក្ខុប៉ុន្មាន?" សុរុចិព្រាហ្មណ៍ទូលថា "បពិត្រ ព្រះអង្គដ៏ចម្រើន ភិក្ខុជាបរិវាររបស់ព្រះអង្គមានប៉ុន្មាន?" ។ ក្នុងកាលនោះ ជា សាវកសន្និបាតគ្រាដំបូងរបស់ព្រះសាស្តា, ព្រោះហេតុនោះ ព្រះអង្គទ្រង់ត្រាស់ថា "១ សែនកោដិរូប" ។ ព្រាហ្មណ៍ទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទទួលភិក្ខាររបស់ខ្ញុំព្រះអង្គ ព្រមទាំងពួកភិក្ខុទាំងអស់រូប" ។ ព្រះសាស្តាទ្រង់ ទទួលនិមន្តន៍ដោយតុណ្ហីភាព ។

ព្រាហ្មណ៍លុះទូលនិមន្ត ដើម្បីទទួលភត្តក្នុងថ្ងៃស្អែករួចហើយ កាលដើរ ត្រឡប់ទៅកាន់ផ្ទះបានគិតថា "អញអាចប្រគេនវត្ថុទាំងឡាយមានយាគូ ភត្ត និង

សំពត់ជាដើម ដល់ភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះបាន, ប៉ុន្តែទីអង្គុយនឹងធ្វើដូចម្ដេចទៅ? ” ។ ការគិតរបស់ព្រាហ្មណ៍នោះ ញ៉ាំងការក្ដៅឱ្យកើតឡើងដល់បណ្ឌុកម្ពលសិលាសនៈនៃស្ដេចទេវតា ដែលស្ថិតនៅកម្ពស់ ៨៤.០០០ យោជន៍ ។ សក្កទេវរាជទ្រង់ប្រមើលមើលដោយទិព្វចក្ខុថា “នរណាហ្ន៎ ! ញ៉ាំងអញឱ្យឃ្លាតចាកឋាននេះ” ។ បានឃើញហើយនូវមហាបុរស ទើបទ្រង់ជ្រាបថា “សុរុចិព្រាហ្មណ៍នេះ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយបានគិតដល់ការរៀបចំទីអង្គុយប្រគេន (លោក), សូម្បីយើងក៏គួរទៅក្នុងទីនោះ ដើម្បីកាន់យកចំណែកបុណ្យ” ។ ហើយនិម្មិតភេទជាជាងឈើកាន់កាំបិត និងពូថៅឈរប្រាកដចំពោះមុខមហាបុរស ។ ព្រះអង្គ (ព្រះឥន្ទ) សួរថា “មាននរណាជួលធ្វើកិច្ចការខ្លះទេ? ” ។ មហាបុរសឃើញព្រះអង្គហើយសួរថា “អ្នកនឹងធ្វើការងារអ្វីបានខ្លះ? ” ជាងឈើនោះឆ្លើយថា: “ធម្មតាសិល្បៈដែលខ្ញុំមិនចេះមិនមានទេ, អ្នកណាឱ្យខ្ញុំធ្វើផ្ទះ ឬមណ្ឌប ឬក៏វត្ថុណា ខ្ញុំចេះធ្វើវត្ថុនោះដល់អ្នកនោះ” ។ មហាបុរសពោលថា: “បើដូច្នោះ ខ្ញុំមានការងារ” ។ ជាងឈើព្រះឥន្ទសួរថា “នែនាយ អ្នកមានការងារអ្វី? ” មហាបុរសឆ្លើយថា “ខ្ញុំនិមន្តភិក្ខុ ១ សែនកោដិរូបមកឆាន់ភត្តាហារក្នុងថ្ងៃស្អែកនេះ ចូរអ្នកជួយធ្វើមណ្ឌបជាទីសម្រាប់គង់ដល់ភិក្ខុទាំង

នោះ” ។ ជាងឈើពោលថា “បើអ្នកឱ្យថ្លៃឈ្នួលដល់ខ្ញុំៗ នឹងគប្បីធ្វើ” មហាបុរសពោលថា “យើងនឹងឱ្យអ្នក” ។ ជាងឈើទទួលដោយពាក្យថា “សាធុខ្ញុំនឹងធ្វើ” ហើយទៅមើលប្រទេសមួយ ។ ប្រទេសនោះមានប្រមាណ ១២ ឬ ១៣ យោជន៍ មានផ្ទៃស្មើដូចកសិណមណ្ឌល ។ ព្រះឥន្ទជាងឈើនោះគិតថា “ចូរមណ្ឌបសម្រេចដោយកែវ ៧ ប្រការ តាំងឡើងក្នុងទីមានប្រមាណប៉ុណ្ណេះ” ហើយទើបប្រមើលមើល ។ រំពេចនោះឯង មណ្ឌបក៏ទម្លាយផែនដីផុសឡើងហើយ ។ មណ្ឌបនោះត្រង់សសរ សម្រេចដោយមាសមានឈូកសសរសម្រេចដោយប្រាក់ ។ បណ្ដាសសរដែលសម្រេចដោយប្រាក់មានឈូកសសរសម្រេចដោយមាស, បណ្ដាសសរដែលសម្រេចដោយកែវមណី មានឈូកសសរសម្រេចដោយកែវប្រពាឡ, បណ្ដាសសរសម្រេចដោយកែវប្រពាឡ មានឈូកសសរសម្រេចដោយកែវមណី, បណ្ដាសសរសម្រេចដោយកែវ ៧ ប្រការ មានឈូកសសរសម្រេចដោយកែវ ៧ ប្រការ ។ តអំពីនោះ ព្រះអង្គក៏ប្រមើលមើលរួចហើយអធិដ្ឋានថា “ចូរសំណាញ់កណ្ដឹង សំយុងចុះត្រង់ចន្លោះទីបំផុតនៃមណ្ឌបព្រមជាមួយការមើលនោះឯង សំណាញ់កណ្ដឹងក៏សំយុងចុះភ្លាម, កណ្ដឹងណាត្រូវខ្យល់តិចៗ បក់មក កណ្ដឹងនោះក៏បន្លឺសំឡេងពិរោះ ដូចសំឡេងពិរោះរបស់

តន្ត្រីប្រកបដោយអង្គ ៥ * មែនពិត; ពេលនោះដូចជាកាលលេងភ្លេងទិព្វសង្គីត។ ហើយអធិដ្ឋានថា "ចូរភួងផ្កាក្រអូប និងភួងផ្កាមាលាទាំងឡាយសំយុងចុះខាងក្នុងចន្លោះៗ"។ ភួងផ្កាទាំងឡាយនោះក៏សំយុងចុះ ។ បន្ទាប់មក ព្រះឥន្ទជាងឈើ ក៏អធិដ្ឋានថា "សូមអាសនៈទាំងឡាយ និងទីសម្រាប់ភិក្ខុ ១ សែនកោដិ រូបទម្លាយផែនដីផុសឡើង" រំពេចនោះវត្ថុទាំងឡាយក៏ប្រាកដឡើង ។ តអំពីនោះ ក៏អធិដ្ឋានថា "សូមពាងទឹកទាំងឡាយ តាំងឡើងត្រង់មុំកែងមួយៗ"។ ពាងទឹកទាំងឡាយនោះក៏តាំងឡើង ។ សក្កទេវរាជ និម្មិតសព្វវត្ថុមានសភាពបែបនេះហើយ ទើបទៅកាន់សំណាក់របស់ព្រាហ្មណ៍ប្រាប់ថា "នែព្រាហ្មណ៍ ចូរអ្នកមកមើលមណ្ឌបរបស់អ្នក ហើយចូរឱ្យថ្លៃឈ្នួលដល់ខ្ញុំ"។

មហាបុរសទៅមើលមណ្ឌបហើយ កាលគាត់មើលនោះឯង បីតិ ៥ យ៉ាង ក៏ពាល់ត្រូវសរីរៈទាំងអស់មិនមានចន្លោះ ។ លំដាប់នោះ មហាបុរសបានមើល

---

* វាទ្យភណ្ឌ (គ្រឿងភ្លេង) ប្រាំឈ្មោះគឺមាន រនាតមួយ ឬមានរនាតបី គឺរនាតឯក ១ រនាតធុង ១ រនាតដែក ១, មានគងវង់មួយឬមានគងវង់ពីរវង់គឺគងវង់ធំ ១ គងវង់តូច ១, មានសាឡៃ ១ មានសម្ភោរ ១ មានស្គរធំពីររួមគ្នាប្រាំឈ្មោះហៅថា ភ្លេងពិណពាទ្យ ។ (សេចក្តីពិស្តារមាននៅក្នុងវចនានុក្រមខ្មែរ ទំ-៧៥២)។

មណ្ឌបដោយគិតថា “មណ្ឌបនេះមិនមែនមនុស្សធ្វើទេ, តែអាស្រ័យអធ្យាស្រ័យ និងគុណរបស់អញ ទើបពិភពសក្កទេវរាជក្តៅពិតប្រាកដ ព្រោះហេតុដូច្នោះ មណ្ឌបនេះ នឹងជាមណ្ឌបដែលសក្កទេវរាជកសាងឱ្យ” ហើយគិត (ទៀត) ថា “ក៏កាលដែលអញថ្វាយទានត្រឹមតែមួយថ្ងៃក្នុងមណ្ឌបមានសភាពបែបនេះ មិនគួរឡើយ អញនឹងថ្វាយទាន ៧ ថ្ងៃ” ។

ការឱ្យទាន ដោយវត្ថុខាងក្រៅមានប្រមាណត្រឹមណា ក៏មិនអាចញ៉ាំងចិត្តរបស់ពោធិសត្វទាំងឡាយឱ្យរីករាយ ។ ប៉ុន្តែ ការរីករាយចិត្តរបស់ពោធិសត្វក៏មាន ព្រោះការបរិច្ចាគក្នុងកាលបានកាត់សីសៈដែលតាក់តែងហើយ ឆ្កៀលនូវភ្នែកទាំងពីរដែលបន្តក់ថ្នាំហើយ ពន្លះនូវសាច់បេះដូងហើយឱ្យទៅ; ពិតណាស់ក្នុង **សិវិរាជជាតក** ពណ៌នាទុកថា សូម្បីក្នុងកាលព្រះពោធិសត្វរបស់យើងទាំងឡាយ លះបង់នូវទ្រព្យរាល់ៗ ថ្ងៃ មួយថ្ងៃប្រមាណ ៥ សែនកហាបណៈ ឱ្យទានហើយក្នុងនគរជិតទ្វារក្រុងទាំង ៤ ។ ការបរិច្ចាគនោះ ក៏មិនញ៉ាំងចិត្តឱ្យរីករាយបាន; ប៉ុន្តែថា កាលណា ស្តេចទេវរាជឈ្មោះសក្កៈ បន្លំជាព្រាហ្មណ៍មកសុំ ព្រះនេត្រទាំងគូរបស់ព្រះអង្គ កាលព្រះអង្គទ្រង់ឆ្កៀលព្រះនេត្រឱ្យហើយនោះឯង

សេចក្ដីរីករាយព្រះទ័យទើបកើតឡើង, ចិត្តរបស់ព្រះអង្គមិនបានជាយ៉ាងដទៃត្រឹមតែប៉ុនចុងសក់ ។ ធម្មតា ការឆ្អែត (ចិត្ត) របស់ព្រះពោធិសត្វទាំងឡាយព្រោះអាស្រ័យទានមានសភាពយ៉ាងនេះ ទើបមិនមាន ។ ព្រោះហេតុដូច្នោះព្រះមហាបុរសនោះ ទើបគិតថា "អញឱ្យទានដល់ភិក្ខុទាំងឡាយ ១ សែនកោដិរូបអស់ ៧ ថ្ងៃទើបគួរ" ទើបនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឱ្យគង់ក្នុងមណ្ឌបនោះហើយថ្វាយអាហារឈ្មោះ **គវបានៈ** អស់ ៧ ថ្ងៃ ។ ពាក្យថា **គវបានៈ** លោកហៅថា ភោជនដែលយកទឹកដោះដាក់ក្នុងឆ្នាំងធំ រហូតដល់ពេញហើយលើកឡើងតាំង (ដាក់) លើចង្ក្រាន កាលទឹកដោះខាប់ចម្អិនឆ្អិនខាប់ហើយដាក់អង្ករទៅបន្តិច រួចផ្សំដោយទឹកឃ្មុំ ស្ករត្នោត និងទឹកដោះថ្លា ។

ក៏មនុស្សទាំងឡាយ មិនអាចអង្គាសភិក្ខុបាន, ទើបទេវតាទាំងឡាយជ្រៀតចូលទៅជួយអង្គាសបាន; ទីប្រមាណ ១២-១៣ យោជន៍ ក៏មិនគ្រាន់ល្មមឱ្យភិក្ខុគង់ទេ; ប៉ុន្តែថា ភិក្ខុទាំងឡាយគង់អង្គុយបានដោយអំណាចនៃអានុភាពរបស់ខ្លួន ។ ក្នុងថ្ងៃទីបំផុត ព្រះពោធិសត្វឱ្យលាងបាត្រភិក្ខុទាំងអស់ បញ្ចុះទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅ ដើម្បីប្រយោជន៍ជាភេសជ្ជៈហើយប្រគេនមួយអន្លើដោយត្រៃចីវរ; សំពត់ចីវរដែលនវភិក្ខុក្នុងសង្ឃបានហើយ

ជាសំពត់មានតម្លៃដល់ ១ សែនកហាបណៈ ។

ព្រះសាស្ដាកាលធ្វើអនុមោទនា ទ្រង់ពិចារណាថា “បុរសនេះឱ្យមហាទានមានសភាពយ៉ាងនេះ, នឹងជាអ្នកណាហ្ន៎?” ទ្រង់ឃើញថា “ក្នុងអនាគតកាល ក្នុងទីបំផុតនៃ ២ អសង្ខេយ្យក្រៃលែងដោយសែនកប្ប នឹងជាព្រះពុទ្ធ **ព្រះនាមគោតម**” ទើបត្រាស់ហៅមហាបុរសហើយទ្រង់ព្យាករថា “កាលកន្លងទៅប៉ុណ្ណេះ អ្នកនឹងជាព្រះពុទ្ធ**ព្រះនាមគោតម**” ។ មហាបុរសបានស្ដាប់ការព្យាករណ៍ហើយគិតថា “ឮថា អញនឹងជាព្រះពុទ្ធ ប្រយោជន៍អ្វីដោយការគ្រប់គ្រងផ្ទះរបស់អញៗ នឹងបួស” ហើយលះបង់សម្បត្តិមានសភាពដូច្នោះ ដូចស្ដោះទឹកមាត់ហើយបួសក្នុងសំណាក់ព្រះសាស្ដា ។ ក៏លុះបួសរួចហើយ បានរៀនព្រះពុទ្ធវចនៈ ញុំាងអភិញ្ញា និងសមាបត្តិទាំងឡាយឱ្យកើតឡើងហើយ ក្នុងវេលាអស់អាយុ ក៏កើតក្នុងព្រហ្មលោក ។

ក៏នគររបស់ព្រះមានជោគព្រះនាមមង្គលនោះឈ្មោះ **ឧត្តរៈ**, ព្រះបិតាជាក្សត្រព្រះនាម **ឧត្តរៈ**, ព្រះមាតាព្រះនាម **ឧត្តរា**, **ព្រះសុទេវត្ថេរ** និង**ព្រះធម្មសេនត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះបាលិតត្ថេរ** ជាឧបដ្ឋាក, **ព្រះសីវលាថេរី** និង

**ព្រះអរសោភាថេរី** ជាគូអគ្គសាវិកា, ដើមឈើឈ្មោះ **នាគៈ** (ដើមខ្ទឹង) ជាឈើត្រាស់ដឹង, **ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ**; ស្ថិតនៅអស់ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ក៏ស្ដេចបរិនិព្វាន, ក៏កាលព្រះមានបុណ្យបរិនិព្វានហើយ មួយម៉ឺនចក្រវាឡ ក៏បានងងឹតព្រមគ្នា; ការយំខ្សឹកខ្សួលដ៏ធំបានមានហើយ ដល់មនុស្សទាំងឡាយក្នុងចក្រវាឡទាំងអស់ ៕

**ចប់មង្គលកថាទី ៣**

## សុមនកថាទី ៤

កាលព្រះមានព្រះភាគព្រះនាម **មង្គល** អង្គនោះបរិនិព្វាន ធ្វើឱ្យមួយហ្មឺនលោកធាតុងងឹតយ៉ាងនេះហើយ តអំពីនោះមក ព្រះសាស្ដាព្រះនាមថា **សុមនៈ** ក៏ទ្រង់ឧប្បត្តិឡើង សាវកសន្និបាតរបស់ព្រះមានព្រះភាគអង្គនោះមាន ៣ លើក; សន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិរូប, លើកទី ២ មានភិក្ខុ ៩ ម៉ឺនកោដិរូបក្នុងកាញ្ចនបពិត និងលើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិរូប ។

គ្រានោះ ព្រះពោធិសត្វជានាគរាជឈ្មោះ **អតុលៈ** មានឫទ្ធិច្រើន មានអានុភាពច្រើន បានឮថា “ព្រះពុទ្ធឧប្បត្តិឡើងហើយ” ទើបនាំពួកញាតិចេញ

អំពីនាគពិភព មកប្រគុំដូរ្យតន្ត្រីទិព្វបូជាព្រះដ៏មានបុណ្យ មានភិក្ខុ ១ សែនកោដិ ជាបរិវារ បានថ្វាយមហាទាន ហើយថ្វាយសំពត់ ១ គូៗ ដល់ភិក្ខុមួយរូបៗ ហើយតាំងនៅក្នុងសរណៈទាំងឡាយ ។ ព្រះសាស្តាសុមនៈអង្គនោះ ព្យាករព្រះពោធិសត្វនោះថា "ក្នុងកាលជាអនាគត អ្នកនឹងជាព្រះពុទ្ធ" ។ នគររបស់ព្រះភគវាព្រះនាមសុមនៈអង្គនោះ ឈ្មោះថា **មេខលៈ**, ព្រះរាជបិតាព្រះនាម **សុទត្ត**, ព្រះរាជមាតាព្រះនាម **សិរិមា**, **ព្រះសរណត្ថេរ** និង**ព្រះភាវិតត្តត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះឧទេនត្ថេរ** ជាឧបដ្ឋាក, **ព្រះសោណាថេរី** និង**ឧបសោណាថេរី** ជាអគ្គសាវិកា, ដើមឈើនាគៈ ជាដើមឈើត្រាស់ដឹង, មានព្រះសរីរកាយ កម្ពស់ ៩០ ហត្ថ, មានព្រះជន្មាយុប្រមាណ ៩ ម៉ឺនឆ្នាំ ៕

**ចប់សុមនកថាទី ៤**

## រេវតកថាទី ៥

ក្នុងកាលតអំពីព្រះសុមនពុទ្ធនោះមក ព្រះសាស្តាព្រះនាម **រេវតៈ** ក៏ទ្រង់ឧប្បត្តិឡើង សាវកសន្និបាតរបស់ព្រះរេវតពុទ្ធអង្គនោះ ក៏មាន ៣ លើក ក្នុង

សន្និបាតលើកទី ១ មានចំនួនរាប់មិនបាន, លើកទី ២ មានភិក្ខុ ១ សែនកោដិរូប និងលើកទី ៣ ក៏ដូចគ្នាដែរ ។

គ្រានោះ ព្រះពោធិសត្វជាព្រាហ្មណ៍នាមថា **អតិទេព** ស្ដាប់ព្រះធម្ម-ទេសនារបស់ព្រះសាស្ដាហើយ តាំងនៅក្នុងសរណៈទាំងឡាយ ប្រណម្យអញ្ជលីទុកខាងលើក្បាល ពោលសរសើរការលះកិលេសរបស់ព្រះសាស្ដាអង្គនោះ ហើយបូជាដោយឧត្តរាសង្គៈ(ចីវរ) ។ សូម្បីព្រះភគវន្តមុនីអង្គនោះ ក៏ព្យាករព្រះពោធិសត្វថា “អ្នកនឹងជាព្រះពុទ្ធ” ។

ក៏ព្រះភគវន្តមុនីអង្គនោះមាននគរឈ្មោះ **សុធញ្ញវតី** ។ ព្រះបិតាជាក្សត្រព្រះនាម **វិបុល**, ព្រះមាតាព្រះនាម **វិបុលា**, **ព្រះវរុណត្ថេរ** និង**ព្រះព្រហ្មទេវត្ថេរ** ជាអគ្គសាវ័ក, **ព្រះសម្ភវត្ថេរ** ជាឧបដ្ឋាក, **ព្រះភទ្ទាថេរី** និង**ព្រះសុភទ្ទាថេរី** ជាអគ្គសាវិកា, ដើម**នាគ**ជាដើមពោធិ៍, ព្រះអង្គមានសរីរៈកម្ពស់ ៨០ ហត្ថ, មានព្រះជន្មាយុ ៦ ម៉ឺនវស្សា ៕

**ចប់រេវតកថាទី ៥**

# សោភិតកថាទី ៦

ក្នុងកាលតអំពីព្រះពុទ្ធរេវតអង្គនោះមក ព្រះសាស្តាព្រះនាម **សោភិតៈ** ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើកដែរ, សន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិរូប, លើកទី ២ មានភិក្ខុ ៩០ កោដិរូប និងលើកទី ៣ មានភិក្ខុ ៨០ កោដិរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រាហ្មណ៍ឈ្មោះ **អជិតៈ** បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ស្ថិតនៅក្នុងសរណៈទាំងឡាយ, ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ សូម្បីព្រះពុទ្ធសោភិតៈ ក៏ទ្រង់ព្យាករពោធិសត្វនោះថា "អ្នកនឹងជាព្រះពុទ្ធ" ។

នគររបស់ព្រះភគវាអង្គនោះ ឈ្មោះថា **សុធម្ម**, ព្រះបិតា ជាព្រះរាជាព្រះនាម **សុធម្មៈ** ព្រះមាតាព្រះនាម **សុធម្មា**, **ព្រះអសមត្ថេរ** និង**ព្រះសុនេត្តត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះអនោមត្ថេរ** ជាឧបដ្ឋាក, **ព្រះនកុលាថេរី** និង**ព្រះសុជាតាថេរី** ជាអគ្គសាវិកា, ដើម **នាគៈ** ជាដើមពោធិ៍, ព្រះអង្គមានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុប្រមាណ ៩ ម៉ឺនឆ្នាំ ៕

**ចប់សោភិតកថាទី ៦**

# អនោមទស្សីកថាទី ៧

ក្នុងកាលតអំពីព្រះពុទ្ធសោភិតៈ កន្លងទៅ ១ អសង្ខេយ្យ ក្នុងកប្បមួយ មានព្រះពុទ្ធ ៣ អង្គ ទ្រង់ឧប្បត្តិឡើង គឺ **ព្រះពុទ្ធអនោមទស្សី**, **ព្រះពុទ្ធបទុមៈ** និង**ព្រះពុទ្ធនារទៈ** ។ ក៏សាសនានៃព្រះមានព្រះភាគ ព្រះនាម **អនោមទស្សី** មានសាវកសន្និបាត ៣ លើក, លើកទី ១ មានភិក្ខុ ៨ សែនរូប, លើកទី ២ មានភិក្ខុ ៧ សែនរូប និងលើកទី ៣ មានភិក្ខុ ៦ សែនរូប ។

ក្នុងកាលនោះ ព្រះពោធិសត្វ ជាសេនាបតីយក្ស ១ រូប មានឫទ្ធិច្រើន មានអានុភាពច្រើន ជាធំជាងយក្សទាំងឡាយច្រើនសែនកោដិរូប ។ សេនាបតីយក្សនោះឮថា "ព្រះពុទ្ធកើតឡើងហើយ" បានមកថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ សូម្បីព្រះសាស្តាក៏ទ្រង់ព្យាករយក្សនេះថា "ក្នុងអនាគត អ្នកនឹងជាព្រះពុទ"។

ព្រះនគររបស់ព្រះមានបុណ្យអនោមទស្សី (នោះ) ឈ្មោះ **ចន្ទវតី**, ព្រះបិតាជាព្រះរាជាព្រះនាម **យសវា**, ព្រះមាតាព្រះនាម **យសោធរា**, ព្រះ**និសភត្ថេរ** និងព្រះ**អនោមត្ថេរ** ជាអគ្គសាវ័ក, ព្រះ**វរុណត្ថេរ** ជាឧបដ្ឋាក, ព្រះ**សុន្ទរីថេរី** និងព្រះ**សុមនាថេរី** ជាអគ្គសាវិកា, ដើម**អជ្ជុន** ជាដើមពោធិ៍, ព្រះ

អង្គមានសរីរៈកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់អនោមទស្សីកថាទី ៧**

## បទុមកថាទី ៨

ក្នុងកាលតអំពីព្រះពុទ្ធអនោមទស្សីនោះ ព្រះសាស្តាព្រះនាម **បទុម** ក៏ឧប្បត្តិឡើង ។ សូម្បីសាសនារបស់ព្រះអង្គនេះ ក៏មានសាវកសន្និបាត ៣ លើក, លើកទី ១ មានភិក្ខុ ១ សែនកោដិរូប, លើកទី ២ មានភិក្ខុ ៣ សែនរូប, និងលើកទី ៣ មានភិក្ខុអ្នកអាស្រ័យនៅព្រៃក្រាស់មហាវ័ន ក្នុងព្រៃស្ងាត់ (គ្មានស្រុក) មកប្រជុំ ២ សែនរូប ។

គ្រានោះ ព្រះតថាគតទ្រង់គង់នៅក្នុងព្រៃក្រាស់នោះឯង ព្រះពោធិសត្វជាស្តេច **សីហៈ** បានឃើញព្រះសាស្តាចូលនិរោធសមាបត្តិហើយ មានចិត្តជ្រះថ្លាបង្អោនចុះ (ថ្វាយបង្គំ) ធ្វើប្រទក្សិណ មានបីតិសោមនស្សកើតឡើងហើយ បន្លឺសីហនាទ ៣ ដង មិនលះបង់បីតិមានព្រះពុទ្ធជាអារម្មណ៍ មិនចេញទៅរកអាហារ ព្រោះសេចក្តីសុខកើតពីបីតិនោះឯង បានធ្វើការលះបង់ជីវិត ចូលទៅឈរ

គាល់ព្រះអង្គអស់ ៧ ថ្ងៃ ។ អំណើះ ៧ ថ្ងៃទៅ ព្រះសាស្ដាទ្រង់ចេញអំពីនិរោធ ហើយទ្រង់ទតឃើញស្ដេចសីហៈ ទើបទ្រង់ព្រះតម្រិះថា "សីហៈនេះញ៉ាំងចិត្តឱ្យជ្រះថ្លា សូម្បីក្នុងព្រះភិក្ខុសង្ឃហើយឱនចុះ (ថ្វាយបង្គំ) ព្រះសង្ឃ, ពួកភិក្ខុសង្ឃចូរមក"។ ពួកភិក្ខុក៏មកហើយក្នុងខណៈនោះតែម្ដង ។ សីហៈ ក៏ញ៉ាំងចិត្តឱ្យជ្រះថ្លាចំពោះព្រះសង្ឃ ។ ព្រះសាស្ដាទ្រង់ប្រមើលមើលចិត្តនៃសីហៈនោះ ហើយទ្រង់ព្យាករថា "ក្នុងកាលអនាគត អ្នកនឹងជាព្រះពុទ្ធ" ។

ក៏នគរនៃព្រះមានព្រះភាគបទុម (នោះ) មានឈ្មោះ **ចម្បកៈ**, ព្រះបិតាជាព្រះរាជាព្រះនាម **អសមៈ**, ព្រះមាតាព្រះនាម **អសមា**, **ព្រះសាលត្ថេរ** និងព្រះ**ឧបសាលត្ថេរ** ជាគូអគ្គសាវ័ក, ព្រះ**វរុណត្ថេរ** ជាឧបដ្ឋាក, **ព្រះរាមាថេរី** និង**សុរាមាថេរី** ជាគូអគ្គសាវិកា, ដើមអំពៅដ៏វិតូច (សោណព្រឹក្ស) ជាដើមពោធិ៍, ព្រះសរីរៈរបស់ព្រះអង្គមានកម្ពស់ ៥៨ ហត្ថ, មានព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់បទុមកថាទី ៨**

## នារទកថាទី ៩

ក្នុងកាលតអំពីព្រះពុទ្ធបទុមនោះ ព្រះសាស្តាព្រះនាម **នារទៈ** ក៏ទ្រង់ឧប្បត្តិឡើង; សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើកដែរ; លើកទី ១ សន្និបាតមានភិក្ខុ ១ សែនកោដិរូប, លើកទី ២ មានភិក្ខុ ៩ ម៉ឺនកោដិរូប និង លើកទី ៣ មានភិក្ខុ ៨ ម៉ឺន កោដិរូប ។

គ្រានោះ **ព្រះពោធិសត្វបួសជាឥសី** ជាអ្នកជំនាញក្នុងអភិញ្ញា ៥ និង សមាបត្តិ ៨ បានថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយបានធ្វើការបូជាដោយចន្ទន៍ក្រហម សូម្បីព្រះមានព្រះភាគអង្គនោះ ក៏ព្យាករពោធិសត្វនោះថា “ក្នុងអនាគតកាល អ្នកនឹងជាព្រះពុទ្ធ” ។

នគរនៃព្រះមានព្រះភាគអង្គនោះមានឈ្មោះថា **ធញ្ញវតី**, ព្រះបិតា ជាក្សត្រព្រះនាម **សុទេព**, ព្រះមាតាព្រះនាម **អនោមា**, **ព្រះភទ្ទសាលត្ថេរ** និងព្រះ**ជិតមិត្តត្ថេរ** ជាគូអគ្គសាវក, **ព្រះវាសិដ្ឋ** ជាឧបដ្ឋាក, **ព្រះឧត្តរាថេរី** និង **ផគ្គុនីថេរី** ជាគូអគ្គសាវិកា, ដើមអំពៅដីរធំ (មហាសោណព្រឹក្ស) ជាដើមពោធិ៍, សរីរៈព្រះអង្គមានកម្ពស់ ៨៨ ហត្ថ, មានព្រះជន្មាយុ ៩ ម៉ឺនវស្សា ៕

**ចប់នារទកថាទី ៩**

# បទុមុត្តរៈជាទី ១០

ក្នុងកាលតអំពីព្រះពុទ្ធនារទៈនោះ កន្លងទៅអស់មួយអសង្ខេយ្យ រាប់ថយទៅពីកប្បនេះ ក្នុងទីបំផុតនៃ ១ សែនកប្ប ក្នុងកប្បមួយ មានព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** មួយអង្គប៉ុណ្ណោះ ទ្រង់ឧប្បត្តិឡើង; សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើកដែរ; ក្នុងលើកទី ១ មានភិក្ខុ ១ សែនកោដិរូប, លើកទី ២ មានភិក្ខុមកប្រជុំគ្នាលើភ្នំវេភារបព៌ត ៩ ម៉ឺនកោដិ និងលើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិរូប ។

គ្រានោះ ព្រះពោធិសត្វ សោយព្រះជាតិជាអ្នកគ្រប់គ្រងមហារដ្ឋ ឈ្មោះថា **ជដិល** បានថ្វាយទានព្រមទាំងចីវរដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ សូម្បីព្រះពុទ្ធបទុមុត្តរៈអង្គនោះបានព្យាករព្រះពោធិសត្វថា "ក្នុងកាលអនាគត អ្នកនឹងជាព្រះពុទ្ធ"។ ក៏ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ធម្មតាអ្នកជាតិរ្ថិយមិនមានទេ, ទេវតា និងមនុស្សទាំងពួង បានដល់ ព្រះពុទ្ធប៉ុណ្ណោះជាសរណៈ ។

នគររបស់ព្រះភគវាព្រះអង្គនោះឈ្មោះថា **ហង្សវតី**, ព្រះបិតាជាក្សត្រព្រះនាម **អានន្ទៈ**, ព្រះមាតាព្រះនាម **សុជាតា**, ព្រះ**ទេវិលត្ថេរ** និងព្រះ**សុជា**–

**តរត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសុមនត្ថេរ** ជាឧបដ្ឋាក, **ព្រះអមិត្តាថេរី** និងព្រះ**អសមាថេរី** ជាគូអគ្គសាវិកា, **ដើមសាលៈ** (សាលព្រឹក្ស) ជាដើមពោធិ៍, ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ, រស្មីព្រះវរកាយផ្សាយទៅជុំវិញ ១២ យោជន៍, ព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់បទុមុត្តរកថាទី ១០**

## សុមេធកថាទី ១១

ក្នុងកាលតអំពីព្រះបទុមុត្តរៈនោះ កន្លងទៅបីម៉ឺនកប្បក្នុងកប្បមួយមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ២ ព្រះអង្គគឺ **ព្រះពុទ្ធសុមេធ** និង**ព្រះពុទ្ធសុជាត**; សូម្បីសាវកសន្និបាតរបស់ព្រះពុទ្ធសុមេធ ក៏មានបីលើក; សន្និបាតលើកទី ១ ក្នុងនគរសុទស្សនៈ មានភិក្ខុខីណាស្រព ១ រយកោដិរូប, លើកទី ២ មានភិក្ខុ ៩០ កោដិរូប និងលើកទី ៣ មាន ភិក្ខុ ៨០ កោដិរូប ។

គ្រានោះ ព្រះពោធិសត្វជាមាណពឈ្មោះថា **ឧត្តរៈ** លះទ្រព្យដែលកប់ទុក ៨០ កោដិ ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌ស្ថិតក្នុង

សរណៈទាំងឡាយហើយចេញបួស ព្រះពុទ្ធអង្គនោះ ក៏បានព្យាករនូវពោធិសត្វនោះថា “ក្នុងអនាគតកាល អ្នកនឹងជាព្រះពុទ្ធ” ។

នគររបស់ព្រះមានព្រះភាគព្រះនាមសុមេធ ឈ្មោះថា **សុទស្សនៈ**, ព្រះបិតាជាព្រះរាជា ព្រះនាម **សុទត្តៈ** ព្រះមាតាព្រះនាម **សុទត្តា**, **ព្រះសរណៈត្ថេរ** និង**ព្រះសព្វកាមត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសាគរត្ថេរ** ជាឧបដ្ឋាក. **ព្រះរាមាថេរី** និង**ព្រះសុរាមាថេរី**ជាគូអគ្គសាវិកា, ដើម **មហានិម្ព** (ស្ដៅធំ) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៨៨ ហត្ថ, ព្រះជន្មាយុ ៩ ម៉ឺនវស្សា ៕

ចប់សុមេធកថាទី ១១

## សុជាតកថាទី ១២

ក្នុងកាលតអំពីព្រះពុទ្ធសុមេធអង្គនោះមក ព្រះសាស្ដាព្រះនាម **សុជាត** ក៏ទ្រង់ឧប្បត្តិឡើង; សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក, លើកទី ១ មានភិក្ខុ ៦ លានរូប, លើកទី ២ មានភិក្ខុ ៥ លានរូប និងលើកទី ៣ មានភិក្ខុ ៤ លានរូប ។

គ្រានោះ ព្រះពោធិសត្វជា **ស្ដេចចក្រពត្តិ** ទ្រង់ឮថា “ព្រះពុទ្ធកើតឡើង” ទើបចូលទៅគាល់ហើយស្ដាប់ធម៌ រួចថ្វាយរាជសម្បត្តិក្នុងចតុមហាទ្វីប ព្រមទាំង

រតនៈ ៧ ប្រការ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ហើយទ្រង់សាងព្រះផ្នួស ក្នុងសំណាក់របស់ព្រះមានព្រះភាគព្រះអង្គនោះ, អ្នកនៅក្នុងដែនទាំងអស់កាន់យកនូវរដ្ឋុប្បាទមកឱ្យសម្រេចក្នុងកិច្ចកម្មរបស់អារាមិក ថ្វាយមហាទានដល់ភិក្ខុមានព្រះពុទ្ធជាប្រមុខ សូម្បីព្រះសាស្តាព្រះអង្គនោះ ក៏ព្យាករព្រះបាទចក្រពត្តិនោះ ។

ក៏នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **សុមង្គល**, ព្រះបិតាជាព្រះរាជាព្រះនាម **ឧគ្គត**, ព្រះមាតាព្រះនាម **បភាវតី**, ព្រះ**សុទស្សនត្ថេរ** និងព្រះ**សុរទេវត្ថេរ** ជាគូអគ្គសាវ័ក, ព្រះ**នារទត្ថេរ** ជាឧបដ្ឋាក, ព្រះ**នាគាថេរី** និង**នាគសមាលាថេរី** ជាគូអគ្គសាវិកា, ដើម **មហាវេឡុ** (ឫស្សីធំ) ជាដើមពោធិ៍, បានឮថា ឫស្សីនោះមូលមិនមានប្រហោង គឺដើមតាន់ស្អាតល្អដោយមែកធំឡើងទៅខាងលើ ហាក់បីដូចសំណុំកន្ទុយក្ងោក; ព្រះសរីរៈនៃព្រះភគវាអង្គនោះកម្ពស់ ៥០ ហត្ថ, ព្រះជន្មាយុ ៩ ម៉ឺនវស្សា ៕

**ចប់សុជាតកថាទី ១២**

# បិយទស្សីកថាទី ១៣

ក្នុងកាលនៃព្រះពុទ្ធសុជាតអង្គនោះ ក្នុងទីបំផុត ១.៨០០ កប្ប * ក្នុងកប្បមួយមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ៣ អង្គគឺ **ព្រះពុទ្ធបិយទស្សី** **ព្រះពុទ្ធអត្ថទស្សី** និង**ព្រះពុទ្ធធម្មទស្សី** ។ សូម្បីព្រះពុទ្ធទ្រង់ព្រះនាមថាបិយទស្សី អង្គនោះ ក៏មានសាវកសន្និបាត ៣ លើក; លើកទី ១ មានភិក្ខុ ១ សែនកោដិ, លើកទី ២ មានភិក្ខុ ៩ ម៉ឺនកោដិ និងលើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិ * ។

គ្រានោះ ព្រះពោធិសត្វជាមាណពឈ្មោះថា **កស្សប** ដល់ត្រើយនៃត្រៃវេទ បានស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយបរិច្ចាគទ្រព្យ ១ សែនកោដិ សាងសង្ឃារាមស្ថិតក្នុងសរណៈ និងសីលទាំងឡាយ ។ គ្រានោះ ព្រះសាស្តាទ្រង់បានព្យាករព្រះពោធិសត្វថា "អំណើះអំពី ១.៨០០ * កប្បទៅ អ្នកនឹងជាព្រះពុទ្ធ"។

---

* ច្បាប់ខ្លះថា ១១៨ កប្ប ។

* ច្បាប់ខ្លះថា លើកទី ១ មាន ១ សែនកោដិ, លើកទី ២ មាន ៩០ កោដិ, លើកទី ៣ មាន ៨០ កោដិ ។

* ច្បាប់ខ្លះថា ១១៨ កប្ប ។

**អនោមនគរ** * ជានគររបស់ព្រះមានព្រះភាគអង្គនោះ, ព្រះបិតា ជាព្រះរាជាព្រះនាម **សុទិន្ន** (សុទត្តៈ), ព្រះមាតាព្រះនាម **ចន្ទា** (សុចន្ទា), **ព្រះបាលិតត្ថេរ** និង**ព្រះសព្វទស្សិត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសោភិតត្ថេរ** ជាឧបដ្ឋាក, **ព្រះសុជាតាថេរី** និង**ព្រះធម្មទិន្នាថេរី** ជាគូអគ្គសាវិកា, ដើម **បិយង្គុ** (ប្រយង្គុ) ជាដើមពោធិ៍, ព្រះសរីរៈរបស់ព្រះអង្គនេះ មានកម្ពស់ ៨០ ហត្ថ, មានព្រះជន្មាយុ ៩ ម៉ឺនវស្សា ៕

**ចប់បិយទស្សីកថាទី ១៣**

## អត្ថទស្សីកថាទី ១៤

ក្នុងកាលតអំពីព្រះពុទ្ធបិយទស្សីអង្គនោះ ព្រះមានបុណ្យព្រះនាមថា **អត្ថទស្សី** ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតនៃព្រះអង្គនោះ ក៏មាន ៣ លើក; លើកទី ១ មានភិក្ខុ ៩ លាន ៨ សែនរូប, លើកទី ២ មានភិក្ខុ ៨ លាន ៨ សែនរូប និងលើកទី ៣ ក៏មានភិក្ខុ ៨ លាន ៨ សែនរូបដូចគ្នា ។

---

* ខុ. អបទាន. ថាជាសុធញ្ញនគរ ។

គ្រានោះ ព្រះពោធិសត្វជាតាបសឥសីមានឫទ្ធិច្រើនឈ្មោះថា **សុសិមា** បាននាំឆ័ត្រផ្កាមណ្ឌរពអំពីទេវលោកមកបូជាព្រះសាស្តា ។ សូម្បីព្រះសាស្តា ក៏បានព្យាករព្រះពោធិសត្វនោះដែរ ។

នគររបស់ព្រះភគវាអង្គនោះឈ្មោះថា **សោភណៈ**, ព្រះបិតាជាព្រះរាជាព្រះនាម **សាគរៈ**, ព្រះមាតាព្រះនាម **សុទស្សនា**, **ព្រះសន្តត្ថេរ** និង**ព្រះឧបសន្តត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះអភយត្ថេរ** ជាឧបដ្ឋាក, **ព្រះធម្មាថេរី** និង**ព្រះសុធម្មាថេរី** ជាគូអគ្គសាវិកា, ដើម **ចម្បកៈ** (ដើមចម្បា) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៨០ ហត្ថ, រស្មីព្រះវរកាយផ្សាយទៅជុំវិញ ១ យោជន៍ អស់កាលជានិច្ច, ព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់អត្ថទស្សីកថាទី ១៤**

# ធម្មទស្សីកថាទី ១៥

ក្នុងកាលតអំពីព្រះពុទ្ធអត្ថទស្សីអង្គនោះ ព្រះសាស្តាព្រះនាមថា **ធម្ម-ទស្សី** ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក;

សន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិរូប, លើកទី ២ មានភិក្ខុ ៧០ កោដិរូប និងលើកទី ៣ មានភិក្ខុ ៨០ កោដិរូប ។

គ្រានោះ ព្រះពោធិសត្វជាសក្កទេវរាជ ទ្រង់បានធ្វើការបូជាដោយផ្កាឈើក្រអូបដ៏ជាទិព្វ និងដោយតន្ត្រីទិព្វ ។ សូម្បីព្រះសាស្តាអង្គនោះ ក៏បានព្យាករនូវសក្កទេវរាជនោះដែរ ។

នគររបស់ព្រះភគវន្តមុនីអង្គនោះឈ្មោះថា **សរណៈ**, ព្រះបិតាជាព្រះ-រាជាព្រះនាម **សរណៈ**, ព្រះមាតាព្រះនាម **សុនន្ទា**, **ព្រះបទុមត្ថេរ** និង**ព្រះបុស្សទេវត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសុនេត្តត្ថេរ** ជាឧបដ្ឋាក, **ព្រះខេមាថេរី** និង**ព្រះសច្ចនាមាថេរី** ជាគូអគ្គសាវិកា, ដើម**រត្តក្ខុរវក** (ដើមទន្លាប់) ជាដើមពោធិ៍, ក៏ព្រះសរីរៈរបស់ព្រះភគវន្តមុនីអង្គនោះ មានកម្ពស់ ៨០ ហត្ថ, មានព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់ធម្មទស្សីកថាទី ១៥**

# សិទ្ធត្ថកថាទី ១៦

ក្នុងកាលតអំពីព្រះសម្មាសម្ពុទ្ធធម្មទស្សីអង្គនោះមក រាប់ថយក្រោយអំពីកប្បនេះទៅ ៩៤ កប្ប ក្នុងកប្បមួយមានព្រះពុទ្ធមួយព្រះអង្គទ្រង់ឧប្បត្តិឡើងព្រះនាមថា **សិទ្ធត្ថ** ។ សូម្បីសាវកសន្និបាតនៃព្រះមានបុណ្យអង្គនោះ ក៏មាន ៣ លើក; លើកទី ១ មានភិក្ខុ ១ សែនកោដិ (រយកោដិ) រូប, លើកទី ២ មានភិក្ខុ ៩0 កោដិរូប និងលើកទី ៣ មានភិក្ខុ ៨0 កោដិរូប ។

គ្រានោះ ព្រះពោធិសត្វជាតាបសឈ្មោះ **មង្គល** មានតេជៈដ៏ខ្ពស់ដល់ព្រមដោយកម្លាំងអភិញ្ញាបាននាំមកនូវមហាជម្ពូផល (ផ្លែព្រីងធំ) មកថ្វាយព្រះតថាគត ។ ព្រះសាស្តាទ្រង់សោយផ្លែនេះហើយ ទ្រង់បានព្យាករពោធិសត្វថា “ក្នុងទីបំផុតនៃកប្ប ៩៤ អ្នកនឹងជាព្រះពុទ្ធ” ។

នគររបស់ព្រះភគវន្តមុនីអង្គនោះឈ្មោះ **វេភារៈ**, ព្រះបិតាជាព្រះរាជាព្រះនាម **ជេយ្យសេន**[*], ព្រះមាតាព្រះនាម **សុផស្សា**, **ព្រះសម្ពលត្ថេរ** និង **ព្រះសុមិត្តត្ថេរ** ជាគូអគ្គសាវក, **ព្រះរេវតត្ថេរ** ជាឧបដ្ឋាក, **ព្រះសីវលាថេរី** និង**ព្រះសុរាមាថេរី** ជាគូអគ្គសាវិកា, **ដើមកណ្ណិការ** ជាដើមពោធិ៍, ព្រះសរីរៈ

[*] ច្បាប់ខ្លះថា ជយសេន ។

របស់ព្រះអង្គមានកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុ ១ សែនវស្សា ៕

**ចប់សិទ្ធត្ថកថាទី ១៦**

## តិស្សកថាទី ១៧

ក្នុងកាលតអំពីព្រះពុទ្ធអង្គនោះមក ថយពីភទ្ទកប្បនេះ ៩២ កប្ប ក្នុងកប្បមួយមានព្រះពុទ្ធ ២ អង្គ គឺ ព្រះសម្មាសម្ពុទ្ធ **តិស្សៈ** និង**ផុស្សៈ** ។ សាវកសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធតិស្សៈក៏មាន ៣ លើក; លើកទី ១ មានភិក្ខុ ១០០ កោដិរូប, លើកទី ២ មានភិក្ខុ ៩០ កោដិរូប និងលើកទី ៣ មានភិក្ខុ ៨០ កោដិរូប ។

គ្រានោះ ព្រះពោធិសត្វជាក្សត្រព្រះនាម **សុជាតៈ** មានរាជសម្បត្តិច្រើន មានយសធំ ទ្រង់សាងផ្នួសជាឥសី ដល់ភាពជាអ្នកមានឫទ្ធិច្រើន ទ្រង់ឮថា “ព្រះពុទ្ធកើតឡើងហើយ” ទើបកាន់យកផ្កាមណ្ឌរពៈ ផ្កាបទុម និងផ្កាបរិច្ឆត្តកៈដ៏ជាទិព្វមកបូជាព្រះតថាគត កាលយាងទៅក្នុងកណ្តាលបរិសទ័ ៤ ពួក ផ្កាឈើនោះបានជាពិតានផ្កាតាំងនៅឰដ៏អាកាស ។ សូម្បីព្រះសាស្តាអង្គនោះ ក៏បានព្យាករពោធិសត្វនោះថា “រាប់អំពីកប្បនេះទៅក្នុងកប្បទី ៩២ អ្នកនឹងជាព្រះពុទ្ធ”។

នគររបស់ព្រះមានបុណ្យអង្គនោះ ឈ្មោះថា **ខេមៈ**, ព្រះបិតាជាក្សត្រ ព្រះនាម **ជនសន្ធ**, ព្រះមាតាព្រះនាម **បទុមា**, **ព្រះទេវត្ថេរ** និង**ព្រះឧភយ-ត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសុមនត្ថេរ** ជាឧបដ្ឋាក, **ព្រះបុស្សាថេរី** និង**ព្រះសុទត្តាថេរី** ជាគូអគ្គសាវិកា, **ដើមអសនៈ** (ធ្នង់) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុ ១ សែនវស្សា ៕

ចប់តិស្សកថាទី ១៧

## បុស្សកថាទី ១៨

ក្នុងកាលតអំពីព្រះពុទ្ធតិស្សៈអង្គនោះមក ព្រះសាស្តាព្រះនាម **បុស្សៈ** ក៏ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ លើកទី ១ មានភិក្ខុ ៦ លានរូប, លើកទី ២ មានភិក្ខុ ៥ លានរូប និងលើកទី ៣ មានភិក្ខុ ៣ លាន ២ សែនរូប ។

គ្រានោះ ពោធិសត្វជាក្សត្រព្រះនាមថា **វិជិតាវី** បានទ្រង់លះរាជសម្បត្តិដ៏ធំ ទ្រង់សាងផ្នួសក្នុងសំណាក់ព្រះសាស្តារៀនចប់ព្រះត្រៃបិដក, បានសម្តែងធម្មកថាដល់មហាជន និងបំពេញសីលបារមី ។ សូម្បីព្រះពុទ្ធអង្គនោះ

ក៏បានព្យាករនូវពោធិសត្វនោះថា "អ្នកនឹងជាព្រះពុទ្ធ" ។ នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **កាសី**, ព្រះរាជបិតាព្រះនាម **ជយសេន**, ព្រះរាជមាតាព្រះនាម **សិរិមា**, **ព្រះសុរក្ខិត្តត្ថេរ** និង**ព្រះធម្មសេនត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសភិយត្ថេរ** ជាឧបដ្ឋាក, **ព្រះចាលាថេរី** និង**ឧបចាលាថេរី** ជាអគ្គសាវិកា, ដើម **អាមលកៈ** (កន្ទួតព្រៃ) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៥៨ ហត្ថ, ព្រះជន្មាយុ ៩ ម៉ឺនវស្សា ៕

ចប់បុស្សកថាទី ១៨

## វិបស្សីកថាទី ១៩

ក្នុងកាលតអំពីព្រះសម្មាសម្ពុទ្ធបុស្សៈនោះមក រាប់ពីកប្បនេះថយទៅក្នុងកប្បទី ៩១ ព្រះភគវាព្រះនាម **វិបស្សី** ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក; ក្នុងសាវកសន្និបាតលើកទី ១ មានភិក្ខុ ៦ លាន ៨ សែនរូប, លើកទី ២ មានភិក្ខុ ១ សែនរូប និងលើកទី ៣ មានភិក្ខុ ៨ ម៉ឺនរូប ។

គ្រានោះ ពោធិសត្វជានាគរាជឈ្មោះ **អតុលៈ** មានឫទ្ធិច្រើន មានអានុ

ភាពច្រើន បានថ្វាយតាំងមាសធំដ៏ល្អ វិចិត្រដោយរតនៈ ៧ ប្រការ ដល់ព្រះភគវា ។ សូម្បីព្រះសាស្តាអង្គនោះ ក៏បានព្យាករពោធិសត្វនោះថា “រាប់ពីកប្បនេះទៅ ក្នុងកប្បទី ៩១ អ្នកនឹងជាព្រះពុទ្ធ” ។

នគររបស់ព្រះភគវាអង្គនោះឈ្មោះ **ពន្ធុមតី**, ព្រះរាជបិតា ព្រះនាម **ពន្ធុមា**, ព្រះមាតាព្រះនាម **ពន្ធុមតី**, **ព្រះខណ្ឌត្ថេរ** និង**ព្រះតិស្សត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះអសោកត្ថេរ** ជាឧបដ្ឋាក, **ព្រះចន្ទាថេរី** និង**ព្រះចន្ទមិត្តាថេរី** ជាគូអគ្គសាវិកា, ដើម **បាដលិ** (អង្កាសដី) ជាដើមពោធិ៍, ព្រះអង្គមានសរីរៈកម្ពស់ ៨០ ហត្ថ, មានរស្មីផ្សាយទៅ ៧ យោជន៍ដោយជុំវិញ, មានជន្មាយុ ៨ ម៉ឺនវស្សា ៕

ចប់វិបស្សីកថាទី ១៩

## សិខីកថាទី ២០

តអំពីព្រះសម្មាសម្ពុទ្ធវិបស្សីនោះមក ថយក្រោយអំពីភទ្ទកប្បនេះ ក្នុងកប្បទី ៣១ មានព្រះពុទ្ធទ្រង់ឧប្បត្តិឡើងពីរព្រះអង្គគឺ **ព្រះសិខី** និង**ព្រះវេស្សភូ**, សូម្បីសាវកសន្និបាតរបស់ព្រះមានព្រះភាគព្រះនាម **សិខី** ក៏មាន ៣ លើក; លើកទី ១ មានភិក្ខុ ១ សែនរូប, លើកទី ២ មានភិក្ខុ ៨ ម៉ឺនរូប និងលើក

ទី ៣ មានភិក្ខុ ៧ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាម **អរិន្ទមៈ** បានថ្វាយមហាទាន និងចីវរដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ បានថ្វាយដំរីកែវ ដែលប្រដាប់ដោយរតនៈ ៧ ប្រការ, ថ្វាយកប្បិយភណ្ឌ ធ្វើឱ្យជាប្រមាណប៉ុននឹងដំរី ។ សូម្បីព្រះអង្គនោះ ក៏បានព្យាករព្រះពោធិសត្វនោះថា "រាប់ពីកប្បនេះទៅ ក្នុងកប្បទី ៣១ អ្នកនឹងបានជាព្រះពុទ្ធ" ។

នគររបស់ព្រះភគវាអង្គនោះឈ្មោះ **អរុណវតី**, ព្រះរាជបិតាព្រះនាម **អរុណៈ**, ព្រះមាតាព្រះនាម **បភាវតី**, **ព្រះអភិភូថេរៈ** និង**ព្រះសម្ភវត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះខេមង្ករត្ថេរ** ជាឧបដ្ឋាក, **ព្រះសខិលាថេរី** និង**ព្រះបទុមាថេរី** ជាគូអគ្គសាវិកា, ដើម **បុណ្ឌរីក** (ស្វាយស) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៧០ ហត្ថ, មានរស្មីនៃសរីរៈផ្សាយទៅ ៣ យោជន៍ដោយជុំវិញ, មានព្រះជន្មាយុ ៧ ម៉ឺនវស្សា ៕

**ចប់សិខីកថាទី ២០**

## វេស្សភូកថាទី ២១

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធសិខីអង្គនោះមក ព្រះសាស្តាព្រះនាម **វេស្សភូ** ក៏ទ្រង់ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក; លើកទី ១ មានភិក្ខុ ៨ ម៉ឺនរូប, លើកទី ២ មានភិក្ខុ ៧ ម៉ឺនរូប និងលើកទី ៣ មានភិក្ខុ ៦ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាម **សុទស្សនៈ** បានថ្វាយមហាទានព្រមទាំងចីវរដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយសាងផ្នួសក្នុងសំណាក់ព្រះសាស្តា ជាអ្នកដល់ព្រមដោយអាចារគុណ ជាអ្នកឱនលំទោន និងច្រើនដោយបីតិក្នុងព្រះពុទ្ធរតនៈ សូម្បីព្រះមានព្រះភាគអង្គនោះ ក៏បានព្យាករព្រះពោធិសត្វនោះថា "រាប់អំពីកប្បនេះទៅ ក្នុងកប្បទី ៣១ អ្នកនឹងជាព្រះពុទ្ធ" ។ នគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះ **អនោមៈ**, ព្រះរាជបិតាព្រះនាម **សុប្បតីតៈ**, ព្រះមាតាព្រះនាម **យសវតី**, **ព្រះសោណត្ថេរ** និង**ព្រះឧត្តរត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះឧបសន្តត្ថេរ** ជាឧបដ្ឋាក, **ព្រះរាមាថេរី** និង **សុបលាថេរី** ជាគូអគ្គសាវិកា*, **ដើមសាលព្រឹក្ស** ជាដើមពោធិ៍, ព្រះអង្គមាន

---

* ច្បាប់ខ្លះថា ទាមា, សមាលា ។

សរីរៈកម្ពស់ ៦០ ហត្ថ, មានព្រះជន្មាយុ ៦ ម៉ឺនវស្សា ៕

ចប់វេស្សភូកថាទី ២១

## កកុសន្ធកថាទី ២២

ក្នុងកាលតអំពីព្រះសម្មាសម្ពុទ្ធវេស្សភូអង្គនោះមក ក្នុងកប្បមួយ មានព្រះពុទ្ធ ៤ អង្គ ទ្រង់ឧប្បត្តិឡើងគឺ **ព្រះពុទ្ធកកុសន្ធៈ**, **ព្រះពុទ្ធកោនាគមនៈ**, **ព្រះពុទ្ធកស្សប** និង**ព្រះមានព្រះភាគរបស់យើងទាំងឡាយ** ។ សូម្បីសាវកសន្និបាតរបស់ព្រះពុទ្ធព្រះនាមកកុសន្ធៈ មានតែម្តងគត់ ដោយមានភិក្ខុប្រជុំ ៤ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វទ្រង់ជាព្រះរាជាព្រះនាម **ខេមៈ** បានថ្វាយមហាទានព្រមទាំងបាត្រចីវរ និងថ្នាំបន្តក់ភ្នែកទាំងឡាយ* បានស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយទ្រង់សាងព្រះផ្នួស ។ សូម្បីព្រះសាស្តាអង្គនោះ បានព្យាករ

* ច្បាប់ខ្លះថា ភេសជ្ជទាំងឡាយមានថ្នាំបន្តក់ភ្នែកជាដើម ។

ពោធិសត្វនោះដែរ ។

នគររបស់ព្រះមានព្រះភាគអង្គនោះឈ្មោះថា **ខេមៈ**, ព្រះបិតាជាព្រាហ្មណ៍ឈ្មោះថា **អគ្គិទត្ត**, ព្រះមាតាជាព្រាហ្មណីឈ្មោះ **វិសាខា**, **ព្រះវិធុរត្ថេរ** និង**ព្រះសញ្ជីវត្ថេរ** ជាគូអគ្គសាវ័ក, ឧបដ្ឋាកឈ្មោះ **វុឌ្ឍិជត្ថេរ**, **ព្រះសាមាថេរី** និង**ព្រះសរព្ភាថេរី** ជាគូអគ្គសាវិកា, ដើម**មហាសិរីសៈ**ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ៤០ ហត្ថ, ព្រះជន្មាយុមាន ៤ ម៉ឺនវស្សា ៕

**ចប់កកុសន្ធកថាទី ២២**

## កោនាគមនកថាទី ២៣

ក្នុងកាលបន្ទាប់ពីព្រះសម្មាសម្ពុទ្ធកកុសន្ធៈនោះមក ព្រះសាស្តាព្រះនាម **កោនាគមនៈ** ឧប្បត្តិឡើង ។ សាវកសន្និបាតរបស់ព្រះអង្គមានតែម្តង ក្នុងសន្និបាតនោះ មានភិក្ខុ ៣ ម៉ឺនរូប ។

គ្រានោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាម **បព្វតៈ** ទ្រង់ហែហមដោយពួកអាមាត្យ ស្តេចយាងទៅសំណាក់ព្រះសាស្តាស្តាប់ធម្មទេសនា ហើយនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ រួចថ្វាយមហាទាន ហើយថ្វាយសំពត់បគុណៈ

(សំពត់ក្រុង) សំពត់ចិន សំពត់សូត្រ សំពត់ព្រៃ សំពត់កម្ពល និងស្បែកជើងមាស ហើយទ្រង់សាងផ្នួសក្នុងសំណាក់ព្រះសាស្តា ។ សូម្បីព្រះសាស្តាអង្គនោះក៏បានព្យាករពោធិសត្វនោះ ។ នគររបស់ព្រះភគវាអង្គនោះឈ្មោះ **សោភនៈ** *, ព្រះបិតាជាព្រាហ្មណ៍ឈ្មោះ **យញ្ញទត្ត**, ព្រះមាតាជាព្រាហ្មណី ឈ្មោះ **ឧត្តរា**, **ព្រះភិយ្យសត្ថេរ** និង**ព្រះឧត្តរត្ថេរ** ជាគូអគ្គសាវ័ក, **ព្រះសោត្ថិជត្ថេរ** ជាឧបដ្ឋាក, **ព្រះសមុទ្ទាថេរី** និង**ព្រះឧត្តរាថេរី** ជាគូអគ្គសាវិកា, ដើម **ឧទុម្ពរ** (ល្វា) ជាដើមពោធិ៍, ព្រះសិរីរៈមានកម្ពស់ ៣០ ហត្ថ, ព្រះជន្មាយុ ៣ ម៉ឺនវស្សា ៕

**ចប់កោនាគមនៈកថាទី ២៣**

## កស្សបកថាទី ២៤

ក្នុងកាលបន្ទាប់ពីព្រះសម្មាសម្ពុទ្ធកោនាគមនៈអង្គនោះមក ព្រះសាស្តាព្រះនាម **កស្សបៈ** ក៏ឧប្បត្តិឡើង ។ សូម្បីសាវកសន្និបាតរបស់ព្រះមានបុណ្យអង្គនោះមានតែម្តងគត់ មានភិក្ខុ ២ ម៉ឺនរូប ។

---

* ច្បាប់ខ្លះថា សោភវតី ។

គ្រានោះ ព្រះពោធិសត្វជាមាណពឈ្មោះ **ជោតិបាល** ជាអ្នកដល់នូវត្រៃវេទ មានកិត្តិសព្ទខ្ចរខ្ចាយទូទៅទាំងផ្លូវផែនដី ទាំងផ្លូវអាកាស បានជាមិត្តរបស់ស្មូនឆ្នាំងឈ្មោះឃដិការ, ព្រះពោធិសត្វបានចូលគាល់ព្រះសាស្តា ព្រមទាំងស្មូនឆ្នាំងនោះ ស្តាប់ធម្មកថាហើយបួស ប្រារព្ធសេចក្តីព្យាយាម រៀនចប់ព្រះត្រៃបិដក ជម្រះពុទ្ធសាសនាដោយវត្តសម្បត្តិ ។ សូម្បីព្រះសាស្តាអង្គនោះ ក៏បានព្យាករពោធិសត្វនោះ ។

នគររបស់ព្រះមានបុណ្យអង្គនោះឈ្មោះ **ពារាណសី**, ព្រះបិតាជាព្រាហ្មណ៍ឈ្មោះ **ព្រហ្មទត្ត**, ព្រះមាតាឈ្មោះ**ធនវតី***, **ព្រះតិស្សត្ថេរ** និង**ព្រះភារទ្វាជត្ថេរ** ជាគូអគ្គសាវ័ក, ឧបដ្ឋាកឈ្មោះ **សព្វមិត្តត្ថេរ**, **ព្រះអនុឡាថេរី** និង**ព្រះឧរុវេឡាថេរី** ជាគូអគ្គសាវិកា, ដើម **និគ្រោធ** (ជ្រៃ) ជាដើមពោធិ៍, ព្រះសរីរៈមានកម្ពស់ ២០ ហត្ថ, ព្រះជន្មាយុ ២ ម៉ឺនវស្សា ។

## ចប់កស្សបកថាទី ២៤

* ច្បាប់សីហឡថា ចន្ទវតី ។

## សម្តែងអំពីធម្មសមោធាន ៨ ប្រការ

ចំណែកក្នុងកាលបន្ទាប់អំពីព្រះសម្មាសម្ពុទ្ធកស្សបអង្គនោះមក វៀរព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយនេះហើយ ព្រះពុទ្ធអង្គដទៃមិនមានទេ * ។ ក៏ព្រះពោធិសត្វបានទទួលព្យាករណ៍អំពីសំណាក់ព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធទីបង្ករជាដើម, ពុទ្ធការកធម៌ទាំងឡាយ មាន**ទានបារមី**ជាដើម ដែលពោធិសត្វទ្រង់ប្រមូលធម៌ ៨ ប្រការនេះ គឺ

**១.មនុស្សត្តំ** ភាពជាមនុស្ស

**២.លិង្គសម្បត្តិ** ដល់ព្រមដោយភេទ

**៣.ហេតុ** មានឧបនិស្ស័យនៃព្រះអរហត្ត

**៤.សត្ថារទស្សនំ** ការបានឃើញព្រះសាស្តា

**៥.បព្វជ្ជា** បានបួស

**៦.គុណសម្បត្តិ** ដល់ព្រមដោយគុណ

**៧.អធិការោ** មានសេចក្តីប្រាថ្នាខ្លាំងក្លា

---

* ប៉ុន្តែនៅក្នុងគម្ពីរពុទ្ធវង្ស ព្រះអង្គទ្រង់សម្តែងថា ក្នុងអនាគតនឹងមានព្រះសម្មាសម្ពុទ្ធ ១ អង្គទៀត ទ្រង់ព្រះនាមថា សិអារ្យមេត្រី ( អរិយមេត្តេយ្យ ) ។

**៨-ឆន្ទតា** មានសេចក្ដីពេញចិត្ត[៦១] ។

បុញ្ញាភិនីហារ រមែងសម្រេចបានដោយធម្មសមោធាន ៨ ប្រការហើយ ទ្រង់ធ្វើអភិនីហារទៀបព្រះបាទមូលនៃព្រះពុទ្ធទីបង្ករ ទ្រង់តាំងសេចក្ដីព្យាយាមថា "ណ្ហើយចុះ ! អញនឹងគន់រកនូវពុទ្ធការកធម៌គ្រប់ផ្នែកអំពីនេះអំពីនោះ" ឃើញហើយថា "គ្រានោះ អាត្មាអញបានពិចារណាឃើញទានបារមីទី ១" ទើបបំពេញពុទ្ធការកធម៌ទាំងនោះ រហូតដល់អត្តភាពជាវេស្សន្តរ ។

ម្យ៉ាងទៀត កាលព្រះអង្គបានសម្រេចអានិសង្សរបស់ព្រះពោធិសត្វអ្នកមានអភិនីហារដែលធ្វើទុកហើយ, អានិសង្សទាំងនោះ លោកពណ៌នាទុកថា ៖-

**"នរជនទាំងឡាយណា អ្នកសម្បូណ៌ដោយគុណទាំងពួងយ៉ាងនេះ ជាអ្នកទៀងដើម្បីត្រាស់ដឹង កាលត្រេចទៅកាន់សង្សារវដ្ដអស់កាលដ៏យូរ សូម្បីតាំងនៅអស់រយនៃកោដិកប្ប ក៏មិនកើតក្នុងអវិចី និងលោកន្តរនរក មិនកើតជានិជ្ឈាមតណ្ហិកប្រេត ខុប្បិបាសិកប្រេត កាលកញ្ជិកប្រេត[*] ; សូម្បីកើតក្នុងទុគ្គតិភព ក៏មិនកើតជាសត្វល្អិតៗ កាលកើតក្នុងមនុស្ស ក៏**

---

[៦១] ខុ. ពុទ្ធ. ។

[*] ម. ម. កាលកញ្ជកា, សីកលកញ្ជកា ។

មិនកើតជាអ្នកខ្វាក់ខ្វិនពីកំណើត មិនជាមនុស្សត្រចៀកថ្លង់ មិនជាមនុស្សគ មិនជាមនុស្សពិការ មិនជាមនុស្សស្រី មិនជាមនុស្សឧភតោព្យញ្ជនកៈ និងមិនជាមនុស្សខ្ទើយ ។ រមែងមិនជាបុគ្គលអ្នករាប់បញ្ចូលហើយ ក្នុងអភព្វបុគ្គលទាំងឡាយ ជាអ្នករួចផុត ហើយចាកអនន្តរិយកម្ម ជានរជនអ្នកទៀងដើម្បីត្រាស់ដឹង មានគោចរដ៏បរិសុទ្ធ ក្នុងទីទាំងពួង, មិនសេពមិច្ឆាទិដ្ឋិ មានការឃើញក្នុងការធ្វើថាជាកម្ម សូម្បីកាលនៅក្នុងសួគ៌ ក៏មិនកើតនៅក្នុងអសញ្ញីភព, ឈ្មោះថា ហេតុកើតក្នុងសុទ្ធាវាសទាំងឡាយ មិនមាន ជាអ្នកបង្អោនទៅក្នុងនេក្ខម្មៈ ជាសប្បុរសមិនជាប់នៅក្នុងភពតូចភពធំ រមែងត្រាច់ទៅដើម្បីប្រយោជន៍ដល់សត្វលោក រមែងបំពេញបារមីទាំងពួង”។

កាលព្រះពោធិសត្វសម្រេចអានិសង្សទាំងនោះ មកបំពេញបារមីទាំងឡាយនៅក្នុងកាលសោយព្រះជាតិជាអកិត្តិព្រាហ្មណ៍, ក្នុងកាលសោយព្រះជាតិជាសង្ខព្រាហ្មណ៍, ជាស្តេចធនញ្ជ័យ, ជាស្តេចមហាសុទស្សនៈ, ជាមហាគោវិន្ទ, ជាស្តេចនិមិមហារាជ, ជាចន្ទកុមារ, ជាវិសយ្ហសេដ្ឋី, ជាសសបណ្ឌិត, ជាសីវិរាជ និងកាលសោយព្រះជាតិជាវេស្សន្តរ, ឈ្មោះថា បរិមាណ

នៃអត្តភាពដែលបំពេញទានបារមី មានគុណរាប់មិនបាន ៕

## សម្តែងអំពីទានជាបរមត្ថ

ក៏ព្រះពោធិសត្វសោយព្រះជាតិជាសសបណ្ឌិត បានលះអត្តភាពដែលលោកពោលទុកក្នុងសសបណ្ឌិតជាតកយ៉ាងនេះថាៈ-

**“ភិក្ខាយ ឧបគតំ ទិស្វា, សកត្តានំ បរិច្ចជឹ;**
**ទានេន មេ សមោ នត្ថិ; ឯសា មេ ទានបារមី ។**

យើងឃើញព្រាហ្មណ៍ចូលមកសុំ, ទើបលះបង់អត្តភាពរបស់ខ្លួន;
**ទានរបស់យើងគ្មានអ្នកស្មើ; នុ៎ះជាទានបារមីរបស់យើង”** [៦២] ។

ឈ្មោះថា ការបំពេញទានជាបរមត្ថបារមី ដោយមួយចំណែក ។

## សម្តែងអំពីសីលបារមីដែលជាបរមត្ថ

ក៏ឈ្មោះថា បរិមាណអត្តភាពដែលបំពេញសីលបារមី មានគុណដែលរាប់មិនបាន គឺក្នុងកាលសោយព្រះជាតិជាសីវិរាជ, ជាចម្បេយ្យនាគរាជ, ជាភូរិ

---

[៦២] ខុ. ចរិយា. (សសបណ្ឌិតចរិយា) ។

**ទត្តនាគរាជ**, **ជាពញ្ញាឆទ្ទន្ត**, ជារាជបុត្តរបស់ព្រះបាទជយទិសរាជ និងកាលសោយព្រះជាតិជា **អលីនចិត្តកុមារ** ។

ក៏កាលព្រះពោធិសត្វនោះ ធ្វើការបរិច្ចាគអត្តភាព ដែលពោលទុកក្នុងសង្ខបាលជាតកយ៉ាងនេះថា ៖-

**“សូលេហិ វិជ្ឈយន្តេបិ កោដ្ដយន្តេបិ សត្តិភិ**

**ភោជបុត្តេ ន កុប្បាមិ ឯសា មេ សីលបារមី** ។

យើងសូម្បីត្រូវគេបាញ់ដោយព្រួញទាំងឡាយ, សូម្បីត្រូវគេចាក់ដោយលំពែងទាំងឡាយ, ក៏មិនក្រោធចំពោះបុត្រមេស្រុក; នុ៎ះជាសីលបារមីរបស់យើង” ។

ឈ្មោះថា **បំពេញសីលជាបរមត្ថបារមី** ដោយចំណែកមួយ ៕

## សម្ដែងអំពីនេក្ខម្មបារមីជាបរមត្ថ

ក៏ឈ្មោះថាការបរិមាណអត្តភាពដែលលះបង់រាជសម្បត្តិធំ បំពេញនេ-ក្ខម្មបារមីមានគុណរាប់មិនបាន គឺក្នុងកាលសោយព្រះជាតិជា **សោមនស្សកុមារ**

ជាតិជាហត្ថិបាលកុមារ និងជាអយោឃរបណ្ឌិត ។ ក៏កាលព្រះពោធិសត្វលះបង់រាជសម្បត្តិ ចេញផ្នួសព្រោះការលះ ដែលលោកពោលទុកក្នុងចូឡសុត្ត-សោមជាតកយ៉ាងនេះថា ៖-

**"មហារជ្ជំ ហត្ថគតំ ខេឡបិណ្ឌំវ ឆឌ្ឌយឹ**
**ចជតោន ហោតិ លគ្គនំ ឯសា មេ នេក្ខម្មបារមី ។**

យើងលះបង់មហារាជសម្បត្តិដែលនៅក្នុងព្រះហស្ត, ដូចការខ្ជាក់ចោលនូវដុំនៃទឹកមាត់ កាលយើងលះហើយ ក៏មិនមានការសោកស្តាយ; នុ៎ះជានេក្ខម្មបារមីរបស់យើង" ។

ឈ្មោះថា **បំពេញនេក្ខម្មជាបរមត្ថបារមី** ដោយចំណែកមួយ ៕

## សម្តែងអំពីបញ្ញាបារមីជាបរមត្ថ

ក៏ឈ្មោះថា បរិមាណអត្តភាពដែលបំពេញបញ្ញាបារមីដែលមានគុណប្រ-មាណមិនបាន គឺកាលព្រះអង្គសោយព្រះជាតិជាវិធុរបណ្ឌិត, ជាបណ្ឌិតនាមថាមហាគោវិន្ទ, ជាកុទ្ទាលបណ្ឌិត, កាលជាអរកបណ្ឌិត, ជាពោធិបរិញ្វជក និង កាលសោយព្រះជាតិជាមហោសថបណ្ឌិត ។

ក៏កាលព្រះពោធិសត្វ សោយព្រះជាតិជាសេនកបណ្ឌិត ក្នុងសត្តុភស្តជាតក សម្ដែងហើយនូវពស់ពិសក្នុងថៃ (បាវ) ដែលពោលទុកយ៉ាងនេះថា ៖-

**"បញ្ញាយ វិចិនន្តោហំ ព្រាហ្មណំ មោចយឹ ទុក្ខា;**

**បញ្ញាយ មេ សមោ នត្ថិ ឯសា មេ បញ្ញាបារមី ។**

យើងប្រើបញ្ញាពិចារណា, ទើបជួយព្រាហ្មណ៍ឱ្យរួចផុតចាកទុក្ខ; បញ្ញារបស់យើងមិនមានអ្នកណាស្មើទេ; នុ៎ះជាបញ្ញាបារមីរបស់យើង" ។

ឈ្មោះថា **ការបំពេញបញ្ញា ជាបរមត្ថបារមី** ដោយចំណែកមួយ ៕

## សម្ដែងអំពីវីរិយបារមីជាដើមដែលជាបរមត្ថ

ក៏ឈ្មោះថា បរិមាណអត្តភាពដែលបំពេញវីរិយបារមីជាដើម ជាគុណរាប់មិនបានដូចគ្នា ។ ក៏កាលព្រះពោធិសត្វ សោយព្រះជាតិជាមហាជនក អ្នកឆ្លងមហាសមុទ្រដែលពោលទុកក្នុង**មហាជនកជាតក**យ៉ាងនេះថា ៖-

**"អតីរទស្សី ជលមជ្ឈេ ហតា សព្វេ ច មានុសា**

**ចិត្តស្ស អញ្ញថា នត្ថិ ឯសោ មេ វីរិយបារមី ។**

មនុស្សទាំងឡាយមើលមិនឃើញត្រើយ; ទាំងអស់គ្នាស្លាប់ក្នុងកណ្ដាលមហាសមុទ្រ; ចិត្តរបស់យើងមិនបានប្រែប្រួលជាយ៉ាងដទៃ; នុ៎ះជាវីរិយបារមីរបស់យើង" ។

ឈ្មោះថា **ការបំពេញវីរិយៈ ជាបរមត្ថបារមី** ដោយចំណែកមួយ ។

កាលពោធិសត្វសោយព្រះជាតិជា **ខន្តិវាទីតាបស** ទ្រង់អត់ទ្រាំហើយនូវទុក្ខដ៏ធំ ដូចមិនមានចិត្តដែលពោលទុកក្នុង **ខន្តិវាទីជាតក** យ៉ាងនេះថា ៖-

**"អចេតនំ វ កោដេន្តោ តិណ្ហេន*[*] ផរសុនា មមំ**

**កាសិរាជេ ន កុប្បាមិ ឯសា មេ ខន្តិបារមី ។**

កាលព្រះបាទកាសិរាជ ប្រើពូថៅដ៏មុតកាប់យើង ដូចជាអ្នកគ្មានចិត្តយើងក៏មិនក្រោធ; នុ៎ះជាខន្តិបារមីរបស់យើង"។

ឈ្មោះថា ការបំពេញ **ខន្តិជាបរមត្ថបារមី** ដោយចំណែកមួយ ។

កាលព្រះពោធិសត្វសោយព្រះជាតិជាព្រះបាទ **មហាសុត្តសោម** បានលះបង់ជីវិតដើម្បីរក្សាពាក្យសត្យៈ ដែលលោកពោលទុកក្នុង **មហាសុត្តសោម**

---

[*] ច្បាប់ខ្លះថា តិក្ខេន ។

ជាតក យ៉ាងនេះថា ៖-

**“សច្ចវាចំ អនុរក្ខន្តោ ចជិត្វា មម ជីវិតំ**

**មោចេមិ * ឯកសតក្ខត្តេ ឯសា មេ សច្ចបារមី ។**

យើងលះបង់ជីវិតរបស់យើង កាលតាមរក្សានូវសច្ចវាចាឱ្យរួចពីក្សត្រ ១០១ ព្រះអង្គ, នុ៎ះជាសច្ចបារមីរបស់យើង” ។

ឈ្មោះថា ការបំពេញ សច្ចជាបរមត្ថបារមី ដោយចំណែកមួយ ។

កាលព្រះពោធិសត្វសោយព្រះជាតិជាតេមិយៈ ក៏ទ្រង់លះបង់ជីវិតអធិដ្ឋានវត្តពោលទុកក្នុង មូគបក្ខជាតក ជាតកពោលដោយបុគ្គលជាអ្នកគ និង (ពិការ) យ៉ាងនេះថា ៖-

**“មាតាបិតា ន មេ ទេស្សា អត្តា មេ ន ច ទេស្សិយោ ***

**សព្វញ្ញុតំ បិយំ មយ្ហំ តស្មា វត្តមធិដ្ឋហឹ ។**

ព្រះមាតាបិតាមិនមែនជាអ្នកគួរស្អប់ខ្ពើមរបស់យើងទេ, ឥស្សរិយៈធំក៏មិនមែនជាទីស្អប់របស់យើងដែរ; តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់

---

* ច្បាប់ខ្លះថា មោចេសី ។

* ច្បាប់ខ្លះថា ន មេ ទេស្សំ មហាយសំ ។

យើង; ព្រោះហេតុដូច្នោះ ការអធិដ្ឋានទើបជាវត្តរបស់យើង”[៦៣] ។

ឈ្មោះថា **អធិដ្ឋានបារមី ជាបរមត្ថបារមី** ។

កាលព្រះពោធិសត្វ សោយព្រះជាតិជាព្រះបាទ**ឯករាជ** អ្នកមិនបាន ឃើញសូម្បីជីវិតរបស់ព្រះអង្គ ទ្រង់ចម្រើនមេត្តាដែលពោលទុកក្នុង**ឯករាជ ជាតក** យ៉ាងនេះថា ៖-

**“ន មំ កោចិ ឧត្តសតិ នបិ ភាយាមិ កស្សចិ**

**មេត្តាពលេនុបត្ថទ្ធោ រមាមិ បវនេ តទា ។**

អ្នកណាមិនតក់ស្លុតនឹងយើង, យើងក៏មិនខ្លាចអ្នកណា; ក្នុងកាល នោះយើងបានកម្លាំងមេត្តាឧបត្ថម្ភហើយ រមែងត្រេកអរក្នុងព្រៃធំ”[៦៤] ។

ឈ្មោះថា បានបំពេញ **មេត្តាបារមី** ជាបរមត្ថបារមី ។

កាលព្រះពោធិសត្វជាអ្នកបួសឈ្មោះ **លោមហង្ស** មិនបានលះភាពជា

---

[៦៣] ខុ. ចរិយា. ( មូគបក្ខចរិយា) ។

[៦៤] ខុ. ចរិយា. ( សុវណ្ណសាមចរិយា) ។

* ច្បាប់ខ្លះថា ឆវដ្ដិកំ ឧបនិធាយហំ ។

* ច្បាប់ខ្លះថា គាមណ្ឌលា, សី. គោមណ្ឌលា ។

ឧបេក្ខាក្នុងពួកក្មេងអ្នកស្រុកដែលញ៉ាំងសេចក្តីទុក្ខ និងសុខឱ្យកើតឡើង ដោយការស្តោះទឹកមាត់ដាក់ជាដើម និងដោយការនាំផ្កាឈើគ្រឿងក្រអូបមក ឱ្យជាដើម តាមដែលពោលទុកក្នុង**លោមហង្សជាតក**យ៉ាងនេះ ៖-

**"សុសានេ សេយ្យំ កប្បេមិ ឧបនិធាយ ឆវដ្ឋិកំ** [*]

**គាមមណ្ឌលា** [*] **ឧបគន្ត្វា រូបំ ទស្សេន្តិ អនប្បកំ ។**

**យើងដេកក្នុងព្រៃស្មសាន មានឆ្អឹងខ្មោចជាគ្រឿងប្រៀបធៀប; ពួកក្មេងអ្នកស្រុកចូលទៅសម្តែងរូបមិនតិច" ។**

ឈ្មោះថា **ឧបេក្ខាបារមី** ជាបរមត្ថបារមី ។ សេចក្តីសង្ខេបក្នុងទីនេះមានប៉ុណ្ណេះ, ចំណែកសេចក្តីពិស្តារ គប្បីកាន់យកក្នុងចរិយាបិដកចុះ ។

ព្រះពោធិសត្វលុះបំពេញបារមីទាំងឡាយយ៉ាងនេះហើយស្ថិតនៅក្នុងអត្តភាពព្រះវេស្សន្តរបានសាងបុណ្យជាច្រើន ជាហេតុឱ្យផែនដីកម្រើកតាមដែលពោលទុកយ៉ាងនេះថា ៖-

---

[៦៥] ខុ. ចរិយា (វេស្សន្តរចរិយា) ។

**"អចេតនាយំ បឋវី អវិញ្ញាយ សុខទុក្ខំ**
**សាបិ ទានពលា មយ្ហំ សត្តក្ខត្តុំ បកម្បថ ។**

**ផែនដីមិនមានចិត្តទេ មិនដឹងនូវសេចក្ដីសុខ និងទុក្ខទេ ហេតុអ្វីក៏កម្រើកញ័រអស់ ៧ ដង ព្រោះកម្លាំងទាននៃយើង"**[៦៥] ។

កាលអស់ព្រះជន្មាយុហើយ ក៏ទ្រង់ចុតិអំពីលោកនេះ កើតក្នុងឋានសួគ៌ជាន់តុសិត ព្រះអង្គធំជាងទេវតាជាន់តុសិតដោយឋាន ១០ យ៉ាង * ទ្រង់សោយទិព្វសម្បត្តិដរាបដល់អស់ព្រះជន្មាយុ ៥៧ កោដិ ៦ លានឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្សឥឡូវនេះ ៧ ថ្ងៃទៀតនឹងដល់អាយុខ័យ; ព្រោះហេតុដូច្នោះ ទើបកើតបុព្វនិមិត្ត ៥ ប្រការនេះ គឺ

១- **វត្ថានិ កិលិស្សន្តិ** សំពត់ទាំងឡាយសៅហ្មង

២- **មាលា មិលាយន្តិ** ផ្កាកម្រងទាំងឡាយស្រពោន

៣- **កច្ឆេហិ សេទា មុច្ចន្តិ** ព្រះសេទៈ (ញើស) ហូរចេញអំពីព្រះកច្ឆៈ

---

* អដ្ឋ. យោ. បានដល់ហេតុ ១០ យ៉ាង គឺ អាយុ, វណ្ណ, សុខ, យស, អធិបតិ, រូប, សំឡេង, ក្លិន , រស និងផោដ្ឋព្វៈ ។

(ក្លៀក) ។

៤- **កាយេ វេវណ្ណិយំ ឱក្កមតិ** ព្រះឆវីវណ្ណក្នុងសរីរៈប្រាសចេញទៅ

៥- **ទេវា ទេវាសនេ ន សណ្ឋហតិ** ទ្រង់នឿយណាយទិព្វាសនៈ ។

ពួកទេវតាឃើញនិមិត្តទាំងនោះ នាំគ្នាស្លុតចិត្តពោលថា “អ្នកដ៏ចម្រើនទាំងឡាយអើយ ស្ថានសួគ៌ទាំងឡាយនឹងសាបសូន្យហើយ” ។ លុះដឹងថា ព្រះមហាពោធិសត្វបំពេញបារមីពេញហើយ ទើបគិតគ្នាថា “ឥឡូវនេះ ព្រះពោធិសត្វនេះទ្រង់មិនទៅកាន់ទេវលោកដទៃទេ ទ្រង់នឹងឧប្បត្តិក្នុងមនុស្សលោក ហើយត្រាស់ជាព្រះពុទ្ធ ពួកមនុស្សនាំគ្នាបំពេញបុណ្យដ៏ច្រើន ចុតិហើយៗ ក៏នឹងញ៉ាំងទេវលោកឱ្យបរិបូណ៌” ទើបនាំគ្នាក្រាបទូលអង្វរព្រះអង្គ ដើម្បីប្រយោជន៍ដល់ភាវៈជាព្រះពុទ្ធ ដូចដែលត្រាស់យ៉ាងនេះថា ៖-

**“ក្នុងកាលណា យើងតថាគតជាទេវបុត្រឈ្មោះសន្តុសិត នៅក្នុងពួកទេវតាជាន់តុសិត, ក្នុងកាលនោះពួកទេវតាមានប្រមាណមួយម៉ឺន នាំគ្នាប្រណម្យអញ្ជលី អារាធនាតថាគតថា បពិត្រព្រះមហាវីរទេព កាលនេះ ជាកាលសមគួរ ដែលព្រះអង្គទ្រង់ឧប្បត្តិក្នុងគភ៌ព្រះមាតាហើយ**

**ត្រាស់ដឹងអមតបទ ប្រោសមនុស្សលោក និងទេវលោក"** [៦៦] ។ ព្រះអង្គទើបត្រួតត្រាមើល **មហាវិលោកនៈ** ៥ នេះ គឺកាល, ទ្វីប, ប្រទេស, ត្រកូល និងកំណត់អាយុព្រះពុទ្ធមាតា, សម្រេចព្រះទ័យហើយ ទើបស្តេចចុតិចាកតុសិតមកចាប់បដិសន្ធិក្នុងសក្យត្រកូល បានការបម្រើដោយសម្បត្តិដ៏ច្រើន ក្នុងសាក្យត្រកូលនោះ ទើបដល់ភាពជាកម្លោះ ស្រស់ល្អស្អាតតាមលំដាប់, ក្នុងរវាងនេះគប្បីជ្រាបសេចក្តីពិស្តារបទនៃព្រះសូត្រទាំងឡាយមានជាអាទិ៍ថា "ម្នាលអានន្ទ ព្រះពោធិសត្វមានសតិ និងសម្បជញ្ញៈ ចុតិចាកទេវតាជាន់តុសិត ហើយយាងចុះកាន់គភ៌ព្រះមាតា" [៦៧] គប្បីជ្រាបដោយអំណាចនៃបទអដ្ឋកថាក្នុងព្រះសូត្រទាំងនោះចុះ ។

ព្រះពោធិសត្វនោះ ទ្រង់សោយសិរីរាជសម្បត្តិដូចនឹងទេវលោកក្នុងប្រា-សាទទាំង ៣ ដ៏សមគួរដល់រដូវទាំង ៣ ក្នុងសម័យដែលទ្រង់យាងទៅប្រពាតក្នុងព្រះឧទ្យានកីឡា ទ្រង់ទតឃើញទេវទូត ៣ គឺមនុស្សចាស់, មនុស្សឈឺ និងមនុស្សស្លាប់ តាមលំដាប់; ទ្រង់ស្លុតព្រះទ័យ ក៏ស្តេចយាងត្រឡប់ពីឧទ្យាន

---

[៦៦] ខុ. ពុទ្ធ. ។

[៦៧] ម. ឧ. ។

ទ្រង់បានឃើញបព្វជិតលើកទី ៤ បានញ៉ាំងការពេញព្រះទ័យក្នុងបព្វជ្ជាឱ្យកើតឡើងថា **"សាធុ បព្វជ្ជា = បួសល្អ"** ទើបស្ដេចទ្រង់យាងទៅកាន់ព្រះឧទ្យានញ៉ាំងពេលវេលា (ថ្ងៃ) ឱ្យកន្លងទៅក្នុងឧទ្យាននោះ ។ ទ្រង់គង់ទៀបឆ្នេរស្រះបោក្ខរណីមង្គល ជាអ្នកដែលវិស្សកម្មទេវបុត្រក្លែងភេទជាជាងកាត់សក់ ប្រដាប់តាក់តែងព្រះអង្គ ទ្រង់ស្ដាប់ឮថា "រាហុលកុមារប្រសូត្រហើយ" ទ្រង់ជ្រាបដល់សេចក្ដីស្រឡាញ់ក្នុងកូន មានសេចក្ដីរំភើបខ្លាំង ទើបទ្រង់ពិចារណាថា "អញនឹងកាត់ចំណងនេះចេញ មុនពេលដែលគ្រឿងចងនេះចម្រើនឡើង" , ទើបយាងទៅកាន់នគរក្នុងវេលាល្ងាច បានស្ដាប់ព្រះគាថាដែលធីតានៃព្រះបិតុច្ឆាព្រះនាមថា កេសាគោតមី ពោលថា ៖-

**"និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា**
**និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតិ។**

បុរសដូចនេះជាបុត្ររបស់មាតាណា, មាតានោះ រលត់ទុក្ខដោយពិត; បុរសដូចនេះ ជាបុត្ររបស់បិតាណា, បិតានោះរលត់ទុក្ខដោយពិត; បុរសដូចនេះ ជាប្ដីរបស់នារីណា, នារីនោះរលត់ទុក្ខដោយពិត"។

ទ្រង់ពិចារណាថា "ព្រះនាងនេះឱ្យយើងបានត្រើយនិព្វុបទ (បទនៃការរលត់)" ទើបដោះខ្សែអលង្ការកែវមុក្តា មានតម្លៃប្រមាណ ១ សែន ពីព្រះសូរង *(ក) បញ្ជូនប្រទានដល់នាង, ហើយស្តេចយាងចូលទៅកាន់ទីប្រថាប់របស់ព្រះអង្គទ្រង់គង់លើព្រះសិរីសយនៈ ទ្រង់ឃើញអាការប្លែករបស់ស្រីរបាំទាំងឡាយ ព្រោះអំណាចនៃការដេកលក់, មានព្រះទ័យនឿយណាយ ដាស់នាយឆន្នឱ្យភ្ញាក់ឡើង ហើយត្រាស់បញ្ជាឱ្យនាំសេះកណ្ឋកៈមក ទ្រង់ឡើងប្រថាប់សេះកណ្ឋកៈ មាននាយឆន្នជាសំឡាញ់ មានពួកទេវតាមួយម៉ឺនលោកធាតុហែហម ហើយយាងចេញកាន់អភិនិស្ក្រមន៍ដ៏ធំ (មហាភិនិស្ក្រមន៍) ក្នុងរាត្រីនោះឯង ។ ទ្រង់យាងឆ្លងមហាអាណាចក្រ ៣ ដែន, ទ្រង់ព្រះផ្នួសជិតឆ្នេរស្ទឹងអនោមា, ហើយយាងទៅតាមលំដាប់ដល់ក្រុងរាជគ្រឹះ ត្រាច់ដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ ទ្រង់គង់ត្រង់ញកភ្នំបណ្ឌវៈ, អ្នកដែលព្រះរាជាដែនមគធៈទូលយាងឱ្យគ្រងរាជសម្បត្តិ ទ្រង់បដិសេធរាជសម្បត្តិនោះ, ទ្រង់ជាអ្នកប្តេជ្ញាដែលព្រះបាទមគធៈនោះជឿហើយ ដើម្បីឱ្យព្រះអង្គត្រាស់ដឹងសព្វញ្ញុតញ្ញាណហើយ យាង

---

* ក្នុងសាស្ត្រាបូរាណ ប្រើជាសុរង្គ (វចនានុក្រមខ្មែរ) ។

មកកាន់ដែនរបស់ព្រះអង្គ, ទ្រង់យាងចូលទៅរកអាឡារតាបស និងឧទកតាបស, នៅមិនទ្រង់ពេញព្រះទ័យដោយគុណវិសេស ដែលបានសម្រេចក្នុងសំណាក់នៃតាបសទាំងនោះ, ទើបទ្រង់តាំង **មហាបធាន** (សេចក្ដីព្យាយាមធំ) ដល់ ៦ វស្សា ។ លុះដល់ថ្ងៃពេញបូរមីខែវិសាខ វេលាព្រឹក ទ្រង់សោយបាយបាយាស ដែលនាង**សុជាតា**អ្នកសេនានិគមថ្វាយ ហើយយាងទៅបណ្ដែតថាសមាសក្នុងស្ទឹង**នេរញ្ជរា** * ។ ក្នុងវេលាថ្ងៃជ្រេ ទ្រង់ទទួលស្មៅមួយកណ្ដាប់ពី**សោត្ថិយព្រាហ្មណ៍** ជាអ្នកមានគុណដែល**កាឡនាគរាជ**សរសើរហើយ, ទ្រង់ឈានឡើងមណ្ឌលនៃដើមពោធិ៍ ទ្រង់លាតស្មៅទាំងឡាយហើយ ទ្រង់ធ្វើប្ដេជ្ញាថា "អញនឹងមិនទម្លាយភ្នែននេះទេ រហូតទាល់តែចិត្តរបស់អញ នឹងរួចផុតចាកអាសវៈទាំងឡាយ ព្រោះការមិនប្រកាន់មាំ" ហើយទ្រង់គង់លើពោធិបល្លង្កមានព្រះភក្ត្រឆ្ពោះទៅទិសបូព៌ កាលព្រះអាទិត្យមិនទាន់អស្ដង្គតនោះឯង ក៏ទ្រង់កម្ចាត់មារ និងសេនារបស់មារ ។ ក្នុងបឋមយាម ទ្រង់សម្រេចបុព្វេនិវាស

---

* ឈ្មោះថា នេរញ្ជរា ព្រោះមិនមានទោសផ្សេងៗ មានចក សារាយ ភក់ និងល្បាប់ជាដើម (អត្ថយោជនា) ។

ញ្ញាណ, ក្នុងមជ្ឈិមយាមទ្រង់សម្រេចចុតូបបាតញ្ញាណ និងក្នុងទីបំផុតនៃបច្ឆិមយាមទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណរបស់ព្រះពុទ្ធទាំងពួងមានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើមនោះឯង ឈ្មោះថា ទ្រង់សម្រេចសមុទ្រ គឺន័យនៃព្រះអភិធម្មនេះ គប្បីជ្រាបអធិគមនិទានរបស់ព្រះអភិធម្មនោះ ដោយអាការដូច្នេះ ៕

**ចប់អធិគមនិទាន**

## សម្តែងអំពីទេសនានិទាន

ព្រះភគវាទ្រង់សម្រេចព្រះអភិធម្មដោយប្រការដូច្នេះហើយ ទ្រង់ប្រថាប់ដោយភ្នែនមួយកន្លងទៅមួយសប្តាហ៍, ទ្រង់សំឡឹងមើលដើមពោធិ៍មិនព្រេចព្រះនេត្រកន្លងទៅ ១ សប្តាហ៍, ទ្រង់ដើរចង្ក្រមកន្លងទៅ ១ សប្តាហ៍, ក្នុងសប្តាហ៍ទី ៤ ទ្រង់ពិចារណាព្រះអភិធម្មដែលទ្រង់សម្រេច ដោយការត្រាស់ដឹងព្រះសយម្ភូញ្ញាណ ហើយទ្រង់ឱ្យសប្តាហ៍ ៣ ដទៃទៀតកន្លងទៅ **ក្រោមដើមអជបាលនិគ្រោធ**, ក្រោមដើម**មុចលិន្ទ** និងក្រោមដើម**រាជាយតនៈ**, ក្នុងសប្តាហ៍ទី ៨ ទ្រង់ត្រឡប់ទៅគង់ក្រោមដើម**អជបាលនិគ្រោធ** ។ ទ្រង់ដល់នូវភាពជាអ្នកខ្វល់

ខ្វាយតិច ព្រោះទ្រង់ពិចារណាដល់ធម៌ជាសភាវៈជ្រាលជ្រៅ កាលទ្រង់សម្តែងធម៌ដែល**សហម្បតីព្រហ្ម** មានមហាព្រហ្មមួយម៉ឺនជាបរិវារមកអារាធនាហើយ ទើបទ្រង់ប្រមើលមើលសត្វលោកដោយ**ពុទ្ធចក្ខុ** ទ្រង់ទទួលការអារាធនារបស់មហាព្រហ្មហើយ ទ្រង់ប្រមើលមើលថា "តថាគតគប្បីសម្តែងធម៌ដល់អ្នកណាមុនហ្ន៎" ។ ទ្រង់ជ្រាបថា "**អាឡារតាបស** និង**ឧទកតាបស** ធ្វើកាលកិរិយាហើយ" ទើបទ្រង់រលឹកដល់បញ្ចវគ្គិយអ្នកមានឧបការច្រើន; ស្តេចក្រោកចាកអាសនៈយាងទៅក្រុងកាសី; ក្នុងចន្លោះផ្លូវ ទ្រង់បានសំណេះសំណាលនឹងឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ក៏ទ្រង់ទៅដល់ទីនៅរបស់បញ្ចវគ្គិយភិក្ខុ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ធ្វើ**បញ្ចវគ្គិយ**ភិក្ខុអ្នកស្រែកហៅព្រះអង្គដោយពាក្យមិនសមគួរឱ្យជឿស្តាប់ ហើយទ្រង់ប្រកាស**ធម្មចក្ក** ប្រោសបញ្ចវគ្គិយភិក្ខុ មាន**អញ្ញាកោណ្ឌញ្ញត្ថេរ**ជាប្រមុខ និងពួកព្រហ្ម ១៨ កោដិ ឱ្យផឹកអមតរស ។ គប្បីជ្រាប**ទេសនានិទាន**រហូតដល់ការប្រកាសធម្មចក្រ ដូចពណ៌នាមកនេះ ។ សេចក្តីសង្ខេបមានត្រឹមប៉ុណ្ណោះ ឈ្មោះថា សេចក្តីពិស្តារ គប្បីជ្រាបដោយអំណាចនៃ**អដ្ឋកថាទាំងឡាយ** និងព្រះសូត្រទាំងឡាយ មាន**អរិយបរិយេសនសូត្រ** និងបព្វជ្ជាសូត្រជាដើម [៦៨] ។ ព្រះអភិធម្មសម្បូណ៌ដោយ**អធិគមនិទាន** និង

[៦៨] ម. មូ. , ខុ. សុ. ។

**ទេសនានិទាន** ដូចពណ៌នាមកដូច្នេះ ៕

## មួយវិញទៀត ព្រះអភិធម្មមាននិទាន ៣

និទានរបស់ព្រះអភិធម្ម មានដទៃទៀត គឺ

**១-ទូរេនិទាន** និទានឆ្ងាយ

**២-អវិទូរេនិទាន** និទានមិនឆ្ងាយ

**៣-សន្តិកេនិទាន** និទានជិត ។

បណ្ដានិទានទាំង ៣ នេះ គប្បីជ្រាប **ទូរេនិទាន** ចាប់ដើមពីបាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាម**ទីបង្ករ**ដរាបដល់**តុសិតបុរី** ។ គប្បីជ្រាប**អវិទូរេនិទាន**ចាប់ដើមពី**តុសិតបុរី**ដរាបដល់**ពោធិមណ្ឌល** ។ ពាក្យថា "សម័យមួយព្រះមានព្រះភាគទ្រង់គង់លើបណ្ឌុកម្ពលសិលាសនៈក្រោមម្លប់ដើម**បារិច្ឆត្តកៈ** ក្នុងពួកទេវតាជាន់តាវត្តិង្សនោះឯង បានត្រាស់ព្រះអភិធម្មដល់ពួកទេវតាជាន់តាវត្តិង្សក្នុងទីនោះ" ឈ្មោះថា **សន្តិកេនិទាន** របស់ព្រះអភិធម្មនោះ ។

**ចប់និទានកថាត្រឹមតែប៉ុណ្ណេះ**

# អដ្ឋកថាមាតិកានុបុព្វបទ

ឥឡូវនេះ ដល់ឱកាសការពោលអភិធម្មកថា តាមដែលខ្ញុំប្ដេជ្ញាយ៉ាងនេះថា ៖-

**“ឥតិ មេ ភាសមានស្ស អភិធម្មកថំ ឥមំ**

**អវិក្ខិត្តា និសាមេថ ទុល្លភា ហិ អយំ កថា ។**

**កាលខ្ញុំពោលអភិធម្មកថានេះហើយ ដោយអាការៈយ៉ាងនេះ សូមសាធុជនទាំងឡាយកុំរាយមាយ ហើយចូរតាំងចិត្តស្ដាប់ ព្រោះកថានេះរកបានដោយលំបាកណាស់” ។**

ក្នុងអភិធម្មកថានោះ បករណ៍ ៧ មាន**ធម្មសង្គណី**ជាដើម ឈ្មោះថាអភិធម្ម; សូម្បីធម្មសង្គណីក៏ចែកជា ៤ កណ្ឌ មាន**ចតុប្បាទកណ្ឌ**ជាដើម; ដល់ចិត្តុប្បាទកណ្ឌនោះ មានមាតិកាជាខាងដើម ហើយមាតិកានោះ ក៏នៅបែងចែកជាពីរ គឺ **តិកមាតិកា** និង**ទុកមាតិកា** ។ ក្នុងមាតិកាទាំង ២ នោះ តិកមាតិកាជាខាងដើម, សូម្បីក្នុងតិកមាតិកា ក៏មានកុសលត្តិកៈជាខាងដើម; ក្នុងកុសលត្តិកៈ ក៏មានបទថា **“កុសលា ធម្មា”** នេះ ជាខាងដើម, ព្រោះហេតុដូច្នោះ៖-

**“ឥតោ បដ្ឋាយ គម្ភីរំ អភិធម្មកថំ ឥមំ**

**ទុច្ចមានំ និសាមេថ ឯកគ្គា សាធុ សាធវោ ។**

តាំងពីនេះទៅ សូមសាធុជនទាំងឡាយមានចិត្តស្ងប់ តាំងចិត្តស្តាប់អភិធម្មកថា ដ៏ជ្រាលជ្រៅនេះ ដែលខ្ញុំពោលឱ្យល្អហើយ” ។

តិកៈដែលមានឈ្មោះព្រោះបទខាងដើមថា **“កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា”** នេះឈ្មោះថា កុសលត្តិកៈសិន ។ តិកៈដែលមានឈ្មោះព្រោះបទទាំងពួងថា **“សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា, អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា”** នេះឈ្មោះថា វេទនាតិកៈ; បណ្ឌិតគប្បីជ្រាបឈ្មោះតិកៈ និងទុកៈ សូម្បីមាតិកាទាំងពួងដោយអំណាចនៃបទខាងដើម ឬបទទាំងអស់ដោយប្រការដូច្នេះ ។

សូម្បីតិកៈ និងទុកៈទាំងឡាយទាំងពួងនោះ លោកញែកទុកទុកៈ ១៥ បរិ-ច្ឆេទ គឺតិកៈមាន ១ បរិច្ឆេទ និងទុកៈមាន ១៤ បរិច្ឆេទ ។ ទុកៈ ៦ មានពាក្យថា **“ហេតូ ធម្មា, ន ហេតូ ធម្មា”** ជាដើមហៅថា ហេតុគោច្ឆកៈ ព្រោះលោកតាំងទុកដូចភួងផ្កាកណិការ ដោយការចងនូវគ្នានឹងគ្នា ទាំងដោយគម្ពីរ (បាលី) ទាំងដោយអដ្ឋកថា ។ បន្ទាប់ពីនោះទៅ ទុកៈ ៧ ទុកៈមានជាអាទិ៍ថា **“សប្បច្ចយា ធម្មា, អប្បច្ចយា ធម្មា”** ជាទុកៈមិនចងនូវគ្នានឹងគ្នា គប្បីជ្រាបថាជា **ចូឡន្តរទុកៈ** ព្រោះទុកៈ លោកជ្រើសរើសទុកៈ ដែលដូចគ្នា

សុទ្ធតាំងទុកតាមលំដាប់នៃគោច្ឆកៈ និងព្រោះជាទុកៈ ដែលតូចជាងក្នុងចន្លោះទុកៈទាំងឡាយដទៃ ។ បន្ទាប់ពីនោះ គប្បីជ្រាបថាជា **អាសវគោច្ឆកៈ** ដោយអំណាចនៃទុកៈ ៦ មានអាសវទុកៈជាដើម, គប្បីជ្រាបថា **សញ្ញោជនគោច្ឆកៈ** ដោយអំណាចនៃទុកៈ ៦ មានសញ្ញោជនទុកៈ ជាដើម; ម្យ៉ាងទៀត គប្បីជ្រាបគន្ថគោច្ឆកៈ, ឱឃគោច្ឆកៈ, យោគគោច្ឆកៈ និងនីវរណគោច្ឆកៈ ដោយអំណាចនៃទុកៈ ៦ មានគន្ថៈ, ឱឃៈ, យោគៈ និងនីវរណទុកៈជាដើម ។ គប្បីជ្រាប **បរាមាសគោច្ឆកៈ** ដោយអំណាចនៃទុកៈ ៥ មានបរាមាសទុកៈជាដើម ។ បន្ទាប់ពីនោះ ទុកៈ ១៤ មានពាក្យថា **“សារម្មណា ធម្មា”** ជាដើម ឈ្មោះថា **មហន្តរទុកៈ** ។ បន្ទាប់អំពីនោះ ទុកៈទាំងឡាយ ៦ មានឧបាទានទុកៈជាដើម ឈ្មោះថា **ឧបាទានគោច្ឆកៈ** ។ បន្ទាប់ពីនោះទុកៈ ៨ មានកិលេសទុកៈជាដើម ឈ្មោះថា **កិលេសគោច្ឆកៈ** ។ បន្ទាប់ពីនោះ ទុកៈ ១៨ មាន **ទស្សនេន បហាតព្វហេតុកា** ជាដើម ឈ្មោះថា **បិដ្ឋិទុកៈ** ព្រោះលោកតាំងទុកក្នុងទីបំផុតនៃព្រះអភិធម្មមាតិកា ។ ចំណែកទុកៈ ៤២ មានពាក្យថា **“វិជ្ជាភាគិនោ ធម្មា, អវិជ្ជាភាគិនោ ធម្មា”** ជាដើមឈ្មោះថា **សុត្តន្តិកទុកៈ**, សូម្បីតិកៈ និងទុកៈទាំងឡាយទាំងអស់នេះ គប្បីជ្រាបថា លោកកំណត់ទុក ១៥ បរិច្ឆេទដូច

ពណ៌នាមកដូច្នេះ ៕

## សម្តែងអំពីសប្បទេស និងនិប្បទេស

ក៏ពួកតិកៈ និងទុកៈនេះ លោកកំណត់ទុកយ៉ាងនេះ ហើយញែកចេញជា ២ កោដ្ឋាសៈ គឺ

**១-សប្បទេស** សម្តែងទុកមិនកំណត់

**២-និប្បទេស** សម្តែងដោយសព្វគ្រប់ ។

ពិតណាស់ បណ្តាចំណែកទាំងពីរនោះ តិកៈ ៩ និងទុកៈ ៧១ ឈ្មោះថា **សប្បទេស** ព្រោះលោកកំណត់ដោយរូបធម៌ និងអរូបធម៌ទុកនៅមិនអស់ ។ តិកៈ ១៣ ដែលសល់ និងទុកៈ ៧១ ឈ្មោះថា **និប្បទេស** ។ បណ្តាធម៌ទាំងពីរនោះ ពួកតិកៈ ៩ នេះ គឺ វេទនាតិកៈ, វិតក្កត្តិកៈ, បីតិត្តិកៈ, ឧប្បន្នត្តិកៈ, អតីតត្តិកៈ និងអារម្មណត្តិកៈ ៤ ឈ្មោះថា **សប្បទេស** ។ ក្នុងទុកៈទាំងឡាយក្នុងទីបំផុតនៃគោច្ឆកៈ ៩ មានហេតុគោច្ឆកៈជាដើម មានឧបាទានគោច្ឆកៈជាទីបំផុត មានគោច្ឆកៈមួយៗ ៣ ទុកៈ, ក្នុងទីបំផុតនៃកិលេសគោច្ឆកៈ មានគោច្ឆកៈមួយៗ ៤ ទុកៈ, មហន្តរទុកៈមួយយ៉ាងៗ ២ គឺ **ចិត្តសម្បយុត្តា ធម្មា, ចិត្តវិប្បយុត្តា ធម្មា, ចិត្តសំសដ្ឋា ធម្មា, ចិត្តវិសំសដ្ឋា ធម្មា** និងក្នុង

សុត្តន្តទុកៈទាំងឡាយវៀរ ៤ ទុកៈទាំងនេះ គឺអធិវចនទុកៈ, និរុត្តិទុកៈ, បញ្ញត្តិទុកៈ និងនាមរូបទុកៈ; ក៏ទុកៈ ៣៨ ដ៏សេសទាំងនេះ ឈ្មោះថា **សប្បទេស**; បណ្ឌិតគប្បីជ្រាបតិកៈ និងទុកៈដែលសល់ តាមដែលពោលហើយទាំងអស់ថាជា **និប្បទេស** ៕

## អធិប្បាយធម៌ជាកុសលត្តិកៈទី ១

ឥឡូវនេះ ជាការពណ៌នាបទតាមលំដាប់បទមាតិកា មានពាក្យថា “**កុសលា ធម្មា**” ជាដើមនេះ ។ **កុសលសព្ទ** ប្រើក្នុងអត្ថថា ការមិនមានរោគ, ការមិនមានទោស, ការឆ្លាត និងមានសុខជាវិបាក ។ ពិតណាស់ កុសលសព្ទនេះប្រើក្នុងអត្ថថា **ការមិនមានរោគ** ដូចក្នុងប្រយោគមានជាដើមថា “**កច្ចិ នុ ភោតោ កុសលំ, កច្ចិ ភោតោ អនាមយំ** = ការមិនមានរោគ មានដល់អ្នកដ៏ចម្រើនខ្លះឬ ?; ការមិនឈឺមានដល់អ្នកដ៏ចម្រើនខ្លះឬ [៦៩] ?”; ប្រើក្នុងអត្ថថា **ការមិនមានទោស** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**កតមោ បន ភន្តេ កាយសមាចារោ កុសលោ? យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ ...** = បពិត្រព្រះអង្គដ៏ចម្រើន ចុះកាយសមាចារជា

[៦៩] ខុ. ជា. ។

កុសលតើដូចម្ដេច ? បពិត្រមហារាជ កាយសមាចារ ដែលមិនមានទោស [៧០]; លោកដ៏ចម្រើន នៅមានខមួយទៀត ដែលជាធមិដ៏ប្រសើរលើស គឺព្រះមានព្រះភាគទ្រង់សម្ដែងធមិ ដូចក្នុងធមិទាំងឡាយដែលមិនមានទោស" [៧១] ។ ក្នុងអត្ថថា ការឆ្លាត ក្នុងប្រយោគជាដើមថា **"កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ, កុសលានច្ចគីតស្ស, សុសិក្ខិត្តា ចតុរិត្ថិយោ** = លោកជាអ្នកឆ្លាតក្នុងគ្រឿងប្រកបរបស់រថ, ស្ត្រីទាំង ៤ នាក់ សិក្សាល្អហើយ ជាអ្នកឆ្លាតក្នុងការរាំច្រៀង" [៧២] ។ ក្នុងអត្ថថា **សុខវិបាក** ដូចក្នុងប្រយោគមានជាអាទិ៍ថា **"កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ កុសលស្ស កម្មស្ស កតត្តា** = ម្នាលភិក្ខុទាំងឡាយ ព្រោះសមាទានធមិទាំងឡាយដែលជាសុខវិបាក និងពាក្យថា ព្រោះធ្វើកម្មដែលជាសុខវិបាក" [៧៣] ។ ក្នុងទីនេះ **កុសលសព្ទ** គួរប្រើ

---

[៧០] ទី.ម. ។

[៧១] ទី. ម. ។

[៧២] ខុ. ជា. (មូគបក្ខជាតក) ។

[៧៣] អភិ. ។

ក្នុងអត្ថថា គ្មានរោគខ្លះ, គ្មានទោសខ្លះ និងមានសុខវិបាកខ្លះ។

**ក៏ធម្មសព្ទនេះ** ប្រើក្នុងអត្ថថា **បរិយត្តិ, ហេតុ, គុណ** និងនិស្សត្ត-និជ្ជីវៈជាដើម ។ ពិតណាស់ **ធម្មសព្ទនេះ** ប្រើក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ** = កុលបុត្ររៀនបរិយត្តិ គឺ សុត្តៈ គេយ្យៈ” [៧៤] ។ ប្រើក្នុងអត្ថថា **ហេតុ** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ហេតុម្ហិ ញាណំ ធម្មប្បដិសម្ភិទា** = ញាណក្នុងហេតុ ឈ្មោះថាធម្មប្បដិសម្ភិទា” [៧៥] ; ប្រើក្នុងអត្ថថា **គុណ** ដូចក្នុងប្រយោគមានជាអាទិ៍ថា ៖-

**“ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ**
**អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។**

**ធម៌** និងអធម៌ទាំងពីរ មានវិបាកមិនស្មើគ្នាទេ, អធម៌នាំសត្វទៅកាន់នរក, ធម៌ញុំាងសត្វឱ្យដល់សុគតិ” [៧៦] ។

---

[៧៤] អំ. ចតុក្ក. ។

[៧៥] ខុ. ថេរ. ។

[៧៦] អភិ. ។

ក្នុងអត្ថថា **និស្សត្តនិជ្ជីវធម៌** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ, ធម្មេសុ ធម្មានុបស្សី វិហរតិ** = ក៏សម័យនោះឯង និស្សត្តនិជ្ជីវធម៌ទាំងឡាយ រមែងមាន [៧៧], និងពាក្យថា ភិក្ខុពិចារណាឃើញនិស្សត្តនិជ្ជីវធម៌ ក្នុងនិស្សត្តនិជ្ជីវធម៌ទាំងឡាយជាប្រក្រតី” [៧៨] ។ សូម្បីក្នុងទីនោះ **ធម្មសព្ទ** គួរប្រើក្នុងអត្ថថា និស្សត្ត និជ្ជីវៈប៉ុណ្ណោះ ៕

## វិគ្រោះសព្ទថា កុសល និងធម៌

គប្បីជ្រាបន័យរបស់ពាក្យកុសលជាដើម ក្នុងទីនេះ ៖-

សភាវៈដែលឈ្មោះថា **កុសល** ព្រោះអត្ថថា ញុំាំងបាបធម៌ដែលបណ្ឌិតខ្ពើមឱ្យកក្រើក, ឱ្យឃ្លាតទៅ, ឱ្យញាប់ញ័រ គឺឱ្យវិនាស ។ **ម្យ៉ាងទៀត** សភាវធម៌ណា ត្រូវពន្ធ័ដោយអាការដែលបណ្ឌិតខ្ពើម សភាវធម៌នោះ ឈ្មោះថា **កុសៈ**, ធម៌ឈ្មោះថា **កុសល** ព្រោះអត្ថថា ដកចោលចេញ គឺកាត់កុសៈ ពោលគឺអកុសលទាំងនោះ ។ **ម្យ៉ាងទៀត** ញាណឈ្មោះថា **កុសៈ** ព្រោះអត្ថថា ធ្វើ

[៧៧] អភិ. ។

[៧៨] ទី. ម. ។

អកុសលដែលបណ្ឌិតខ្ពើមឱ្យធូរ, ឱ្យស្រាល និងឱ្យអស់ ។ **ម្យ៉ាងទៀត** ឈ្មោះថា **កុសល** គឺញាណឈ្មោះកុសះនោះ គប្បីកាត់ គឺគប្បីកាន់យក ពោលគឺគប្បីប្រព្រឹត្តទូទៅដោយកុសលញ្ញាណនោះ ។ ម្យ៉ាងទៀត ឈ្មោះថា **កុសល** ព្រោះអត្ថថា ធម៌ទាំងនេះ កាត់ចំណែកសង្កិលេសដែលជាចំណែកទាំងពីរ គឺដែលកើតឡើងហើយ និងនៅមិនទាន់កើត, ដូចស្បូវភ្លាំងកាត់ចំណែកនៃដៃ (មុតដៃ) ដែលក្រសោបស្មៅទាំងពីរ; ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់ គឺទម្លាយអកុសលដូចស្បូវភ្លាំងដូច្នោះ ។

ចំណែកសភាវៈដែលឈ្មោះថា **ធម៌** ព្រោះអត្ថថា ទ្រទ្រង់នូវសភាវៈរបស់ខ្លួន។ **ម្យ៉ាងទៀត** ឈ្មោះថាធម៌ ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយទ្រទ្រង់ទុក ឬថា ទ្រទ្រង់ទុកតាមសភាវធម៌ ឈ្មោះថា **អកុសល** ព្រោះអត្ថថា **មិនមែនកុសល**។ អធិប្បាយថា ធម៌ដែលជាបដិបក្សចំពោះកុសល ដូចអមិត្រ ជាបដិបក្សចំពោះមិត្រ; អលោភៈជាដើម ជាបដិបក្សចំពោះលោភៈជាដើម ។ ធម៌ដែលឈ្មោះថា **អព្យាកតៈ** ព្រោះអត្ថថា មិនធ្វើឱ្យជាក់ច្បាស់, អធិប្បាយថា លោកមិនពោលទុកដោយសេចក្ដីជាកុសល និងអកុសល ។ បណ្ដាធម៌ទាំងបីនោះ កុសលមានការគ្មានទោស និងមានវិបាកជាសុខជាលក្ខណៈ, អកុសលមានទោស និងមានទុក្ខជាវិបាកជាលក្ខណៈ, អព្យាកតៈមានអវិបាកជាលក្ខណៈ ។

**សួរថា** : បទទាំងពីរនេះ គឺ កុសលា ឬថា **ធម្មា** មានអត្ថដូចគ្នា ឬផ្សេងគ្នា?

**ឆ្លើយថា** : ក្នុងខនេះដូចម្តេចទៅ បើសភាវៈទាំងពីរនេះ មានអត្ថដូចគ្នា, ពាក្យថា **"កុសលា ធម្មា"** នេះ ក៏ដូចនឹងពោលថា **"កុសល កុសល"** បើពោលថាមានអត្ថផ្សេងគ្នា ក៏ប្រាកដថា **តិកៈ និងទុកៈ ជាឆក្កៈ** និងចតុក្កៈ និងបទទាំងឡាយមិនទាក់ទងគ្នាទេ; ដូចគេពោលថា **"កុសល រូប** មនុស្ស មានភ្នែក" កាលបទទាំងឡាយមិនក្រឡេកមើល (មិនទាក់ទង) សេចក្តីដល់គ្នានឹងគ្នាដោយអំណាចនៃអត្ថ, ការទាក់ទងគ្នាអ្វីៗ ក៏មិនមាន; ក្នុងពាក្យថា **"កុសលា ធម្មា"** ជាដើមនេះ ក៏ដូចគ្នា, គឺបទទាំងឡាយមិនសម្ពន្ធគ្នា (មិនជាប់ទាក់ទងគ្នា) ក្នុងបទខាងដើម និងខាងចុង ឈ្មោះថា មិនមានប្រយោជន៍។ តទៅក៏នឹងទាស់នឹងពាក្យដែលសួរថា **"កតមេ ធម្មា កុសលា"**, ព្រោះថាធមិទាំងឡាយមិនមែនកុសល, កាលបើដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា **"កតមេ ធម្មា កុសលា"** ។ **ន័យម្យ៉ាងទៀត** បើបទទាំងនេះមានអត្ថដូចគ្នា, សូម្បីធមិទាំង ៣ មានកុសលជាដើម ក៏ប្រាកដដូចគ្នា; ពិតណាស់ធមិទាំងបីមានបទនៃកុសលជាដើម ប្រាកដដូចគ្នាដោយសេចក្តីជាធមិ ។ ព្រោះហេតុដូច្នោះ សូម្បីកុសលជាដើម ដែលមានសេចក្តីសម្គាល់មិនផ្សេងគ្នា ដោយ

អត្ថ និងធម៌ទាំង ៣ យ៉ាង ក៏ប្រាកដដូចគ្នាថា “គឺពាក្យណាជាកុសល ពាក្យនោះជាអកុសល, ជាអព្យាកតៈ” ; ប្រសិនបើថា មិនព្រមទទួលយកធម៌ ៣ យ៉ាងដូចគ្នាទេ, ក៏នឹងត្រូវពោលថា “ធម៌ដែលមានសព្ទថា កុសលនៅខាងមុខ ក៏ម្យ៉ាង, ធម៌ដែលមានសព្ទថា អកុសលនៅខាងមុខក៏ម្យ៉ាង, ធម៌ដែលមានអព្យាកតៈនៅខាងមុខក៏ម្យ៉ាង” , កាលបើដូច្នេះ ភាវៈក្តី អភាវៈដទៃក្រៅអំពីភាវៈក្តី ក៏ឈ្មោះថា **ធម៌**, ព្រោះហេតុដូច្នោះ ធម៌ដែលមានអកុសលសព្ទនៅខាងមុខ ក៏ទៅអំពីធម៌ដែលមានកុសលសព្ទនៅខាងមុខ, ដែលជាភាវៈ ក៏គប្បីជាអភាវៈ; សូម្បីធម៌មានអព្យាកតៈនៅខាងមុខ សូម្បីធម៌មានកុសលសព្ទនៅខាងមុខទៀត ក៏ជាអភាវៈដូចគ្នា; សូម្បីកុសលទាំងឡាយដទៃក្រៅអំពីធម៌ដែលដល់សេចក្តីជាអភាវៈជាដើមយ៉ាងនេះ ក៏គប្បីជាអភាវៈ, ពាក្យទាំងអស់នោះ មិនមែនហេតុសំខាន់ទេ ។

**សួរថា** : ព្រោះហេតុអ្វី?

**ឆ្លើយថា** : ព្រោះពាក្យទាំងអស់នោះ សម្រេចដោយវោហារដែលដឹងគ្នា ។

ពិតណាស់ វោហារដែលគេដឹងគ្នា រាប់រងគ្នា ក្នុងអត្ថទាំងឡាយដោយប្រការណា ៗ, ក៏សម្រេចដោយប្រការនោះ ៗ ឯង; ក៏ការពោលដល់ធម៌ដែលមានកុសលជាបទមុខ និងការពោលដល់កុសលសព្ទដែលមានធម៌ជាបទក្រោយ

ក្នុងពាក្យជាដើមថា **“កុសលា ធម្មា”** បណ្ឌិតទាំងឡាយ មិនព្រមទទួល ព្រោះមិនមានន័យសេចក្តីផ្សេងគ្នានឹងរបស់ខ្លួន ដូចពាក្យដែលមិនរាប់រងសព្ទទាំងនេះថា **“កុសលា កុសលា”** , និងមិនទទួលរងថា មានអត្ថដែលផ្លុះដល់គ្នានឹងគ្នា ដូចសព្ទថា **“កុសលារូបំ ចក្ខុមា** = កុសលរូប អ្នកមានភ្នែក” ។

**ចំណែកកុសលសព្ទ** ក្នុងពាក្យថា **កុសលា ធម្មា** នេះ បណ្ឌិតរាប់រងហើយ ដោយផ្លុះដល់អត្ថ គឺការគ្មានទោស និងមានសុខជាវិបាក អកុសលសព្ទ បណ្ឌិតរាប់រងហើយ ដោយការផ្លុះដល់អត្ថថាជាទោស និងមានទុក្ខជាវិបាក ។ អព្យាកតសព្ទ បណ្ឌិតរាប់រងហើយដោយការផ្លុះដល់អត្ថថា មិនមានវិបាក ។

**ធម្ម**សព្ទ បណ្ឌិតរាប់រងដោយការផ្លុះដល់អត្ថថា ទ្រទ្រង់ទុកនូវភាវៈរបស់ខ្លួនជាដើម ។ ធម្មសព្ទនោះ កាលលោកពោលទុកក្នុងចន្លោះនៃសព្ទទាំងនោះសព្ទណាមួយ ក៏សម្តែងដល់សេចក្តីស្មើគ្នារបស់អត្ថនៃខ្លួន ។ ពិតណាស់ សព្ទទាំងអស់នេះ ឈ្មោះថា **ធម្មៈ** ព្រោះមានការទ្រទ្រង់ទុកនូវភាវៈរបស់ខ្លួនជាដើម ជាលក្ខណៈ និងសូម្បីកុសលសព្ទជាដើម ដែលលោកពោលទុកហើយខាងមុខ ធម្មសព្ទ ក៏រមែងផ្លុះដល់សេចក្តីប្លែកគ្នានៃអត្ថរបស់ធម្មសព្ទនោះៗ របស់ខ្លួន ។

ពិតណាស់ ធម៌ជាកុសលក៏មាន, ជាអកុសលក៏មាន, ជាអព្យាកតៈក៏មាន; សព្ទទាំងអស់នេះ កាលបើពោលញែកគ្នា បណ្ឌិតទាំងឡាយក្នុងលោក ក៏ធានា

ត្រឹមតែឆ្លុះបំភ្លឺន័យសេចក្តីរបស់ខ្លួនៗ; កាលបើពោលរួមគ្នា ដោយធម្មសព្ទ បណ្ឌិតទាំងឡាយក្នុងលោក ក៏ព្រមទទួលសេចក្តីដែលស្មើគ្នានឹងរបស់ខ្លួន និងសេចក្តីដែលផ្សេងគ្នា; ព្រោះហេតុដូច្នោះ ពាក្យណាដែលលោកកំណត់ដល់សេចក្តីដែលដូចគ្នា និងផ្សេងគ្នាក្នុងពាក្យថា **“កុសលា ធម្មា”** នេះ នឹងធ្វើឱ្យជាខដែលគួរតិះដៀល, ពាក្យទាំងអស់នោះ ទើបមិនមែនជាហេតុសំខាន់ ដោយប្រការដូច្នេះ ។ ការពណ៌នាតាមបទកុសលត្តិកៈត្រឹមប៉ុណ្ណោះសិន ។ សូម្បីតិកៈ និងទុកៈដែលសេសសល់ ក៏គប្បីជ្រាបដោយន័យនេះឯង ៕

## សំដែងអំពីសុខវេទនាតិកៈទី ២

តពីនេះទៅ ខ្ញុំនឹងពោលដល់ខត្រឹមតែផ្សេងគ្នាប៉ុណ្ណោះ ។ ខាងដើមនេះ **សុខ**សព្ទ ក្នុងពាក្យថា **សុខវេទនា** ជាដើម លោកប្រើក្នុងន័យច្រើនយ៉ាង មានពាក្យថា **សុខវេទនា, សុខមូល, សុខារម្មណ៍, សុខហេតុ, សុខបច្ចយដ្ឋាន, អព្យាបជ្ឈ** និង**និព្វាន**ជាដើម ។

ពិតណាស់ **សុខ**សព្ទនេះ ដែលប្រើក្នុងអត្ថថា **សុខវេទនា** ដូចក្នុងប្រយោគជាដើមថា **“សុខស្ស ច បហានា** = ព្រោះលះបង់សុខវេទនា បាន

[៧៩] ” ; ប្រើក្នុងអត្ថថា **សុខមូល** ដូចក្នុងប្រយោគជាដើមថា “**សុខោ ពុទ្ធានំ ឧប្បាទោ សុខា វិរាគតា លោកេ** = កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយជាមូលនៃសេចក្តីសុខ [៨០], ការប្រាសចាកតម្រេកជាមូលនៃសេចក្តីសុខក្នុងលោក [៨១] ” ; ប្រើក្នុងអត្ថថា **សុខារម្មណ៍** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**យស្មា ច ខោ មហាលិ រូបំ សុខំ សុខានុបតិតំ សុខាវក្កន្តំ** = ម្នាលមហាលិ ក៏ព្រោះដែលរូបមានអារម្មណ៍ជាសុខ មានសុខតាមស្នង ឈាន (តាមជាប់) ចុះកាន់សេចក្តីសុខ” [៨២] ; ប្រើក្នុងអត្ថថា **សុខហេតុ** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានិ** = ម្នាលភិក្ខុទាំងឡាយពាក្យថា បុណ្យទាំងឡាយនោះ ជាឈ្មោះ (ហេតុ) នៃសេចក្តីសុខ” [៨៣] ។ ប្រើក្នុងអត្ថថា **សុខបច្ចយដ្ឋាន** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**យាវញ្ចិទំ**

---

[៧៩] ម. មូ, អភិ. ។

[៨០] ខុ. ធ. ។

[៨១] វិនយ, ខុ. ឧ. ។

[៨២] សំ. ខ. ។

[៨៣] អំ. សត្តក. ។

**ភិក្ខវេ សុករំ អក្ខានេន បាបុណិតុំ យាវ សុខា សគ្គា ន តេ សុខំ បជានន្តិ យេ ន បស្សន្តិ នន្ទនំ** = ម្នាលភិក្ខុទាំងឡាយ ការដល់ឋានដែលជាបច្ច័យនៃសេចក្តីសុខ ដោយការប្រាប់នេះ មិនមែនធ្វើបានដោយងាយទេ [៨៤] និងពាក្យថា ទេវតាទាំងឡាយណាមិនឃើញនន្ទវ័ន... ទេវតា ទាំងឡាយនោះរមែងមិនដឹងនូវឋានដែលជាបច្ច័យនៃសេចក្តីសុខ” [៨៥]; ប្រើក្នុងអត្ថថា **អព្យាបជ្ឈៈ** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**ទិដ្ឋធម្មសុខវិហារា ឯតេ ធម្មា** = ធមិទាំងឡាយនេះ ជាគ្រឿងនៅមិនបៀតបៀនក្នុងបច្ចុប្បន្ន” [៨៦]; ប្រើក្នុងពាក្យថា **និព្វាន** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**និព្វានំ បរមំ សុខំ** = ព្រះនិព្វានជាសេចក្តីសុខយ៉ាងក្រៃលែង” [៨៧]; តែក្នុងទីនេះ **សុខ**សព្ទនេះ ប្រើក្នុងសុខវេទនាប៉ុណ្ណោះ ។ **វេទនា**សព្ទ ប្រើក្នុងអត្ថថា សោយអារម្មណ៍ប៉ុណ្ណោះ

---

[៨៤] ម. ឧ. ។

[៨៥] សំ. ស. ។

[៨៦] ម. មូ. ។

[៨៧] ខុ. ធ. ។

ដូចក្នុងប្រយោគមានជាអាទិ៍ថា "**វិទិតា មេ វេទនា ឧប្បជ្ជន្តិ** = វេទនារបស់តថាគត កំពុងប្រាកដកើតឡើង"[៨៨] ដូច្នេះរមែងសមគួរ ៕

## សម្តែងអំពីទុក្ខវេទនា

ទុក្ខសព្ទ លោកប្រើក្នុងអត្ថច្រើនយ៉ាង មានពាក្យថា **ទុក្ខវេទនា, ទុក្ខវត្ថុ, ទុក្ខារម្មណា, ទុក្ខបច្ច័យ** និង**ទុក្ខបច្ចយដ្ឋាន**ជាដើម ។

ពិតណាស់ **ទុក្ខសព្ទ**ប្រើក្នុងអត្ថថា ទុក្ខវេទនា ដូចក្នុងប្រយោគមានជាអាទិ៍ថា "**ទុក្ខស្ស ច បហានា** = ព្រោះលះសេចក្តីទុក្ខវេទនាបាន" ; ប្រើក្នុងអត្ថថា **ទុក្ខវត្ថុ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "**ជាតិបិ ទុក្ខា** = សូម្បីការកើត ក៏ជាទីតាំងនៃទុក្ខ"[៨៩] ; ប្រើក្នុងអត្ថថា **ទុក្ខារម្មណ៍** ដូចក្នុងប្រយោគមានជាអាទិ៍ថា "**យស្មា ច ខោ មហាលិ រូបំ ទុក្ខំ ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ** = ម្នាលមហាលិ ក៏ព្រោះហេតុរូបមានអារម្មណ៍ជាទុក្ខ ត្រូវទុក្ខជាប់តាមឈានចុះកាន់សេចក្តីទុក្ខ" ; ប្រើក្នុងអត្ថថា **ទុក្ខបច្ច័យ** ដូចក្នុងប្រយោគមានជា

---

[៨៨] ម. ឧ. ។

[៨៩] ទី. ម. ។

អាទីថា **“ទុក្ខោ បាបស្ស ឧច្ចយោ** = ការសន្សំបាប ជាបច្ច័យនៃទុក្ខ” [៩០]; ប្រើក្នុងអត្ថថា **ទុក្ខបច្ចយដ្ឋាន** ដូចក្នុងប្រយោគមានអាទីថា **“យាវញ្ចិទំ ភិក្ខវេ ន សុករំ អក្ខាតេន បាបុណិតុំ យាវ ទុក្ខា និរយា** = ម្នាលភិក្ខុទាំងឡាយ ការដល់ឋានជាបច្ច័យនៃទុក្ខ ដរាបដល់នរកដោយការប្រាប់នេះ ធ្វើមិនបានងាយ” [៩១]; តែក្នុងទីនេះ **ទុក្ខសព្ទ**នេះ គប្បីជ្រាបថា ជាទុក្ខវេទនាប៉ុណ្ណោះ ៕

## សម្តែងអំពីសេចក្តីសម្គាល់នៃសព្ទ

ក៏គប្បីជ្រាបវចនត្ថៈ (សេចក្តីនៃពាក្យ) ក្នុងទីនេះ ៖-

ឈ្មោះថា **សុខ** ព្រោះញ៉ាំងអ្នកសោយឱ្យសប្បាយ ។

ឈ្មោះថា **ទុក្ខ** ព្រោះអត់ទ្រាំបានដោយលំបាក ។

ឈ្មោះថា **អទុក្ខមសុខ** ព្រោះអត្ថថា មិនមែនទុក្ខ និងមិនមែនសុខ ។

---

[៩០] ខុ. ធ. ។

[៩១] ម. ឧ. ។

៥អក្សរ លោកពោលទុកដោយអំណាចនៃការតបទ ។ សូម្បីធម៌មានសុខជាដើមទាំងអស់ឈ្មោះថា **វេទនា** ព្រោះអត្ថថា ដឹង គឺសោយរសរបស់អារម្មណ៍ ។ បណ្ដាវេទនាទាំងនោះ សុខវេទនាមានការសោយអារម្មណ៍ ដែលគួរប្រាថ្នាជាលក្ខណៈ, ទុក្ខវេទនាមានការសោយអារម្មណ៍ ដែលមិនគួរប្រាថ្នាជាលក្ខណៈ, អទុក្ខមសុខវេទនា មានការសោយអារម្មណ៍ខុសប្លែកពីវេទនាទាំងពីរ ៕

## សំម្ដែងអំពីសម្បយុត្ត

ក៏សម្បយុត្តសព្ទ ក្នុងបទនៃវេទនា ៣ នេះ គប្បីជ្រាបដូច្នេះ ៖-

ឈ្មោះថា **សម្បយុត្ត** ព្រោះអត្ថថា ប្រកបដោយការធ្វើផ្សេងៗ ដោយល្អ ។ សួរថាៈ ការធ្វើផ្សេងៗ តើដូចម្ដេច ?, ឆ្លើយថាៈ ការធ្វើទាំងឡាយមានការកើតឡើងព្រមគ្នាជាដើម ។ សួរថាៈ ធម៌ទាំងឡាយខ្លះ សម្បយុត្តដោយធម៌ទាំងឡាយខ្លះមិនមានឬ? ឆ្លើយថាៈ មែន (មិនមាន) [៩២] ព្រោះបដិសេធបញ្ហានេះ ដោយប្រការដូច្នេះ ទើបខ្ញុំពោលអត្ថនៃសម្បយោគ ដោយអំណាចនៃធម៌ទាំងឡាយ មានការកើតឡើងព្រមគ្នាជាដើមយ៉ាងនេះថា “ធម៌ទាំងឡាយខ្លះសហគតៈកើតព្រមគ្នា, លាយចូលគ្នា; កើតព្រមគ្នា, រលត់ព្រមគ្នា, មានវត្ថុ

---

[៩២] អភិ. ។

ដូចគ្នា, មានអារម្មណ៍ដូចគ្នា, ដោយធម៌ទាំងឡាយពួកខ្លះមានហើយ មិនមែនឬ?” ; ព្រោះហេតុដូច្នោះ ធម៌ ឈ្មោះថា **សម្បយុត្ត** ព្រោះអត្ថថា ប្រកបហើយដោយការធ្វើដោយប្រពៃ គឺមានការកើតព្រមគ្នាជាដើមនេះ ៕

## សម្ដែងអំពីវិបាកត្តិកៈទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃវិបាកតទៅ ៖-

ឈ្មោះថា **វិបាក** ព្រោះអត្ថថា ជាផលរបស់កុសល និងអកុសលកម្មទាំងឡាយ ដែលពិសេសជាងគ្នានឹងគ្នា, ពាក្យថា **វិបាក** នេះជាឈ្មោះរបស់អរូបធម៌ទាំងឡាយ ដែលដល់ភាពជាវិបាក ។ បទថា **វិបាកធម្មធម្មា** បានដល់ ធម៌ទាំងឡាយរបស់វិបាកធម៌ទាំងឡាយ, គឺធម៌ទាំងឡាយដែលញ៉ាំងវិបាកឱ្យកើតឡើង, ដូចសត្វទាំងឡាយ មានការកើត និងការចាស់ជាសភាវៈ មានប្រក្រតីធ្លាក់ចុះកាន់ការកើត និងការចាស់ លោកហៅថា “មានការកើតជាធម្មតា, មានការចាស់ជាធម្មតា” ; អធិប្បាយថា ធម៌ទាំងឡាយមានវិបាកជាសភាវៈ មានវិបាកធ្លាក់ចុះជាប្រក្រតី ព្រោះការដែលធម៌ទាំងឡាយនេះ ញ៉ាំងវិបាកឱ្យកើតឡើងដោយប្រការដូច្នេះ ។ បទទី ៣ លោកពោលទុកដោយការបដិសេធសភាវៈទាំងពីរ ៕

## សម្តែងអំពីឧបាទិន្នត្តិកៈទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃឧបាទិន្នុបាទានិយធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **ឧបាទិន្នៈ** ព្រោះកម្មប្រកបដោយតណ្ហាជាដើម ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍ ប្រកាន់យកហើយ គឺកាន់យកដោយសេចក្តីជាផល, ក៏ឈ្មោះថា **ឧបាទានិយៈ** ព្រោះជាប្រយោជន៍ដល់ឧបាទានទាំងឡាយ ដោយចូលដល់សេចក្តីជាអារម្មណ៍ ហើយសម្ពន្ធនឹងឧបាទាន ។ ពាក្យថា **ឧបាទានិយៈ** នេះជាឈ្មោះរបស់ធម៌ដែលជាអារម្មណប្បច្ច័យរបស់ឧបាទាន ។ ឈ្មោះថា **ឧបាទិន្នុបាទានិយៈ** ព្រោះអត្ថថា ជាឧបាទិន្នៈផង និងជាឧបាទានិយៈផង ។ ពាក្យថា **ឧបាទិន្នុបាទានិយៈ** នេះជាឈ្មោះរបស់រូបធម៌ និងអរូបធម៌ទាំងឡាយដែលកើតឡើងដោយកម្មដែលមានអាសវៈ ។ ក្នុង ២ បទ ដែលនៅសល់ គប្បីជ្រាបដោយសេចក្តីដែលជាប្រយោជន៍ដល់ការបដិសេធដោយន័យនេះចុះ ៕

## សម្តែងអំពីសង្កិលិដ្ឋត្តិកៈទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃសង្កិលិដ្ឋសង្កិលេសិកធម៌ តទៅ ៖-

ធម៌ដែលឈ្មោះថា **សង្កិលេស** ព្រោះអត្ថថា ញ៉ាំងសត្វឱ្យសៅហ្មង ។

អធិប្បាយថា រមែងបៀតបៀន គឺឱ្យសត្វក្តៅក្រហាយ ។ ដែលឈ្មោះថា **សង្កិលិដ្ឋៈ** ព្រោះប្រកបព្រមហើយដោយកិលេស ។ ឈ្មោះថា **សង្កិលេសិកៈ** ព្រោះអត្ថថា រមែងគួរដល់សង្កិលេស ដោយធ្វើខ្លួនឱ្យជាអារម្មណ៍ហើយ ទើបប្រព្រឹត្តទៅ ឬថា ចូលទៅប្រកបក្នុងកិលេស ដោយការមិនឈានកន្លងភាព ជាអារម្មណ៍របស់សង្កិលេសនោះ ។ ពាក្យថា **សង្កិលេសិក** នេះជាឈ្មោះរបស់ធម៌ទាំងឡាយដែលជាអារម្មណប្បច្ច័យរបស់សង្កិលេស ។ ឈ្មោះថា **សង្កិលិដ្ឋសង្កិលេសិក** ព្រោះអត្ថថា ធម៌ទាំងនោះជាសង្កិលិដ្ឋផង និងជាសង្កិលេសិកផង ។ ២ បទដែលសល់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងតិកៈខាងដើមនោះឯង ៕

## សំម្តែងអំពីវិតក្កតិកៈទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃវិតក្កៈតទៅ ៖-

ធម៌ដែលឈ្មោះថា **សវិតក្កៈ** ព្រោះប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ គឺប្រព្រឹត្តទៅហើយដោយអំណាចនៃសម្បយោគ ។ ធម៌ដែលឈ្មោះថា **សវិចារ** ព្រោះប្រព្រឹត្តទៅជាមួយនឹងវិចារ ។ ធម៌ដែលឈ្មោះថា **សវិតក្កសវិចារ** ព្រោះធម៌ទាំងឡាយនោះមានសវិតក្កៈ និងសវិចារ ។ ធម៌ដែលវៀរចាកវិតក្កៈ និងវិចារ

ទាំងពីរ ឈ្មោះថា **អវិតក្កាវិចារ** ។ ធម៌ដែលឈ្មោះថា **វិចារមត្ត** (ត្រឹមតែវិចារ) ព្រោះអត្ថថា បណ្ដាវិតក្កៈ និងវិចារ ធម៌មានត្រឹមតែវិចារប៉ុណ្ណោះ ជាប្រមាណ, អធិប្បាយថា ធម៌នោះក្រៅអំពីវិចារហើយ រមែងមិនសម្បយោគ (ប្រកបព្រម) នឹងវិតក្កៈ ។ ធម៌ទាំងនោះ មិនមានវិតក្កៈ មានត្រឹមតែវិចារប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អវិតក្កាអវិចារមត្តា** ៕

## សម្ដែងអំពីបីតិត្តិកៈទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃបីតិធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **បីតិសហគតៈ** ព្រោះអត្ថថា ដល់ភាវៈសម្បយោគមានការកើតព្រមគ្នាជាដើមរួមនឹងបីតិ, អធិប្បាយថា សម្បយុត្តដោយបីតិ ។ សូម្បីក្នុង ២ បទដែលសល់ ក៏ន័យនេះដែរ ។ ក៏អទុក្ខមសុខវេទនា លោកពោលក្នុងបទទី ៣ នេះថា **ឧបេក្ខា** ព្រោះថា ឧបេក្ខានោះ ចូលទៅសំឡឹងមើលនូវការប្រព្រឹត្តទៅនៃអាការរបស់សុខ និងទុក្ខ គឺមិនឱ្យប្រព្រឹត្តទៅតាមអាការនៃសុខនិងទុក្ខនោះ ទើបឈ្មោះថា **ឧបេក្ខា** ព្រោះការតាំងនៅដោយអាការនៃភាពជាកណ្ដាល ។ ព្រោះហេតុនោះ ទើបលោកពោលតិកៈនេះ ព្រោះកាន់យក ២ បទចាកវេទនាតិកៈនោះឯង ហើយសម្ដែងសុខដែលគ្មានបីតិ ឱ្យប្លែកពីសុខដែល

មានបីតិ ៕

## សម្តែងអំពីទស្សនត្តិកៈទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃទស្សនធមិតទៅ ៖-

បទថា **“ទស្សនេន”** បានដល់ សោតាបត្តិមគ្គ, ពិតណាស់ សោតាបត្តិ-មគ្គនោះ ព្រះមានព្រះភាគត្រាស់ថា **“ទស្សនៈ”** ព្រោះឃើញព្រះនិព្វានលើកដំបូង; ចំណែកគោត្រភូញាណ ឃើញព្រះនិព្វានមុនជាង ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា គោត្រភូញាណនោះ តាំងនៅក្នុងឋាននៃអាវជ្ជនៈរបស់មគ្គ; ដូចយ៉ាងថា បុរសមកកាន់សំណាក់ព្រះរាជាដោយករណីយ៍ណាមួយ សូម្បីឃើញព្រះរាជាទ្រង់ប្រថាប់លើ-កដំរី កំពុងស្តេចយាងទៅតាមថ្នល់អំពីចម្ងាយ ត្រូវគេសួរថា លោកចូលគាល់ព្រះរាជាហើយឬ ? សូម្បីឃើញហើយ ក៏ពោលថា ខ្ញុំនៅមិនបានចូលគាល់ទេ ព្រោះការដែលកិច្ច គឺបុគ្គលគប្បីធ្វើខ្លួន នៅមិនបានធ្វើយ៉ាងណា, សូម្បីគោត្រភូញាណឃើញព្រះនិព្វាន ក៏មិនហៅថា **ទស្សនៈ** ព្រោះមិនមានការលះកិលេសដែលគួរធ្វើយ៉ាងនោះដែរ ។ ពិតណាស់ ញាណនោះ (គោត្រភូញាណ) រមែងតាំងនៅក្នុងទី (ឋាន) ដែលពិចារណាចំពោះមគ្គ ។ ទុតិយបទថា **“ភាវ**

**នាយ** ” បានដល់ មគ្គទាំង ៣ ដែលសេសសល់ ។ ពិតណាស់ មគ្គទាំង ៣ ដែលនៅសល់ រមែងកើតឡើងក្នុងធម៌ ដែលបឋមមគ្គឃើញហើយនោះឯង; ដោយអំណាចនៃភាវនា គឺមិនឃើញនូវធម៌ណា១ ដែលបឋមមគ្គមិនធ្លាប់ឃើញហើយ; ព្រោះហេតុដូច្នោះ ព្រះភគវា ទ្រង់ត្រាស់ហៅថា **ភាវនា** ។ បទទី ៣ ពោលទុកដោយការបដិសេធបទទាំង ២ ខាងដើម ៕

## សំដែងអំពីទស្សនហេតុត្តិកៈទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈជាលំដាប់តទៅ ៖-

ហេតុដែលគប្បីលះដោយសោតាបត្តិមគ្គ (ទស្សនៈ) មានហើយដល់ធម៌ទាំងឡាយនោះ, ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **ទស្សនេនបហាតព្វហេតុកា** ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដែរ ។ ក្នុងបទទី ៣ មិនគប្បីកាន់យកសេចក្ដីយ៉ាងនេះថា **“ហេតុដែលគប្បីលះដោយសោតាបត្តិមគ្គនិងមគ្គខាងលើ ៣ មិនមានដល់ធម៌ទាំងនោះទេ”** , គប្បីកាន់យកសេចក្ដីយ៉ាងនេះថា “ហេតុដែលគប្បីលះដោយសោតាបត្តិមគ្គ ក៏មិនមែន និងដោយមគ្គខាងលើ ៣ (ភាវនា) ក៏មិនមែន មានហើយដល់ធម៌ទាំងនោះ” ។ ពិតណាស់ កាលកាន់យកសេចក្ដីក្រៅអំពីនេះ ក៏មិនគប្បីកាន់យកអហេតុកធម៌,

ព្រោះថា ហេតុប៉ុណ្ណោះ មិនមានដល់ធម៌ទាំងឡាយនោះ ។ សូម្បីក្នុងហេតុកធម៌ទាំងឡាយ ធម៌ដែលលះដោយសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើគប្បីមាន ។ ការលះធម៌ដែលមិនមានហេតុ រមែងប៉ះត្រូវ, ការលះធម៌ដែលមានហេតុ មិនប៉ះត្រូវ ។ ព្រោះថា ហេតុរបស់ធម៌ទាំងឡាយនោះឯង លោកពោលទុកថា មិនគួរលះដោយសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើ, ធម៌ទាំងនោះ ព្រះអង្គមិនបានត្រាស់ទុក សូម្បីតែហេតុ និងធម៌ទាំង ២ នេះ ក៏មិនប្រាថ្នាយក; ព្រោះហេតុដូច្នោះ គប្បីកាន់យកសេចក្ដីនេះថា ហេតុធម៌ទាំងឡាយ មិនគប្បីលះដោយសោតាបត្តិមគ្គ, មិនគប្បីលះដោយមគ្គ ៣ ខាងលើ; ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **មានហេតុដែលគួរគប្បីលះដោយសោតាបត្តិមគ្គ ក៏មិនមែន ដោយមគ្គ ៣ ខាងលើ ក៏មិនមែនដែរ** ៕

## សំម្ដែងអំពីអាចយគាមិត្តិកៈទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃអាចយគាមិធម៌តទៅ ៖-

ធម៌ណា គឺកម្ម និងកិលេសរមែងកសាងទុក, ព្រោះហេតុនោះ ធម៌នោះទើបឈ្មោះថា **អាចយៈ**; ពាក្យថា **អាចយៈ** នេះ ជាឈ្មោះរបស់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅរបស់សត្វអ្នកធ្វើដំណើរទៅកាន់បដិសន្ធិ និងចុតិ ។ អធិប្បាយ

ថា កម្ម និងកិលេសទាំងឡាយរមែងដល់បដិសន្ធិ និងចុតិនោះ ឬថា រមែងញុំាង បុគ្គលនោះឱ្យប្រព្រឹត្តទៅដោយហេតុ ឱ្យបដិសន្ធិនោះសម្រេច តាមដែលពោល ហើយនោះឯង ។ ធម៌ទាំងឡាយដែលឈ្មោះថា **អាចយគាមិនោ** ព្រោះអត្ថថា ញុំាងសត្វឱ្យដល់បដិសន្ធិ និងចុតិ ។ ពាក្យថា "**អាចយគាមិ**" នេះជាឈ្មោះ របស់កុសល និងអកុសលដែលមានអាសវៈ, ព្រះនិព្វានប្រាសចាកការកពូន, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អបចយៈ** ព្រោះប្រាសចាកការកពូន គឺបដិសន្ធិ និងចុតិនោះៗ ឯង; ធម៌ទាំងឡាយណា រមែងដល់ព្រះនិព្វានដែលជាអប្បច្ច័យ, ធម៌ទាំងនោះ ឈ្មោះថា **អបចយគាមិនោ** ព្រោះធ្វើព្រះនិព្វាននោះ ឱ្យជា អារម្មណ៍ហើយប្រព្រឹត្តទៅ ។ ពាក្យថា **អបចយគាមិ** នេះជាឈ្មោះរបស់អរិយ មគ្គ ។ម្យ៉ាងទៀត កម្ម និងកិលេសទាំងឡាយណា កពូនញុំាងបដិសន្ធិ និងចុតិ ឱ្យប្រព្រឹត្តទៅ ដូចជាងឥដ្ឋធ្វើកំពែង; ព្រោះហេតុដូច្នោះ កម្ម និងកិលេសទាំង នោះ ឈ្មោះថា **អាចយគាមិនោ** ។ ធម៌ទាំងឡាយណា មិនកពូនបដិសន្ធិ និងចុតិ នោះឱ្យប្រព្រឹត្តទៅ ដូចបុរសទម្លាយឥដ្ឋដែលកសាងហើយៗ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **អបចយគាមិនោ** ។ បទទី ៣ លោកពោល បដិសេធ ២ បទខាងដើម ៕

## សម្តែងអំពីសេក្ខត្តិកៈទី ១១

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃ សេក្ខធម៌តទៅ ៖-

ឈ្មោះថា សេក្ខៈ ព្រោះកើតហើយក្នុងសិក្ខា ៣ ដូច្នេះខ្លះ, ឈ្មោះថា សេក្ខៈ ព្រោះជាធម៌របស់ព្រះសេក្ខៈ ៧ ដូច្នេះខ្លះ, ឈ្មោះថា សេក្ខៈ ព្រោះកំពុងសិក្សាដោយនៅមិនទាន់សម្រេចការសិក្សានោះឯង ។ ឈ្មោះថា អសេក្ខៈ ព្រោះមិនត្រូវសិក្សា ព្រោះមិនមានវត្ថុដែលគប្បីសិក្សាឱ្យក្រៃលែងទៅទៀត; ម្យ៉ាងទៀត ដែលឈ្មោះថា **អសេក្ខៈ** ព្រោះព្រះអសេក្ខបុគ្គលមានសេចក្តីចម្រើនដល់ទីបំផុតហើយ ។ ពាក្យថា **អសេក្ខៈ** នេះជាឈ្មោះរបស់ធម៌ គឺអរហត្តផល ។ បទទី ៣ លោកពោលទុកដោយបដិសេធ ២ បទខាងដើម ៕

## សម្តែងអំពីបរិត្តត្តិកៈទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃបរិត្តធម៌តទៅ ៖-

វត្ថុមានប្រមាណតិចហៅថា **បរិត្ត** ព្រោះថា របស់ដែលបែកទៅដោយជុំវិញ ដូចក្នុងប្រយោគមានជាអាទិ៍ថា **“បរិត្តំ គោមយបិណ្ឌំ** = ដុំអាចម៍គោតិចតួច”[៩៣]; សូម្បីធម៌ទាំងនេះ ក៏ដូចជារបស់តិចតួច, ព្រោះហេតុដូច្នោះ ទើប

[៩៣] សំ. ខ. ។

ឈ្មោះថា **បរិត្ត** ព្រោះមានអានុភាពតិច, ពាក្យថា **បរិត្ត** នេះ ជាឈ្មោះរបស់កាមាវចរធម៌ ។ ធម៌ដែលឈ្មោះថា **មហគ្គតៈ** ព្រោះអត្ថថា ដល់ភាពជាធំ ព្រោះអាចសង្កត់កិលេស ព្រោះមានផលទូលាយ និងព្រោះការតវែង ឈ្មោះថា បុគ្គលអ្នកបដិបត្តិហើយ ដល់ភាពជាអ្នកប្រសើរដោយឆន្ទៈ វីរិយៈ ចិត្តៈ និងបញ្ញាដូច្នេះខ្លះ ។ ធម៌ទាំងឡាយមានរាគៈជាដើម ធ្វើឱ្យមានប្រមាណ ឈ្មោះថា **បមាណធម៌**, ធម៌ទាំងឡាយដែលមានឈ្មោះថា **មិនមានប្រមាណ** ព្រោះអត្ថថា បមាណធម៌ មិនមានដល់ធម៌ទាំងនេះដោយអារម្មណ៍ ឬដោយសម្បយោគ និងជាធម៌បដិសេធបមាណធម៌ ៕

## សំម្តែងអំពីបរិត្តារម្មណត្តិកៈទី ១៣

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃបរិត្តារម្មណធម៌ តទៅ ៖-

ធម៌ឈ្មោះថា **បរិត្តារម្មណៈ** ព្រោះអារម្មណ៍របស់ធម៌ទាំងនេះតិចតួច សូម្បីក្នុង ២ បទនៅសល់ ក៏ន័យនេះឯង ៕

## សំម្តែងអំពីហីនត្តិកៈទី ១៤

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃហីនធម៌តទៅ ៖-

បទថា **“ហីនៈ”** បានដល់ លាមក គឺអកុសលធម៌ ។ ធម៌ទាំងឡាយនេះ មានក្នុងកណ្ដាលនៃធម៌ដែលលាមក និងប្រណីត; ព្រោះហេតុដូច្នោះ ធម៌ទាំងនេះ ទើបឈ្មោះថា **មជ្ឈិមា** គឺធម៌ដ៏សេសទៀត ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្រៅអំពីហីនធម៌ និងបណីតធម៌ ។ **លោកុត្តរ** ឈ្មោះថា ធម៌ដែលប្រណីត ព្រោះអត្ថថា ខ្ពង់ខ្ពស់ និងព្រោះអត្ថថា ត្រជាក់សប្បាយពេកណាស់ គឺមិនក្ដៅក្រហាយទេ ៕

## សំម្ដែងអំពីមិច្ឆត្តតិកៈទី ១៥

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃមិច្ឆត្តធម៌តទៅ ៖-

ធម៌ដែលឈ្មោះ **មិច្ឆត្តៈ** ព្រោះថា សូម្បីជនទាំងឡាយមានសេចក្ដីសង្ឃឹមយ៉ាងនេះថា “ធម៌ទាំងនេះនឹងនាំប្រយោជន៍ និងសេចក្ដីសុខមកឱ្យដល់យើង” ក៏មិនបានដូចយ៉ាងនោះឡើយ ព្រោះភាវៈរបស់ខ្លួន ជាការឃើញខុសអំពីការប្រព្រឹត្តទៅដែលជាវិបរិត សូម្បីក្នុងអសុភជាដើម ថាជាសុភជាដើម ។ ការឱ្យវិបាកមានធម៌ទាំងនោះ ឈ្មោះថា **និយតៈ** ព្រោះការឱ្យវិបាកក្នុងចន្លោះ នៃការទម្លាយខន្ធនោះឯង, ធម៌ទាំងឡាយនោះជាមិច្ឆត្តៈផង ជានិយតៈផង, ព្រោះ

ហេតុនោះ ទើបឈ្មោះថា **មិច្ឆត្តនិយតា** ។ ធម៌ដែលឈ្មោះថា **សម្មត្តៈ** ព្រោះអត្ថថា ជាសភាវៈដោយប្រពៃដោយអត្ថខុសអំពី **មិច្ឆត្តៈ** ដែលពោលរួចហើយ ធម៌ទាំងឡាយនោះជាសម្មត្តៈផង ជានិយតៈផង ដោយឱ្យផល មិនមានចន្លោះយ៉ាងនោះឯង, ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មត្តនិយតា** ។ ធម៌ទាំងឡាយណា ឱ្យផលមិនទៀង សូម្បីដោយប្រការនៃបទទាំងពីរដែលពោលហើយ, ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អនិយតា** ៕

## សំដែងអំពីមគ្គារម្មណត្តិកៈទី ១៦

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃមគ្គារម្មណធម៌ តទៅ ៖-

ឈ្មោះថា **មគ្គ** ព្រោះអត្ថថា ស្វែងរក គឺស្វែងរកព្រះនិព្វាន; ម្យ៉ាងទៀតឈ្មោះថា **មគ្គ** ដោយអត្ថថា សម្លាប់កិលេសទាំងឡាយ (ហើយទើប) ទៅ ។ មគ្គជាអារម្មណ៍នៃធម៌ទាំងឡាយនោះ, ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះទើបឈ្មោះថា **មគ្គារម្មណ៍** (មានមគ្គជាអារម្មណ៍) ។ សូម្បីមគ្គប្រកបដោយអង្គ ៨ ក៏ជាហេតុនៃធម៌ទាំងនោះ ព្រោះអត្ថថា ជាបច្ច័យ; ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **មគ្គហេតុកា** (មានមគ្គជាហេតុ) ។ ហេតុ

ទាំងឡាយសម្បយុត្តដោយមគ្គ ឬថា ហេតុទាំងឡាយមានក្នុងមគ្គ ឈ្មោះថា **មគ្គហេតុ** ។ មគ្គហេតុទាំងឡាយនោះ ជាហេតុនៃធម៌ទាំងនោះ, ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **មគ្គហេតុកា** (មានមគ្គជាហេតុ) សម្មាទិដ្ឋិជាមគ្គផង ជាហេតុផង ព្រោះហេតុដូចនោះ ទើបឈ្មោះថាជា **មគ្គ** និង**ជាហេតុ**។ ធម៌ដែលជាមគ្គ និងជាហេតុទាំងឡាយនោះ មានហើយដល់ធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មគ្គហេតុកា** ។ មគ្គជាធំរបស់ធម៌ទាំងនោះ ដោយអត្ថថា គ្របសង្កត់ហើយប្រព្រឹត្តទៅ, ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **មគ្គាធិបតី** ៕

## សម្ដែងអំពីឧប្បន្នតិកៈទី ១៧

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃឧប្បន្នធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **ឧប្បន្នៈ** ព្រោះអត្ថថា ប្រព្រឹត្តទៅចាប់ដើមពីឧប្បាទក្ខណៈ ដរាបដល់ភង្គខណៈ ដែលនៅមិនហួសទៅ ។ ធម៌ដែលមិនមែនឧប្បន្នៈ ហៅថា **អនុប្បន្នៈ**, ធម៌ណាដែលទៀងតែកើតឡើង ព្រោះមួយចំណែកនៃហេតុដែលសម្រេចហើយ; ព្រោះហេតុដូច្នោះ ធម៌នោះ ទើបឈ្មោះថា **ឧប្បាទិ** ៕

## **សម្តែងអំពីអតីតត្តិកៈទី ១៨**

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃអតីតធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **អតីតៈ** ព្រោះអត្ថថា ដល់សភាពរបស់ខ្លួន ឬដល់ឧប្បាទក្ខណៈជាដើម កន្លងហួសទៅហើយ ។ ធម៌ដែលនៅមិនដល់សភាវៈរបស់ខ្លួន ឬឧប្បាទក្ខណៈជាដើមទាំងពីរនោះ ឈ្មោះថា **អនាគត**, ធម៌ដែលអាស្រ័យហេតុនោះៗ ទើបកើតឡើង ហៅថា **បច្ចុប្បន្នៈ** ៕

## **សម្តែងអំពីអនន្តរត្តិកៈទី ១៩**

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃអនន្តរធម៌ជាដើម ៖-

អតីតធម៌ដែលជាអារម្មណ៍របស់ធម៌ទាំងនោះ, ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អតីតារម្មណ៍**; សូម្បី ២ បទដែលនៅសល់ ក៏ន័យដូចគ្នា ៕

## **សម្តែងអំពីអជ្ឈត្តត្តិកៈទី ២០**

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃអជ្ឈត្តធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **អជ្ឈត្តៈ** ព្រោះអត្ថថា ធ្វើខ្លួនឱ្យជាធំ ដូចកាលប្រា-

ថ្នាយកយ៉ាងនេះថា "ពួកយើងកាលរស់នៅយ៉ាងនេះ ពួកយើងក៏ប្រកាន់ជាអត្តា" ។ ចំណែកអជ្ឈត្តសព្ទនេះ ប្រើក្នុងអត្ថ ៤ យ៉ាងគឺ

**១. គោចរជ្ឈត្តៈ** អារម្មណ៍ទូទៅ

**២. និយកជ្ឈត្តៈ** ធម៌ដែលកើតហើយក្នុងខ្លួន

**៣. អជ្ឈត្តជ្ឈត្តៈ** អជ្ឈត្តាយតនៈ ៦ (អាយតនៈខាងក្នុង)

**៤. វិសយជ្ឈត្តៈ** ផលសមាបត្តិ ។

ពិតណាស់ អជ្ឈត្តសព្ទនេះ ប្រើក្នុងអត្ថថា គោចរជ្ឈត្តៈ ដូចក្នុងប្រយោគមានជាអាទិ៍ថា "**តេនានន្ទ ភិក្ខុនា តស្មិំយេវ បុរិមស្មិំ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្វំ អជ្ឈត្តរតោ សមាហិតោ** = ម្នាលអានន្ទ ភិក្ខុនោះ គប្បីតាំងចិត្តដែលមានអារម្មណ៍ក្នុងខាងក្នុងនោះឯង ឱ្យមាំក្នុងសមាធិនិមិត្តខាងដើមនោះឯង[៩៤], អ្នកមានសេចក្តីត្រេកអរហើយក្នុងខាងក្នុង មានចិត្តតាំងមាំហើយ"[៩៥] ។ ប្រើក្នុងអត្ថថា **និយកជ្ឈត្តៈ** ដូចក្នុងប្រយោគមានជា

---

[៩៤] ម. ឧ. ។

[៩៥] ខុ. ធ. ។

[៩៦] ទី. សី., អភិ. ។

[៩៧] ទី. ម. ។

អាទិ៍ថា **“អជ្ឈត្តំ សម្បសាទនំ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី** = សេចក្តីជ្រះថ្លាក្នុងខាងក្នុង [៩៦] ឬភិក្ខុមានប្រក្រតីពិចារណាឃើញនូវធមិក្នុងធមិទាំងឡាយក្នុងខាងក្នុង” [៩៧] ។ ប្រើក្នុងអត្ថថា **អជ្ឈត្តជ្ឈត្ត:** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ឆ អជ្ឈត្តិកានិ អាយតនានិ** = អាយតនៈ ៦ ប្រព្រឹត្តទៅក្នុងខាងក្នុង” [៩៨] ។ ប្រើក្នុងអត្ថថា**វិសយជ្ឈត្ត:** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“អយំ ខោ បនានន្ទ វិហារោ តថាគតេន អភិសម្ពុទ្ធោ យទិទំ សព្វនិមិត្តានំ អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរតិ** = ម្នាលអានន្ទ ក៏ធមិជាគ្រឿងនៅនោះឯង ដែលតថាគតត្រាស់ដឹងប្រពៃហើយ ដែលតថាគតចូលទៅដល់សុញ្ញតៈខាងក្នុង ព្រោះមិនធ្វើទុកក្នុងចិត្តដល់និមិត្តទាំងអស់” [៩៩] ។ អធិប្បាយថា ប្រើក្នុងឋានដ៏ធំក្រៃលែង ។ ពិតណាស់ **ផលសមាបត្តិ** ឈ្មោះថា ឋានដ៏ធំក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយ ចំណែកអជ្ឈត្តសព្ទ ក្នុងទីនេះ ប្រាថ្នាយក **និយកជ្ឈត្ត:** ព្រោះហេតុដូច្នោះ ធមិដែលប្រព្រឹត្តទៅក្នុង

---

[៩៨] ម. ឧ. ។

[៩៩] ម. ឧ. ។

សន្តានរបស់ខ្លួនចំពោះតែបុគ្គលម្នាក់ៗ គប្បីជ្រាបថាជា **អជ្ឈត្តធម៌** ។ ចំណែកធម៌ខាងក្រៅអំពីអជ្ឈត្តធម៌នោះ ជាប់ដោយឥន្ទ្រិយក៏ដោយ មិនជាប់ដោយឥន្ទ្រិយក៏ដោយ ឈ្មោះថា **ពហិទ្ធធម៌**; បទទី ៣ លោកពោលទុកដោយអំណាចនៃបទទាំងពីរ ។

ចំណែកពួក ៣ នៃអនន្តរធម៌ (អតីតារម្មណត្តិកៈ) លោកពោលថា សូម្បីធម៌ទាំង ៣ ប្រការ (មានអជ្ឈត្តជាដើម) ទាំងនោះឯង ឱ្យជាអារម្មណ៍ហើយ ទើបប្រព្រឹត្តទៅ ៕

## សម្តែងអំពីសនិទស្សនត្តិកៈទី ២២

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃសនិទស្សនធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **សនិទស្សនៈ** ព្រោះប្រព្រឹត្តទៅជាមួយនឹងការឃើញ ពោលគឺការដែលរូបនោះត្រូវចក្ខុវិញ្ញាណគប្បីឃើញ ។ ធម៌ដែលឈ្មោះថា **សប្បដិឃៈ** ព្រោះប្រព្រឹត្តទៅជាមួយនឹងបដិឃៈ ពោលគឺការខ្ទាំងខ្ទប់ ។ ធម៌ទាំងឡាយនោះ ប្រព្រឹត្តទៅព្រមដោយការឃើញ និងការខ្ទាំងខ្ទប់, ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **សនិទស្សនសប្បដិឃ** ។ និទស្សនធម៌ ពោលគឺការដែលចក្ខុវិញ្ញាណមិនគប្បីឃើញដល់ធម៌ទាំងឡាយនោះ, ព្រោះហេតុ

នោះ ទើបឈ្មោះថា **អនិទស្សនៈ**; ធម៌ទាំងនោះជាអនិទស្សនធម៌ផង ជាសប្បដិឃធម៌ផង ដោយន័យដែលពោលហើយនោះឯង ឈ្មោះថា **អនិទស្សនសប្បដិឃៈ** ។ បទទី ៣ លោកបដិសេធដោយបទទាំងពីរ ។

**នេះជាការពណ៌នាតាមលំដាប់បទនៃតិកមាតិកា ចប់ត្រឹមតែប៉ុណ្ណេះ ៕**

ក៏ក្នុងបទទុកមាតិកា ខ្ញុំនឹងពណ៌នានូវបទដែលនៅមិនមានមក ក្នុងតិកៈទាំងឡាយប៉ុណ្ណោះ, នឹងពណ៌នាបទក្នុងហេតុគោច្ឆកៈជាមុនសិន ។

បទថា **"ហេតូ ធម្មា"** បានដល់ធម៌ទាំងឡាយ ពោលគឺហេតុ ដោយអត្ថថា ជាឫសគល់ (មូលដ្ឋាន) ព្រះបាលីថា **"ហេតុ ធម្មា"** ដូច្នេះក៏មាន ។ បទថា **"ន ហេតូ"** ជាពាក្យបដិសេធហេតុទាំងឡាយដោយពិត ។ ធម៌ដែលឈ្មោះថា **សហេតុកៈ** ព្រោះមានហេតុប្រព្រឹត្តទៅដោយសម្បយោគ ។ ធម៌ដែលឈ្មោះថា **អហេតុកៈ** ព្រោះគ្មានហេតុដែលប្រព្រឹត្តទៅរបស់ធម៌ទាំងឡាយដូចយ៉ាងនោះ ។ ធម៌ដែលឈ្មោះថា **ហេតុសម្បយុត្ត** ព្រោះសម្បយុត្តដោយហេតុដោយមានឯកុប្បាទជាដើម ។ ធម៌ដែលឈ្មោះថា **ហេតុវិប្បយុត្ត** ព្រោះមិនប្រកបដោយហេតុ ។

ក៏ទុកៈទាំងពីរ (គឺសហេតុកៈ និងអហេតុកៈ) នេះ ដោយអត្ថមិនមានសេចក្ដីផ្សេងគ្នា ក៏ពិតមែនហើយ, ប៉ុន្តែថា ព្រះមានព្រះភាគក៏ត្រាស់សម្ដែងទុកៈទាំងពីរទុកដោយសេចក្ដីពិរោះនៃទេសនា ឬដោយអធ្យាស្រ័យរបស់បុគ្គលទាំងឡាយ គឺសត្វអ្នកនឹងត្រាស់ដឹងដោយធម៌យ៉ាងនោះ; បន្ទាប់ពីនោះ ក៏ទ្រង់ប្រកបដោយទុកៈដំបូង ដោយអំណាចនៃឯកទេសទាំងអស់ និងដោយទុកៈទី ២ ទី ៣ និងទុកៈ ៣ ដទៃទៀត ដោយសេចក្ដីដែលហេតុទាំងនោះតាមតែកើតបានដោយអំណាចនៃបទទាំងឡាយ មានពាក្យថា "**ហេតូ**" ជាដើម ។

បណ្ដាទុកៈទាំងនោះ ពាក្យថា "**ហេតូ ចេវ ធម្មា សហេតុកា ច** = សភាវធម៌ទាំងឡាយដែលឈ្មោះថា ហេតុ និងមានហេតុប្រកប" នេះកើតឡើងយ៉ាងណា, សូម្បីទុកៈនេះថា "**ហេតូ ចេវ ធម្មា អហេតុកា ច** = សភាវធម៌ទាំងឡាយ ដែលឈ្មោះថា ហេតុ និងមិនមានហេតុប្រកប" ក៏កើតឡើងយ៉ាងនោះដែរ ។

ម្យ៉ាងទៀត ពាក្យថា "**សហេតុកា ចេវ ធម្មា ន ច ហេតូ** = សភាវធម៌ទាំងឡាយដែលមានហេតុប្រកប និងមិនឈ្មោះថា ហេតុ" នេះ រមែងកើតឡើងយ៉ាងណា, សូម្បីពាក្យថា "**អហេតុកា ចេវ ធម្មា ន ច ហេតូ** = សភាវធម៌ទាំងឡាយដែលគ្មានហេតុប្រកប និងមិនឈ្មោះថា ហេតុ" នេះក៏

រមែងកើតឡើងយ៉ាងនោះដែរ ។ សូម្បីក្នុងការប្រកប និងសម្បយុត្តទុកៈ ក៏ន័យនេះដែរ ។

គប្បីជ្រាបអត្ថដែលកើនលើសទៅក្នុងហេតុសហេតុកទុកៈ ដែលលោករួបរួមទុកដោយអំណាចនៃបទថា “កាលអត្ថរូបជា **ន ហេតូ ធម្មា សហេតុកាបិ អហេតុកាបិ** = សភាវធម៌ដែលមិនមែនហេតុ មានហេតុប្រកបខ្លះ, មិនមានហេតុប្រកបខ្លះ” ។ បទដែលត្រាស់ថា “**ខោ បន**” ក្នុងបទថា “**ន ហេតូ ខោ បន ធម្មា**” ក៏សូន្យទទេមិនមែនឬ? ដូម្តេច? គឺមិនមានធម៌ទាំងឡាយជាហេតុទាំងអស់ទេ, តែដោយពិត ធម៌ទាំងឡាយនោះជាយ៉ាងដទៃខ្លះ, មានហេតុប្រកបខ្លះ, គ្មានហេតុប្រកបខ្លះ, ប៉ុន្តែថា សូម្បីដោយប្រការម្យ៉ាង តាមដែលពោលហើយ ។

លោកពោលអធិប្បាយទុកថា “ដូចយ៉ាងថា ធម៌ទាំងឡាយដែលមិនមែនហេតុ រមែងមានហេតុប្រកបខ្លះ, មិនមានហេតុប្រកបខ្លះ យ៉ាងណា, ធម៌ទាំងឡាយដែលមានហេតុ ក៏រមែងមានហេតុប្រកបខ្លះ, មិនមានធម៌ប្រកបខ្លះ ក៏យ៉ាងនោះដែរ ។ ក៏ហេតុធម៌ជាសហេតុកៈខ្លះ, ជាអហេតុកៈខ្លះ យ៉ាងណា, ធម៌ដែលជា **នហេតូ** ក៏ជាហេតុសម្បយុត្តខ្លះ, ជាហេតុវិប្បយុត្តខ្លះ យ៉ាងនោះដែរ” ៕

# អដ្ឋកថាព្រះអភិធម្មបិដក

## សម្តែងអំពីចូឡន្តរទុកៈ

គប្បីវិនិច្ឆ័យក្នុងពួក ២ នៃចូឡន្តរធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **សប្បច្ចយា** ព្រោះប្រព្រឹត្តទៅជាមួយនឹងបច្ច័យដែលឱ្យសម្រេចដល់ខ្លួន ។ ធម៌ដែលឈ្មោះថា **អប្បច្ចយា** ព្រោះមិនមានបច្ច័យក្នុងឧប្បាទ ( ការកើត) ឬឋិតិ ( ការតាំងនៅ) របស់ធម៌ទាំងឡាយនោះ ។ ធម៌ដែលឈ្មោះថា **អសង្ខតៈ** ព្រោះបច្ច័យទាំងឡាយមិនប្រជុំគ្នាតាក់តែង ។ រូបរបស់ធម៌ទាំងនោះ មានហើយដោយអំណាចនៃអវិនិព្ភោគ ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **រូបិនោ** ។ ឈ្មោះថា **អរូបិនោ** ព្រោះរូបរបស់ធម៌ទាំងនោះមិនមានដូចយ៉ាងនោះ ។ម្យ៉ាងទៀត រូបនោះ មានការសូន្យទៅជាលក្ខណៈរបស់ធម៌ទាំងនោះ, ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **រូបិនោ**, ធម៌ទាំងឡាយដែលមិនមែនរូប ឈ្មោះថា **អរូបិនោ** ។

វដ្តៈត្រាស់ហៅថា **លោក** ក្នុងបទថា **លោកិយា ធម្មា** ព្រោះអត្ថថាទ្រុឌទ្រោម ។ ធម៌ទាំងឡាយប្រកបហើយក្នុងលោក ដោយការរាប់បញ្ចូលហើយក្នុងលោកនេះ ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **លោកិយ** ។ធម៌ទាំងឡាយនោះ ឈ្មោះថា **ឧត្តរ** ព្រោះឆ្លងផុតហើយចាកលោកនេះ ។

ធម៌ណាដែលឆ្លងផុតហើយចាកលោកដោយការប្រព្រឹត្តទៅ មិនរាប់បញ្ចូលក្នុងលោក ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបឈ្មោះថា **លោកុត្តរ** ។

បទថា **កេនចិ វិញ្ញេយ្យា** បានដល់ គប្បីដឹងដោយចក្ខុវិញ្ញាណ ឬសោតវិញ្ញាណយ៉ាងណាមួយ ក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម។ បទថា **កេនចិ ន វិញ្ញេយ្យា** បានដល់ មិនគប្បីដឹងដោយចក្ខុវិញ្ញាណ ឬសោតវិញ្ញាណនោះឯង ។ កាលបើមានសេចក្ដីយ៉ាងនេះ សូម្បីទុកៈក្នុងបទទាំង ២ ក៏ផ្សេងគ្នាដោយអត្ថដែរ ៕

## សម្ដែងអំពីអាសវគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**អាសវគោច្ឆកៈ**តទៅ ៖-

ធម៌ដែលឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ហូរទៅ, អធិប្បាយថា អាសវៈទាំងនោះ រមែងហូរទៅ គឺរមែងប្រព្រឹត្តទៅតាមផ្លូវភ្នែកខ្លះ ។ ល ។ តាមផ្លូវចិត្តខ្លះ ។ម្យ៉ាងទៀត ធម៌ដែលឈ្មោះថា **អាសវៈ** ព្រោះអត្ថថា កាលពោលដោយធម៌ រមែងហូរទៅដល់គោត្រភូ, ពោលដោយភូមិ (ឱកាស) រមែងហូរទៅដល់ភវគ្គព្រហ្ម, អធិប្បាយថា ធ្វើធម៌ទាំងនេះ និងភូមិទុកក្នុងខាងក្នុងហើយប្រព្រឹត្តទៅ ។ ព្រោះថា **អា** អក្សរនេះ មានអត្ថថា ធ្វើធម៌ទុកខាង

ក្នុង; ដែលឈ្មោះថា **អាសវៈ** ព្រោះជាគ្រឿងត្រាំ ដោយអត្ថថា ត្រាំទុកយូរ មានគ្រឿងស្រវឹងជាដើម, ពិតណាស់ គ្រឿងត្រាំដែលត្រាំទុកយូរ មានគ្រឿងស្រវឹងជាដើម លោកហៅថា **អាសវៈ** ក្នុងលោក ។ តែបើឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ត្រាំទុកយូរ អាសវៈទាំងនោះ ក៏សមគួរជាយ៉ាងនោះដែរ ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើម នៃអវិជ្ជា មិនប្រាកដថា មុនពីនេះ អវិជ្ជា ក៏មិនបានមាន"[១០០] ជាដើម ។ម្យ៉ាងទៀត ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា រមែងហូរ គឺរមែងហូរទៅកាន់សំសារទុក្ខដ៏យូរអង្វែង ។ ក្រៅអំពីអាសវៈនោះ ធម៌ទាំងឡាយដទៃ មិនឈ្មោះថាអាសវៈទេ ។

ធម៌ដែលឈ្មោះថា **សាសវៈ** ព្រោះមានអាសវៈព្រមទាំងធ្វើខ្លួនឱ្យជាអារម្មណ៍ហើយប្រព្រឹត្តទៅ ។ ឈ្មោះថា **អនាសវៈ** ព្រោះអត្ថថា គ្មានអាសវៈរបស់ធម៌ទាំងនោះ ដែលកំពុងប្រព្រឹត្តទៅហើយយ៉ាងនេះ ។ គប្បីជ្រាបបទដ៏សេសក្នុងហេតុគោច្ឆកៈដោយន័យដែលពោលហើយ ។

ចំណែកសេចក្ដីដែលប្លែកគ្នាមានដូចតទៅនេះ ៖-

---

[១០០] អំ. ទសក. ។

ក្នុងហេតុគោច្ឆកៈនោះ ទុកៈចុងក្រោយថា **“ន ហេតូ ខោ បន ធម្មា សហេតុកាបិ អហេតុកាបិ”** នេះ ព្រះភគវាទ្រង់ត្រាស់ទុកបទទី ២ នៃទុកៈដំបូងទុកក្នុងខាងដើមយ៉ាងណា, ក្នុងអាសវគោច្ឆកៈនេះ មិនត្រាស់បទខាងចុងបំផុតថា **“នោ អាសវា ខោ បន ធម្មា សាសវាបិ អនាសវាបិ”** យ៉ាងនោះដែរ; ព្រះភគវាទ្រង់មិនត្រាស់ទុក ក៏ពិតមែនហើយ, ប៉ុន្តែថា គប្បីជ្រាបសេចក្តីនេះ និងសេចក្តីប្លែកគ្នាដោយន័យដែលត្រាស់ទុកក្នុងហេតុគោច្ឆកៈនោះឯង ៕

## សំម្តែងអំពីសញ្ញោជនគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងសញ្ញោជនគោច្ឆកធម៌តទៅ ៖-

ធម៌ដែលឈ្មោះថា **សញ្ញោជនៈ** ព្រោះអត្ថថា រមែងប្រកប, គឺចងបុគ្គលអ្នកមានសញ្ញោជនៈទុកក្នុងវដ្តៈ; ធម៌ក្រៅអំពីនោះ មិនឈ្មោះថា សញ្ញោជនៈទេ ។ ធម៌ដែលឈ្មោះថា **សញ្ញោជនិយៈ** ព្រោះអត្ថថា ចូលដល់សេចក្តីជាអារម្មណ៍ ហើយជាប្រយោជន៍ដល់សញ្ញោជនៈទាំងឡាយដោយចំណងសញ្ញោជនៈ ពាក្យថា **សញ្ញោជនិយៈ** នេះ ជាឈ្មោះរបស់ធម៌ដែលជាអារម្មណប្បច្ច័យរបស់សញ្ញោជនៈ; ធម៌ដែលមិនមែនសញ្ញោជនិយៈ ឈ្មោះថា អសញ្ញោជនិយធម៌;

ពាក្យនៅសល់ គប្បីប្រកបសេចក្តីដោយន័យដែលពោលទុកហើយ ក្នុងហេតុគោច្ឆកៈនោះឯង ៕

## សម្តែងអំពីគន្ថគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**គន្ថគោច្ឆកធម៌**តទៅ ៖-

ធម៌ដែលឈ្មោះថា **គន្ថៈ** ព្រោះអត្ថថា ចង គឺតបុគ្គលអ្នកមានកិលេសទុកក្នុងវដ្តៈ ដោយអំណាចនៃចុតិ និងបដិសន្ធិ ។ ធម៌ក្រៅពីនេះ មិនឈ្មោះថា**គន្ថៈ**ទេ; ធម៌ដែលឈ្មោះថា **គន្ថនិយៈ** ព្រោះអត្ថថា ត្រូវគន្ថធម៌ចងទុក ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍; ពាក្យដែលនៅសល់ គប្បីប្រកបសេចក្តីដោយន័យដែលពោលហើយ ក្នុងហេតុគោច្ឆកៈនោះឯង; តែពាក្យដែលសល់ក្រៅពីពាក្យដែលត្រាស់ទុក សូម្បីក្នុងទុកៈដទៃអំពីទុកៈទាំងនេះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងទុកៈនោះៗឯង ដូចត្រាស់ទុកក្នុងទុកៈនេះ ៕

## សម្តែងអំពីឱឃគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**ឱឃគោច្ឆកៈ**តទៅ ៖-

ធម៌ដែលឈ្មោះថា **ឱឃៈ** ព្រោះអត្ថថា ដាប គឺញុំាងសត្វមានកិលេសឱ្យ

លិចចុះក្នុងវដ្តៈ; ក៏ឈ្មោះថា **ឱឃនិយៈ** ព្រោះញុំាងឱឃធម៌ទាំងឡាយ ឱ្យឈានកន្លងដោយធ្វើឱ្យជាអារម្មណ៍ហើយគប្បីឈានកន្លង ។ គប្បីជ្រាបឱឃនិយធម៌ថាជាអារម្មណ៍របស់ឱឃៈទាំងឡាយនោះឯង ៕

## សម្តែងអំពីយោគគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**យោគគោច្ឆកធម៌** តទៅ ៖-

ធម៌ដែលឈ្មោះថា **យោគៈ** ព្រោះអត្ថថា ប្រកបសត្វអ្នកមានកិលេសទុកក្នុងវដ្តៈ; គប្បីជ្រាបយោគនិយធម៌ដូចឱឃនិយធម៌ ៕

## សម្តែងអំពីនីវរណគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**នីវរណគោច្ឆកធម៌**តទៅ ៖-

ធម៌ដែលឈ្មោះថា **នីវរណៈ** ព្រោះរារាំង គឺស្រោបចិត្តទុក, គប្បីជ្រាប**នីវរណនិយធម៌** ដូចសញ្ញោជនិយធម៌ ៕

## សម្តែងអំពីបរាមាសគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**បរាមាសគោច្ឆកធម៌** តទៅ ៖-

ធម៌ដែលឈ្មោះថា **បរាមាសៈ** * ព្រោះអត្ថថា ប្រកាន់ភ្ជាប់ដោយសេចក្ដីជាយ៉ាងដទៃ ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការឈានកន្លងអាការរបស់ធម៌ទាំងឡាយ ដែលមានសេចក្ដីមិនទៀងជាដើម តាមសេចក្ដីពិតថាជាធម៌ទៀងជាដើម, ឈ្មោះថា **បរាមដ្ឋធម៌** ព្រោះបរាមាសធម៌ទាំងឡាយប្រកាន់ភ្ជាប់ទុកដោយការធ្វើឱ្យជាអារម្មណ៍ ៕

## សម្ដែងអំពីមហន្តរទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ២ **នៃមហន្តរធម៌** តទៅ ៖-

ធម៌ទាំងឡាយណា ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ព្រោះហេតុនោះធម៌ទាំងឡាយនោះ ទើបឈ្មោះថា **សារម្មណ៍** ព្រោះមិនកាន់យកអារម្មណ៍ហើយក៏មិនប្រព្រឹត្តទៅបាន ។ អារម្មណ៍របស់ធម៌ទាំងឡាយនោះ មិនមានព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អនារម្មណ៍** ។

ធម៌ដែលឈ្មោះថា **ចិត្ត** ព្រោះអត្ថថា គិត (**ចិន្តនដ្ឋេន**); ម្យ៉ាងទៀតឈ្មោះថា **ចិត្ត** ព្រោះអត្ថថា វិចិត្រ (**វិចិត្តដ្ឋេន**) ។ ធម៌ដែលប្រកបក្នុងចិត្ត

---

* បរាមាសៈ < បរ+អាមាសៈ, បរ ប្រែថា ដទៃ, អាមាសៈ ប្រែថា ពាល់ត្រូវ ឬប្រកាន់ភ្ជាប់ ។

ដោយមិនប្រាសចាកគ្នា ឈ្មោះថា **ចេតសិក** ។ ធម៌ដែលជាប់ដោយចិត្ត ( ច្រឡូកច្រឡំដោយចិត្ត) តាំងពីកើតរហូតដល់រលត់ ដោយការចូលទៅប្រកបគ្នាជានិច្ច ឈ្មោះថា **ចិត្តសំសដ្ឋ** ។ សូម្បីធម៌កាលដែលប្រព្រឹត្តទៅព្រមទាំងចិត្ត តែមិនជាប់ជាមួយនឹងចិត្ត ព្រោះមិនចូលទៅប្រកបជាមួយគ្នាជានិច្ចឡើយ ឈ្មោះថា **វិសំសដ្ឋ** ។

ចិត្តជាសមុដ្ឋានរបស់ធម៌ទាំងនោះ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **ចិត្តសមុដ្ឋាន** ។ ធម៌ដែលកើតព្រមគ្នា ឈ្មោះថា **សហភូ** ធម៌ដែលកើតព្រមគ្នានឹងចិត្ត ឈ្មោះថា **ចិត្តសហភូ** ។ ធម៌ដែលប្រព្រឹត្តទៅតាមគ្នា ឈ្មោះថា **អនុបរិវត្តិ** ។ ប្រព្រឹត្តទៅតាមអ្វី? ប្រព្រឹត្តទៅតាមចិត្ត ឈ្មោះថា **ចិត្តានុបរិវត្តិធម៌** ។

ធម៌ទាំងឡាយនោះ ឈ្មោះថា **ចិត្តសំសដ្ឋសមុដ្ឋាន** ព្រោះច្របូកច្របល់ដោយចិត្ត និងតាំងឡើងដោយចិត្ត ។ ធម៌ដែលឈ្មោះថា **ចិត្តសំសដ្ឋសមុដ្ឋាន-សហភូ** ព្រោះច្រឡូកច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត និងកើតព្រមគ្នាជាមួយនឹងចិត្ត ។ **ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិ** ព្រោះច្រឡូកច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត និងប្រព្រឹត្តទៅតាមចិត្ត ។ បទទាំងអស់ដែលនៅសល់

គប្បីជ្រាបដោយការបដិសេធបទដែលពោលហើយ ។ ធម៌ដែលជាខាងក្នុងនោះឯង ឈ្មោះថា **អជ្ឈត្តិកធម៌** តាមដែលពោលទុកក្នុងអជ្ឈត្តិកៈ ក្នុងទីនេះ សំដៅយក **អជ្ឈត្តជ្ឈត្តធម៌** (គឺអជ្ឈត្តាយតនៈ) ធម៌ដែលក្រៅពីនោះ ឈ្មោះថា **ពាហិរធម៌** ។ ធម៌ដែលឈ្មោះថា **ឧបាទា** ព្រោះអាស្រ័យភូតរូបហើយ ទើបកើតឡើង, តែមិនមែនដូចជាភូតខ្មោចចូលអាស្រ័យទេ ។ ធម៌ដែលមិនអាស្រ័យភូតរូបហើយទើបកើតឡើង ឈ្មោះថា **អនុបាទា** ៕

## សំម្តែងអំពីឧបាទានគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**ឧបាទានគោច្ឆកធម៌** តទៅ ៖-

ធម៌ដែលឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់យ៉ាងក្រៃលែង, គឺប្រកាន់មាំ, ធម៌ក្រៅអំពីឧបាទាន មិនឈ្មោះថា **ឧបាទាន**ទេ (គឺឈ្មោះថា**អនុបាទាន**) ៕

## សំម្តែងអំពីកិលេសគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង**កិលេសគោច្ឆកធម៌** តទៅ ៖-

អត្ថនៃកិលេសគោច្ឆកៈ គប្បីជ្រាបដោយន័យ ដែលពោលទុកក្នុង**សង្កិលិដ្ឋតិកៈ**នោះឯង ៕

# សម្តែងអំពីបិដ្ឋិទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ២ នៃបិដ្ឋិធមិ តទៅ ៖-

ធមិទាំងឡាយណា រមែងត្រាច់ទៅ (អាស្រ័យនៅ) ក្នុងកាម ព្រោះហេតុនោះ ធមិទាំងនោះ ទើបឈ្មោះថា **កាមាវចរ** ។ ឈ្មោះថា **រូបាវចរ** ព្រោះត្រាច់ទៅក្នុងរូប ។ ឈ្មោះថា **អរូបាវចរ** ព្រោះត្រាច់ទៅក្នុងអរូប ។ ក្នុងទុកៈនេះមានសេចក្តីសង្ខេបត្រឹមនេះ, ចំណែកសេចក្តីពិស្តារនឹងមានជាក់ច្បាស់ទៅខាងមុខ ។

ធមិទាំងឡាយណា រាប់បញ្ចូលក្នុងសំសារឈានចុះខាងក្នុង គឺក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣, ព្រោះហេតុដូច្នោះ ធមិទាំងនោះ ទើបឈ្មោះថា **បរិយាបន្ន** (តេភូមិកវដ្ត) ធមិដែលមិនរាប់បញ្ចូលក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **អបរិយាបន្ន** (**នតេភូមិកវដ្ត**) ។

ធមិទាំងឡាយណា កាត់ឫសនៃវដ្តៈ* ធ្វើព្រះនិព្វានឱ្យជាអារម្មណ៍ហើយចេញចាកវដ្តៈ, ព្រោះហេតុដូច្នោះ ធមិទាំងឡាយនោះ ទើបឈ្មោះថា **និយ្យានិក**; ធមិទាំងឡាយណា មិនចេញចាកវដ្តៈ, ព្រោះហេតុនោះ ធមិទាំងឡាយនោះ

---

* អដ្ឋ. យ. ធមិដែលជាឫសគល់នៃវដ្តៈ បានដល់ អវិជ្ជា និងតណ្ហា ។

ឈ្មោះថា **អនិយ្យានិក** ។ ព្រោះឱ្យផលទៀងទាត់ក្នុងលំដាប់នៃចុតិ ឬការប្រព្រឹត្តទៅរបស់ខ្លួន ។ ធម៌ដែលឱ្យផលមិនទៀងទាត់យ៉ាងនេះ ឈ្មោះថា **អនិយត** ។

ធម៌ដែលឈ្មោះថា **ឧត្តរ** ព្រោះឆ្លងផុត គឺលះធម៌ទាំងឡាយដទៃហើយទៅ ។

ដែលឈ្មោះថា **សឧត្តរ** ព្រោះមានឧត្តរធម៌ដែលអាចដើម្បីឆ្លងផុតខ្លួនឡើងទៅ ។ ដែលឈ្មោះថា **អនុត្តរធម៌** ព្រោះឧត្តរធម៌នៃធម៌ទាំងនោះ មិនមាន ។

ធម៌ទាំងឡាយណា ដែលញុំាងសត្វទាំងឡាយឱ្យយំ, ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **រណៈ**, ពាក្យថា រណធម៌នេះ ជាឈ្មោះនៃកិលេសទាំងឡាយមានរាគៈជាដើម ដែលសត្វទាំងឡាយត្រូវកិលេសគ្របសង្កត់ហើយ យំខ្សឹកខ្សួលដោយប្រការផ្សេងៗ ។ ធម៌ដែលឈ្មោះថា **សរណៈ** ព្រោះមានរណធម៌ដោយអំណាចនៃសម្បយោគ និងដោយអំណាចនៃការតាំងនៅក្នុងឋានដូចគ្នានៃការលះ; ធម៌ដែលមានឈ្មោះថា **អសរណៈ** ព្រោះសរណធម៌ នៃធម៌ទាំងឡាយនេះមិនមាន ដោយប្រការដូច្នេះ ៕

# សម្តែងអំពីសុត្តន្តិកទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ២ ក្នុងសុត្តន្តិកទុកៈតទៅ ៖-

ធម៌ទាំងឡាយណា រមែងសេពគប់វិជ្ជា ដោយអំណាចនៃសម្បយោគ, ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **វិជ្ជាភាគី** ។ មួយវិញទៀត ធម៌ទាំងឡាយណា រមែងញុំាងចំណែកនៃវិជ្ជាឱ្យប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា, ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **វិជ្ជាភាគី** ។ ក្នុងវិជ្ជាភាគីនោះ វិជ្ជាមាន ៨ គឺ **វិបស្សនាញាណ ១ មនោមយិទ្ធិ ១ អភិញ្ញា ៦** ។ ពោលដោយអត្ថមុន ធម៌ដែលសម្បយុត្តដោយវិជ្ជាទាំងនោះ ឈ្មោះថា **វិជ្ជាភាគី** ។ ពោលដោយអត្ថជាមុន បណ្តាវិជ្ជាទាំង ៨ នោះ វិជ្ជាតែមួយ ក៏ឈ្មោះថា **វិជ្ជា** ដែរ, វិជ្ជាទាំងឡាយដែលសល់ ឈ្មោះថា **វិជ្ជាភាគី**; ព្រោះហេតុដូច្នោះ វិជ្ជាក្តី, ធម៌ដែលសម្បយុត្តដោយវិជ្ជាក្តី, គប្បីជ្រាបថា ជាវិជ្ជាភាគីនោះឯង; តែក្នុងសុត្តន្តិកទុកៈ ក្នុងទីនេះ សំដៅយកសម្បយុត្តធម៌ ។ ធម៌ទាំងឡាយណា សេពគប់អវិជ្ជាដោយអំណាចនៃសម្បយោគៈ, ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អវិជ្ជាភាគី** ។ សូម្បីធម៌ដែលញុំាងចំណែកនៃវិជ្ជាឱ្យប្រព្រឹត្តទៅក្នុងពួកនៃអវិជ្ជាក៏ឈ្មោះថា **អវិជ្ជាភាគី** ។ ក្នុងអវិជ្ជាភាគីនោះ អវិជ្ជាមាន ៤ គឺការងងឹតដែល

បិទបាំងទុក្ខ (១), ការងងឹតដែលបិទបាំងសមុទយៈជាដើម (៣) ។

សូម្បីធម៌ដែលសម្បយុត្តដោយអវិជ្ជាទាំងនោះ ឈ្មោះថា **អវិជ្ជាភាគី** ដោយន័យមុននោះឯង ។ បណ្ដាអវិជ្ជាទាំងនោះ អវិជ្ជាយ៉ាងណានីមួយ ឈ្មោះថា **អវិជ្ជា** (ដោយន័យក្រោយ), អវិជ្ជាដែលសល់ ឈ្មោះថា **អវិជ្ជាភាគី**; ព្រោះហេតុដូច្នោះ អវិជ្ជាយ៉ាងនេះក្ដី, ធម៌ដែលសម្បយុត្តដោយអវិជ្ជាក្ដី, គប្បីជ្រាបថា អវិជ្ជាភាគីនោះឯង ។ ក្នុងទុកៈនេះ លោកសំដៅយកធម៌ដែលសម្បយុត្តគ្នា ។

ធម៌ដែលឈ្មោះថា **វិជ្ជូបមៈ** ព្រោះប្រៀបដោយផ្លេកបន្ទោរ ហេតុដែលមិនអាចដើម្បីកម្ចាត់សេចក្ដីងងឹត គឺកិលេសបានដោយការមិនគ្រប់សង្កត់ទៀត ។ ដែលឈ្មោះថា **វជិរូបមធម៌** ព្រោះធម៌ទាំងឡាយនោះ ប្រៀបដូចពេជ្រ * ហេតុដែលអាចកំចាត់កិលេសបានដោយសព្វគ្រប់ ។ ដែលឈ្មោះថា **ពាលធម៌** ព្រោះជាធម៌តាំងនៅក្នុងពាលទាំងឡាយ ដោយឧបចារៈនៃធម៌ដែលពាលតាំងនៅ ។ ដែលឈ្មោះថា **បណ្ឌិតធម៌** ព្រោះជាធម៌តាំងនៅក្នុងបណ្ឌិតទាំងឡាយ ។ ម្យ៉ាងទៀត ឈ្មោះថា **ពាលធម៌** ព្រោះធ្វើឱ្យជាមនុស្សល្ងង់, ឬ

---

* មូលដិកា វត្ថុណានីមួយមានកែវមណី និងថ្មជាដើម ដែលមានពេជ្រធ្លាក់ត្រូវហើយ ត្រូវតែបែក គឺដែលថា មិនបែក រមែងមិនមាន ។

ឈ្មោះថា បណ្ឌិតធម៌ ព្រោះធ្វើឱ្យជាមនុស្សឆ្លាត ។ ធម៌ខ្មៅធ្វើចិត្តមិនឱ្យមានពន្លឺ ឈ្មោះថា **កណ្ហធម៌** ។ ធម៌សធ្វើចិត្តឱ្យមានពន្លឺ ឈ្មោះថា **សុក្កធម៌** ។ ម្យ៉ាងទៀត ដែលឈ្មោះថា **កណ្ហធម៌** ព្រោះហេតុដែលកំណើតខ្មៅ, ឬឈ្មោះថា **សុក្កធម៌** ព្រោះហេតុដែលកំណើតស ។ ដែលឈ្មោះថា **តបនីយធម៌** ព្រោះដុតកម្ដៅក្នុងលោកនេះ និងលោកខាងមុខ ធម៌ដែលមិនមែនជាតបនីយធម៌ ឈ្មោះថា **អតបនីយធម៌** ។

ទុកៈ ៣ មានអធិវចនទុកៈជាដើម ពោលដោយអត្ថមិនមានការធ្វើដែលផ្សេងគ្នាក្នុងអធិវចនទុកៈជាដើមនេះ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ, ពិតណាស់ពាក្យថា "**សិរិវឌ្ឍកោ ធនវឌ្ឍកោ**" ជាដើម ដែលធ្វើត្រឹមតែជាពាក្យសម្ដីប៉ុណ្ណោះ ឱ្យជាធំហើយប្រព្រឹត្តទៅ ឈ្មោះថា **អធិវចនៈ** ។ ធម៌ដែលជាគន្លងនៃឈ្មោះទាំងឡាយ ឈ្មោះថា **អធិវចនបថ** ។ ពាក្យនិយាយដែលពោលហើយធ្វើឱ្យមានហេតុដោយពិស្ដារយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណាតាក់តែង, ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **សង្ខារ**" ឈ្មោះថា **និរុត្តិ** ។ គន្លងនៃនិរុត្តិធម៌ទាំងឡាយ ហៅថា **និរុត្តិបថធម៌** ។ ធម៌ដែលឈ្មោះថា **បញ្ញត្តិ** ព្រោះការថែងឱ្យដឹងដោយប្រការនោះៗ យ៉ាងនេះថា

“**គរុភ្ជា** = ការត្រិះរិះ, **ទិគរុភ្ជា** = វិតក្កៈ, **សំករប្បា** = សេចក្តីរិះរក”[១០១] ។ គន្លងនៃបញ្ញត្តិទាំងឡាយ ហៅថា **បញ្ញត្តិបថធម៌** ។ ក្នុងទីនេះ នឹងពោលតែមួយទុកៈ គប្បីជ្រាបប្រយោជន៍ ក្នុងពាក្យដោយន័យ ដែលពោលហើយក្នុងហេតុគោច្ឆកៈនោះឯង ៕

## សំដែងអំពីនាមរូបទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ២ នៃ**នាមរូប** តទៅ ៖-

ធម៌ដែលឈ្មោះថា **នាម** ព្រោះអត្ថថា ការតាំងឈ្មោះ **នាមករណ-ដ្ឋេន**, ឬព្រោះអត្ថថា បង្អោនទៅ **នមនដ្ឋេន**, ឬថា ព្រោះអត្ថថា ការឱ្យបង្អោនទៅ **នាមនដ្ឋេន**, ឬក៏ព្រោះអត្ថថា ការឱ្យបង្អោនទៅ **នាមនត្ថេន** ។ ធម៌ដែលឈ្មោះថា **រូប** ព្រោះអត្ថថា បែកធ្លាយទៅ **រុប្បនដ្ឋេន**, ក្នុងសុត្តន្តិកទុកៈនេះ មានសេចក្តីសង្ខេបត្រឹមនេះ ។ ចំណែកសេចក្តីពិស្តារ នាមធម៌នឹងជាក់ច្បាស់ក្នុងនិក្ខេបកណ្ឌ ។

ការមិនចេះក្នុងសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម ឈ្មោះថា **អវិជ្ជា** ។

---

[១០១] អភិ. ។

ការប្រាថ្នាក្នុងភពឈ្មោះថា **ភវតណ្ហា** ។ **សស្សតៈ** (ទៀង) ឈ្មោះថា **ភវៈ** ក្នុងបទថា **"ភវទិដ្ឋិ"** គឺទិដ្ឋិដែលកើតឡើង ដោយអំណាចនៃការឃើញថាទៀង ។ ការដាច់សូន្យ លោកហៅថា **វិភវៈ** ក្នុងបទថា **វិភវទិដ្ឋិ** គឺទិដ្ឋិដែលកើតឡើងដោយអំណាចនៃការដាច់សូន្យ ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា "អត្តា និងលោកទៀង" ឈ្មោះថា **សស្សតទិដ្ឋិ**; ទិដ្ឋិដែលប្រព្រឹត្តទៅថា **"អត្តា** និងលោកមានទីបំផុត" ឈ្មោះថា **អន្តវាទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា **"អត្តា** និងលោកមិនមានទីបំផុត" ឈ្មោះថា **អនន្តវាទិដ្ឋិ**; ទិដ្ឋិដែលស្របតាមខន្ធចំណែកអតីតៈឈ្មោះថា **បុព្វន្តានុទិដ្ឋិ** ។ ទិដ្ឋិដែលស្របតាមចំណែកអនាគត ឈ្មោះថា **អបរន្តានុទិដ្ឋិ** ។ ការមិនខ្មាស់ លោកពោលឱ្យពិស្តារយ៉ាងនេះថា "កម្មណាដែលបុគ្គលគួរ ខ្មាស់រមែងមិនខ្មាស់ [១០២], កម្មនោះ ឈ្មោះថា **អហិរិកៈ"** [១០៣], អាការដែលមិនមិនខ្លាច លោកពោលឱ្យពិស្តារទុកយ៉ាងនេះថា "កម្មណាដែលបុគ្គលគួរខ្លាច [១០៤] រមែងមិនខ្លាចកម្មនោះ ឈ្មោះថា **អនោត្តប្បៈ"**,

[១០២] អភិ. ។

[១០៣] អភិ. ។

[១០៤] អភិ. ។

ការខ្មាស់ ឈ្មោះថា **ហិរិ**, ការខ្លាចឈ្មោះថា **ឱត្តប្បៈ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង**ទោវចស្សតា** (ភាពជាអ្នកដែលគេប្រដៅក្រ) ជាដើម បុគ្គលនោះ ឈ្មោះថា **ទុព្វចៈ** (ប្រដៅក្រ) ព្រោះអត្ថថា ការទូន្មានបុគ្គលអ្នកកាន់យកការទាស់ទែងគ្នាផ្សេងៗ, អ្នកស្រឡាញ់ការប្រណាំងប្រជែង, អ្នកមិនអើពើការទូន្មាននោះ ធ្វើបានដោយក្រ កម្មរបស់អ្នកប្រដៅក្រនោះ ឈ្មោះថា **ទោវចស្សតា**; ភាវៈនៃកម្មរបស់អ្នកប្រដៅក្រនោះ ឈ្មោះថា **ទោវចស្សតា** ។ បុគ្គលលាមកមិនមានសទ្ធាជាដើម ជាមិត្រនៃបុគ្គលនោះ, ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **បាបមិត្រ** ។ ភាវៈនៃមិត្រនោះ ឈ្មោះថា **បាបមិត្តតា** ។ គប្បីជ្រាប **សោវចស្សតា** (ភាពជាអ្នកប្រដៅងាយ) និងកល្យាណមិត្រ ដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយនោះឯង ។

ភាពជាអ្នកឆ្លាតក្នុងអាបត្តិទាំងឡាយ ដែលត្រាស់ទុកយ៉ាងនេះថា "កងអាបត្តិ ៥ ក៏មាន, កងអាបត្តិ ៧ ក៏មាន" [១០៥] ឈ្មោះថា **អាបត្តិកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងការចេញចាកអាបត្តិទាំងឡាយនោះ ឈ្មោះថា **អាបត្តិវុដ្ឋានកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងសមាបត្តិទាំងឡាយ ឈ្មោះថា **សមាបត្តិ**

---
[១០៥] អភិ. ។

**កុសលតា** នេះជាឈ្មោះរបស់បញ្ញា ដែលកំណត់ដោយអប្បនារបស់សមាបត្តិទាំងឡាយ ។ ភាពជាអ្នកឆ្លាតក្នុងការចេញចាកសមាបត្តិទាំងឡាយ ឈ្មោះថា **សមាបត្តិវុដ្ឋានកុសលតា** ។

ភាពជាអ្នកឆ្លាតក្នុងធាតុ ១៨ យ៉ាង ឈ្មោះថា **ធាតុកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងមនសិការធាតុទាំងអស់នោះឯង ឈ្មោះថា **មនសិការកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម ឈ្មោះថា **អាយតនកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងបដិច្ចសមុប្បាទ មានអង្គ ១២ ឈ្មោះថា **បដិច្ចសមុប្បាទកុសលតា** ។ ភាពជាអ្នកឆ្លាតក្នុងឋាននោះ ឈ្មោះថា **ឋានកុសលតា** ។ **ហេតុ** ត្រាស់ថា **ឋាន** ។ ពិតណាស់ **ផល** ឈ្មោះថា **រមែងតាំងនៅ** ព្រោះអាស្រ័យហេតុនោះប្រព្រឹត្តទៅហើយ ព្រោះហេតុដូច្នោះ ទើបហៅថា **ឋាន** ។ ភាពជាអ្នកឆ្លាតក្នុង **អឋាន** ទាំងឡាយ ឈ្មោះថា **អឋានកុសលតា** ។ ភាពជាអ្នកត្រង់ឈ្មោះថា **អាជ្ជវៈ** ។ ភាពជាអ្នកទន់ភ្លន់ ឈ្មោះថា **មទ្ទវៈ** ។ ភាពជាអ្នកអត់ទ្រាំ គឺការអត់សង្កត់ ឈ្មោះថា **ខន្តិ** ។ ភាពជាអ្នកត្រេកអរីករាយ ឈ្មោះថា **សោរច្ចៈ** ។ ភាពជាអ្នកមានវាចាផ្អែមល្ហែម គឺការរីករាយចិត្ត និងការទន់ភ្លន់ ឈ្មោះថា **សាខល្យៈ** ។ ការបដិសណ្ឋារៈ ដោយធមិ

និងអាមិសទាំងឡាយដោយមិនឱ្យមានទោសដល់ខ្លួន និងអ្នកដទៃ ឈ្មោះថា **បដិសណ្ឋារៈ** ។ ភាពជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មានចិត្តជាទី ៦ គឺភាពជាអ្នកទម្លាយឥន្ទ្រិយសំវរៈ ឈ្មោះថា **ឥន្ទ្រិយេសុ អគុត្តទ្វារតា** ។ ភាពជាអ្នកមិនដឹងប្រមាណក្នុងភោជន ដោយអំណាចនៃការទទួល និងការបរិភោគ ឈ្មោះថា **ភោជនេ អមត្តញ្ញុតា** ។ គប្បីជ្រាបពួក ២ ក្នុងចន្លោះ ដោយអំណាចនៃការបដិសេធពាក្យដែលពោលហើយ, ភាពនៃបុគ្គលអ្នកភ្លេចសតិ គឺការនៅប្រាសចាកសតិ ឈ្មោះថា **មុដ្ឋស្សច្ចៈ** ។ ភាពជាអ្នកមិនដឹងខ្លួន ឈ្មោះថា **អសម្បជញ្ញៈ** ។

ធម៌ដែលឈ្មោះថា សតិ ព្រោះរលឹកបាន (**សរតីតិ** > **សតិ**) ។ ឈ្មោះថា **សម្បជញ្ញៈ** ព្រោះដឹងច្បាស់ (**សម្បជានាតីតិ** > **សម្បជញ្ញំ**) ។ ពលៈពោលគឺការពិចារណាវត្ថុដែលនៅមិនបានពិចារណា ឈ្មោះថា **បដិសង្ខានពលៈ** ព្រោះអត្ថថា មិនញាប់ញ័រ (**អកម្បនដ្ឋេន**) ។ ពលៈ ដែលកើតឡើងដល់អ្នកចម្រើនពោជ្ឈង្គៈ ៧ ដោយវីរិយៈជាប្រធាន ឈ្មោះថា **ភាវនាពលៈ** ។ ធម៌ដែលឈ្មោះថា **សមថៈ** ព្រោះញុំាងធម៌ជាសត្រូវឱ្យស្ងប់ * ។ ធម៌ឈ្មោះថា **វិបស្សនា** ព្រោះឃើញដោយអាការផ្សេងៗ ដោយអំណាចនៃការមិនទៀងជាដើម

---

* បច្ចនីកធម្មេ សមេតីតិ សមថោ ។

* សមថៈនោះឯង ឈ្មោះថា **សមថនិមិត្ត** ដោយអំណាចនៃនិមិត្តរបស់សមថៈមុន ដែលព្រះយោគាវចរកាន់យកអាការនោះ ហើយឱ្យប្រព្រឹត្តទៅទៀត ។ សូម្បីក្នុងបគ្គាហនិមិត្ត ក៏ន័យនេះដែរ ។ ធម៌ដែលឈ្មោះថា **បគ្គាហៈ** ព្រោះផ្គងសម្បយុត្តធម៌ទុក ។ ឈ្មោះថា **អវិក្ខេបៈ** ព្រោះមិនរាយមាយ ។ ការវិនាសសីល គឺការមិនសង្រួមដែលញ៉ាំងសីលឱ្យវិនាស ឈ្មោះថា **សីលវិបត្តិ** ។ ការវិនាសនៃទិដ្ឋិ គឺមិច្ឆាទិដ្ឋិដែលញ៉ាំងសម្មាទិដ្ឋិឱ្យវិនាស ឈ្មោះថា **ទិដ្ឋិវិបត្តិ** ។ ការដល់ព្រមដោយសីល ឈ្មោះថា **សីលសម្បទា** ព្រោះញ៉ាំងការត្រេកអរឱ្យដល់ព្រមដោយសីល គឺឱ្យបរិបូណ៌ដោយសីលនោះឯង ។ ញាណដែលបរិបូរណ៍ដោយទិដ្ឋិ ជាការដល់ព្រមដោយទិដ្ឋិ ឈ្មោះថា **ទិដ្ឋិសម្បទា** ។ ការហ្មត់ចត់នៃសីលពោលគឺសីលដែលដល់ភាពបរិសុទ្ធ ឈ្មោះថា **សីលបរិសុទ្ធិ** ។ ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ព្រោះអាចដើម្បីសម្រេចវិសុទ្ធិ គឺព្រះនិព្វាន ជាការហ្មត់ចត់នៃទិដ្ឋិពោលគឺការឃើញ ។ បទថា **"ទិដ្ឋិវិសុទ្ធិ ខោ បន"** និង **"យថា ទិដ្ឋស្ស ច បធានំ"** បានដល់ ទិដ្ឋិវិសុទ្ធិ គឺកម្មស្សកតាញាណជាដើម និងការព្យាយាមដែលសម្បយុត្តដោយទិដ្ឋិវិសុទ្ធិនោះៗ ឯង របស់បុគ្គលអ្នកមានការឃើញត្រូវ មានការឃើញដ៏សមរម្យ មានការឃើញដ៏ល្អ ។

**ការសង្វេគ ពោលគឺការខ្លាច (ភ័យ) ដែលកើតឡើង ព្រោះអាស្រ័យ**

---

* អនិច្ចាទិវសេន វិវិធេន អាការេន បស្សតីតិ វិបស្សា ។

ហេតុ មានជាតិជាដើម ឈ្មោះថា **សំវេគ** * ។ ហេតុមានជាតិជាដើម ដែលញុំាងការតក់ស្លុតឱ្យកើតឡើង ឈ្មោះថា **សំវេជនីយដ្ឋាន** ។ ការព្យាយាមជារបស់អ្នកមានចិត្តតក់ស្លុត ដែលកើតឡើងហើយយ៉ាងនេះ ឈ្មោះថា **ការព្យាយាមដោយឧបាយរបស់អ្នកមានចិត្តតក់ស្លុត** ។ ភាពជាអ្នកមិនសន្តោសក្នុងការបំពេញកុសលធម៌ ឈ្មោះថា ការមិនត្រេកអរក្នុងកុសលធម៌ ។ ការមិនថយត្រឡប់ និងមិនទម្រន់ក្នុងការប្រឹងប្រែង ដែលនៅមិនសម្រេចព្រះអរហត្តឈ្មោះថា ធម៌ដែលមិនធ្វើការទម្រន់ក្នុងសេចក្តីព្យាយាម ។ ឈ្មោះថា **វិជ្ជា** ព្រោះដឹងច្បាស់ (**វិជ្ជាននតោ**) ។ ឈ្មោះថា **វិមុត្តិ** ព្រោះរួចផុត * ។ ញាណក្នុងអរិយមគ្គដែលធ្វើការអស់កិលេស ឈ្មោះថា **ខយេ ញាណំ** = ញាណក្នុងការអស់កិលេស ។ ញាណក្នុងអរិយផល ដែលកើតឡើងក្នុងទីបំផុតនៃការមិនកើតឡើងនៃកិលេសដែលមគ្គនោះៗ គប្បីសម្លាប់ ជាញាណដែលមិនកើតឡើងដោយអំណាចនៃបដិសន្ធិ ឈ្មោះថា **អនុប្បាទេ ញាណំ** = ញាណក្នុងការមិនកើតឡើង ។

## ចប់អដ្ឋកថាមាតិកានុបុព្វបទ

---

* សង្វេគោតិ ជាតិអាទីនិ បដិច្ច ឧប្បន្នភយសង្ខាតំ សំវេជនំ ។

* អដ្ឋ. យោ. ការរួចផុត គឺរួចដ៏ក្រៃលែងពីអារម្មណ៍ទាំងឡាយ ឈ្មោះថា **វិមុត្តិ** បានដល់សមាបត្តិ ៨ ។ ការរួចផុតចាកកិលេសទាំងឡាយផង ចាកសង្ខារទាំងឡាយផង ឈ្មោះថា **វិមុត្តិ** បានដល់ ព្រះនិព្វាន ។ រួមសេចក្តីទៅថា **វិមុត្តិ** (ក្នុងសមាបត្តិ ៨) ផង **វិមុត្តិ** (ក្នុងព្រះនិព្វាន) ផង ឈ្មោះថា **វិមុត្តិ** ។

# អដ្ឋកថាកាមាវចរកុសល

# អធិប្បាយ

# បទភាជនិយនៃកាមាវចរកុសល

ឥឡូវនេះ ដើម្បីសម្ដែងធម៌ទាំងឡាយ ដែលទ្រង់រួបរួមទុកដោយមាតិកា (មេបទ) តាមដែលទ្រង់តាំងទុកដោយប្រភេទផ្សេងៗ ទើបផ្ដើមបទភាជនិយនេះថា "**កតមេ ធម្មា កុសលា** = ធម៌ជាកុសលតើដូចម្ដេច" ជាដើម ។

ក្នុងបទភាជនិយនោះ កាមាវចរកុសលណា ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកគ្រាដំបូងថា "កាមាវចរកុសលចិត្តកើតឡើងក្នុងសម័យណា" ក្នុងនិទ្ទេសនៃកាមាវចរកុសលនោះ មានមហាវារៈ ៣ គឺ

-**ធម្មវវត្ថានវារៈ** វារៈថាដោយការកំណត់ធម៌

-**សង្គហវារៈ** វារៈថាដោយការរួបរួម

-**សុញ្ញតវារៈ** វារៈថាដោយសេចក្ដីសូន្យទទេ ។

បណ្ដាវារៈទាំង ៣ នោះ **ធម្មវវត្ថានវារៈ** ទ្រង់តាំងទុក ២ យ៉ាង ដោយអំណាចនៃឧទ្ទេសវារៈ និងនិទ្ទេសវារៈ; បណ្ដាឧទ្ទេសវារៈ និងនិទ្ទេសវារៈទាំង ២ នោះ **ឧទ្ទេសវារៈ**មាន ៤ បរិច្ឆេទ (ផ្នែក) គឺបុច្ឆា, សមយនិទ្ទេស, ធម្មនិទ្ទេស និងអប្បមាណា ។ បណ្ដាឧទ្ទេសវារៈ ៤ បរិច្ឆេទនោះ បរិច្ឆេទថា "**កតមេ ធម្មា កុសលា**" នេះ ឈ្មោះថា **បុច្ឆា** ។ បរិច្ឆេទថា "**យស្មឹ សមយេ កាមាវចរំ**

**កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ។ ល ។ តស្មិំ សមយេ** = កាមាវចរកុសលចិត្តកើតឡើងក្នុងសម័យណា ។ ល ។ ក្នុងសម័យនោះ” នេះឈ្មោះថា **សមយនិទ្ទេស** (សម្ដែងវេលា) ។ បរិច្ឆេទថា “**ផស្សោ ហោតិ ។ ល ។ អវិក្ខេបោ ហោតិ** = ផស្សៈរមែងមាន ។ ល ។ សេចក្ដីមិនរាយមាយរមែងមាន” នេះឈ្មោះថា **ធម្មនិទ្ទេស** (សម្ដែងអំពីធម៌) ។ បរិច្ឆេទថា ឬក៏ថា “អរូបធម៌ទាំងឡាយដែលអាស្រ័យគ្នាហើយកើតឡើង សូម្បីយ៉ាងដទៃណា មានក្នុងសម័យនោះ ធម៌ពួកនេះជាកុសល” នេះឈ្មោះថា **អប្បនា** (ឈាន)៕

## សម្ដែងអំពីពាក្យបុច្ឆា ៥ យ៉ាង

បរិច្ឆេទសម្ដែងអំពីពាក្យសួរទីមួយរបស់ឧទ្ទេសវារៈតាំងទុក ៤ បរិច្ឆេទយ៉ាងនេះ ដូចនេះ ៖-

បណ្ដាបរិច្ឆេទសម្ដែងអំពីពាក្យសួរនោះ បរិច្ឆេទថា “កុសលធម៌ តើដូចម្ដេច?” នេះឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។ ពិតមែន ពាក្យសួរ មាន ៥ យ៉ាង គឺ

**~អទិដ្ឋជោតនាបុច្ឆា** សួរដើម្បីឱ្យយល់នូវវត្ថុ (រឿង) ដែលខ្លួនមិនទាន់យល់ ។

**-ទិដ្ឋសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបជាមួយនឹងវត្ថុដែលខ្លួនបានដឹងហើយ ។

**-វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់នូវសេចក្ដីសង្ស័យ

**-អនុមតិបុច្ឆា** សួរដើម្បីការឃើញដោយប្រពៃ

**-កថេតុកម្យតាបុច្ឆា** សួរដើម្បីប្រាថ្នានឹងឆ្លើយតបដោយខ្លួនឯង ។

ពាក្យសួរទាំងនោះ មានសេចក្ដីប្លែកផ្សេងគ្នាដូច្នេះ ៖-

**អទិដ្ឋជោតនាបុច្ឆា**[១០៦] តើដូចម្ដេច?

ដោយប្រក្រតី (ធម្មតា) លក្ខណៈបញ្ហាណាដែលខ្លួនមិនបានដឹង មិនបានឃើញ មិនបានពិចារណា មិនបានត្រិះរិះ មិនជាក់ច្បាស់ នៅមិនទាន់ជាក់ច្បាស់ បុគ្គលរមែងសួរបញ្ហានៃលក្ខណៈនោះ ដើម្បីការដឹង ដើម្បីឃើញ ដើម្បីពិចារណា ដើម្បីត្រិះរិះ ដើម្បីជាក់ច្បាស់ ដើម្បីឱ្យបានច្បាស់លាស់ នេះឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

**ទិដ្ឋសំសន្ទនាបុច្ឆា** តើដូចម្ដេច?

ដោយប្រក្រតី លក្ខណៈបញ្ហាណាដែលដឹងហើយ ឃើញហើយ ពិចារណាហើយ ត្រិះរិះហើយ ជាក់ច្បាស់ហើយ ធ្វើឱ្យជាក់ច្បាស់ហើយ បុគ្គលរមែងសួរនូវ

---

[១០៦] ខុ. មហា. (តុវដ្ដកសុត្តនិទ្ទេស), ខុ. ចូឡ. (បុណ្ណកមានវបញ្ហានិទ្ទេស) ។

បញ្ហាដើម្បីប្រៀបធៀបជាមួយនឹងបណ្ឌិតពួកដទៃ នេះឈ្មោះថា **ទិដ្ឋសំសន្ទនាបុច្ឆា** ។

**វិមតិច្ឆេទនាបុច្ឆា** តើដូចម្ដេច?

ដោយប្រក្រតី បុគ្គលដែលមានសេចក្ដីសង្ស័យក្នុងចិត្ត មានការយល់ ២ ចំណុចថា "យ៉ាងនេះ ឬហ្ន៎?, មិនមែនឬហ្ន៎?, អ្វីហ្ន៎?, យ៉ាងណាហ្ន៎?" ។ គេរមែងសួរបញ្ហា ដើម្បីត្រូវការកាត់នូវសេចក្ដីសង្ស័យនេះចេញ ឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** ។

**អនុមតិបុច្ឆា** តើដូចម្ដេច?

ព្រះមានព្រះភាគ រមែងត្រាស់សួរបញ្ហា ដើម្បីការឃើញដ៏ប្រពៃ របស់ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នករមែងសម្គាល់សេចក្ដីក្នុងបញ្ហានោះដូចម្ដេច រូបទៀង ឬមិនទៀង?" ។ មិនទៀងទេព្រះអង្គ ។ ក៏របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ? ។ ជាទុក្ខព្រះអង្គ ។ ក៏របស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា គួរឬហ្ន៎ ដើម្បីពិចារណាឃើញរបស់នោះថា "នោះជារបស់យើង, នោះជាយើង, នោះជាអត្តារបស់យើង"[១០៧] ។ បញ្ហានោះ មិនគួរឡើយព្រះអង្គ នេះឈ្មោះថា **អនុមតិបុច្ឆា** ។

---

[១០៧] វិនយ., សំ. ខ. ។

**ករថេតុកម្យតាបុច្ឆា** តើដូចម្ដេច?

ព្រះមានព្រះភាគ រមែងត្រាស់សួរបញ្ហា ដើម្បីប្រាថ្នានឹងត្រាស់ដល់ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤, ក៏សតិប្បដ្ឋាន ៤ នេះតើដូម្ដេច?"[១០៨] នេះឈ្មោះថា **ករថេតុកម្យតាបុច្ឆា** ។

បណ្ដាពាក្យបុច្ឆាទាំង ៥ នោះ ពាក្យសួរ ៣ ខាងដើម មិនមានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយឡើយ ។ ព្រោះហេតុអ្វី? ។ ព្រោះធមិណា១ ដែលបច្ច័យប្រជុំតាក់តែងហើយក្នុងកាលទាំង ៣ ឬផុតចាកកាលជាអសង្ខតៈ ដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនទ្រង់ឃើញហើយ មិនទ្រង់ដឹងហើយ មិនទ្រង់ជ្រាបហើយ មិនពិចារណា មិនត្រិះរិះ មិនជាក់ច្បាស់ មិនច្បាស់លាស់ហើយ មិនមានឡើយ ។ ព្រោះហេតុនោះ **អទិដ្ឋជោតនាបុច្ឆា** ទើបមិនមានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយនោះ; ក៏ធម្មជាតិណាដែលព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយដោយព្រះញាណរបស់ព្រះអង្គ កិច្ចដែលនឹងត្រូវប្រៀបធៀបរបស់ធម្មជាតិនោះជាមួយនឹងអ្នកដទៃ ទោះជាសមណៈ ឬព្រាហ្មណ៍ ឬទេវតា ឬមារ ឬព្រហ្ម រមែងមិនមាន ។ ព្រោះហេតុនោះ **ទិដ្ឋសំសន្ទនាបុច្ឆា** របស់ព្រះមានព្រះភាគទើបមិនមាន ក៏ព្រោះព្រះមានព្រះភាគមិនមានសេចក្ដីសង្ស័យ ទ្រង់កន្លងផុត

---

[១០៨] ទី. ម. ។

វិចិកិច្ឆាហើយ មានសេចក្ដីសង្ស័យកំចាត់បានហើយក្នុងធម៌ទាំងពួង; ព្រោះហេតុដូច្នោះ ទើបមិនមានវិមតិឆេទនាបុច្ឆារបស់ព្រះអង្គ ។ ប៉ុន្តែថា បុច្ឆា ២ ក្រៅពីនេះ មានដល់ព្រះមានព្រះភាគ ។ ក្នុងបុច្ឆាទាំង ២ នោះ គប្បីជ្រាប **កតមេ ធម្មា កុសលា** ដូចនេះថាជាកថេតុកម្យតាបុច្ឆា តទៅ ៖-

បណ្ដាបទទាំងនោះ ព្រះមានព្រះភាគ រមែងត្រាស់សួរក្នុងធម៌ដែលទ្រង់លើកឡើងសម្ដែងដោយបទថា "**កតមេ**" ព្រោះថា ដោយពាក្យត្រឹមតែថា "**ធម្មា កុសលា**" នរណាៗ ក៏មិនអាចដើម្បីនឹងដឹងបានថា "ធ្វើអ្វីហើយ ឬថារមែងធ្វើអ្វី" ប៉ុន្តែកាលត្រាស់ពាក្យថា "**កតមេ**" ដូច្នេះហើយ សេចក្ដីនៃធម៌ដែលព្រះព្រះអង្គ គប្បីលើកឡើងសម្ដែងទាំងនោះមកសួរហើយ ក៏រមែងប្រាកដ; ដោយហេតុនោះ ទើបពោលថា "ព្រះមានព្រះភាគរមែងត្រាស់សួរក្នុងធម៌ដែលទ្រង់លើកឡើងសម្ដែង ដោយបទថា "**កតមេ**" ។ រមែងទ្រង់សម្ដែងធម៌ដែលត្រាស់សួរដោយពាក្យពីរបទថា "**ធម្មា កុសលា**" សេចក្ដីនៃធម៌ទាំងនោះ ទ្រង់ប្រកាសទុកហើយក្នុងខាងក្រោយមែនពិត ។

សួរថា ក៏ព្រោះហេតុអ្វី ក្នុងទីនេះ មិនត្រាស់ពាក្យថា "**កុសលា ធម្មា**" ដូចមាតិកា, បែរជាត្រាស់ធ្វើទៅតាមលំដាប់នៃបទថា "**ធម្មា កុសលា**" ទៅវិញ? ឆ្លើយថា ដើម្បីសម្ដែងទេសនានៃធម៌ទាំងឡាយ ដោយប្រភេទហើយ

សម្តែងធម៌មានប្រភេទផ្សេងៗ ។ ព្រោះថា ក្នុងអភិធម្មនេះ គប្បីសម្តែងធម៌សុទ្ធៗ ក៏ធម៌ទាំងនោះ មានប្រភេទមិនមែនតិច មានប្រភេទផ្សេងៗ មានកុសលាជាដើម; ព្រោះហេតុដូច្នោះ ក្នុងអភិធម្មនេះ គប្បីសម្តែងធម៌ទាំងឡាយប៉ុណ្ណោះ; ទេសនានេះ មិនមែនសម្តែងដោយវោហារ, ប៉ុន្តែធម៌ទាំងនោះ គប្បីសម្តែងប្រភេទផ្សេងៗ មិនមែនតិច, មិនមែនសម្តែងត្រឹមតែធម៌ទេ ព្រោះទេសនាដោយប្រភេទផ្សេងៗ រមែងនាំមកនូវញាណក្នុងការបំបែកនូវដុំសំណុំ និងញាណក្នុងបដិសម្ភិទា ។ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាទ្រង់សម្តែងទេសនានៃធម៌ទាំងឡាយ ដោយប្រភេទថា **“កុសលា ធម្មា”** ដូច្នេះហើយ, ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ពួកណា ក៏ដើម្បីសម្តែងនូវធម៌ពួកនោះ ដោយប្រភេទនោះៗ ទើបទ្រង់ធ្វើលំដាប់បទនេះថា **“កតមេ ធម្មា កុសលា”** ព្រោះថា កាលបើប្រភេទនៃធម៌ទាំងឡាយដែលទ្រង់សម្តែងហើយ ប្រភេទនៃធម៌ដែលសត្វកំពុងឃើញ រមែងត្រឹមត្រូវ និងគប្បីដឹងបានងាយ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ”** នេះតទៅ៖-

## សម្តែងអំពីសមយសព្ទ

**សមយេ និទ្ទិសិ ចិត្តំ ចិត្តេន សមយំ មុនិ**

**និយមេត្វាន ទីបេតុំ ធម្មេ តត្ថ បភេទតោ**

**ព្រះមានព្រះភាគព្រះអង្គជាមុនី ទ្រង់សម្តែងចិត្តក្នុងសម័យ ដើម្បីកំណត់សម័យដោយចិត្តហើយ សម្តែងនូវធម៌ទាំងឡាយ ដោយប្រភេទក្នុងសម័យនោះ ។**

ពិតមែនហើយ ព្រះមានព្រះភាគកាលទ្រង់សម្តែងថា "ក្នុងសម័យណា កាមាវចរចិត្ត" ជាដើម, ក៏ទ្រង់សម្តែងចិត្តក្នុងសម័យនោះ ។ ព្រោះហេតុអ្វី? ព្រោះទ្រង់កំណត់សម័យយ៉ាងនេះថា "**តស្មឹ សមយេ**" ក្នុងកាលជាទីបំផុតដោយចិត្តដែលកំណត់សម័យនោះ លំដាប់នោះ ដើម្បីឱ្យត្រាស់ដឹងនូវធម៌ទាំងឡាយ មានផស្សៈ និងវេទនាជាដើម ដែលជាប្រភេទត្រាស់ដឹងតាមបានសែនលំបាក ដោយអំណាចនៃឃនៈ (ដុំ), ដោយសន្តតិ (តំណ), **សមូហៈ** (ប្រជុំ), **កិច្ច អារម្មណ៍ទាំងនោះ ក្នុងសម័យដែលទ្រង់កំណត់ដោយចិត្តនោះ យ៉ាង**នេះថា សូម្បីកាលមានសម័យផ្សេងគ្នា បើសម័យណាមានចិត្ត, សម័យនោះឯងផស្សៈក៏មាន, វេទនាក៏មាន ។

ឥឡូវនេះ គប្បីជ្រាបការពណ៌នាតាមបទក្នុងពាក្យវិនិច្ឆ័យថា "**យស្មឹ សមយេ**" ជាដើមនេះតទៅ ៖-

បទថា "**យស្មឹ**" ជាអត្ថសម្តែងដល់សត្តមីវិភត្តិ ដោយមិនប្រាកដ ។

បទថា "**សមយេ**" ជាពាក្យសម្តែងដល់សម័យ ដែលសម្តែងទុកដោយ

មិនកំណត់ ។ សម័យទ្រង់សម្ដែងដោយមិនកំណត់ទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ក្នុងពាក្យថា សម័យនោះ សមយសទ្ទ លោកប្រើក្នុងអត្ថថា ព្រមព្រៀង, ក្នុងខណៈ, ក្នុងកាល, ក្នុងការប្រជុំ, ក្នុងហេតុ, ក្នុងទិដ្ឋិ, ការបានចំពោះ, ការលះ, ការត្រាស់ដឹង ។

ពិតយ៉ាងនោះមែន **សមយសទ្ទ** នោះ ប្រើក្នុងន័យសេចក្ដីថា **ការព្រមព្រៀង** ដូចក្នុងប្រយោគមានអាទិ៍យ៉ាងនេះថា "ធ្វើម្ដេចទៅ ស្អែកនេះពួកយើងត្រិះរិះពិចារណានូវកាល និងការ**ព្រមព្រៀងគ្នា** ហើយគប្បីចូលទៅរក[១០៩]" ។ ប្រើក្នុងន័យសេចក្ដីថា **ខណៈ** ដូចក្នុងប្រយោគជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ ខណៈ (ឱកាស) និងសម័យក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មានប្រការមួយ" ។ ប្រើក្នុងន័យសេចក្ដីថា **កាល** (វេលា) ដូចក្នុងប្រយោគមានជាអាទិ៍ថា "រដូវក្ដៅជា **វេលា** ក្ដៅខ្លាំង" ។ ប្រើក្នុងសេចក្ដីថា **ប្រជុំ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "ការប្រជុំធំ មានក្នុងព្រៃធំ" ។ ប្រើក្នុងសេចក្ដីថា **ហេតុ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "ម្នាលភទ្ទាលិ ហេតុដែលអ្នកត្រូវត្រាស់ដឹងថា ព្រះមានព្រះភាគប្រថាប់នៅឯព្រះនគរសាវត្ថី, សូម្បីព្រះមានព្រះភាគ ក៏នឹងទ្រង់ជ្រាបយើងថា

---

[១០៩] ទី. សី. ។

'ភិក្ខុឈ្មោះភទ្ទាលិ មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា' ដូចនេះ ម្នាលភទ្ទាលិ ហេតុនេះឯង អ្នកក៏មិនត្រាស់ដឹងបាន" [១១០] ។ ប្រើក្នុងសេចក្តីថា **ឪដ្ឋិ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "ក៏គ្រានោះឯង បរិព្វាជកឈ្មោះឧគ្គាហមានៈ ជាបុត្ររបស់នាងសមណមុណ្ឌិកា អាស្រ័យនៅក្នុងអារាមរបស់នាងមល្លិកាទេវី ដែលមានសាលាមួយខ្នង ឡោមពទ្ធទៅដោយជួរដើមទម្លាប់ ជាទីប្រជុំសម្តែងឫទ្ធិ"[១១១] ។ ប្រើក្នុងសេចក្តីថា ការបានចំពោះ ដូចក្នុងប្រយោគមានជាអាទិ៍ថា **"អ្នកប្រាជ្ញលោកហៅថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ក្នុងភពនេះ និងប្រយោជន៍ក្នុងភពខាងមុខ"** [១១២] ។

ប្រើក្នុងសេចក្តីថា **លះបង់** ដូចក្នុងប្រយោគមានជាអាទិ៍ថា "ភិក្ខុបានធ្វើទីបំផុតនៃទុក្ខបានហើយ ព្រោះលះបង់មានៈដោយប្រពៃ" [១១៣]។ ប្រើក្នុងសេចក្តីថា **ការត្រាស់ដឹង** ដូចក្នុងប្រយោគមានជាអាទិ៍ថា "សភាពនៃទុក្ខមានអត្ថថា បៀតបៀន, មានអត្ថថា ប្រជុំតាក់តែង, មានអត្ថថា ធ្វើឱ្យក្តៅក្រហាយ,

---

[១១០] អំ. អដ្ឋក. ។

[១១១] វិនយ. ។

[១១២] វិនយ. ។

[១១៣] ម. មូ. ។

មានអត្ថថា ប្រែប្រួល និងមានអត្ថថា គួរត្រាស់ដឹង”[១១៤] ក្នុងសមយសព្ទ មានអត្ថជាអនេក ដោយប្រការដូច្នេះ ។

**សមយោ ខណោ កាលោ សមូហោ ហេតុយេវ ច**
**ឯតេ បញ្ចាបិ វិញ្ញេយ្យា សមយា ឥធ វិញ្ញុនា**

សមយសព្ទ ក្នុងអធិការនេះ គប្បីជ្រាបថា មានត្រឹមតែ ៥ គឺ
ការព្រមព្រៀង ១ ខណៈ ១ កាល ១ ប្រជុំ ១ និងហេតុ ១។

ពិតមែនហើយ បណ្ដាសមយសព្ទទាំង ៩ យ៉ាងនោះ ក្នុងអធិការ ពោល ដោយកុសលនេះថា **“យស្មិំ សមយេ កាមាវចរំ កុសលំ”** , បណ្ឌិតគប្បី ជ្រាបសមយសព្ទ ៥ មានការព្រមព្រៀងជាដើមតទៅ ៖-

បណ្ដាសមយសព្ទទាំងនោះ ការព្រមព្រៀងនៃបច្ច័យ គប្បីជ្រាប ថា ការព្រមព្រៀង, ចំណែកសមយសព្ទ ដែលជាអត្ថ បញ្ហាទី ៩ (ការ ត្រាស់ដឹង ) គប្បីជ្រាបថា ជាខណៈមួយ;ម្យ៉ាងទៀត សូម្បីចក្កៈទាំង ៤ ក៏គប្បីជ្រាបថាជាខណៈ ។

ព្រោះថា ការព្រមព្រៀងនៃបច្ច័យទាំងឡាយ ដែលតាំងនៅដោយសេចក្ដី ជាហេតុ ដែលញ៉ាំងផលទូទៅឱ្យសម្រេចនោះ បណ្ឌិតគប្បីជ្រាបថា ជាការព្រម

---

[១១៤] ខុ. បដិ. ។

ព្រៀងក្នុងទីនេះ ។ ចំណែកសមយសព្ទ ជាអត្ថទី ៩ ដែលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យក្នុងការប្រព្រឹត្តិព្រហ្មចរិយៈមានប្រការមួយ” [១១៥] គប្បីជ្រាបថា “ខណៈមួយ” ។ ម្យ៉ាងវិញទៀត ចក្កៈ (ការដល់ព្រម) ៤ គឺ

**១- បដិរូបទេសវាសោ** ការនៅក្នុងប្រទេសដ៏សមគួរ

**២- សប្បុរិសូបសំសេវ** ការសេពគប់នឹងសប្បុរស

**៣- អត្តសម្មាបណិធិ** ការតម្កល់ខ្លួនទុកដោយប្រពៃ

**៤- បុព្វេកតបុញ្ញតា** ភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ ក្នុងកាលមុន [១១៦] ។

ដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងបាលីថា “ម្នាលភិក្ខុទាំងឡាយ ចក្កៈ ៤ ប្រការ ជាគ្រឿងដំណើរទៅរបស់ទេវតា និងមនុស្សទាំងឡាយ ជាអ្នកប្រកបព្រមហើយដោយចក្កៈទាំងឡាយណា, ចក្កៈទាំងឡាយនោះមាន ៤” គប្បីជ្រាបថា ជាខណៈដោយអត្ថថា ជាឱកាសរួមនៃចក្កៈទាំង ៤ នោះដូចគ្នា ។ ព្រោះថា ចក្កៈទាំង ៤ នោះ ជាឱកាសក្នុងការញុំាងកុសល ឱ្យកើតឡើង ។ គ្រាជ្រាប

---

[១១៥] អំ. អដ្ឋក. ។

[១១៦] អំ. ចតុក្ក. ។

សមយសព្ទ គឺការព្រមព្រៀង និងខណៈយ៉ាងនេះហើយ បណ្ឌិតគប្បីជ្រាបថា ពាក្យពន្យល់បញ្ជាក់ ក្នុងសមយសព្ទទាំងឡាយ មានកាលជាដើម ទាំងនេះតទៅ ៖-

**បញ្ញត្តិ ឈ្មោះថា កាល ព្រោះអាស្រ័យធម៌នោះៗ, ក៏កាលនោះ ត្រឹមតែជាវោហារ (មិនមែនបរមត្ថ) គំនរនៃធម៌មានផស្សៈជាដើម គប្បីជ្រាបថា ជាការព្រមព្រៀង (សមូហៈ) ។**

បញ្ញត្តិ ឈ្មោះថា **កាល** ព្រោះអាស្រ័យធម៌នោះៗ យ៉ាងនេះ គឺព្រោះអាស្រ័យធម៌ទាំងឡាយ ដោយន័យជាដើមថា "**ចិត្តកាលោ** = កាលនៃចិត្ត, **រូបកាលោ** = កាលនៃរូប" ឬព្រោះអាស្រ័យការប្រព្រឹត្តធម៌ ដោយន័យជាដើមថា "អតីតធម៌ អនាគតធម៌" , ឬព្រោះអាស្រ័យលំដាប់នៃធម៌ ដោយន័យជាដើមថា "កាលនេះជាកាលនៃពូជ, កាលនេះជាកាលនៃពន្លក" , ឬព្រោះអាស្រ័យលក្ខណៈនៃធម៌ ដោយន័យជាដើមថា "នេះជាកាលកើត, នេះជាកាលចាស់" , ឬព្រោះអាស្រ័យកិច្ចនៃធម៌ ដោយន័យជាដើមថា "ជាកាលដែលសោយនូវអារម្មណ៍ ជាកាលដែលចាំនូវអារម្មណ៍" , ឬព្រោះអាស្រ័យកិច្ចដែលសត្វត្រូវធ្វើ ដោយន័យជាដើមថា "នេះជាកាលងូតទឹក នេះជាកាលផឹកទឹក" , ឬព្រោះអាស្រ័យឥរិយាបថ ដោយន័យជាដើមថា "កាលដែលដើរ កាលដែល

ឃរ” , ឬព្រោះអាស្រ័យ ការវិលទៅរបស់ព្រះចន្ទ្រ និងព្រះអាទិត្យ ដោយន័យជាដើមថា “កាល (វេលា) ព្រឹក ល្ងាច ពេលថ្ងៃ ពេលយប់” , ឬព្រោះអាស្រ័យការប្រជុំនៃកាល ពោលគឺពេលថ្ងៃ និងពេលយប់ជាដើម ដោយន័យជាដើមថា “កន្លះខែ, មួយខែ” ជាដើម ។

ក៏កាលនោះបណ្ឌិតគប្បីជ្រាបថា ត្រឹមតែជាបញ្ញត្តិប៉ុណ្ណោះ ព្រោះមិនមានសភាវៈ (សភាវៈរបស់ខ្លួន) ។ ចំណែកពួកនៃធម៌ទាំងឡាយមានផស្សៈ និងវេទនាជាដើមនោះ លោកពន្យល់បញ្ជាក់ថា “ជាការប្រជុំ (សមូហៈ)” ក្នុងអធិការនេះ ។ គ្រាជ្រាបសម័យ ដែលប្រើក្នុងពាក្យថា **កាល** និង**ការប្រជុំ** យ៉ាងនេះហើយ គប្បីជ្រាបសមយសព្ទដែលប្រើក្នុងសេចក្តីថា **ហេតុ** តទៅ ៖-

**ហេតូតិ បច្ចយោ ចេត្ថ*  តស្ស ទ្វារវសេន វា**
**អនេកភាវោបិ វិញ្ញេយ្យោ  បច្ចយានំ វសេន វា ។**

**ក៏ក្នុងសមយសព្ទនេះ បច្ច័យ ឈ្មោះថា ហេតុ បណ្ឌិតគប្បីជ្រាបសេចក្តីដែលហេតុនោះ មានច្រើនយ៉ាង សូម្បីតែដោយទ្វារ ឬដោយបច្ច័យទាំងឡាយ ។**

---

* ច្បាប់ខ្លះថា បច្ចយោវេត្ថ ។

ពិតមែនហើយ ក្នុងអធិការនេះ បច្ច័យនោះឯង ឈ្មោះថា **ហេតុ** បណ្ឌិតគប្បីជ្រាបសេចក្ដីដែលហេតុនោះមានច្រើនយ៉ាង ដោយអំណាចនៃទ្វារ ឬបច្ច័យទាំងឡាយ ។ គប្បីជ្រាបយ៉ាងណា? គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់បច្ច័យ ៤ មានចក្ខុ រូប អាលោកៈ មនសិការជាដើម នៃចក្ខុវិញ្ញាណជាដើម ដែលកើតឡើងក្នុងចក្ខុទ្វារជាដើម; និងត្រាស់បច្ច័យ ២៤ **ក្នុងមហាបករណ៍** ដោយន័យមានជាអាទិ៍ថា **"ហេតុប្បច្ចយោ"** ។ បណ្ដាបច្ច័យទាំងនោះ វៀរវិបាកប្បច្ច័យចេញហើយ បច្ច័យដែលនៅសល់ជាបច្ច័យ ដល់កុសលធម៌ទាំងឡាយនោះឯង ។ ប៉ុន្តែក្នុងអធិការនេះ លោកប្រាថ្នាយកធម៌ទាំងអស់នោះជាហេតុ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលហេតុនោះ ជាបច្ច័យច្រើនយ៉ាងដោយអំណាចនៃទ្វារនេះ ឬដោយអំណាចនៃបច្ច័យយ៉ាងនេះ អត្ថទាំង ៥ មានការព្រមព្រៀងជាដើមទាំងនេះ គប្បីជ្រាបថា លោកកំណត់ដោយសមយសព្ទ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

**សួរថា** ព្រោះហេតុអ្វី បណ្ដាអត្ថទាំងនោះ លោកមិនកំណត់យកអត្ថយ៉ាងណានីមួយតែម្យ៉ាងទេ, ប៉ុន្តែកំណត់យកទាំងអស់?

**ឆ្លើយថា** ព្រោះការសម្ដែងអត្ថ ដែលប្លែកផ្សេងគ្នានោះៗ ដោយ**សមយសព្ទ**នោះៗ រមែងមាន ។

ពិតមែនហើយ បណ្ដាសមយសព្ទទាំងនោះ សមយសព្ទ ពោលគឺ ការព្រមព្រៀង រមែងសម្ដែងដល់ការប្រព្រឹត្តទៅដោយហេតុមិនមែនតិច ដោយ**សមយ**សព្ទមួយនោះ រមែងមានការបដិសេធលទ្ធិដែលមានហេតុមួយ ។ ក៏ធម្មតាការព្រមព្រៀង រមែងឈានទៅដល់វត្ថុដែលអាស្រ័យគ្នានឹងគ្នា ក្នុងការញុំាងផលទូទៅឱ្យសម្រេច; ព្រោះហេតុដូច្នោះ ទើបលោកសម្ដែងអត្ថនេះថា “ឈ្មោះថា**អ្នកសាងមនុស្សម្នាក់ រមែងមិនមាន”** ។ ដោយសភាវៈ កាលអ្នកកសាងមាន ក៏មិនគួរសំឡឹងដល់ហេតុដទៃ ដោយលក្ខណៈយ៉ាងនេះ និងការបដិសេធនូវពាក្យមានជាអាទិ៍ថា “សុខ និងទុក្ខដែលខ្លួនធ្វើដោយខ្លួនឯង” ដោយសម្ដែងដល់សេចក្ដីមិនមានអ្នកធ្វើមនុស្សណាម្នាក់នោះ ។

ក្នុងពាក្យដែលពោលហើយនោះ ប្រសិនបើនឹងមានពាក្យជំទាស់ថា “ពាក្យណាដែលពោលហើយថា ‘រមែងសម្ដែងសេចក្ដីប្រព្រឹត្តទៅ ដោយហេតុមិនមែនតិច’ ពាក្យនោះ ក៏មិនត្រូវ មិនមែនទេឬ ព្រោះហេតុអ្វី? ព្រោះវត្ថុដែលមិនជាហេតុ មិនមាននៅក្នុងការព្រមព្រៀងគ្នា, សូម្បីក្នុងការព្រមព្រៀងក៏ជាហេតុមិនបាន; ពិតមែន កាលមនុស្សខ្វាក់ភ្នែកម្នាក់ មិនអាចមើលឃើញមនុស្សខ្វាក់ភ្នែកទាំងរយ ក៏រមែងមើលមិនឃើញ” ។

**ឆ្លើយថា** ដែលថាមិនត្រូវមិនគួរឡើយ, ព្រោះសេចក្ដីដែលហេតុញុំាងផល

ទូទៅឱ្យសម្រេចបានតាំងនៅហើយ, ឈ្មោះថា **ការព្រមព្រៀង** មិនមែនហេតុត្រឹមតែថា ការប្រជុំនៃហេតុមិនមែនតិចឡើយ ។ ក៏ផលទូទៅ ឈ្មោះថា ការឃើញរបស់បុគ្គលអ្នកខ្វាក់ភ្នែកទាំងឡាយមិនមានឡើយ ។ ព្រោះហេតុអ្វី? ព្រោះកាលបុគ្គលខ្វាក់ភ្នែកមានទាំងរយនាក់ ផលដោយទូទៅក៏មិនមាន, ក៏ផលដោយទូទៅនោះរបស់ចក្ខុជាដើមមាន, ព្រោះសេចក្ដីដែលធម៌មានចក្ខុវិញ្ញាណជាដើមនោះមាន ។

ម្យ៉ាងវិញទៀត ការមិនមានហេតុទាំងឡាយ ក្នុងការមិនព្រមព្រៀងជាហេតុ ក្នុងការព្រមព្រៀងសម្រេចបាន សេចក្ដីនេះគប្បីជ្រាបថា ព្រោះការមិនមានផលក្នុងការមិនព្រមព្រៀង, ប៉ុន្តែមានផលក្នុងការព្រមព្រៀង, ព្រោះថាកាលចក្ខុជាដើមបែកធ្លាយ ចក្ខុវិញ្ញាណក៏មិនបាន និងកាលចក្ខុជាដើម មិនបែកធ្លាយ ចក្ខុវិញ្ញាណទើបសម្រេចប្រចក្សដល់សត្វលោក នេះជាការសម្ដែងអត្ថដោយសមយសព្ទ គឺការព្រមព្រៀងជាមុនសិន ។

ចំណែកខណៈទី ៩ វៀរអខណៈទាំង ៨ លោកហៅថា ខណៈ ព្រោះអត្ថថា ជាឱកាស ពោលគឺចក្កៈ ៤ មានការនៅក្នុងប្រទេសដ៏សមគួរជាដើម; ខណៈនោះ វៀរចាកការព្រមព្រៀងនៃខណៈ គឺសេចក្ដីជាមនុស្ស, ការឧប្បត្តិឡើងនៃព្រះពុទ្ធជាម្ចាស់, ការស្ដាប់ព្រះសទ្ធម្ម មានសម្មាទិដ្ឋិជាដើម ក៏មិនមាន

និងសេចក្តីជាមនុស្សជាដើម ជាសភាវៈដែលបានដោយកម្រ, មានការឧបមាដោយអណ្តើកខ្វាក់ភ្នែក [១១៧] ជាដើម ។ កុសលដែលជាឧបការៈ ដល់លោកុត្តរធម៌ទាំងឡាយ ដែលប្រកបដោយខណៈ ដែលបានដោយសែនលំបាកពិតៗ, ព្រោះការដែលខណៈជារបស់រកបានដោយក្រ ដូចពណ៌នាមកដូច្នេះ ។

បណ្តាសមយសព្ទតាមដែលពោលហើយ សមយសព្ទ គឺខណៈ រមែងឆ្លុះដល់ភាពជារបស់បានដោយលំបាក ព្រោះជាការកើតនៃកុសល, ពោលដោយឋានដែលសម្តែងហើយយ៉ាងនេះ ។ ជាចំណែកដែលលោកបដិសេធការនៅដោយសេចក្តីប្រមាទរបស់ជនអ្នកបានខណៈហើយ ធ្វើខណៈឱ្យជាមោឃៈ ព្រោះការមិនញ៉ាំងកុសលនោះ ដែលប្រកបដោយខណៈឱ្យកើតឡើង; អត្ថនេះ លោកអធិប្បាយទុកដោយសមយសព្ទ ពោលគឺខណៈ ។

ក៏ធម្មតាថា ភាពនៃកុសលចិត្តនេះនោះ ជារបស់តូចពេកណាស់, ក៏កាលដែលកុសលចិត្តនោះជារបស់តូចពេកណាស់នោះ គប្បីជ្រាបដោយអំណាចនៃអដ្ឋកថាព្រះសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងថា ការឆាប់រហ័សរបស់ដួងចន្ទ និងដួងអាទិត្យ ឆាប់ជាងការឆាប់របស់បុរស, ទេវតាអ្នកនៅខាងមុខព្រះចន្ទ្រ និងព្រះអាទិត្យ ហៅថា ព្រះចន្ទ្រ និងព្រះអាទិត្យ, អាយុសង្ខារទាំង

---

[១១៧] ម. ឩ. ។

ឡាយ រមែងអស់ទៅឆាប់ជាងនោះ” ។ ពិតណាស់ សូត្រនេះ ព្រះភគវា ត្រាស់កាលតិចតួចរបស់រូបជីវិតិន្ទ្រិយសិន, រូបដែលកើតឡើងចំពោះ ហើយតាំង នៅត្រឹមណា, ចិត្ត ១៦ ដួងកើតឡើងហើយរលត់ត្រឹមនោះ; សូម្បីការឧបមា ដោយខដែលចិត្តទាំងឡាយនោះ ជារបស់តិចតួចដោយកាល រមែងមិនមាន ដោយប្រការដូច្នេះ; ដោយហេតុនោះឯង ព្រះភគវា ទើបត្រាស់ថា “ម្នាលភិក្ខុ ទាំងឡាយ ចិត្តនេះប្រព្រឹត្តទៅលឿនណាស់, សូម្បីការប្រៀបធៀប ក៏ធ្វើមិន ងាយធ្វើបាន”[១១៨] ។ បណ្ដាសមយសព្ទទាំងនោះ សមយសព្ទ ពោលគឺកាល រមែងសម្ដែងតិចតួចណាស់ របស់កាលដែលប្រព្រឹត្តទៅក្នុងកុសលចិត្ត ដោយ ប្រការដូច្នេះ ។ ពោលដោយឋានដែលទ្រង់សម្ដែងហើយយ៉ាងនេះ ជាឱវាទដែល ទ្រង់ប្រទានទុកថា “**ចិត្តនេះ ចាក់ធ្លុះបានដោយលំបាក ដូចការក្រងកែវ មុក្តាដោយពន្លឺភ្លីនៃផ្លេកបន្ទោរ ព្រោះការដែលចិត្តមានវេលាប្រព្រឹត្តទៅ តិចណាស់**; ព្រោះហេតុដូច្នោះ អ្នកទាំងឡាយគប្បីធ្វើសេចក្ដីឧស្សាហៈ ឱ្យច្រើន និងការអើពើឱ្យច្រើន ក្នុងការចាក់ធ្លុះចិត្តនេះ” ។ សេចក្ដីនេះសម្ដែងសមយសព្ទ គឺកាល ។

ចំណែកសមយសព្ទ ពោលគឺការប្រជុំ រមែងសម្ដែងការកើតឡើងព្រម

---

[១១៨] ឯកក. ។

គ្នានៃធម៌មិនមែនតិចតួចទេ; ពិតណាស់ កងនៃធម៌មានផស្សៈជាដើម លោកពោលទុកថា "ការប្រជុំ" ។ម្យ៉ាងទៀត ចិត្តកាលកើតឡើងក្នុងកងនៃធម៌នោះ ព្រមទាំងធម៌នោះ; ព្រោះហេតុដូច្នោះ លោកទើបសម្តែងការកើតឡើងព្រមគ្នានៃធម៌ទាំងឡាយមិនមែនតិច; ដោយឋានដែលសម្តែងហើយយ៉ាងនេះ ជាចំណែកដែលពោលសម្តែងបដិសេធការកើតឡើងនៃធម៌ដូចគ្នានោះឯង ។ សេចក្តីនេះ សម្តែងសមយសព្ទ ពោលគឺការប្រជុំ ។

ចំណែកសមយសព្ទ ពោលគឺហេតុ រមែងសម្តែងការប្រព្រឹត្តទៅ គឺប្រកបដោយធម៌ដទៃ ។ ពិតមែន ពាក្យថា "**យស្មឹ សមយេ**" មានអធិប្បាយថា កាលហេតុយ៉ាងណាមាន, កុសលក៏រមែងកើតឡើង; ទើបសម្តែងការដែលធម៌មានការប្រព្រឹត្តទៅដោយអាស្រ័យហេតុដទៃ ព្រោះមានហេតុដែលប្រព្រឹត្តទៅដោយឋានដែលសម្តែងហើយ យ៉ាងនេះ ទើបជាការបដិសេធការសម្គាល់ខុសថា ធម៌ទាំងឡាយប្រព្រឹត្តិទៅ តាមអំណាចនៃខ្លួនបាន ។ សេចក្តីនេះ សម្តែងការប្រព្រឹត្តទៅបានដោយសមយសព្ទ ពោលគឺហេតុ ។

បណ្តាបទទាំងនោះ បទថា "**យស្មឹ សមយេ**" អធិប្បាយថា ក្នុងកាលណាដោយអំណាចនៃសមយសព្ទ ពោលគឺកាល ។ គប្បីជ្រាបសេចក្តីនៃសមយសព្ទ គឺការប្រជុំនៃបទថា **យស្មឹ សមយេ** នេះ បានដល់ បណ្តា

សមយសព្ទទាំងឡាយ គឺខណៈ ការព្រមព្រៀង និងហេតុ គឺកាលបើខណៈណាមាន, កាលបើការព្រមព្រៀងណាមាន, កាលបើហេតុណាមាន, កាមាវចរកុសលចិត្ត រមែងកើតឡើង, កាលកាមាវចរកុសលចិត្តនោះៗ ឯង មានហើយ ធម៌ទាំងឡាយសូម្បីមានផស្សៈជាដើម ក៏កើតឡើងដែរ ។ ព្រោះថា សមយសព្ទ ពោលគឺកាល និងការប្រជុំជាអធិករណៈ (ជាអាធារសត្តមីវិភត្តិ ឱ្យប្រែថា ក្នុង) ។

បណ្ដាបទទាំងនោះ បទថា **“ទុត្តធម្មានំ”** នេះ ជាសត្តមីវិភត្តិ ដោយអំណាចនៃអធិករណៈ; អធិប្បាយថា ភាវៈក្នុងធម៌ទាំងនោះ គប្បីកំណត់ដោយភាវៈនៃសមយសព្ទ ពោលគឺខណៈ ការព្រមព្រៀង និងហេតុ; ព្រោះហេតុដូច្នោះ ក្នុងពាក្យថា **ទុត្តធម្មានំ** នេះ ទើបជាសត្តមីវិភត្តិ ដោយអំណាចនៃការកំណត់ភាវៈ ដោយភាវៈ ៕

## អធិប្បាយពាក្យថា កាមាវចរ

បទថា **កាមាវចរ** បានដល់ ចិត្តដែលរាប់បញ្ចូលក្នុងកាមាវចរធម៌ទាំងឡាយ ដែលត្រាស់ទុកដោយន័យជាដើមថា “ធម៌ជាកាមាវចរតើដូចម្ដេច?” ។ គឺខាងក្រោមមានអវេចីនរក* ជាទីបំផុត, ខាងលើមានសួគ៌ជាន់បរនិម្មិតវសវត្តី

---

* ពាក្យនេះ ហៅថា អវិចី ក៏បាន ។

ជាទីបំផុត[១១៩] ។

ក្នុងកាមាវចរនេះ មានវចនត្ថៈ (សេចក្តីនៃពាក្យ) ដូចតទៅ ៖-

ពោលដោយឧទាន (សង្ខេប) **កាម** មានពីរ គឺវត្ថុកាម និងកិលេសកាម ។ បណ្តាកាមទាំង ២ នោះ ពោលដោយអត្ថ (សភាវៈគឺការសរុប) **កិលេសកាម** បានដល់ឆន្ទរាគៈ, វត្ថុកាម បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មយ៉ាង កិលេសកាម ឈ្មោះថា **កាម** ព្រោះអត្ថថា រមែងប្រាថ្នា **កាមេតីតិ** > **កាមោ,** **វត្ថុកាម** ឈ្មោះថា **កាម** ព្រោះអត្ថថា វត្ថុដែលគេប្រាថ្នា **កាមិយតីតិ** > **កាមោ** ។ ក៏កាមទាំងពីរយ៉ាងនេះ រមែងត្រាច់ចរទៅក្នុងប្រទេសណា ដោយអំណាចនៃការប្រព្រឹត្តទៅ, ប្រទេសនោះ មាន ១១ គឺអបាយភូមិ ៤, មនុស្សភូមិ ១, ទេវលោក ៦ ជាន់ ។ កាមរមែងត្រាច់ទៅក្នុងទីនេះ, ព្រោះហេតុដូច្នោះ ទីនេះ ទើបឈ្មោះ **កាមាវចរ** ដូចការត្រាច់ទៅជាមួយនឹងពួករទេះ។ ដូចយ៉ាងថា ឈ្នួញរទេះ រមែងត្រាច់ទៅក្នុងប្រទេសឯណា, ប្រទេសនោះ លោកហៅថា បុរសអ្នកត្រាច់ទៅជាមួយនឹងឈ្នួញរទេះ; សូម្បីនឹងមានសត្វជើង ២ និងសត្វជើង ៤ ទាំងឡាយដទៃត្រាច់ទៅក៏ដោយ លោកក៏កំណត់ចំពោះជនអ្នកត្រាច់ទៅទាំងនោះយ៉ាងណា, ប្រទេសនេះ លោកក៏ហៅថា កាមាវចរដែរប៉ុណ្ណោះ; ព្រោះសូម្បី

---

[១១៩] អភិ. ។

កាលបើរូបាវចរជាដើមពួកដទៃត្រាច់ទៅក្នុងប្រទេសនោះ លោកក៏កំណត់យកចំពោះកាមាវចរទាំងនោះប៉ុណ្ណោះ យ៉ាងនោះដែរ ។ កាមនេះ លោកហៅថាកាមប៉ុណ្ណោះ ព្រោះលប់បទក្រោយចេញ ដូចរូបភពលោកហៅថា រូបយ៉ាងណា, ចិត្តនេះ រមែងត្រាច់ទៅក្នុងកាម ពោលគឺ ១១ ប្រទេសនោះ យ៉ាងនោះដែរ; ព្រោះហេតុនោះ លោកហៅថា **កាមាវចរ** ។

សូម្បីចិត្តនេះត្រាច់ទៅក្នុងរូបភព និងអរូបភព ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ដំរីធំមានឈ្មោះដែលបានហើយថា “ចូរកាន់សង្គ្រាម” ព្រោះការចុះកាន់សង្គ្រាម, សូម្បីដើរទៅក្នុងក្រុង គេក៏ហៅថា “ដំរីសង្គ្រាមដែរ” ។ សត្វចំនួនច្រើន ដែលដើរទៅលើគោក និងក្នុងទឹក សូម្បីឈរនៅក្នុងទីមិនមែន គោក និងមិនមែនទឹក គេក៏ហៅថា “សត្វដើរទៅលើគោក និងដើរទៅក្នុងទឹក” យ៉ាងណា ។ ចិត្តនេះ សូម្បីត្រាច់ទៅក្នុងទីដទៃៗ ក៏គប្បីជ្រាបថា កាមាវចរ (ត្រាច់ទៅក្នុងកាម) ក៏យ៉ាងនោះដែរ ។ម្យ៉ាងទៀត កាមរមែងត្រាច់ទៅក្នុងចិត្តនេះ ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍, សូម្បីព្រោះហេតុនោះ ចិត្តនេះ ក៏ហៅថា **កាមាវចរ** ។ កាមនោះ រមែងត្រាច់ទៅ សូម្បីត្រាច់ទៅ រូបភព និងអរូបភព ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា គប្បីជ្រាបឧបមានេះ ដូចគេពោលថា សត្វដែលឈ្មោះថា **ភួនគោ** ព្រោះវាបញ្ចេញសំឡេងយំ, សត្វដែលឈ្មោះថា **ក្រមី** ព្រោះ

វាដេកលើផែនដី សត្វមានចំនួនប៉ុណ្ណាក៏ដោយ និងបញ្ចេញសំឡេងយំ ឬដេកលើផែនដីក៏ដោយ, សត្វទាំងអស់នោះ មិនមានឈ្មោះយ៉ាងនេះទេ ។ ម្យ៉ាងវិញទៀត ចិត្តណា រមែងត្រាច់ទៅកាន់បដិសន្ធិក្នុងកាម ពោលគឺកាមភព, ព្រោះហេតុនោះ ចិត្តនោះ ទើបឈ្មោះថា **កាមាវចរ** ៕

## អធិប្បាយពាក្យថា កុសល

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **កុសល** តទៅ ៖-

ធម៌ដែលឈ្មោះថា **កុសល** ដោយសេចក្ដី (**អត្ថ**) ទាំងឡាយ មានការកាត់ជាដើម នូវបាបទាំងឡាយដែលបណ្ឌិតត្រូវខ្ពើម ។ ម្យ៉ាងទៀត ដែលឈ្មោះថា **កុសល** ដោយអត្ថថា ការមិនមានរោគ (**អរោគ្យដ្ឋេន**), ការមិនមានទោស (**អនវជ្ជដ្ឋេន**) និងដោយអត្ថថា កើតតែសេចក្ដីឆ្លាត (**កោសល្យសម្ភូតដ្ឋេន**) ។

បណ្ឌិតគប្បីជ្រាបធម៌ ដែលឈ្មោះថា **កុសល** ដោយអត្ថថាមិនមានរោគ ព្រោះការមិនរសាប់រសល់ដោយកិលេស, មិនមានការឈឺថ្កាត់ដោយកិលេស, មិនមានព្យាធិក្នុងអរូបធម៌ឡើយ, ដូចពាក្យដែលលោកពោលថា ឈ្មោះថា **កុសល** ដោយអត្ថថា មិនមានរោគ ព្រោះមិនមានការរសាប់រសល់ក្នុងរាងកាយ, ព្រោះ

មិនមានការឈឺថ្កាត់ក្នុងរាងកាយ, ព្រោះមិនមានព្យាធិក្នុងរាងកាយ, ដូចក្នុងពាក្យថា "ការមិនមានរោគ មានដល់លោកដ៏ចម្រើនខ្លះដែរឬ?" ។

ក៏ធម៌ដែលឈ្មោះថា **កុសល** ព្រោះអត្ថថា មិនមានទោស ព្រោះការមិនមានទោសដែលគួរវៀរ គឺកិលេស, ទោសដែលប្រទូសរ៉ាយ គឺកិលេស, ទោសដែលក្រវល់ក្រវាយ គឺកិលេស ។ បញ្ញាលោកហៅថា កោសល្ល (ភាពជាអ្នកឆ្លាត) ធម៌ដែលឈ្មោះថា កុសល ព្រោះអត្ថថា កើតតែសេចក្ដីឆ្លាត ព្រោះការកើតឡើងពីបញ្ញា ដែលឈ្មោះថា **កោសល្ល** ។

ពាក្យថា **កុសល** ដែលជាញាណសម្បយុត្ត ចូរផ្អាកទុកសិន ។ តែពាក្យថា កុសលដែលជាញាណវិប្បយុត្ត តើដូចម្ដេច ? សូម្បីកុសលដែលជាញាណវិប្បយុត្តនោះ ក៏ជាកុសលនោះឯង ដោយរុឡ្ហីសព្ទ[*] ។ ដូចយ៉ាងថា ផ្ទិតសូម្បីដែលបុគ្គលធ្វើដោយកន្ទេលផែងជាដើម មិនបានធ្វើដោយស្លឹកត្នោត គេក៏ពោលថា "ផ្ទិតស្លឹកត្នោត" នោះឯងដោយរុឡ្ហីសព្ទ ព្រោះវត្ថុនោះដូចគ្នាយ៉ាងណា, សូម្បីកុសលជាញាណវិប្បយុត្ត បណ្ឌិតគប្បីជ្រាបថាជាកុសល ក៏យ៉ាងនោះដែរ ។ តែបើពោលដោយនិប្បរិយាយ (ដោយត្រង់) កុសលដែលជាញាណសម្បយុត្ត

---

[*] ពាក្យដែលគេនិយមនិយាយ (អត្ថនោមតិ) ។

បានឈ្មោះថា **កុសល** ដោយអត្ថ ៣ យ៉ាង គឺដោយអត្ថថា មិនមានរោគ, ដោយអត្ថថា មិនមានទោស, ដោយអត្ថថា កើតតែសេចក្ដីឆ្លាត ។ កុសលដែលជាញាណវិប្បយុត្ត បានឈ្មោះថា **កុសល** ដោយអត្ថត្រឹមតែ ២ យ៉ាងប៉ុណ្ណោះ (គឺការមិនមានរោគ និងការមិនមានទោស) ។ ព្រោះហេតុនោះ កុសលណាដែលពោលទុកហើយដោយការបរិយាយនូវជាតកក្ដី, ដោយការបរិយាយនូវពាហិរជាតកក្ដី និងដោយការបរិយាយនូវអភិធម្មក្ដី កុសលទាំងអស់នោះ រមែងបានក្នុងចិត្តនេះ ដោយអត្ថទាំងឡាយបី ។ កុសលនោះ ពោលដោយលក្ខណាទិចតុក្កៈគឺៈ-

**កុសលមានសុខវិបាកដែលមិនមានទោស ជាលក្ខណៈ, មានការកម្ចាត់អកុសល ជារស, មានការផ្ទូរផង់ជាបច្ចុប្បដ្ឋាន និងមានយោនិសោមនសិការ ឬមានការមិនមានទោសជាបទដ្ឋាន** * ។

ម្យ៉ាងទៀត កុសលឈ្មោះថា **មានការមិនមានទោស** ជាលក្ខណៈនោះឯង ព្រោះជាបដិបក្សចំពោះធម៌ដែលមានទោស, មានការផ្ទូរផង់ជារស, មានវិបាកដែលគួរប្រាថ្នាជាបច្ចុប្បដ្ឋាន និងមានយោនិសោមនសិការ ឬមានការមិនមានទោសជាបទដ្ឋាន ។

---

* អនវជ្ជសុខវិបាកលក្ខណំ, អកុសលវិទ្ធំសនរសំ, វោទានបច្ចុប្បដ្ឋានា, យោនិសោមនសិការបទដ្ឋានំ អនវជ្ជបទដ្ឋានំ វា ។

ពិតណាស់ ធម៌ទាំង ៤ មានលក្ខណៈជាដើម សភាវៈ ឬការស្មើគ្នានៃធម៌នោះៗ ឈ្មោះថា **លក្ខណៈ**, កិច្ច (នាទីការងារ) ឬសម្បត្តិ (ការដល់ព្រម) ឈ្មោះថា **រសៈ**, អាការប្រាកដ ឬផល ឈ្មោះថា **បច្ចុប្បដ្ឋាន**, ហេតុជិត ឈ្មោះថា **បទដ្ឋាន**; ព្រោះហេតុដូច្នោះ ខ្ញុំនឹងពោលធម៌ទាំងឡាយមានលក្ខណៈជាដើម ក្នុងទីណាៗ គប្បីជ្រាបសេចក្តីផ្សេងគ្នានៃធម៌ទាំងឡាយ ក្នុងទីនោះៗ ដោយន័យនេះឯង ៕

## អធិប្បាយពាក្យថា ចិត្ត

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចិត្តំ**, សភាវៈដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា រមែងគិតនូវអារម្មណ៍ *; អធិប្បាយថា ដឹងច្បាស់នូវអារម្មណ៍ (**វិជានាតីតិ អត្ថោ**) ។ ម្យ៉ាងទៀត សព្ទថា **ចិត្ត** នេះ ទូទៅដល់ចិត្តទាំងពួង ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងបទថា **ចិត្តំ** នេះ ចិត្តណាជាកុសល អកុសល និងមហាកិរិយាចិត្តខាងលោកិយចិត្តនោះ ឈ្មោះថា **ចិត្ត** ព្រោះអត្ថថា សន្សំសន្តានរបស់

---

* អារម្មណំ ចិន្តេតីតិ ចិត្តំ ។

* ជវនវីថិវសេន អត្តនោ ចិនោតីតិ ។ វិបាកំ កម្មកិលេសេហិ ចិតន្តិ ចិត្តំ ។

ខ្លួន ដោយអំណាចនៃជវនវីថិ * ។ ឈ្មោះថា **ចិត្ត** ព្រោះអត្ថថា ជាធម្មជាតិដែលកម្ម និងកិលេសទាំងឡាយសន្សំហើយនូវវិបាក * ។ ម្យ៉ាងទៀត សូម្បីចិត្តទាំងអស់ ឈ្មោះថា ចិត្ត ព្រោះជាធម្មជាតិវិចិត្តតាមសមគួរ ។ ឈ្មោះថា ចិត្ត ព្រោះធ្វើឱ្យវិចិត្ត គប្បីជ្រាបសេចក្ដីក្នុងបទថា **ចិត្តំ** នេះ ដូចពណ៌នាមកដូច្នេះ ។

បណ្ដាចិត្តទាំងនោះ ចិត្តមានរាគៈក៏ម្យ៉ាង, ចិត្តមានទោសៈក៏ម្យ៉ាង, ចិត្តមានមោហៈក៏ម្យ៉ាង, ចិត្តមានកាមាវចរក៏ម្យ៉ាង, ចិត្តមានរូបាវចរជាដើមក៏ម្យ៉ាង, ចិត្តមានរូបជាអារម្មណ៍ក៏ម្យ៉ាង, ចិត្តមានសំឡេងជាដើម ជាអារម្មណ៍ក៏ម្យ៉ាង, ក៏បណ្ដាចិត្តមានរូបជាអារម្មណ៍ទាំងនោះ, ចិត្តមានពណ៌ខៀវជាអារម្មណ៍ក៏ម្យ៉ាង, ចិត្តមានពណ៌លឿងជាដើមជាអារម្មណ៍ក៏ម្យ៉ាង; សូម្បីចិត្តមានសំឡេងជាដើមជាអារម្មណ៍ ក៏ន័យនេះដែរ ។ សូម្បីក្នុងចិត្តទាំងអស់នោះ ហីនចិត្តក៏ម្យ៉ាង, មជ្ឈិមចិត្តក៏ម្យ៉ាង, បណីតចិត្តក៏ម្យ៉ាង; ដល់ក្នុងចិត្តដែលជាហីនចិត្តជាដើម ចិត្តដែលមានឆន្ទៈជាអធិបតីក៏ម្យ៉ាង, ចិត្តដែលមានវិរិយៈជាអធិបតីក៏ម្យ៉ាង ។ ល ។ ចិត្តដែលមានវីមំសាជាអធិបតីក៏ម្យ៉ាង; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបការដែលចិត្តពួកនេះ ជាធម្មវិចិត្តដោយអំណាចនៃសម្បយុត្តធម៌ ភូមិ អារម្មណ៍ ជាហីនៈ, មជ្ឈិមៈ, បណីតៈ និងអធិបតី ។ ក៏បណ្ដាចិត្តទាំងនេះ ជាចិត្តមួយដួងៗ មិនមែនចិត្តទាំងឡាយឡើយ សូម្បីយ៉ាងនោះ, ចិត្តនោះ ឈ្មោះថា ចិត្ត ព្រោះ

រួមនៅក្នុងការវិចិត្រទាំងឡាយ; បណ្តាចិត្តពួកនោះ ចិត្តដួងណាមួយសមគួរហៅថា ចិត្ត ព្រោះជាធម្មវិចិត្រ ។ ឈ្មោះថា **ចិត្ត** ព្រោះការវិចិត្រយ៉ាងនេះសិន ។

ឈ្មោះថា **ចិត្ត** ព្រោះធ្វើឱ្យវិចិត្រ តើដូចម្តេច?

ពិតណាស់ ឈ្មោះថា **វិចិត្រដទៃក្រៃលែងជាងចិត្តកម្ម** មិនមានក្នុងលោកទេ. ធម្មតាថា ក្បាច់សូម្បីក្នុងចិត្តកម្មនោះ ក៏ជាការវិចិត្ត គឺការស្អាតល្អពេកណាស់ ។ ពួកចិត្តកម្មកាលធ្វើចិត្តកម្មនោះ ក៏កើតសញ្ញាដ៏វិចិត្រថា "រូបទាំងឡាយមានប្រភេទផ្សេងៗ យើងគួរធ្វើយ៉ាងនេះ ក្នុងទីនេះ" ។ ការធ្វើដ៏វិចិត្រដែលសម្រេចហើយដោយកិច្ចមានការសរសេរ (គូរ), ការផាត់ពណ៌, ការធ្វើពណ៌ឱ្យភ្លឺស្រស់ឡើង និងផាត់ពណ៌ជាដើម រមែងកើតឡើងដោយសញ្ញាវិចិត្រ រូបដ៏វិចិត្រយ៉ាងណាមួយក្នុងការវិចិត្រ ពោលគឺក្បាច់ក្បូរ រមែងសម្រេចពីចិត្រកម្មនោះ ។ ការកើតឡើងនៃសិល្បៈយ៉ាងណានីមួយក្នុងលោកយ៉ាងនេះ, សិល្បៈទាំងអស់នោះ ដែលចិត្តប៉ុណ្ណោះគិតថា "រូបនេះចូរមានខាងលើរូបនេះ, រូបនេះចូរមានខាងក្រោមរូបនេះ, រូបនេះចូរនៅខាងទាំងពីររបស់រូបនេះ" ហើយទើបធ្វើចិត្រកម្មនោះ ដែលជាងឱ្យវិចិត្រហើយយ៉ាងណា, សូម្បីចិត្តដែលឱ្យសម្រេចការវិចិត្រ ក៏ឈ្មោះថា **ចិត្ត** យ៉ាងនោះដែរ ។ ម្យ៉ាងទៀត ចិត្តនោះឯង ឈ្មោះថា **វិចិត្រជាងចិត្រកម្មនោះ** ព្រោះឱ្យសម្រេចចិត្រកម្ម គ្រប់ប្រភេទតាមដែលចិត្ត

គិត ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ក្បាច់ដ៏វិចិត្រពួកអ្នកឃើញហើយឬ?” ពួកភិក្ខុក្រាបទូលថា “ឃើញ ហើយព្រះអង្គ” ។ ព្រះភគវាទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សូម្បីក្បាច់ ដ៏វិចិត្រនោះ ដែលចិត្តគិតហើយ ម្នាលភិក្ខុទាំងឡាយ ចិត្តប៉ុណ្ណោះ វិចិត្រជាង ក្បាច់ដ៏វិចិត្រនោះឯង”។

ម្យ៉ាង សូម្បីចិត្តដែលប្រព្រឹត្តទៅក្នុងខាងក្នុង ដែលផ្សេងដោយកម្ម ភេទ សញ្ញា និងវោហារជាដើម ក្នុងគតិទាំងឡាយ មានទេវតា មនុស្ស នរក និង តិរច្ឆាន ក៏ត្រូវចិត្តធ្វើឱ្យវិចិត្រហើយដូចគ្នា។

ពិតណាស់ **កុសលកម្ម** និង**អកុសលកម្ម** ដែលផ្សេងដោយកម្មមានកាយ កម្មជាដើម ដែលប្រព្រឹត្តទៅដោយន័យមានទាន, សីល, ការបៀតបៀន និងការ លួចជាដើម សម្រេចហើយដោយចិត្ត, ឈ្មោះថា **មានការផ្សេងគ្នាដោយកម្ម**។ ទ្រង់ទ្រាយនៃអវយវៈ មានដៃ, ជើង, ពោះ,ក និងមុខជាដើម ក្នុងគតិនោះៗ ប្លែកផ្សេងទៅដោយការផ្សេងគ្នានៃកម្មនោះឯង ឈ្មោះថា **ការផ្សេងគ្នានៃភេទ**។ កាលសញ្ញាកើតឡើងថា “នេះស្រី, នេះប្រុស” ដោយអំណាចនៃសណ្ឋានតាម ដែលកាន់យក ព្រោះការផ្សេងនៃភេទ ឈ្មោះថា **ការផ្សេងគ្នានៃសញ្ញា** ។ កាលជនទាំងឡាយហៅដោយពាក្យថា “ស្រី” ឬថា “ប្រុស” ដែលសមគួរ

ដល់សញ្ញា ព្រោះការផ្សេងគ្នានៃសញ្ញា ឈ្មោះថា ការផ្សេងគ្នាដោយវោហារ ។ ពីព្រោះហេតុដែលបុគ្គលធ្វើកម្មដែលឱ្យកើតក្នុងអត្តភាពនោះៗ ដោយអំណាចនៃការផ្សេងគ្នានៃវោហារយ៉ាងនេះថា "ខ្ញុំនឹងជាស្រី, ខ្ញុំនឹងជាប្រុស, យើងនឹងជាក្សត្រ, យើងនឹងជាព្រាហ្មណ៍" ទើបឈ្មោះថា **ការផ្សេងគ្នានៃកម្ម** ព្រោះការផ្សេងគ្នានៃវោហារ ។ ក៏ការផ្សេងគ្នានៃកម្មនោះៗ កាលនឹងញុំាងភពតាមដែលប្រាថ្នាឱ្យកើតឡើង រមែងឱ្យកើតដោយគតិ ព្រោះហេតុណា; ព្រោះហេតុនោះ ទើបឈ្មោះថា **ការផ្សេងគ្នានៃគតិ** ព្រោះការផ្សេងគ្នានៃកម្ម ។

ម្យ៉ាងទៀត កាលដែលសត្វទាំងឡាយនោះៗ កើតជាសត្វមិនមានជើង និងសត្វជើង ២ ជាដើម, កើតជាសត្វខ្ពស់ និងសត្វទាបជាដើម ក្នុងគតិនោះៗ, កើតជាអ្នកមានសម្បុរល្អ និងសម្បុរអាក្រក់ជាដើម, ជាសត្វមានលាភ និងអត់លាភជាដើមក្នុងលោកធម៌ទាំងឡាយក្នុងអត្តភាពនោះៗ, រមែងប្រាកដដល់ការផ្សេងគ្នានៃកម្មនោះឯង; ព្រោះហេតុនោះ ចិត្តដែលប្រព្រឹត្តទៅក្នុងខាងក្នុងដែលផ្សេងគ្នាដោយកម្ម, ភេទ, សញ្ញា និងវោហារជាដើម ក្នុងគតិទាំងឡាយដែលផ្សេងគ្នាដោយទេវតា, មនុស្ស, នរក និងសត្វតិរច្ឆានទាំងអស់នោះឯង គប្បីជ្រាបថា គឺចិត្តនោះឯងធ្វើហើយ ។ សេចក្តីនេះ គប្បីជ្រាបដោយអំណាចនៃព្រះសូត្រ **ដែលនៅមិនបានឡើងកាន់សង្គីតិនេះ** ។ សមពិតដូចលោកពោលទុក

ថា "ការកំណត់ប្រភេទរបស់ការផ្សេងគ្នានៃភេទដែលមានច្រើន រមែងមានបាន ដោយអំណាចនៃការកំណត់ប្រភេទនៃការផ្សេងគ្នានៃកម្មមានច្រើន, ការកំណត់ប្រភេទនៃការផ្សេងគ្នារបស់សញ្ញាមានច្រើន, រមែងមានបានដោយអំណាចនៃការកំណត់ប្រភេទផ្សេងគ្នានៃភេទមានច្រើន ការកំណត់ប្រភេទនៃការផ្សេងគ្នានៃវោហារមានច្រើន, រមែងមានដោយអំណាចការកំណត់ប្រភេទនៃការផ្សេងគ្នានៃសញ្ញាមានច្រើន, ការកំណត់ប្រភេទនៃការផ្សេងគ្នានៃកម្មមានច្រើន, រមែងមានដោយអំណាចការកំណត់ប្រភេទនៃការផ្សេងគ្នា នៃវោហារមានច្រើន, ការផ្សេងគ្នានៃគតិរបស់សត្វទាំងឡាយរមែងប្រាកដ, ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម, សត្វទាំងឡាយគ្មានជើង, មានជើង ២, មានជើង ៤, មានជើងច្រើន, មានរូប, គ្មានរូប, មានសញ្ញា, គ្មានសញ្ញា, មានសញ្ញាក៏មិនមែន, គ្មានសញ្ញា ក៏មិនមែន, ការផ្សេងគ្នានៃការឧប្បត្តិរបស់សត្វទាំងឡាយ គឺខ្ពស់, ទាប, ថោកទាប, ប្រណីត, ទៅកាន់សុគតិ និងទុគ្គតិ, រមែងប្រាកដព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម, ការផ្សេងគ្នាក្នុងអត្តភាពរបស់សត្វទាំឡាយ គឺជាអ្នកមានពណ៌សម្បុរល្អ និងសម្បុរអាក្រក់, ភាពជាអ្នកមានជាតិល្អ និងមិនល្អ, ភាពជាអ្នកមានទ្រង់ទ្រាយល្អ និងមិនល្អ រមែងប្រាកដ, ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម, ការផ្សេងគ្នាក្នុងលោកធម៌របស់សត្វទាំងឡាយ ក្នុងការមានលាភ, អត់លាភ, មានយស,

អត់យស, និន្ទា, សរសើរ, សុខ និងទុក្ខ រមែងប្រាកដ, ព្រោះអាស្រ័យការផ្សេងគ្នានៃកម្ម”។

សូម្បីខដទៃទៀត ព្រះភគវាទ្រង់ត្រាស់ទុកថា ៖-

“ភេទរមែងប្រព្រឹត្តទៅព្រោះកម្ម, សញ្ញារមែងប្រព្រឹត្តទៅ ព្រោះភេទ, សត្វទាំងឡាយរមែងដល់ការផ្សេងគ្នាព្រោះសញ្ញាថា ‘នេះជាស្រីឬជាប្រុស’ សត្វលោករមែងប្រព្រឹត្តទៅតាមកម្ម **កម្មុនា វត្តតិ លោកោ**, ពួកសត្វរមែងប្រព្រឹត្តទៅតាមកម្ម **កម្មុនា វត្តតិ បជា** សត្វទាំងឡាយមានកម្មជាគ្រឿងចង ដូចឈើខ្ទាស់ភ្លៅរថដែលរត់ទៅហើយ[១២០]; បុគ្គលរមែងបានកិត្តិសព្ទ បានការសរសើរក៏ព្រោះកម្ម[*], បានការវិនាស ការដែលត្រូវគេប្រហារ (សម្លាប់) និងការចាប់ចង ក៏ព្រោះកម្ម, បុគ្គលដឹងការផ្សេងគ្នានៃកម្មនោះហើយ ព្រោះហេតុអ្វីទើបពោលថា ‘កម្មមិនមានក្នុងលោក’[១២១]។ ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន, ជាទាយាទ

---

[១២០] ម. ម. ។

[*] មូលដីកា ការសរសើរក្នុងទីកំបាំងមុខ ឈ្មោះថា កិត្តិសព្ទ, ការសរសើរក្នុងទីចំពោះមុខ ឈ្មោះថា ការសរសើរ។

[១២១] អភិ.។

របស់កម្ម, មានកម្មជាកំណើត, មានកម្មជាផៅពង្ស, មានកម្មជាទីពំនាក់, កម្មរមែងបែងចែកសត្វទាំងឡាយឱ្យថោកទាប និងប្រណីត”[១២២] ។

បណ្ឌិតគប្បីជ្រាបការដែលចិត្តជាធម្មជាតិវិចិត្រ ព្រោះវិចិត្រទៅដោយការធ្វើ ដូចពណ៌នាមកនេះ ។

ពិតណាស់ ការវិចិត្រទាំងឡាយសូម្បីទាំងអស់នេះ គឺចិត្តនោះឯង ធ្វើហើយ; ក៏ចិត្តប៉ុណ្ណោះជាធម្មជាតិវិចិត្រជាងការវិចិត្រ ដែលប្រព្រឹត្តទៅខាងក្នុងដែលចិត្តធ្វើហើយ ដែលពោលហើយនេះ ព្រោះការដែលចិត្តមិនបានឱកាស មិនមានការធ្វើ ការវិចិត្រខ្លះ ឬថា ព្រោះការដែលចិត្តខ្វះដោយបច្ច័យដែលសល់ ក៏មិនមានការធ្វើឱ្យវិចិត្រខ្លះ; ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញនូវពួកសត្វដទៃសូម្បីតែមួយដែលវិចិត្រដូចសត្វតិរច្ឆានទាំងឡាយនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តនោះឯងដែលវិចិត្រជាធម្មជាតិ វិចិត្រជាងសត្វតិរច្ឆានទាំងឡាយនោះ”[១២៣*] ៕

---

[១២២] ម. ឧ. ។

[១២៣] សំ. ខ. ។

* ការដែលសត្វតិរច្ឆានទាំងឡាយមានការវិចិត្រផ្សេងៗគ្នា ប្រភេទសត្វខ្លះមានទ្រង់ ទ្រាយដូចមែកឈើ ប្រភេទសត្វខ្លះមានទ្រង់ទ្រាយដូចស្លឹកឈើជាដើម (នេះតាមដែលខ្ញុំបានឃើញផ្ទាល់) ។

## អធិប្បាយពាក្យថា ឧប្បន្នធម៌ ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“ឧប្បន្នំ ហោតិ”** នេះតទៅ ៖-

ធម៌ដែលឈ្មោះថា **ឧប្បន្ន** មានប្រភេទច្រើនយ៉ាង ដោយអំណាចនៃ **វត្តមានឧប្បន្ន, ភូតាបគតឧប្បន្ន, ឱកាសកតឧប្បន្ន** និង**ភូមិលទ្ធឧប្បន្ន**។

បណ្ដា**វត្តមានឧប្បន្ន**ជាដើមទាំងនោះ ក៏ធម្មជាតិទាំងអស់ ពោលគឺការព្រមព្រៀងគ្នាដោយការកើតឡើង, ការចាស់ និងការរលត់ ឈ្មោះថា **វត្តមានឧប្បន្ន**; កុសល និងអកុសលដែលសោយរសនៃអារម្មណ៍ហើយរលត់ទៅ ពោលគឺសោយហើយ ក៏រលត់ទៅផង, កុសល និងអកុសដែលចូលដល់ពួក ៣ មានឧប្បាទខណៈជាដើម ហើយក៏រលត់ទៅ ពោលគឺកើតហើយ ក៏រលត់ផង, កុសល និងអកុសល ដែលបច្ច័យតាក់តែងដ៏សេសផង ឈ្មោះថា **ភូតាបគតឧប្បន្ន**, កម្មដែលត្រាស់ទុកដោយន័យជាដើមថា “កម្មពួកនោះណា ដែលសត្វធ្វើហើយក្នុងកាលមុន”[១២៤] សូម្បីជាអតីតៈ ព្រោះហាមវិបាកដទៃដែលមានហើយ ឱ្យឱកាសដល់វិបាករបស់ខ្លួនហើយឋិតនៅ និងវិបាកដែលមានឱកាសដែលធ្វើយ៉ាងនោះ សូម្បីនៅមិនទាន់កើតឡើង, តែងត្រូវកើតឡើងពិតប្រាកដ ព្រោះឱកាសធ្វើហើយយ៉ាងនោះ ឈ្មោះថា **ឱកាសកតឧប្បន្ន**, អកុសលដែលនៅមិនបានដកឡើងក្នុងភូមិទាំងឡាយនោះៗ ឈ្មោះថា **ភូមិលទ្ធឧប្បន្ន** បណ្ឌិតគប្បីជ្រាប

---

[១២៤] ម. ឧ. ។

ការផ្សេងគ្នានៃភូមិ និងភូមិលទ្ធ ក្នុងពាក្យថា **ភូមិលទ្ធឧប្បន្ន** នោះតទៅ ៖-

ខន្ធ ៥ ប្រព្រឹត្តទៅក្នុងភូមិ ៣ ជាអារម្មណ៍ដល់វិបស្សនា ឈ្មោះថា **ភូមិ** ។ ការកើតឡើងនៃកិលេស ដែលគួរដល់ការកើតឡើងក្នុងខន្ធទាំងនោះ ឈ្មោះថា **ភូមិលទ្ធ** = ភូមិដែលបានហើយ ។ ពិតណាស់ ភូមិទាំងនោះ **ដែលកិលេសនោះបានហើយ** ព្រោះហេតុដូច្នោះ ទើបលោកហៅថា **ភូមិលទ្ធៈ** = មានភូមិដែលបានហើយ ។ បណ្តាឧប្បន្ន ៤ ដែលបានពោលមកយ៉ាងនេះ ក្នុងពាក្យថា **"ឧប្បន្នំ ហោតិ"** នេះលោកប្រាថ្នាយកវត្តមានឧប្បន្ន ៕

## សម្តែងអំពីឧប្បន្នសព្ទ

គប្បីជ្រាបពាក្យសម្គាល់សេចក្តី ក្នុងពាក្យថា **"ឧប្បន្នំ ហោតិ"** នេះតទៅ ៖-

ធម៌ដែលឈ្មោះថា **ឧប្បន្ន** ព្រោះអត្ថថា ឃ្លាតចាកកម្មចំណែកខាងដើម (គឺអតីតធម៌) ឆ្ពោះត្រង់ចំពោះឧប្បាទខណៈជាដើម ។ ក៏សព្ទថា **ឧប្បន្ន**នេះ ប្រើក្នុងអត្ថច្រើនយ៉ាង គឺក្នុង **អតីតៈ** (ធម៌ដែលកន្លងហើយ) **បដិលទ្ធ** (បានចំពោះ), **សមុដ្ឋិតៈ** (តាំងឡើងព្រម), **អវិក្ខម្ភិតៈ** (គ្របសង្កត់មិនបាន), **អសមុច្ឆិន្នៈ** (កាត់មិនបាន), **ខណត្តយគតៈ** (ដល់ខណៈទាំង ៣) ។

ពិតណាស់ ឧប្បន្នសព្ទនេះមកក្នុងន័យថា **អតីតះ** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“តេន ខោ បន ភិក្ខវេ សមយេន កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ** = ម្នាលភិក្ខុទាំងឡាយ ក៏សម័យនោះឯង ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមថា **កកុសន្ធៈ** កើតឡើងហើយក្នុងលោក”[១២៥] ។ មកក្នុងន័យនេះថា **បដិលទ្ធ** ដូចក្នុងប្រយោគនេះថា **“អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្បន្នំ ហោតិ** = អតិរេកចីវរនៃព្រះអានន្ទដ៏មានអាយុ បានចំពោះហើយ”[១២៦] ។ មកក្នុងន័យថា **សមុដ្ឋិតះ** ដូចក្នុងប្រយោគនេះថា **“សេយ្យថាបិ ភិក្ខវេ ឧប្បន្នំ មហាមេឃំ តមេនំ មហាវាតោ អន្តរាយេវ អន្តរធាបេតិ** = ម្នាលភិក្ខុទាំងឡាយ មហាមេឃ **តាំងឡើងព្រមហើយ**, មហាខ្យល់បក់ផាត់មហាមេឃនេះ ឱ្យអន្តរធានទៅក្នុងចន្លោះនោះឯង យ៉ាងណា”[១២៧] ។ មកក្នុងន័យថា **អវិក្ខម្ភិតះ** ដូចក្នុងប្រយោគថា **“ឧប្បន្នំ គមិយចិត្តំ ឧប្បជ្ជិវិនោទនពហុ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ** = ចិត្តគិតនឹងទៅ គ្របសង្កត់

---

[១២៥] សំ. និ. ។

[១២៦] វិនយ. ។

[១២៧] សំ. ម. ។

**មិនបាន** [១២៨] (ហាមឃាត់បានដោយលំបាក) បន្ទោបង់បានដោយលំបាក, នឹងញ៉ាំងបាបអកុសលធម៌ ដែលគ្របសង្កត់មិនបានៗ ដោយឆាប់ភ្លាមទេ” [១២៩]។ មកក្នុងន័យថា **កាត់មិនបាន** ដូចក្នុងប្រយោគថា **“អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរាយេវ អន្តរធាបេតិ** = បុគ្គលកាលចម្រើន ធ្វើឱ្យច្រើននូវអរិយមគ្គប្រកបដោយអង្គ ៨ រមែងញ៉ាំងបាបអកុសលធម៌ ដែលនៅមិនទាន់លះបាន និងលះមិនបានឱ្យអន្តរធានទៅក្នុងចន្លោះនោះឯង ក្នុងខណៈនោះ”[១៣០]។ មកក្នុងន័យថា **ដល់ខណៈទាំង ៣** ដូចក្នុងប្រយោគថា **“ឧប្បជ្ជមានំ ឧប្បន្នន្តិ អាមន្តា** = (សួរថា) ចិត្តកំពុងកើតឡើង **ដល់ខណៈទាំង ៣** ឬ? (ឆ្លើយថា) អើ” [១៣១]។ សូម្បីឧប្បន្នសព្ទក្នុងទីនេះ ក៏គប្បីជ្រាបដល់ខណៈទាំង ៣ ប៉ុណ្ណោះ។ ព្រោះហេតុដូច្នោះ ក្នុងពាក្យថា **“ឧប្បន្នំ ហោតិ”** នេះ គប្បីជ្រាបសេចក្ដីសង្ខេបនេះថា ដល់ខណៈទាំង ៣ កំពុងប្រព្រឹត្តទៅ បានដល់បច្ចុប្បន្ន ៕

---

[១២៨] វិនយ., អំ. បញ្ចក. ទុប្បដិវិនោទយសូត្រ ។

[១២៩] វិនយ. ។

[១៣០] សំ. ម. ។

[១៣១] អភិ. ។

## អធិប្បាយពាក្យថាចិត្តជាប្រធាន

ក៏ពាក្យថា **"ចិត្តំ ឧប្បន្នំ ហោតិ"** នេះជាប្រធាននៃទេសនាមែនពិត, ក៏ចិត្តរមែងមិនកើតតែមួយដួងប៉ុណ្ណោះទេ ។ ព្រោះហេតុដូច្នោះ កាលបើគេនិយាយថា "ព្រះរាជាទ្រង់យាងមកហើយ" ក៏ព្រះរាជាទ្រង់លះបរិស័ទហើយទ្រង់យាងមកតែមួយព្រះអង្គប៉ុណ្ណោះ ក៏មិនមែន, តែតាមការពិត រមែងប្រាកដថា ព្រះអង្គយាងមកព្រមទាំងបរិស័ទតែម្តងយ៉ាងណា, សូម្បីចិត្តនេះ ក៏យ៉ាងនោះដែរ; បណ្ឌិតគប្បីជ្រាបថា ចិត្តកើតព្រមនឹងកុសលធម៌លើស ៥០ ដោយពិត ។ ម្យ៉ាងទៀត ពាក្យថា **"ចិត្តំ ឧប្បន្នំ ហោតិ"** នេះ ព្រះភគវាទ្រង់ត្រាស់ទុកដោយអត្ថថា ជាប្រធាន (សភាវៈដល់មុន) * ។

ពិតមែន សំឡឹងដល់លោកិយធម៌ហើយ ចិត្តក៏ជាធំ,ជាធុរៈ, ជាប្រធាន; តែបើសំឡឹងដល់លោកុត្តរធម៌ហើយ បញ្ញាជាធំ, ជាធុរៈ, ជាប្រធាន; ព្រោះហេតុនោះឯង ព្រះភគវាលុះបរិយាយព្រះវិន័យហើយ (វិនយទេសនា) កាលត្រាស់សួរបញ្ហា ក៏មិនត្រាស់សួរថា "អ្នកមានផស្សៈដូចម្តេច? មានវេទនាដូចម្តេច? មានសញ្ញាដូចម្តេច? មានចេតនាដូចម្តេច?" រមែងត្រាស់សួរធ្វើចិត្ត

---

* បុព្វង្គមដ្ឋេន ចិត្តំ ។

ប៉ុណ្ណោះឱ្យជាធុរៈថា "ម្នាលភិក្ខុ អ្នកមានចិត្តដូចម្ដេច?"[១៣២] កាលភិក្ខុក្រាបទូលថា "បពិត្រព្រះភគវា ខ្ញុំព្រះអង្គមិនមានចិត្តលួចទេ" ។ ព្រះអង្គក៏មិនត្រាស់ថា "ភិក្ខុមិនមានថេយ្យផស្សៈ ក៏មិនត្រូវអាបត្តិ" ជាដើម, តែរមែងត្រាស់ថា "ម្នាលភិក្ខុ មិនជាអាបត្តិដល់ភិក្ខុ មិនមានថេយ្យចិត្តទេ"[១៣៣] ។ ព្រះភគវា កាលទ្រង់បរិយាយព្រះវិន័យ ទ្រង់លើកចិត្តឡើងជាធុរៈប៉ុណ្ណោះ ក៏មិនមែន, សូម្បីកាលទ្រង់សម្ដែងលោកិយទេសនាដទៃ ក៏ទ្រង់ធ្វើចិត្តនោះឯង ឱ្យជាធុរៈ; ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ពួកណាមួយ ជាចំណែកអកុសល និងជាបក្សពួកអកុសល, ធម៌ពួកនោះទាំងអស់ មានចិត្តជាប្រធាន, ចិត្តរមែងកើតមុនពួកធម៌នោះ[១៣៤]; ដូចគាថាដែលលោកត្រាស់ប្រព័ន្ធទុកថា ៖-

**"មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ**

---

[១៣២] វិនយ. ។

[១៣៣] ឯកក. ។

[១៣៤] អំ. ឯកក. ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន, មានចិត្តប្រសើរបំផុត, សម្រេចហើយដោយចិត្ត, បើបុគ្គលមានចិត្តប្រទូស្តហើយ, ទោះនិយាយក្តី, ធ្វើក្តី, ព្រោះទុច្ចរិត ៣ ប្រការនោះ ទុក្ខរមែងជាប់តាមគេទៅ, ដូចជាកង់រទេះកាលជាប់តាមស្នាម ជើងគោដែលកំពុងអូសនឹមទៅដូច្នោះដែរ” ។

“មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី

ធម៌ទាំងឡាយមានចិត្តជាប្រធាន, មានចិត្តប្រសើរបំផុត, សម្រេចហើយពីចិត្ត, បើបុគ្គលមានចិត្តជ្រះថ្លាហើយ, ទោះនិយាយក្តី, ធ្វើក្តី ព្រោះសុចរិត ៣ ប្រការនោះ សេចក្តីសុខរមែងជាប់តាមគេទៅ ដូចជាស្រមោលអន្ទោលតាមប្រាណដូច្នោះឯង”[១៣៥] ។

“ចិត្តេន នីយតិ លោកោ ចិត្តេន បរិកស្សតិ
ចិត្តស្ស ឯកធម្មស្ស សព្វេវ វសមន្វគូ

សត្វលោកត្រូវចិត្តនាំទៅ រមែងទាញទៅព្រោះចិត្ត, សត្វទាំងអស់

---

[១៣៥] ខុ. ធ. ។

រមែងប្រព្រឹត្តទៅតាមធម៌មួយ គឺចិត្ត”[១៣៦] ។

ម្នាលភិក្ខុទាំងឡាយ សត្វលោកទាំងឡាយ រមែងសៅហ្មង ព្រោះចិត្តសៅហ្មង[*] , រមែងបរិសុទ្ធ ព្រោះចិត្តផូរផង់[*១៣៧] , ម្នាលភិក្ខុទាំងឡាយ ចិត្តនេះជាបភស្សរៈ (ភ្លឺថ្លា), តែថាចិត្តនោះឯង សៅហ្មងហើយ ព្រោះឧបក្កិលេសទាំងឡាយចូលមក[១៣៨] ។ ម្នាលគហបតី បុគ្គលកាលមិនរក្សាចិត្ត សូម្បីកាយកម្ម ក៏ឈ្មោះថា គេមិនរក្សាហើយ, សូម្បីវចីកម្ម ក៏ឈ្មោះថា គេមិនរក្សាហើយ, សូម្បីមនោកម្ម ក៏ឈ្មោះថាគេមិនរក្សាហើយ; ម្នាលគហបតី កាលបើបុគ្គលរក្សាចិត្ត ។ ល ។ ម្នាលគហបតី កាលចិត្តព្យាបាទ ។ ល ។ ម្នាលគហបតី កាលចិត្តមិនព្យាបាទ ។ ល ។ ម្នាលគហបតី កាលចិត្តត្រូវកិលេសលេចស្រោច ។ ល ។ ម្នាលគហបតី កាលចិត្តត្រូវកិលេសមិនលេចស្រោចហើយ កាយកម្មក្តី វចីកម្មក្តី មនោកម្មក្តី ក៏មិនត្រូវកិលេសលេចស្រោចហើយដែរ”[១៣៩] ។ សំឡឹងដល់លោកិយ

---

[១៣៦] សំ. ស. ។

[*] ចិត្តសង្កិលេសំ ភិក្ខវេ សត្តា សង្កិលេស្សន្តិ ។

[១៣៧] សំ. ខ. ។

[១៣៨] ឯកក. ។

[១៣៩] អំ. តិក. ។

ធម៌ហើយដោយប្រការដូច្នេះ, បណ្ឌិតគប្បីជ្រាបថា **ចិត្តជាធំ, ជាធុរៈ និងជាប្រធានដូច្នេះ**; ក៏បណ្ដាសូត្រដែលពោលហើយទាំងនេះ គប្បីជ្រាបថា លោកមិនកាន់យកសូត្រមួយ ឬសូត្រពីរទេ, តែកាន់យកសូត្រទាំងអស់ ដើម្បីតាមរក្សាទុកនូវសូត្រ ។

តែកាលព្រះមានព្រះភាគ ត្រាស់សួរលោកុត្តរធម៌ ក៏មិនត្រាស់សួរថា "លោកពន្លុះផស្សៈណា?, ពន្លុះវេទនាណា?, ពន្លុះសញ្ញាណា?, ពន្លុះចេតនាណា? ពន្លុះចិត្តណា?" , ទ្រង់សួរធ្វើបញ្ញាឱ្យជាធុរៈថា "ម្នាលភិក្ខុ អ្នកពន្លុះបញ្ញាណា? ឬថា លោកពន្លុះមគ្គទី ១, ទី ២, ទី ៣ និងទី ៤ ឬ?" ។

ក្នុងទីនេះ គប្បីជ្រាបព្រះសូត្រជាដើម យ៉ាងនេះថា "កុសលធម៌ទាំងពួងមានបញ្ញាជាកំពូល គឺមិនសាបសូន្យ[១៤០] ។ ក៏បញ្ញាមានប្រយោជន៍យ៉ាងណា?[១៤១] ម្នាលភិក្ខុទាំងឡាយ សទ្ធាដែលទៅតាមបញ្ញារបស់អរិយសាវ័ក អ្នកមានបញ្ញានោះ រមែងតាំងនៅ, វីរិយៈដែលទៅតាមសទ្ធានោះ រមែងស្ថិតនៅ, សតិដែលទៅតាមវីរិយៈនោះ រមែងស្ថិតនៅ, សមាធិដែលទៅតាមសតិនោះ រមែងស្ថិត

[១៤០] អំ. អដ្ឋក., អំ. ទសក. ។

[១៤១] ម. មូ. ។

នៅ[១៤២] ” ។ ព្រោះហេតុដូច្នោះ សំឡឹងដល់លោកុត្តរធម៌ហើយ គប្បីជ្រាបថា បញ្ញាជាធំ, ជាធុរៈ និងជាប្រធាន ។ តែនេះជាលោកិយទេសនា; ព្រោះហេតុដូច្នោះ កាលទ្រង់សម្ដែងចិត្តធ្វើឱ្យជាធុរៈ ហើយទើបត្រាស់ថា **“ចិត្តំ ឧប្បន្នំ ហោតិ”** ៕

## អធិប្បាយពាក្យថាសោមនស្សសហគតៈ

ពាក្យថា **“សោមនស្សសហគតំ”** បានដល់ (ចិត្ត) ដល់សភាវៈកើតព្រមគ្នាជាដើម ជាមួយនឹងសោមនស្ស ពោលគឺការសោយអារម្មណ៍ដែលឆ្ងាញ់ដូចទឹកឃ្មុំ, ក៏សហគតសព្ទប្រើក្នុងអត្ថទាំងនេះ គឺ**ភាពយ៉ាងនោះ** = **តព្ភាវៈ**, **លាយហើយ** = **វោកិណ្ណៈ**, **ទីអាស្រ័យ** = **និស្សយៈ**, **អារម្មណ៍** = **អារម្មណៈ** **និងការច្រឡូកច្រឡំគ្នា** = **សំសដ្ឋៈ** ។

បណ្ដាអត្ថទាំងនោះ សហគតសព្ទនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា **ភាពយ៉ាងនោះ** ដូចក្នុងប្រយោគថា **“យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា** = តណ្ហានេះណា ដែលបង្កឱ្យកើតក្នុងភពថ្មីទៀត ព្រោះភាពយ៉ាង

---

[១៤២] សំ. ម. ។

**នោះនៃនន្ទិរាគៈ”**[១៤៣] ។ (តណ្ហា) អធិប្បាយថា ជាការរីករាយ ដោយការត្រេកអរភ្លើតភ្លើន ។ ប្រើក្នុងអត្ថថា **លាយហើយ** ដូចក្នុងប្រយោគថា **“យាយំ ភិក្ខវេ វីមំសា កោសជ្ជសហគតា កោសជ្ជសម្បយុត្តា** = ម្នាលភិក្ខុទាំងឡាយ វីមំសានេះណា **លាយហើយ**ដោយការខ្ជិលច្រអូស ប្រកបហើយដោយការខ្ជិលច្រអូស” [១៤៤]; ក្នុងអធិការនេះ គប្បីជ្រាបថា វីមំសានេះណា **លាយហើយ** ដោយការខ្ជិលច្រអូស ដែលកើតឡើងក្នុងចន្លោះៗ” ។ ប្រើក្នុងន័យថា **អាស្រ័យ** ដូចក្នុងប្រយោគថា **“អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ** = ភិក្ខុចម្រើនសតិសម្ពោជ្ឈង្គៈ **អាស្រ័យអដ្ឋិកសញ្ញា”**[១៤៥]; អធិប្បាយថា ចម្រើនអដ្ឋិកសញ្ញា បានចំពោះហើយ ព្រោះអាស្រ័យអដ្ឋិកសញ្ញា ។ ប្រើក្នុងន័យថា **អារម្មណ៍** ដូចក្នុងប្រយោគថា **“លាភី ហោតិ រូបសហគតានំ វា សមាបត្តីនំ អរូបសហគតានំ វា** = ភិក្ខុមានប្រក្រតីបានសមាបត្តិទាំងឡាយមានរូបជា **អារម្មណ៍** ឬមានអរូបជា **អារម្មណ៍”** [១៤៦]; អធិប្បាយថា មានរូប

---

[១៤៣] អភិ. ។

[១៤៤] សំ. ម.។

[១៤៥] សំ. ម.។

[១៤៦] អភិ. ។

និងអរូបជា**អារម្មណ៍** ។ ប្រើក្នុងន័យថា **ច្រឡំ** ដូចក្នុងប្រយោគថា **"ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ** = សុខនេះជាធម្មជាតិសហគតៈហើយ, កើតព្រមហើយ, ច្រឡំហើយ, សម្បយុត្តហើយ ដោយបីតិនេះ" [១៤៧] ; ក្នុងបទថា **សំសដ្ឋៈ** នេះ លោកប្រាថ្នាយកន័យនេះប៉ុណ្ណោះ ។ ពិតណាស់ ចិត្តដែលច្រឡំនឹងសោមនស្សក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ថា **"សោមនស្សសហគតៈ"** ៕

## សម្តែងអំពីសំសដ្ឋសព្ទ

ម្យ៉ាងទៀត សូម្បីសំសដ្ឋសព្ទ ក៏ប្រើក្នុងន័យច្រើនយ៉ាង គឺក្នុងន័យថា **ដូចគ្នា** (សទិសេ), កិលេសលេចស្រោច (អវស្សុតេ), ការស្និទ្ធស្នាលពេញចិត្តមិត្ត (មិត្តសន្ថវេ), កើតព្រមគ្នា (សហគតេ) ។

ពិតណាស់ **សំសដ្ឋសព្ទ**នេះ មកក្នុងន័យថា **ដូចគ្នា** ដូចក្នុងប្រយោគនេះថា **"កីសេ ថូលេ ច វិវជ្ជេត្វា សំសដ្ឋា យោជិតា ហយា** = សេះទាំងឡាយដែលទឹមហើយ លើកលែងតែសេះស្គមទាំងឡាយ និងសេះធាត់ទាំងឡាយ

---

[១៤៧] អភិ. ។

ក៏ដូចគ្នា"[១៤៨] ។ មកក្នុងន័យថា កិលេសលេចស្រោច ដូចក្នុងប្រយោគថា **"សំសដ្ឋា ច[*] តុម្ហេ អយ្យេ វិហរថ** = ម្នាលនាងទាំងឡាយ ពួកនាងចូរជាអ្នកគឺកិលេសលេចស្រោចហើយនៅចុះ"[១៤៩]។ មកក្នុងន័យថា **ស្និទ្ធស្នាលពេញចិត្តមិត្ត** ដូចក្នុងប្រយោគថា **"គិហិសំសដ្ឋោ វិហរតិ** = ភិក្ខុស្និទ្ធស្នាលពេញចិត្តមិត្តនឹងគ្រហស្ថ"[១៥០]។ មកក្នុងន័យថា **កើតព្រមគ្នា** ដូចក្នុងប្រយោគថា **"ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ** = សុខនេះ សហគតៈហើយកើតរួមគ្នា **កើតព្រមគ្នា** សម្បយុត្តគ្នាដោយបីតិនេះ"[១៥១]។ សូម្បីសំសដ្ឋសព្ទក្នុងន័យនេះ ប្រាថ្នាយកសេចក្ដីថា កើតព្រមគ្នា (សហគតៈ) ។ ក៏ក្នុងអត្ថពួកនេះ ធម៌ដែលសហគតៈ ឈ្មោះថាមិនកើតព្រមគ្នា, មិនច្រឡំគ្នា, មិនសម្បយុត្តគ្នា, រមែងមិនមាន; តែថា ធម៌

---

[១៤៨] ខុ. ជា. តេមិយជាតក ។

[*] ច្បាប់ខ្លះថា សំសដ្ឋា វ ។

[១៤៩] វិនយ.។

[១៥០] សំ. ខ.។

[១៥១] អភិ. ។

ដែលកើតព្រមគ្នា, ច្របល់គ្នា, សម្បយុត្តគ្នា, មានខ្លះ, មិនមានខ្លះ ។ ពិតណាស់ កាលរូបធម៌ និងអរូបធម៌កើតព្រមគ្នា រូបរមែងកើតព្រមនឹងអរូប, តែមិនច្របល់គ្នា, មិនសម្បយុត្តគ្នា ។ អរូបក៏ដូចគ្នា គឺកើតព្រមនឹងរូប តែមិនច្របល់គ្នា, មិនសម្បយុត្តគ្នានឹងរូប ក៏កើតព្រមជាមួយរូប, មិនច្របល់គ្នា, មិនសម្បយុត្តគ្នា ។ ចំណែកអរូប ដោយទៀងតែងកើតព្រមគ្នា, ចូលជាមួយគ្នា, សម្បយុត្តគ្នានឹងអរូបតែម្តង, ព្រោះហេតុដូច្នោះ ទ្រង់សំដៅយកការកើតព្រមគ្នានោះ ទើបត្រាស់ពាក្យថា **"សោមនស្សសហគតំ"** ៕

## អធិប្បាយពាក្យថាញាណសម្បយុត្ត

បទថា **"ញាណសម្បយុត្តំ** = សម្បយុត្តដោយញាណ (បញ្ញា)" អធិប្បាយថា ប្រកបដោយអាការមានការកើតព្រមគ្នាជាដើមស្មើគ្នា ។ ក៏ពាក្យណាដែលគួរពោលក្នុងញាណសម្បយុត្តនេះ ពាក្យនោះខ្ញុំបានពោលទុកហើយ ក្នុងវេទនាត្តិកៈ ក្នុងការពណ៌នាបទមាតិកានោះឯង; ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ញាណនោះសម្បយុត្តដោយលក្ខណៈនេះ គឺកើតព្រមគ្នា (**ឯកុប្បាទា**) រលត់ព្រមគ្នា (**ឯកនិរោធា**) មានវត្ថុដូចគ្នា (**ឯកវត្ថុកា**) មានអារម្មណ៍ដូចគ្នា (**ឯការម្មណា**) ។

ចំណែកនិទ្ទេស ( ការចង្អុលបង្ហាញ) ដោយ**ឧក្រិដ្ឋដូច្នេះ** ៈ- ក៏ក្នុងអរូប សូម្បីវៀរការមានវត្ថុដូចគ្នា ក៏បានសម្បយោគ ។

**សួរថា** ដោយពាក្យប៉ុណ្ណេះ លោកពោលទុកយ៉ាងណា?

**ឆ្លើយថា** លោកពោលមហាចិត្ត ដែលសហគតៈដោយសោមនស្ស ក្នុងកាមាវចរទាំងឡាយ ដែលជាហេតុញាណសម្បយុត្តជាអសង្ខារិក ។

ពិតមែន លោកកាន់យកកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយពាក្យសួរដែលមិនបានកំណត់ទៀងទាត់ថា "ធម៌ជាអកុសលតើដូចម្តេច?" , ដោយព្រះបាលីថា "**កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ** = កាមាវចរកុសលចិត្តកើតឡើងហើយ" ទ្រង់វៀរកុសលចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣ ទ្រង់កាន់យកកាមាវចរកុសលចិត្ត ៨ ដួងប៉ុណ្ណោះ ។ ព្រះបាលីថា "**សោមនស្សសហគតំ**" ទ្រង់វៀរឧបេក្ខាសហគតៈ ៤ យ៉ាង ពីកាមាវចរកុសលចិត្តនោះ៧ឯងហើយទ្រង់កាន់យកសោមនស្សសហគតចិត្តតែ ៤ ប៉ុណ្ណោះ ដោយព្រះបាលីថា "**ញាណសម្បយុត្តំ**" , ទ្រង់វៀរចិត្តដែលជាញាណវិប្បយុត្ត ២ ដួង ពីចិត្តដែលជាសោមនស្សសហគតៈនោះ៧ ឯង ទ្រង់កាន់យកចំពោះចិត្តដែលជាញាណសម្បយុត្តតែ ២ ដួងប៉ុណ្ណោះ ។ ចំណែកចិត្តដែលជាអសង្ខារិកមិនបានទ្រង់កាន់យកព្រោះចិត្តដែលជាអសង្ខារិកៈនោះ មិនបានត្រាស់ទុក; សូម្បីទ្រង់មិនកាន់យកចិត្ត

ដែលជាអសង្ខារិក ក៏ពិតមែនហើយ, ប៉ុន្តែថា ព្រោះព្រះបាលីថា “**សសង្ខារេន**” ខាងមុខ សូម្បីមិនបានត្រាស់ទុកថា “**អសង្ខារេន**” ទុកក្នុងទីនេះ បណ្ឌិតគប្បីជ្រាបចិត្តដែលជាអសង្ខារិក; ព្រោះព្រះអង្គទ្រង់បានកំណត់ដើម្បីសម្ដែងមហាចិត្តនេះតាំងតែពីដើមមក, ហើយទើបទ្រង់ផ្ដើមទេសនានេះដូច្នេះ, ក្នុងខនេះ គប្បីជ្រាបថា លោកធ្វើការសន្និដ្ឋានទុកយ៉ាងនេះ ៕

## អធិប្បាយពាក្យថាអារម្មណ៍

ឥឡូវនេះ ដើម្បីសម្ដែងចិត្តនោះៗ ឯង ដោយអារម្មណ៍ ទើបត្រាស់ថា “**អារម្មណំ វា**” ជាដើម ។ សេចក្ដីថា ព្រះមានព្រះភាគកាលសម្ដែងអរូបធម៌ទាំងឡាយ រមែងទ្រង់សម្ដែងដោយវត្ថុ ។ អរូបធម៌ទាំងឡាយដែលទ្រង់សម្ដែងដោយវត្ថុ ដូចក្នុងប្រយោគជាដើមថា “**ចក្ខុសម្ផស្សោ ។បេ។ មនោសម្ផស្សោ** វេទនាកើតពីចក្ខុសម្ផស្ស ។ល។ វេទនាកើតពីមនោសម្ផស្សចក្ខុវិញ្ញាណ ។ល។ មនោវិញ្ញាណ” ។ ក៏ទ្រង់សម្ដែងអរូបធម៌ទាំងឡាយជាអារម្មណ៍ ដូចក្នុងប្រយោគជាដើមថា “**រូបសញ្ញា ។បេ។ ធម្មសញ្ញា; រូបសញ្ចេតនា ។បេ។ ធម្មសញ្ចេតនា**” ។ ក៏ទ្រង់សម្ដែងអរូបធម៌ទាំងឡាយ ទាំងវត្ថុ និងអារម្មណ៍ ដូចមានក្នុងប្រយោគជាដើមថា “ចក្ខុវិញ្ញាណរមែងកើតឡើង ព្រោះអាស្រ័យចក្ខុ

និងរូប ឈ្មោះ ថាផស្សៈ គឺការប្រជុំធមិទាំង ៣ ។ ល ។ មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យមនៈ និងធមិទាំងឡាយ ឈ្មោះថា ផស្សៈ គឺការប្រជុំនូវធមិទាំង ៣”[១៥២] ។ ទ្រង់សម្ដែងអរូបធមិទាំងឡាយ ដោយសភាវៈព្រមទាំងរស ដូចក្នុងប្រយោគជាដើមថា “ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបសង្ខារទាំងឡាយកើតឡើង, ព្រោះសង្ខារជាបច្ច័យ ទើបវិញ្ញាណកើតឡើង”[១៥៣] ។

ឥឡូវនេះ ព្រះមានព្រះភាគកាលសម្ដែងក្នុងឋានៈនេះ ដោយអារម្មណ៍ ទើបត្រាស់ថា **“រូបារម្មណំ វា”** ជាដើម ។

បណ្ដាធមិជារូបាអារម្មណ៍ជាដើមនោះ រូបមានសមុដ្ឋាន ៤ ដែលជាអតីតៈ អនាគត និងបច្ចុប្បន្ននោះឯង ហៅថា **រូបារម្មណ៍** ។ សំឡេងមានសមុដ្ឋាន ២ ដែលជាអតីតៈ,អនាគត និងបច្ចុប្បន្ននោះឯង ហៅថា **សទ្ទារម្មណ៍** ។ ក្លិនមានសមុដ្ឋាន ៤ ដែលជាអតីតៈ អនាគត និងបច្ចុប្បន្ននោះឯង ហៅថា **គន្ធារម្មណ៍**។ រសមានសមុដ្ឋាន ៤ ដែលជាអតីតៈ, អនាគតៈ និងបច្ចុប្បន្ននោះឯង ហៅថា **រសារម្មណ៍** ។ ផោដ្ឋព្វៈនោះឯង មានសមុដ្ឋាន ៤ ដែលជាអតីតៈ, អនាគតៈ

---

[១៥២] សំ. សឡា.។

[១៥៣] សំ. និ. ។

និងបច្ចុប្បន្ននោះឯង ហៅថា **ផោដ្ឋព្វារម្មណ៍** ។ ធម៌ទាំងឡាយនោះឯង ពោល គឺគោចរ (អារម្មណ៍) មានសមុដ្ឋាន ១, មានសមុដ្ឋាន ២, មានសមុដ្ឋាន ៣ និង មានសមុដ្ឋាន ៤ សូម្បីមិនកើតអំពីសមុដ្ឋានណាៗ ដែលជាអតីតៈ អនាគត និង បច្ចុប្បន្ន ទាំងធម៌ដែលមិនគប្បីពោល និងដែលសល់អំពីធម៌ដែលពោល ហើយ ហៅថា **ធម្មារម្មណ៍** ។

តែអាចារ្យពួកខ្លះពោលថា ធម៌ទាំងឡាយណា សូម្បីមានរូបជាដើម ដែលមិនមកកាន់គន្លង ធម៌ទាំងនោះ ជាធម្មារម្មណ៍មែនពិត; អាចារ្យពួកនោះ ត្រូវបដិសេធដោយសូត្រនេះ ។

ខនេះ សមនឹងពាក្យដែលព្រះសារីបុត្តត្ថេរពោលថា ៖-

"ម្នាលលោកដ៏មានអាយុ ឥន្ទ្រិយទាំង ៥ នេះឯង មានវិស័យផ្សេងៗ គ្នា, មាន គោចរផ្សេងគ្នា, មិនទទួលយកគោចរវិស័យរបស់គ្នានឹងគ្នា (ទទួលចំពោះតែ របស់ខ្លួនឯង) មានចិត្តជាទីពឹង, ចិត្តប៉ុណ្ណោះរមែងទទួលយកគោចរវិស័យរបស់ ឥន្ទ្រិយ ៥ នេះ"[១៥៤] ។

ពិតប្រាកដណាស់ អារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម នៃពួក ឥន្ទ្រិយ ៥ នោះឈ្មោះថា **គោចរវិស័យ**, រូបារម្មណ៍ជាដើមពួកនោះ ដែលចិត្ត

---

[១៥៤] ម. មូ. ។

សោយហើយ ក៏គឺរូបារម្មណ៍នោះឯង; ព្រោះហេតុដូច្នោះ ទើបសម្រេចប្រយោជន៍នេះ, ម្យ៉ាង ការដែលញាណទាំងឡាយ មានទិព្វចក្ខុញាណជាដើម មានរូបជាដើម ក៏រមែងសម្រេចប្រយោជន៍នេះដូចគ្នាដែរ; ព្រោះថា ការកំណត់ដោយន័យដែលពោលថា រូបារម្មណ៍ជាដើមដែលមិនមកកាន់គន្លងនោះឯង ជាអារម្មណ៍របស់ទិព្វចក្ខុញាណជាដើម, តែរូបារម្មណ៍ទាំងនោះ មិនជាធម្មារម្មណ៍ មានហើយដូច្នេះ ។

បណ្ដាអារម្មណ៍មានរូបារម្មណ៍ជាដើមទាំងនោះ អារម្មណ៍មួយៗ រមែងមកកាន់គន្លងក្នុងទ្វារទាំងពីរ ។ ពិតមែន រូបារម្មណ៍ប៉ះខ្ទប់ចក្ខុប្បសាទហើយមកកាន់គន្លងមនោទ្វារក្នុងខណៈនោះឯងទាន់ពេល, អធិប្បាយថា ជាបច្ច័យដល់ភវង្គចលនៈ; សម្ពស្សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍ និងផោដ្ឋព្វារម្មណ៍ ក៏ន័យនេះដែរ ។ ដូចយ៉ាងថា បក្សីហើរមកតាមផ្លូវអាកាស លាក់ខ្លួនហើយលើចុងឈើនោះឯង រមែងប៉ះខ្ទប់មែកឈើផង ស្រមោលរបស់បក្សីនោះ រមែងប៉ះខ្ទប់ផែនដីផង, ការប៉ះខ្ទប់នឹងមែកឈើ និងការបញ្ចេញនៃស្រមោល លើផែនដីរមែងមានក្នុងខណៈដូចគ្នា គឺមិនមុន មិនក្រោយ យ៉ាងណា, ការប៉ះខ្ទប់ចក្ខុប្បសាទជាដើមរបស់រូប ដែលជាបច្ចុប្បន្នជាដើម និងការមកកាន់គន្លងមនោទ្វារ

ព្រោះអំណាចនៃភវង្គញ័រ រមែងមានក្នុងខណៈដូចគ្នានោះឯង មិនមុន មិនក្រោយគ្នា ក៏យ៉ាងនោះដែរ ។

លំដាប់នោះ មហាចិត្តនេះ ក៏កើតឡើងក្នុងអារម្មណ៍ណាមួយនៃអារម្មណ៍ពួកនោះ ដែលជាប់តគ្នាទៅនៃអាវជ្ជនចិត្តជាដើម ដែលកាត់ភវង្គហើយកើតឡើងក្នុងចក្ខុទ្វារជាដើម មានវោដ្ឋវនចិត្តជាទីបំផុត ។ តែថា ក្នុងមនោទ្វារសុទ្ធៗ មិនមានកិច្ចដែលប៉ះខ្ទប់បសាទ, ដោយប្រក្រតី អារម្មណ៍ពួកនេះ រមែងមកកាន់គន្លងដោយអំណាចនៃរូបដែលឃើញហើយ, សំឡេងដែលឮហើយ, ក្លិនដែលធុំហើយ, រសដែលភ្លក្សហើយ និងកាយដែលប៉ះខ្ទប់ហើយប៉ុណ្ណោះ ។

**សួរថា** អារម្មណ៍ពួកនេះ មកកាន់គន្លង (មនោទ្វារ) យ៉ាងណា?

**ឆ្លើយថា** បុគ្គលខ្លះក្នុងលោកនេះ ធ្វើប្រទក្សិណមហាចេតិយ ប្រដាប់តាក់តែងហើយលាបបូកដោយកំបោរ វិចិត្រដោយពណ៌ផ្សេងៗ មានពណ៌ហរិតាល និងមនោសិលាជាដើម មានការដោតទង់ជ័យ និងទង់បដា មានប្រការផ្សេងៗ មានកម្រងផ្កាពន្លឺពន្ធ័ដោយប្រទីប និងមាលារុងរោចន៍ដោយសិរីដែលជាទីមនោរម្យដ៏ក្រៃលែង, ថ្វាយបង្គំដោយបញ្ចង្គប្បតិដ្ឋានទៀបឋានព្រះចេតិយ ១៦ ជាន់, ហើយឈរផ្គងអញ្ជលី ងើបមើលកាន់យកនូវបីតិមានព្រះពុទ្ធជាអារម្មណ៍; កាលបុគ្គលនោះឃើញព្រះចេតិយ ញុំាងបីតិមានព្រះពុទ្ធជាអារម្មណ៍ ឱ្យកើតឡើង

យ៉ាងនេះហើយ ខាងក្រោយទៅនៅក្នុងទីណាមួយ អង្គុយក្នុងស្ថានពេលយប់ និងពេលថ្ងៃរំពឹងហើយ, មហាចេតិយដែលប្រដាប់តាក់តែងហើយដូចគ្នា ដែលមកកាន់គន្លងក្នុងចក្ខុទ្វារនោះឯង ដូចធ្វើប្រទក្សិណហើយថ្វាយបង្គំព្រះចេតិយដូច្នោះដែរ រូបារម្មណ៍រមែងមកកាន់គន្លងដោយអំណាចនៃរូប ដែលខ្លួនឃើញមកពីមុនដោយប្រការដូច្នេះ ។

ក៏កាលបុគ្គលស្តាប់សំឡេងព្រះធម្មកថិក អ្នកពោលធម្មកថា ដោយសំឡេងដ៏ពីរោះ ឬស្តាប់សំឡេងអ្នកសូត្រ (**សរភញ្ញ**) ដែលសូត្រហើយ ដោយសំឡេងដ៏ពីរោះ ខាងក្រោយមក ទើបទៅអង្គុយក្នុងទីណាមួយ ហើយរំពឹងធម្មកថា ឬសំឡេងសរភញ្ញ១ ដូចមកកាន់គន្លងក្នុងសោតទ្វារ និងដូចវេលាឱ្យសាធុការហើយស្តាប់ធម៌ដូច្នោះ, សទ្ទារម្មណ៍ រមែងមកកាន់គន្លងដោយអំណាចនៃសំឡេងដែលខ្លួនឮហើយ ដោយប្រការដូច្នេះ។

ក៏បុគ្គលកាលបានគ្រឿងក្រអូប ឬផ្កាកម្រងដែលមានក្លិនក្រអូប ហើយធ្វើការបូជាលើអាសនៈ ឬលើព្រះចេតិយ ដោយចិត្តមានក្លិនជាអារម្មណ៍ ខាងក្រោយមក ទៅអង្គុយលើទីណាមួយ រំពឹងហើយដល់គន្ធារម្មណ៍១ ហាក់បីដូចជា

មកកាន់គន្លងក្នុងឃានទ្វារ ដូចវេលាដែលខ្លួនធ្វើការបូជា គន្ធារម្មណ៍រមែងមកកាន់គន្លងដោយអំណាចនៃក្លិនដែលខ្លួនធ្លាប់ធុំហើយ មានប្រការដូច្នេះ ។

ក៏បុគ្គលកាលបានខាទនីយៈ និងភោជនីយៈដ៏ប្រណីតហើយ បែងចែកជាមួយនឹងសព្រហ្មចារីទាំងឡាយ ទើបបរិភោគក្នុងពេលក្រោយបានភោជន មានស្ងោរតែលលកជាដើម ក្នុងទីណាមួយ, ហើយរំពឹងថា "ក្នុងកាលនោះ អញបែងចែកភោជនដ៏ប្រណីត ជាមួយនឹងសព្រហ្មចារីទាំងឡាយ ទើបបរិភោគ" រសារម្មណ៍នោះ ដូចមកកាន់គន្លងក្នុងជិវ្ហាទ្វារ ដូចវេលាដែលខ្លួនបរិភោគ, រសារម្មណ៍រមែងមកកាន់គន្លងដោយអំណាចនៃរស ដែលខ្លួនបានភ្លក្សហើយ មានប្រការដូច្នេះ ។

ក៏បុគ្គលកាលប្រើប្រាស់គ្រែ និងតាំង ឬគ្រឿងកម្រាល ឬក៏សំពត់ដណ្ដប់មានសាច់ទន់ មានសម្ផស្សជាសុខ ខាងក្រោយមក ត្រូវដេកលើទីដេកដែលមិនល្អក្នុងទីណាមួយ ក៏រំពឹងថា "កាលមុនអញប្រើគ្រែ, តាំង, កម្រាល និងសំពត់ដណ្ដប់ទន់" ផោដ្ឋព្វារម្មណ៍នោះ ដូចមកកាន់គន្លងក្នុងកាយទ្វារ ហាក់ដូចជាសោយសម្ផស្សដែលល្អដូច្នេះ ផោដ្ឋព្វារម្មណ៍រមែងមកកាន់គន្លងដោយអំណាចនៃការប៉ះពាល់ ដោយប្រការដូច្នេះ ។ ក្នុងមនោទ្វារសុទ្ធៗ កិច្ច គឺការប៉ះខ្ទប់ប្រសាទ (ទាំង ៥) រមែងមិនមានដោយប្រការដូច្នេះ; តាមប្រក្រតីអារម្មណ៍ពួក

នេះ គប្បីជ្រាបថា រមែងមកកាន់គន្លងដោយអំណាចនៃរូបដែលខ្លួនធ្លាប់ឃើញហើយ, សំឡេងដែលបានឮហើយ, ក្លិនដែលបានធុំហើយ, រសដែលធ្លាប់ភ្លក្សហើយ និងផោដ្ឋព្វៈដែលធ្លាប់ប៉ះពាល់ហើយដូច្នេះ ៕

## សម្ដែងអំពីន័យអដ្ឋកថាមុត្តកៈ

ឥឡូវនេះ ក្នុងការដែលអារម្មណ៍មកកាន់គន្លងដោយអំណាចនៃរូបដែលធ្លាប់ឃើញហើយជាដើម តាមប្រក្រតី; មានន័យមួយទៀត **អដ្ឋកថាមុត្តកៈ** (ក្រៅពីអដ្ឋកថា) មួយខាងដើម បណ្ឌិតគប្បីជ្រាបរូបទាំងឡាយ ដែលឃើញហើយជាដើមពួកនេះថា **ទិដ្ឋំ សុតំ** ជាការទាក់ទងគ្នាទាំងពីរបទ ។

ក្នុងពាក្យថា **“ទិដ្ឋំ សុតំ”** នេះ រូបដែលធ្លាប់កាន់យកដោយអំណាចនៃទ្វារ ៥ ឈ្មោះថា **ទិដ្ឋំ**, ក៏រូបជាដើមដែលបុគ្គលមិនបានប្រត្យក្ស, តែកាន់យកដោយការបានឮមក ឈ្មោះថា **សុតំ**, ការជាប់គ្នាដោយបទថា **“ទិដ្ឋំ សុតំ”** ពួកនេះសូម្បីទាំងពីរ ឈ្មោះថា **ឧភយសម្ពន្ធ**។ គប្បីជ្រាបថា អារម្មណ៍ពួកនេះ រមែងមកកាន់គន្លងក្នុងមនោទ្វារ ដោយអំណាចនៃរូប ដែលបានឃើញហើយជាដើម ក្នុងរូបដែលបានឃើញហើយជាដើមនោះ មកកាន់គន្លងដោយអំណាចនៃរូបដែលឃើញហើយ ក្នុងបទថា **“ទិដ្ឋំ សុតំ”** នោះប៉ុណ្ណោះ ខ្ញុំពោលទុកហើយ ដោយ

ន័យទាំងឡាយ ៥ ន័យ ក្នុងខាងក្រោយនោះឯង ។

ក៏អ្នកខ្លះបានឮថា "រូបឈ្មោះថា មានសភាពបែបនេះ កើតដោយបុណ្យដ៏ប្រសើរក្រៃលែងរបស់ព្រះមានព្រះភាគ, ព្រះសូរសៀង ក៏ពីរោះណាស់, ក្លិនផ្កាឈើទាំងឡាយខ្លះ ក្នុងទីខ្លះ ក្រអូបជាទីគាប់ចិត្តក្រៃលែង, រសរបស់ផ្លែឈើទាំងឡាយខ្លះ ក៏ឆ្ងាញ់ក្រៃលែង, សម្ផស្សរបស់សំពត់ស្បៀកដណ្ដប់ជាដើមខ្លះ ក៏ជាសុខក្រៃលែង"។ រូបជាដើមទាំងនេះ គ្រាន់តែស្ដាប់មកប៉ុណ្ណោះ មិនបានប៉ះខ្ទប់បសាទមានចក្ខុប្បសាទជាដើម របស់បុគ្គលនោះឡើយ រមែងមកកាន់គន្លងក្នុងមនោទ្វារ ។ លំដាប់នោះ ចិត្តនោះរបស់បុគ្គលនោះរមែងប្រព្រឹត្តទៅដោយអំណាចនៃការជ្រះថ្លាក្នុងរូប ឬក្នុងសំឡេង ឬថា ប្រព្រឹត្តទៅក្នុងក្លិនជាដើម ដោយអំណាចនៃការថ្វាយទានដល់ព្រះអរិយបុគ្គលទាំងឡាយ ឬថាដោយអំណាចនៃការអនុមោទនាក្នុងទានទាំងឡាយ ដែលបុគ្គលដទៃទាំងឡាយថ្វាយហើយ រូបជាដើមទាំងនេះ រមែងមកកាន់គន្លងក្នុងមនោទ្វារ ដោយអំណាចនៃការបានស្ដាប់ហើយ ដោយប្រការដូច្នេះ ។ ប្រការមួយទៀត រូបជាដើមដែលឃើញមកហើយ, ធ្លាប់ស្ដាប់មកហើយ, តាមដែលពោលមកហើយ គឺអារម្មណ៍ទាំងនោះរមែងមកកាន់គន្លងក្នុងមនោទ្វារ ដោយការចងជាប់គ្នានឹងរូបដែលឃើញហើយ និងសំឡេងដែលឮហើយ ដោយមិនប៉ះខ្ទប់នឹងចក្ខុប្បសាទជាដើមនោះឯង ដោយ

ន័យជាដើមថា "រូបដូចនេះរបស់ព្រះពុទ្ធនោះ ទ្រង់ឧប្បត្តិឡើងក្នុងកាលតទៅនឹងមាន" ទីនេះ មហាចិត្តនេះ ក៏មានអារម្មណ៍ណាមួយ ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមនោះ របស់បុគ្គលនោះ ក៏ប្រព្រឹត្តទៅដោយន័យដែលពោលទុកឮដ៏ខាងក្រោយនោះឯង អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមទាំងនោះរមែងមកកាន់គន្លងក្នុងមនោទ្វារ ដោយអំណាចនៃការសម្ពន្ធរូបដែលឃើញហើយនិងសំឡេងដែលឮហើយទាំងពីរ ដោយប្រការដូច្នេះ ។

ក៏ពាក្យដែលពោលនេះត្រឹមតែផ្លូវ (តួយ៉ាង) ប៉ុណ្ណោះ ចំណែកដោយពិស្តារ បណ្ឌិតគប្បីជ្រាបការមកកាន់គន្លងក្នុងមនោទ្វាររបស់អារម្មណ៍ទាំងនោះៗឯង ដោយអំណាចនៃសទ្ធា, ការពេញចិត្ត, អាការ, បរិវិតក្ក, ទិដ្ឋិ, ការរំពឹងមើលនិងខន្តីជាដើម; ក៏អារម្មណ៍ដែលមកកាន់គន្លងទាំងនេះ ដោយអាការយ៉ាងនេះពិតខ្លះ មិនពិតខ្លះ ព្រោះហេតុដូច្នោះ ន័យនេះ ព្រះអដ្ឋកថាចារ្យទើបមិនកាន់យក ក្នុងអដ្ឋកថា ដោយពាក្យតាមដែលពោលមកនេះ ជវ៌នដែលមានអារម្មណ៍មួយៗ បណ្ឌិតគប្បីជ្រាបថា រមែងកើតក្នុងទ្វារទាំងពីរៗ; ពិតមែន ជវនចិត្តដែលមានរូបជាអារម្មណ៍ រមែងកើតឡើងក្នុងចក្ខុទ្វារខ្លះ, ក្នុងមនោទ្វារខ្លះ; សូម្បីសទ្ទារម្មណ៍ជាដើម ក៏ន័យនេះដែរ ។

ក្នុងទ្វារទាំងពីរនេះ ជវនចិត្តដែលមានរូបជាអារម្មណ៍ កាលកើតឡើងក្នុង

មនោទ្វារមាន ៣ យ៉ាងប៉ុណ្ណោះ គឺ

**១-ទានមយៈ** ជវនចិត្តកើតតែពីការឱ្យទាន

**២-សីលមយៈ** ជវនចិត្តកើតតែពីការរក្សាសីល

**៣-ភាវនាមយៈ** ជវនចិត្តកើតតែពីការចម្រើនភាវនា ។

ក្នុងជវនចិត្តដែលកើតឡើងតែពីទានមយៈជាដើមទាំងនោះ ជវ៏នមួយៗ ក៏មាន ៣ យ៉ាង គឺកាយកម្ម, វចីកម្ម និងមនោកម្ម; សូម្បីក្នុងសទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ក៏ន័យនេះដែរ ។ បណ្ដាជវនចិត្តមានរូបារម្មណ៍ជាដើមទាំងនោះ មហាកុសលចិត្ត ១ ដួង កាលធ្វើរូបឱ្យជាអារម្មណ៍ហើយកើតឡើង រមែងធ្វើពណ៌ ពោលគឺសុភនិមិត្តយ៉ាងណាមួយ ក្នុងផ្កាឈើ សំពត់ និងធាតុទាំងឡាយដែលមានពណ៌ខៀវ ពណ៌លឿង ពណ៌ ក្រហម និងពណ៌ស ដែលគួរប្រាថ្នា គួរត្រូវការ គួរពេញចិត្ត និងគួរត្រេកអរឱ្យជាអារម្មណ៍ហើយកើតឡើង ។

**សួរថា** ក៏ឥដ្ឋារម្មណ៍ (អារម្មណ៍គួរប្រាថ្នា) នេះជាទីតាំងនៃលោភៈ មិនមែនឬ? ចុះដូចម្ដេច ចិត្តនេះទើបកើតមានឈ្មោះថា **កុសល**?

**ឆ្លើយថា** ដែលមានឈ្មោះថា **កុសល** ដោយអំណាចនៃការកំណត់ (និយមិត), ដោយអំណាចនៃការប្រែប្រួល (**បរិណាមិត**), ដោយអំណាចនៃការ

ប្រព្រឹត្តល្អ (**សមុទាចារ**) និងដោយអំណាចនៃការតាំងចិត្ត (**អាភុជិត**) ។

ពិតណាស់ ចិត្តរបស់បុគ្គលណា ឈ្មោះថា **កំណត់** ព្រោះការធ្វើកុសលថា "កុសលប៉ុណ្ណោះ គឺអញគួរធ្វើ" ។ ដែលឈ្មោះថា **ប្រែប្រួល** ព្រោះការញ៉ាំងអកុសលដែលប្រព្រឹត្តទៅឱ្យត្រឡប់ ហើយធ្វើកុសលវិញ ។ ដែលឈ្មោះថា **ប្រព្រឹត្តល្អ** ដោយការប្រព្រឹត្តកុសលនោះឯង ដោយការធ្វើរឿយៗ; និងការចងចិត្ត (នឹកគិត) ដោយឧបាយត្រូវទំនង ដោយឧបនិស្ស័យទាំងឡាយ មានការនៅក្នុងប្រទេសដ៏សមគួរ ១, ការសេពគប់សប្បុរស ១, ការស្តាប់ព្រះសទ្ធម្ម ១ និងភាវៈនៃបុគ្គលជាអ្នកធ្វើបុណ្យទុកហើយក្នុងកាលមុន ១ ។ ធម្មតាថា កុសលរមែងកើតឡើងដល់ចិត្តនោះ ដោយអំណាចនៃការកំណត់ ដោយអំណាចនៃការប្រែប្រួល ដោយអំណាចនៃការប្រព្រឹត្តល្អ និងដោយអំណាចនៃការតាំងចិត្ត (នឹកគិត) នេះ ។

ក៏ការដែលមហាកុសលចិត្តជាសោមនស្សសហគតៈ ក្នុងចិត្តនេះ គប្បីជ្រាបដោយអំណាចនៃអារម្មណ៍ ។ ពិតណាស់ ចិត្តនេះ ឈ្មោះថា សោមនស្សសហគតៈ, ព្រោះកាកើតឡើងក្នុងអារម្មណ៍ដែលគួរជាទីប្រាថ្នា និងហេតុទាំងឡាយមានសភាពជាអ្នកច្រើនដោយសទ្ធាជាដើម ក៏កើតឡើងក្នុងចិត្តដែលមានសោមនស្សសហគតៈនេះដូចគ្នា; ព្រោះថា សោមនស្សរមែងមិនកើតដល់អ្នក

មិនមានសទ្ធា និងជាមិច្ឆាទិដ្ឋិទាំងឡាយ សូម្បីឃើញរូបតថាគតដែលជាឥដ្ឋារម្មណ៍ ដោយចំណែកមួយ និងបុគ្គលពួកណាមិនឃើញអានិសង្សក្នុងការសាងកុសល, សោមនស្សក៏រមែងមិនកើតឡើងដល់បុគ្គលពួកនោះ សូម្បីបុគ្គលពួកដទៃ ជួយឱ្យកើតឧស្សាហៈ, សាងកុសល; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបការដែលកុសលចិត្ត ជាសោមនស្សសហគតៈក្នុងទីនេះ យ៉ាងនេះ គឺភាពជាអ្នកច្រើនដោយសទ្ធា, ភាពជាអ្នកមានទិដ្ឋិបរិសុទ្ធ និងភាពជាអ្នកមានប្រក្រតីឃើញអានិសង្ស (នៃកុសល)។

ម្យ៉ាងទៀតធម៌ ១១ យ៉ាង រមែងប្រព្រឹត្តទៅ ព្រោះអាស្រ័យបីតិសម្ពោជ្ឈង្គគឺ

**១. ពុទ្ធានុស្សតិ**

**២. ធម្មានុស្សតិ**

**៣. សង្ឃានុស្សតិ**

**៤. សីលានុស្សតិ**

**៥. ចាគានុស្សតិ**

**៦. ទេវតានុស្សតិ**

**៧. ឧបសមានុស្សតិ**

**៨~លូខបុគ្គលបរិវជ្ជនតា** ការវៀរចាកបុគ្គលដែលសៅហ្មង

**៩~សិនិទ្ធបុគ្គលបរិវជ្ជនតា** ការគប់រកបុគ្គលអ្នកគួរស្រឡាញ់

**១០~បសាទនីយសុត្តន្តបច្ចវេក្ខណតា** ការពិចារណាព្រះសូត្រ ជាទីតាំងនៃសេចក្តីជ្រះថ្លា ។

**១១~តទធិមុត្តតា** ភាពជាអ្នកបង្អោនទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ។

ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបការដែលចិត្តសោមនស្សសហគតៈ ក្នុងទីនេះ ដោយហេតុទាំងឡាយសូម្បីទាំងនេះ; ចំណែកសេចក្តីពិស្តារ របស់ធម៌ដែលជាហេតុទាំងនេះនឹងជាក់ច្បាស់ក្នុង **ពោជ្ឈង្គវិភង្គ** ។

ក៏បណ្ឌិតគប្បីជ្រាបការដែលចិត្តជាសោមនស្សសហគតៈជាធម៌សម្បយុត្តដោយញាណក្នុងទីនេះដោយហេតុទាំងនេះ គឺ**ដោយកម្ម, ដោយការកើតឡើង, ដោយការចាស់ក្លានៃឥន្ទ្រិយ និងដោយការឆ្ងាយចាកកិលេស**[*] ។

ពិតណាស់ បុគ្គលណាណែនាំធម៌ដល់ពួកជនដទៃ, គឺឱ្យសិក្សាសិប្បាយតនៈ (គឺវិជ្ជាជិះដំរី វិជ្ជាជិះសេះ និងបើករថជាដើម) កម្មាយតនៈ(គឺវិជ្ជាកសិកម្ម ពាណិជ្ជកម្ម និងហត្ថកម្មជាដើម) និងអវិជ្ជដ្ឋាន (គឺតារាសាស្ត្រ ហោរាសាស្ត្រ

---

[*] កម្មតោ ឧប្បត្តិតោ ឥន្ទ្រិយបរិបាកតោ កិលេសទូរីភាវតោ ។

វេជ្ជសាស្ត្រ និងសេយ្យសាស្ត្រ) ដែលមិនមានទោស, ថ្វាយគ្រឿងសក្ការៈ អារាធនាធម្មកថិកឱ្យសម្ដែងធម៌, តាំងការប្រាថ្នាថា "ក្នុងកាលខាងមុខ ខ្ញុំសូមបានជាអ្នកប្រាជ្ញ" ហើយថ្វាយទានមានប្រការផ្សេងៗ, កុសលដែលជាញាណសម្បយុត្ត កាលកើតដល់បុគ្គលនោះ ចូលទៅអាស្រ័យកម្មមានសភាពបែបនេះ ហើយរមែងកើតឡើង; ម្យ៉ាងទៀត បើបុគ្គលនោះ កើតក្នុងលោកដែលមិនមានការបៀតបៀន បទនៃធម៌ដែលងាយស្រួល រមែងប្រាកដដល់គេក្នុងទីនោះ ។

កុសលចិត្តញាណសម្បយុត្ត កាលកើតក៏អាស្រ័យ **ការកើតឡើង** ដោយន័យនេះថា "ម្នាលភិក្ខុទាំងឡាយ កាលកើតឡើងនៃសតិយឺត, តែថា សត្វនោះរមែងជាអ្នកមានចំណែកនៃគុណវិសេសយ៉ាងឆាប់រហ័ស" [១៥៥] ។

ក៏កុសលញាណសម្បយុត្តចិត្ត កាលកើតសូម្បីព្រោះអារម្មណ៍ចាស់ក្លានៃឥន្ទ្រិយរបស់បុគ្គលអ្នកប្រកប គឺការចាស់ក្លានៃឥន្ទ្រិយរបស់អ្នកពន្លុះពួក ១០ នៃវិបស្សនា (វិបស្សនាញាណ ១០) កើតឡើង ។

ក៏កិលេសទាំងឡាយដែលបុគ្គលណា គ្របសង្កត់ហើយ, កុសលញាណ-សម្បយុត្តចិត្តរបស់បុគ្គលនោះកាលកើត ក៏អាស្រ័យការដែលខ្លួនជាអ្នកឆ្ងាយចាកកិលេសហើយទើបកើតឡើង ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖-

---

[១៥៥] អំ. ចតុក្ក. ។

**“យោគា វេ ជាយតេ ភូរិ អយោគា ភូរិ សង្ខយោ;**
**ឯតំ ទ្វិធា បថំ ញត្វា ភវាយ វិភវាយ ច;**
**តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ។**

ភូរិបញ្ញារមែងកើតព្រោះការប្រកប (ព្យាយាម) និងការអស់ទៅនៃភូរិបញ្ញា រមែងកើតព្រោះការមិនប្រកប (ព្យាយាម) បណ្ឌិតគប្បីជ្រាបផ្លូវបែកជា ២ នៃការចម្រើន និងការសូន្យទៅនេះឯង ហើយគប្បីតាំងខ្លួនទុកដោយអាការដែលបញ្ញាស្មើដោយផែនដី (ភូរិបញ្ញា) នឹងចម្រើនកើតឡើង”[១៥៦] * ។

បណ្ឌិតគប្បីជ្រាបការដែលកុសលចិត្តជាញាណសម្បយុត្តដោយហេតុទាំងនេះ គឺដោយកម្ម, ដោយការកើតឡើង, ដោយការចាស់នៃឥន្ទ្រិយ និងដោយភាពជាអ្នកឆ្ងាយអំពីកិលេស ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀតធម៌ ៧ យ៉ាង រមែងប្រព្រឹត្តទៅ ព្រោះអាស្រ័យធម្មវិចយសម្ពោជ្ឈង្គ គឺ

---

[១៥៦] ខុ. ធ. ។ * សំដៅសេចក្ដីថា ការចម្រើនឡើងភូរិបញ្ញាយ៉ាងណា, បុគ្គលក៏គប្បីតម្កល់ខ្លួនយ៉ាងនោះដែរ (អត្តនោមតិ) ។

**១. បរិបុច្ឆកតា** ការសាកសួរនូវសេចក្ដីដែលអាស្រ័យខន្ធ ធាតុ អាយតនៈជាដើម ។

**២. វត្ថុវិសទកិរិយតា** ការធ្វើវត្ថុខាងក្នុង និងខាងក្រៅឱ្យស្អាត *

**៣. ឥន្ទ្រិយសមត្តបដិបាទនតា** ការតម្រូវឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមឱ្យស្មើគ្នា ។

**៤. ទុប្បញ្ញបុគ្គលបរិវជ្ជនតា** ការវៀរចាកបុគ្គលអ្នកមានបញ្ញាខ្សោយ

**៥. បញ្ញវន្តបុគ្គលសេវនតា** ការគប់រកបុគ្គលអ្នកមានបញ្ញា

**៦. គម្ភីរញ្ញាណចរិយបច្ចវេក្ខណតា** ការពិចារណាចរិយាដោយញាណដ៏ជ្រាលជ្រៅ ។

**៧. តទធិមុត្តតា** ការបង្អោនចិត្ត ដើម្បីឱ្យធម្មវិចយសម្ពោជ្ឈង្គនោះកើតឡើង ។

បណ្ឌិតគប្បីជ្រាបការដែលកុសលចិត្តជាញាណសម្បយុត្តក្នុងទីនេះ ដោយហេតុទាំងឡាយនេះ ។ ចំណែកសេចក្ដីពិស្ដារក្នុងហេតុទាំង ៧ នេះ នឹងជាក់ច្បាស់ក្នុង**ពោជ្ឈង្គវិភង្គ**។

---

* អ. យោ. វត្ថុខាងក្នុងមានសរីរៈជាដើម វត្ថុខាងក្រៅមានចីវរជាដើម ។

ក៏កុសលដែលកើតឡើងដោយញាណសម្បយុត្ត ដោយអាការយ៉ាងនេះ ឈ្មោះថា **អសង្ខារិក** ព្រោះការដែលចិត្តជាសភាវៈដោយអសង្ខារ (គឺមិនមានការតាក់តែង ឬមិនមានការបបួលដឹកនាំ) ដោយមិនមានប្រយោគ (ការប្រកប) ដោយមិនគិតដោយឧបាយ; កុសលចិត្តដែលឈ្មោះថា អសង្ខារិកនេះនោះ មានពណ៌ដែលជាទីប្រាថ្នាជាអារម្មណ៍ទើបកើតដោយពិត រមែងកើតដោយការកំណត់ (និយម) ៣ យ៉ាង គឺទានមយៈ, សីលមយៈ និងភាវនាមយៈ ។

**សួរថា** កុសលញាណសម្បយុត្តចិត្តដែលឈ្មោះថា អសង្ខារិកក្នុងទានមយៈជាដើមនោះ កើតឡើងបានយ៉ាងណា?

**ឆ្លើយថា** ក៏កាលណា បុគ្គលបានផ្កាឈើយ៉ាងណាមួយ ក្នុងបណ្ដាផ្កាឈើដែលមានពណ៌ ខៀវ លឿង ក្រហម និងសជាដើម ដោយគិតថា "អញថ្វាយពណ៌ជាទាន" ទើបបូជានូវរតនៈទាំងឡាយមានព្រះពុទ្ធរតនៈជាដើម, កាលនោះបុណ្យរមែងសម្រេចដោយទាន ។ ក្នុងទានមយៈនោះ មានរឿងដូចនេះថា ៖-

បានឮថា អ្នករក្សាឃ្លាំងឈ្មោះ **សង្ឃមិត្ត** បានសំពត់ដែលវិចិត្រដោយមាសមួយផ្ទាំងទើបគិតថា "សូម្បីសំពត់នេះមានពណ៌ដូចមាស, សូម្បីព្រះសម្មាសម្ពុទ្ធ ក៏មានឆវីវណ្ណដូចមាសដែរ, សំពត់ដែលមានពណ៌ដូចមាស សមគួរដល់អ្នកដែលមានសម្បុរស្បែកដូចមាសប៉ុណ្ណោះ, ឯការឱ្យពណ៌នឹងមានដល់ពួកយើង"

ទើបឱ្យគេលើកឡើងទៅដណ្តប់ព្រះមហាចេតិយ ។ កុសលញ្ញាណសម្បយុត្តចិត្ត សូម្បីមានសភាពបែបនេះ បណ្ឌិតគប្បីជ្រាបថា ជា**ទានមយៈ** ។

ក៏កាលណា បុគ្គលបានទេយ្យធម៌ (វត្ថុដែលគួរឱ្យ) ដូចយ៉ាងនោះឯង ហើយបូជាព្រះរតនត្រ័យមានព្រះពុទ្ធជាដើម ដោយគិតថា “នោះជាវង្សត្រកូល, ជាបែបផែនត្រកូល, ជាប្រពៃណីត្រកូល និងជាវត្តនៃត្រកូលរបស់អញ” , កាលនោះជា **សីលមយៈ** ។

ក៏កាលណា បុគ្គលបានធ្វើការបូជាព្រះត្រៃរតន៏ដោយវត្ថុដូចនេះ ហើយផ្តើមតាំងការអស់ទៅ សូន្យទៅ ដោយមនសិការថា “ពណ៌នេះនឹងដល់នូវការអស់ទៅ, នឹងដល់នូវការសូន្យទៅ” , កាលនោះគប្បីជ្រាបថាជា **ភាវនាមយៈ**។ ក៏កុសលញ្ញាណសម្បយុត្តចិត្តជាទានមយៈប្រព្រឹត្តទៅហើយក្នុងកាលណា ការប្រព្រឹត្តទៅរបស់បុគ្គលអ្នកបូជាព្រះត្រៃរត្ន ដោយដៃរបស់ខ្លួន, ក្នុងកាលនោះ ជា **កាយកម្ម** ។ ក្នុងកាលណា បុគ្គលបូជាព្រះត្រ័យរត្នទើបបង្គាប់ឱ្យបុត្រ ភរិយា ទាសៈ កម្មករ និងបុរសជាដើមបូជា, ក្នុងពេលនោះ គប្បីជ្រាបថាជា **វចីកម្ម** ។ ក្នុងពេលណា កាលបុគ្គលប្រារព្ធវត្ថុទានដែលមានហើយ មានប្រការតាមដែលពោលហើយនោះៗ ឯង ទើបគិតថា “អញនឹងឱ្យពណ៌ជាទាន (**វណ្ណទាន**)” , ក្នុងពេលនោះ គប្បីជ្រាបថាជា**មនោកម្ម** ។

ម្យ៉ាងទៀត សំឡឹងដល់សំនួន (បរិយាយ) ព្រះវិន័យហើយកុសលចិត្ត នោះឈ្មោះថា **ជាទាន** ដោយលក្ខណៈនេះថា “ការបន្លឺវាចាថា អញនឹងថ្វាយ នឹងធ្វើ” [១៥៧], តែបើសំឡឹងដល់សំនួន (បរិយាយ) ព្រះអភិធម្មហើយ ចិត្តនោះ រមែងជាកុសល ចាប់ផ្តើមពីពេលដែលចិត្តគិតប្រារព្ធដល់វត្ថុដែលមានថា “អញ នឹងឱ្យ” ។ លោកអធិប្បាយទុកថា ក្នុងកាលដទៃទៀតបុគ្គលនោះនឹងធ្វើកិច្ចដែល គួរធ្វើដោយកាយ និងវាចា ។ ទានមយៈតាមដែលពោលមកនេះ ទើបមាន ៣ យ៉ាង ដោយអំណាចនៃកាយកម្ម វចីកម្ម និងមនោកម្ម ។

ក៏ក្នុងកាលណា បុគ្គលបានវត្ថុ មានប្រការតាមដែលពោលហើយ រមែង បូជាព្រះត្រៃរត្នដោយដៃរបស់ខ្លួន ដោយអំណាចនៃវង្សត្រកូលជាដើម, ក្នុងកាល នោះ កុសលចិត្តនោះ ក៏ជាសីលមយៈ ឬកាយកម្ម ។ ក្នុងកាលណា បុគ្គលបង្គាប់ ឱ្យបុត្រ និងភរិយាជាដើម ដោយអំណាចនៃវង្សត្រកូលជាដើម ហើយបូជា, ក្នុង កាលនោះ កុសលចិត្តជាវចីកម្ម ។ ក្នុងកាលណា បុគ្គលគិតថា “អញនឹងឱ្យពណ៌ ជាទាន (**វណ្ណទាន**)” ព្រោះប្រារព្ធវត្ថុដែលមានហើយថា “នេះជាវង្សនៃត្រកូល ជាបែបផែននៃត្រកូល ជាប្រពៃណីនៃត្រកូល ជាវត្តនៃត្រកូលរបស់អញ” , ក្នុងកាលនោះ កុសលចិត្តនោះ ក៏ជាមនោកម្ម ។ កុសលចិត្តដែលជាសីលមយៈ

---

[១៥៧] វិនយ. ។

មាន ៣ យ៉ាង ដោយអំណាចនៃកាយកម្ម វចីកម្ម និងមនោកម្ម មានប្រការដូច្នេះ ។

ចំណែកក្នុងកាលណា បុគ្គលបានវត្ថុមានប្រការដែលពោលហើយនោះ កាលបើបូជាព្រះត្រ័យរត្ន ហើយដើរចង្ក្រម ក៏ផ្តើមការអស់ទៅសូន្យទៅ, ក្នុងកាលនោះ កុសលញាណសម្បយុត្តចិត្តដែលជាភាវនាមយៈ ជាកាយកម្ម ។ កាលបុគ្គលផ្តើមការពិចារណាដោយវាចា ក៏ជាវចីកម្ម ។ កាលបុគ្គលមិនឱ្យចំណែកនៃកាយ និងវាចាញាប់ញ័រ (កម្រើក) ផ្តើមនូវការពិចារណាដោយចិត្តប៉ុណ្ណោះ ក៏ជាមនោកម្មតែម្យ៉ាង; កុសលញាណសម្បយុត្តចិត្ត ជាភាវនាមយៈ មាន ៣ យ៉ាង ដោយអំណាចនៃកាយ វាចា និងចិត្ត ដោយប្រការដូច្នេះ ។ ក្នុងអធិការនេះ ព្រះធម្មរាជា (ព្រះសម្មាសម្ពុទ្ធ) ទ្រង់សម្តែងចែកកុសលដែលមានរូបារម្មណ៍ដោយកម្ម និងទ្វារ ៩ យ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដោយប្រការដូច្នេះ; សទ្ទារម្មណ៍ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

សេចក្តីពិត កុសលចិត្តនេះ ធ្វើសំឡេងដែលជាទីតាំងនៃសេចក្តីត្រេកអរក្នុងសំឡេងស្គរជាដើម ឱ្យជាអារម្មណ៍ ហើយទើបកើតឡើងដោយការកំណត់ ៣ យ៉ាង ដោយន័យដែលពោលមកហើយនោះឯង ។ បណ្តាកុសលចិត្ត មានទានមយៈជាដើមនោះ ឈ្មោះថា សំឡេងអ្នកណាមិនអាចដើម្បីដាក់ទុកក្នុងដៃហើយឱ្យ ដូចដកឫសឈូកឡើង ឬដូចជាដាក់ក្តាប់ផ្កាឧប្បលក្នុងដៃបាន, តែកាលបុគ្គល

ធ្វើសំឡេងព្រមទាំងវត្ថុ ហើយឱ្យ ឈ្មោះថា ឱ្យនូវសំឡេងជាទាន; ព្រោះហេតុដូច្នោះ ក្នុងកាលណា បុគ្គលគិតថា “អញនឹងឱ្យសំឡេងជាទាន” ទើបធ្វើការបូជាព្រះត្រៃរត្នដោយគ្រឿងតន្ត្រីយ៉ាងណាមួយ មានស្គរ និងស្គរសម្ភោរជាដើម, ហើយឱ្យឈប់គ្រឿងតន្ត្រីមានស្គរជាដើម ដោយគិតថា “អញនឹងឱ្យសំឡេងរបស់អញជាទាន” , ទើបឱ្យភេសជ្ជៈ ប្រេង និងទឹកអំពៅជាដើម ដោយបន្លឺសំឡេងថ្វាយភិក្ខុអ្នកជាធម្មកថិក, ឃោសនាការស្តាប់ធម៌, សូត្រសរភញ្ញ, ពោលធម្មកថា, ពោលឧបនិសន្នកថា (ពាក្យពោលក្នុងទីជិត) និងអនុមោទនាកថា; ក្នុងកាលនោះ កុសលចិត្តនោះ ជាទានមយៈ ។ ក្នុងកាលណា បុគ្គលធ្វើវិធីយ៉ាងនោះឯង ដោយអំណាចនៃវង្សត្រកូលជាដើម ដោយអំណាចនៃវត្ត, ក្នុងកាលនោះកុសលចិត្តនោះ ជាសីលមយៈ ។ ក្នុងកាលណា បុគ្គលធ្វើវិធីទាំងអស់នោះ ហើយផ្តើមពិចារណាថា “សំឡេងនេះមានប្រមាណប៉ុណ្ណេះ សូម្បីមានប្រមាណប៉ុនព្រហ្មលោក ក៏នឹងដល់នូវការអស់ទៅ និងដល់ការសូន្យទៅ” , ក្នុងកាលនោះ កុសលចិត្តនោះ ជាភាវនាមយៈ ។

បណ្តាបុញ្ញកិរិយាវត្ថុទាំងនោះ នឹងពោលដោយកុសលចិត្ត ដែលជាទានមយៈសិន ក្នុលកាលណាបុគ្គលកាន់យកគ្រឿងតន្ត្រីមានស្គរជាដើម ធ្វើការបូជាព្រះត្រៃរត្ន ដោយដៃរបស់ខ្លួន, សូម្បីតាំងទុកដើម្បីត្រូវការបូជាជាប្រចាំ ក៏ដាក់

ទុកដោយដៃរបស់ខ្លួន, តែងដើរឃោសនាការស្តាប់ធម៌, ទៅពោលធម្មកថា និងសូត្រសរភញ្ញ ដោយគិតថា "អញនឹងឱ្យសំឡេងរបស់អញជាទាន" , ក្នុងកាលនោះកុសលចិត្តនោះ ក៏ជាកាយកម្ម ។ ក្នុងកាលណា បុគ្គលបង្គាប់ជនដទៃថា "នែអ្នកទាំងឡាយ អ្នកចូរទៅ, ចូរធ្វើសំឡេងរបស់ពួកយើងឱ្យជាទាន បូជាព្រះត្រៃរត្ន" , ដោយគិតថា "អញនឹងឱ្យរបស់អញជាទាន" ទើបប្រើបុគ្គលដទៃថា "ពួកអ្នកចូរដាក់ស្គរសម្ភោរនេះ ត្រង់ទីលានព្រះចេតិយ" , រមែងឃោសនាធម្មស្សវនៈ (ការស្តាប់ធម៌) ដោយខ្លួនឯង, ពោលធម្មកថា និងសូត្រសរភញ្ញ, ក្នុងកាលនោះ កុសលចិត្តជាវចីកម្ម ។ ក្នុងកាលណា បុគ្គលមិនឱ្យចំណែកនៃកាយនិងវាចាកម្រើកញ័រ លះវត្ថុដែលមានដោយចិត្តថា "អញនឹងឱ្យសំឡេងជាទាន", ក្នុងកាលនោះ កុសលចិត្តនោះ ជាមនោកម្ម ។

សូម្បីកុសលក្នុងភាវនាមយៈ ក្នុងកាលណា បុគ្គលកំពុងដើរ ផ្តើមការអស់ទៅ ការសូន្យទៅក្នុងសំឡេង, ក្នុងកាលនោះ កុសលចិត្តជាកាយកម្ម ។ ក៏ឬថា កាលបុគ្គលមិនញុំាងចំណែកនៃកាយឱ្យកម្រើក ពិចារណាតាមវាចា កុសលចិត្តដែលជាភាវនាមយៈ ក៏ជាវចីកម្ម ។ កាលបុគ្គលមិនឱ្យកាយ និងវាចាកម្រើក ពិចារណាហើយនូវសទ្ទាយតនៈដោយចិត្តប៉ុណ្ណោះ កុសលចិត្តដែលជាភាវនា ក៏ជាមនោកម្ម ។ ព្រះធម្មរាជាទ្រង់សម្តែងចែកហើយនូវកុសលចិត្ត សូម្បីមានសទ្ទា

រម្មណ៍ដោយកម្ម និងទ្វារ ៩ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ យ៉ាង ដូចបាន ពណ៌នាមកនេះ ។

កុសលចិត្តនេះធ្វើក្លិនដែលគួរត្រេកអរ សូម្បីក្នុងក្លិនដែលកើតឡើងពីឫសឈើជាដើម ឱ្យជាអារម្មណ៍ ហើយកើតឡើងដោយការកំណត់ ៣ យ៉ាង ដោយន័យដែលពោលហើយក្នុងខាងក្រោយនោះឯង; ក្នុងកាលណា បុគ្គលបានគ្រឿងក្រអូបណាមួយ ក្នុងក្លិនទាំងឡាយ មានក្លិនដែលកើតពីឫសឈើជាដើម ហើយចងចិត្ត (នឹកគិត) ដោយអំណាចនៃក្លិន ហើយគិតថា “អញនឹងឱ្យក្លិនរបស់អញជាទាន” ទើបបូជាព្រះពុទ្ធរតនៈជាដើម, ក្នុងកាលនោះ កុសលចិត្ត ក៏ជាទានមយៈ ។ បណ្ឌិតគប្បីជ្រាបសេចក្តីពិស្តារ ដោយន័យដែលពោលទុកក្នុងការឱ្យពណ៌ជាទាននោះឯង; ព្រះធម្មរាជាទ្រង់សម្តែងចែកកុសលចិត្ត សូម្បីមានក្លិនជាអារម្មណ៍ ដោយកម្ម និងទ្វារ ៩ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ យ៉ាង ដោយប្រការដូច្នេះ ។

ក៏កុសលចិត្តដែលធ្វើរសជាទីត្រេកអរ ក្នុងរសទាំងឡាយ ដែលកើតពីឫសជាដើម ឱ្យជាអារម្មណ៍ហើយកើតដោយការកំណត់ ៣ យ៉ាង ដោយន័យដែលពោលហើយខាងក្រោយនោះឯង; ក្នុងកាលណា បុគ្គលបានរសដែលគួរត្រេកអរណាមួយ ក្នុងរសទាំងឡាយដែលកើតពីឫសជាដើមនោះ ហើយរំពឹង

ដោយអំណាចនៃរស **រមែងឱ្យ** គឺរមែងលះបង់ដោយគិតថា "អញនឹងឱ្យរសរបស់អញជាទាន" ក្នុងកាលនោះ កុសលចិត្តនោះ ជាទានមយៈ ។ គប្បីជ្រាបសេចក្តីទាំងពួងដោយពិស្តារតាមន័យដែលពោលទុកក្នុងការឱ្យពណ៌ជាទាន ។ ក៏ក្នុងកុសលចិត្តដែលជាសីលមយៈនេះ មានរឿងទាំងឡាយមកក្នុងមហាអដ្ឋកថា តាំងពីរឿងព្រះបាទទុដ្ឋគាមណីអភ័យ ទ្រង់ព្រះតម្រិះថា "ធម្មតាការមិនថ្វាយសង្ឃទានហើយបរិភោគ អញមិនធ្លាប់ប្រព្រឹត្តទេ" ទើបឱ្យទានដល់ភិក្ខុប្រមាណ ១.២០០[*] រូប ហើយទើបសោយក្រយាហារមានរសល្អ ។ សេចក្តីប្លែកគ្នាមានត្រឹមប៉ុណ្ណេះ ។ ព្រះធម្មរាជាទ្រង់ចែកកុសលចិត្តសូម្បីមានរសជាអារម្មណ៍ ដោយកម្ម និងទ្វារ ៩ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុនោះឯង ។

សូម្បីផោដ្ឋព្វារម្មណ៍ មហាភូតរូប ៣ គឺ **បឋវីធាតុ, តេជោធាតុ** និង **វាយោធាតុ** ឈ្មោះថា **ផោដ្ឋព្វារម្មណ៍** ។ ក្នុងឋានៈនេះ បណ្ឌិតមិនគួរធ្វើការប្រកបដោយអំណាចនៃធាតុទាំង ៣ នេះ គប្បីធ្វើការប្រកបដោយអំណាចនៃគ្រែ និងតាំងជាដើម ។ ពិតណាស់ ក្នុងកាលណា បុគ្គលបានវត្ថុដែលគួរប៉ះពាល់ (គួរពាល់ត្រូវ) គួររីករាយយ៉ាងណាមួយ ក្នុងវត្ថុទាំងឡាយមានគ្រែ និងតាំងជា

---

[*] ច្បាប់ខ្លះថា ១០១២ រូប (ទ្វាទសន្នំ ភិក្ខុសហស្សានំ) ។

ដើម ហើយគិតរំពឹងដល់វត្ថុនោះ ដោយអំណាចនៃការពាល់ត្រូវ រមែងឱ្យ គឺថា រមែងបរិច្ចាគដោយគិតថា “អញនឹងឱ្យផោដ្ឋព្វៈរបស់អញជាទាន” , ក្នុងកាលនោះ កុសលចិត្តក៏ជាទានមយៈ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីទាំងពួងដោយពិស្តារតាមន័យដែលពោលមកហើយ ក្នុងការឱ្យពណ៌ជាទាននុ៎ះឯង, ព្រះធម្មរាជា ទ្រង់សម្ដែងចែកកុសលចិត្ត សូម្បីមានផោដ្ឋព្វារម្មណ៍ដោយកម្ម និងទ្វារទាំង ៩ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ ដោយប្រការដូច្នេះ ។

ចំណែក **ធម្មារម្មណ៍** បានដល់ធម៌ទាំងឡាយដែលជាបរិយាបន្ន (រាប់បញ្ចូល) និងអបរិយាបន្ន (មិនរាប់បញ្ចូល) ក្នុងធម្មាយតនៈនេះ គឺអាយតនៈខាងក្នុង ៦, លក្ខណៈ ៣, អរូបក្ខន្ធ ៣, សុខុមរូប ១៥, និព្វាន និងបញ្ញត្តិ ឈ្មោះថា **ធម្មាយតនៈ**”។ តែក្នុងឋានៈនេះ បណ្ឌិតមិនធ្វើការប្រកបទុកដោយអំណាចនៃធម៌ទាំងនេះ គប្បីប្រកបទុកដោយការឱ្យឱជៈ (រសឆ្ងាញ់) ការឱ្យបានៈ* (ទឹកបាន) និងការឱ្យជីវិតជាទាន ។ ពិតណាស់ កុសលចិត្តនេះ ធ្វើធម្មារម្មណ៍ដែលគួរត្រេកអរក្នុងឱជៈជាដើម ឱ្យជាអារម្មណ៍ ហើយកើតឡើង ដោយការកំណត់ ៣ យ៉ាង តាមន័យដែលពោលទុកហើយក្នុងខាងក្រោយនុ៎ះឯង ។ ក្នុង

---

* ទឹកដែលគេធ្វើអំពីផ្លែឈើផ្សេងៗ មានផ្លែចេកមានគ្រាប់, ចេកឥតគ្រាប់, ព្រីង, ស្វាយ, ស្រគុំ, ទំពាំងបាយជូរ, មាក់ប្រាង និងឫស ឬក្រអៅឈូក ។ (អត្ថយោជនា) ។

ធម្មារម្មណ៍នោះ ក្នុងកាលណា បុគ្គលថ្វាយទឹក ដោះថ្លា និងទឹកដោះខាប់ជាដើម ដោយគិតថា “អញនឹងឱ្យឱជះជាទាន” , ថ្វាយទឹកបាន ៨ យ៉ាង ដោយគិតថា “អញនឹងឱ្យទឹកបានជាទាន” , ថ្វាយសលាកភត្ត, បក្ខិកភត្ត និងសង្ឃភត្តជាដើម ដោយគិតថា “អញនឹងឱ្យជីវិតជាទាន” ថ្វាយភេសជ្ជៈដល់ភិក្ខុអ្នកមានការមិនសប្បាយទាំងឡាយ, ឱ្យពេទ្យមករក្សា, ឱ្យដុតសំណាញ់, ឱ្យបំផ្លាញលប, ឱ្យបំផ្លាញទ្រុងបក្សី, ឱ្យគេរួចចាកគុក, ឱ្យវាយស្គរហាមការសម្លាប់សត្វ, ធ្វើកម្មមានសភាពយ៉ាងនេះ សូម្បីយ៉ាងដទៃទៀត ដើម្បីការពារជីវិត, ក្នុងកាលនោះ កុសលចិត្តជាទានមយៈ ។ ក៏ក្នុងកាលណាបុគ្គលគិតថា “ការឱ្យឱជះជាទាន ឱ្យទឹកបានជាទាន ឱ្យជីវិតជាទាន ជាវង្សនៃត្រកូល ជាបែបផែននៃត្រកូល ជាប្រពៃណីនៃត្រកូលរបស់អាត្មាអញ” ទើបញ៉ាំងទានមានឱជទានជាដើម ឱ្យប្រព្រឹត្តទៅដោយវត្តជាប្រធាន ក្នុងកាលនោះ កុសលចិត្តនោះជាសីលមយៈ ។ ក្នុងកាលណា ផ្ដើមការអស់ទៅ និងសូន្យទៅក្នុងធម្មារម្មណ៍, ក្នុងកាលនោះ កុសលចិត្តនោះ ជាភាវនាមយៈ ។ ក៏កុសលចិត្តដែលជាទានមយៈ កំពុងប្រព្រឹត្តទៅក្នុងកាលណា បុគ្គលថ្វាយឱជះជាទាន, ថ្វាយទឹកបានជាទាន, ថ្វាយជីវិតជាទានដោយដៃរបស់ខ្លួន, ក្នុងកាលនោះ ជាកាយកម្ម ។ ក្នុងកាលណា បុគ្គលឱ្យកូន និងប្រពន្ធជាដើមថ្វាយទាន, ក្នុងកាលនោះ កុសលចិត្តក៏ជាវចីកម្ម។ ក្នុងកាលណា

បុគ្គលមិនញ៉ាំងចំណែកនៃកាយ និងវាចាឱ្យកម្រើក រមែងគិតដោយចិត្តថា "អញនឹងឱ្យវត្ថុដែលមានដោយអំណាចនៃការឱ្យឱជៈជាទាន ឱ្យទឹកបានជាទាន ឱ្យជីវិតជាទាន" , ក្នុងកាលនោះ កុសលចិត្ត ក៏ជាមនោកម្ម ។ ក៏ក្នុងកាលណា បុគ្គលឱ្យវត្ថុដែលមានហើយ មានប្រការដែលពោលហើយដោយ ដៃរបស់ខ្លួន ដោយអំណាចនៃវង្សត្រកូលជាដើម, ក្នុងកាលនោះ កុសលចិត្តជា សីលមយៈ ជាកាយកម្ម ។ ក្នុងកាលណា បុគ្គលប្រើកូន និងប្រពន្ធជាដើម ឱ្យថ្វាយ ដោយ អំណាចនៃវង្សត្រកូលនុ៎ះឯង, ក្នុងកាលនោះ កុសលចិត្តជាសីលមយៈ ជាវចីកម្ម។ ក្នុងកាលណាបុគ្គលគិតដោយចិត្តថា "អញនឹងឱ្យវត្ថុដែលមានហើយ មានប្រការដែលពោលហើយ" ដោយអំណាចនៃវង្សត្រកូលជាដើមនោះឯង, ក្នុងកាលនោះ កុសលចិត្តជាសីលមយៈ ជាមនោកម្ម។

ក៏បុគ្គលដើរទៅហើយ ផ្ដើមការអស់ទៅ និងសូន្យទៅក្នុងធម្មារម្មណ៍ កុសលចិត្ត ជាភាវនាមយៈ ជាកាយកម្ម ។ កាលបុគ្គលមិនញ៉ាំងចំណែកនៃកាយ ឱ្យកម្រើក ផ្ដើមការអស់ទៅ និងសូន្យទៅដោយវាចា កុសលចិត្ត ជាភាវនាមយៈ ជាវចីកម្ម ។ បុគ្គលមិនញ៉ាំងចំណែកនៃកាយ និងវាចាឱ្យកម្រើក ផ្ដើមការអស់ទៅ និងសូន្យទៅដោយចិត្តប៉ុណ្ណោះ កុសលចិត្ត (នោះ) ជាភាវនាមយៈ ជាមនោកម្ម ។ កុសលចិត្តជាភាវនាមយៈ ៣ យ៉ាង មានដោយអំណាចនៃកាយកម្ម

វចីកម្ម និងមនោកម្ម ដោយប្រការដូច្នេះ ។ ព្រះធម្មរាជាទ្រង់សម្ដែងចែកកុសលចិត្តដែលជាធម្មារម្មណ៍ក្នុងទីនេះ ដោយកម្ម និងទ្វារ ៩ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ៣ យ៉ាង ដូចពណ៌នាមកនេះ ។

ចិត្តនេះ ព្រះមានព្រះភាគទ្រង់សម្ដែងហើយយ៉ាងនេះ ដោយអំណាចនៃអារម្មណ៍ផ្សេងៗ ក្នុងវត្ថុទាំងឡាយផ្សេងៗ ។ តែចិត្តនេះ បណ្ឌិតរមែងបានក្នុងវត្ថុដូចគ្នា ដោយអំណាចនៃអារម្មណ៍ដែលផ្សេងគ្នា ។ **សួរថា** បានយ៉ាងណា? **ឆ្លើយថា** ព្រោះក្នុងបច្ច័យ ៤ ចំពោះចីវរ (ឯកវត្ថុ) បណ្ឌិតរមែងបានអារម្មណ៍ ៦ យ៉ាង ។ ពិតណាស់ ពណ៌នៃចីវរដែលជ្រលក់ថ្មី មានពណ៌ជាទីពេញចិត្ត គួរមើល, នេះហៅថាមានពណ៌ជាអារម្មណ៍ ។ ក៏ក្នុងវេលាប្រើប្រាស់ សម្ដែងសំឡេងឮថា “បដះបដះ” , នេះជាសទ្ទារម្មណ៍ ។ ក្នុងសំពត់នោះ ក្លិនឯណាមានក្លិនសម្បកឈើជ្រៃខ្មៅជាដើម, នេះជាគន្ធារម្មណ៍ ។ ក៏រសារម្មណ៍ លោកពោលដោយអំណាចនៃរស គឺការប្រើប្រាស់ ។ ក្នុងសំពត់នោះ សម្ផស្សជាសុខឯណា, នេះជាផោដ្ឋព្វារម្មណ៍ ។ សុខវេទនាកើតឡើងព្រោះអាស្រ័យចីវរ, នេះជាធម្មារម្មណ៍ ។ រសារម្មណ៍ បណ្ឌិតរមែងបានក្នុងបិណ្ឌបាតដោយនិប្បរិយាយ (ដោយត្រង់) តែម្ដង ។ បណ្ឌិតធ្វើការប្រកបក្នុងបច្ច័យ ៤ ដោយអំណាចនៃអារម្មណ៍ផ្សេងៗ យ៉ាងនេះហើយ គប្បីជ្រាបការផ្សេងគ្នានៃចិត្តដែលជាទានមយៈជាដើម ។ ក៏អារម្មណ៍

ជាសភាវៈ ជាប់ជានិច្ចនៃចិត្តនេះ ព្រោះវៀរចាកអារម្មណ៍ហើយ ចិត្តក៏មិនកើតឡើង ។ ចំណែកទ្វារមិនជាប់ចិត្តទេ ។ **សួរថា** ព្រោះហេតុអ្វី? **ឆ្លើយថា** ព្រោះកម្មជាសភាវៈមិនជាប់ជានិច្ច ។ ពិតណាស់ កាលកម្មមិនជាប់ចិត្ត សូម្បីទ្វារ ក៏មិនជាប់ដូចគ្នាដែរ ។

# អដ្ឋសាលិនី
# អដ្ឋកថាព្រះអភិធម្មបិដក
# ឈ្មោះ ធម្មសង្គណី បឋមភាគ ១
# ចប់

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ (ហាមថតចម្លង)